# ជ្រោះភ្នំគូលែន

*និពន្ធដោយ : ស៊ុំ ឈុំ*

*រឿងនេះនិយាយអំពីប្រវត្តិនារីកំសត់ម្នាក់ឈ្មោះ យ៉ាហាន ធ្លាក់ខ្លួនដោយសារឪពុកចុងចិត្តឫស្យា ហើយបានមកជាជួបនិងលោកអធិការ ស៊ី ឈឿនដោយចៃដន្យនៅចំការដូង ខេត្តសៀមរាប ។ ស៊ី ឈឿន និង យ៉ាហាន ក៏ចាប់ផ្តើមស្រឡាញ់គ្នាយ៉ាងខ្លាំង... ។ ស៊ី ឈឿនក៏នាំនាងមករស់នៅ ភ្នំពេញ ។ នាងបានប្រកបរបរក្រៅម៉ោងជាអ្នកចម្រៀងក្នុងរង្គសាល "រំចង់ទិព្វ" ហើយតស៊ូរៀនយកឯកទេសផ្នែកខាងពាណិជ្ជកម្ម ប៉ុន្តែមុនប្រឡងយក សញ្ញាប័ត្រ ១ ខែ រឿងមួយក៏បានផ្ទុះឡើង...*

*រឿង ជ្រោះភ្នំគូលែននេះ អ្នកនិពន្ធយើងបានរៀបរាប់អំពី ភូមិសាស្ត្រ និង ទេសភាពដ៏ស្រស់ត្រកាលនៃភ្នំគូលែនយ៉ាងក្បោះក្បាយ ។ សូមអញ្ជើញអានដោយមេត្រីភាព ។*

## មាតិការឿង


ចំពូក ១ : ចំការដូង

ចំពូក ២ : បំណុលវាសនា

ចំពូក ៣ : ភ្នំគូលែន

ចំពូក ៤ : រំចង់ទិព្វ

ចំពូក ៥ : អាថ៌កំបាំង

ចំពូក ៦ : ពលិកម្ម

ចំពូក ៧ : ភ្លេងបើករាំងនន

ចំពូក ៨ : ជ្រោះភ្នំគូលែន

# ជំពូក ១
## ចំការដូង

ខែវិច្ឆិកា ឆ្នាំ ១៩៦២.... រឿងដ៏ពាក់ចិត្តមួយបានចាប់កំណើតឡើង កណ្ដាលទឹកដីដ៏ស្រងេះស្រងោចនៃខេត្តសៀមរាប ដែលបរិបូណ៌ទៅដោយសម្បត្តិអារ្យធម៌បុរាណ...

ក្នុងរាត្រីជ្រៅមួយនៃខែនោះ ព្រះចន្ទ១៤កើតអណ្តែតខ្ពស់នៅលើមេឃ ចោលរស្មីព្រាតមកលើទឹកដែលនៅដក់សងខាងផ្លូវថ្នល់កាត់ស្រុងស្រែ លាតសន្ធឹងតាមចន្លោះដើមឈើពីរជួរដែលឈរស្ងប់ទ្រឹង ។

រថយន្តតូចច្រឡឹង ពណ៌សមួយបរសន្សឹម បើកតែចង្កៀងតូចពីរនៅខាងមុខ ហាក់ដូចជាមិនចង់ឱ្យខូចលំអរបស់ធម្មជាតិ ។ រស្មីព្រះចន្ទចាំងចូលតាមចន្លោះមែកឈើមកលើតួឡានភ្លឺផ្លេកៗម្ដងៗ ។ យប់ស្ងើរណោះមានអ្នកឯណាក្រៅពីតួកំសត់ខ្លះ ដែលតែងតែបណ្តែតអារម្មណ៍តាមអាកាសត្រជាក់ឆ្ងាយអំពីទីក្រុងសៀមរាប ។ មិនសូវមានទេសចរណ៍ឯណាដើរលេងដល់យប់ជ្រៅយ៉ាងនេះទេ ។

លុះទៅដល់វាលមួយធំល្វឹងល្វើយ រថយន្តបង្អង់អែបទៅស្ដាំ ហើយឈប់បន្តិចម្ដងៗ ។ បុរសម្នាក់មានឧស្ដើង រូបរាងស្អាតបាត បើកទ្វារខាងមុខចេញមកក្រៅ ស្លៀកខោក្រមៅ ពាក់អាវសឺមិសម្វរដៃ ប្ដូកពារស្រឥត់ស្រពុំខ្ពង់ខ្ពស់ទំនងជាមានវ័យក្មេងគួរសមនៅឡើយ ។ មិនឃើញមានអ្នកឯណាមកជាមួយសោះ ! ។ បុរសឡើងទៅលើចិញ្ចើមថ្នល់ខាងស្ដាំ ឈរស្ងៀមមួយស្របក់ ហើយផ្អែកខ្នងទៅលើទ្វារឡានខាងមុខ សម្លឹងមើលទៅព្រះចន្ទ ។ ពពកស្ដើងៗរសាត់ខ្ពស់ទៅលើអាកាស ដូចជាជិតជាប់នៅនឹងលោកខែ ។ ខ្យល់ជំនោរត្រជាក់ផ្លាក់រំភើយ ម៉ោងជិតដប់ពីរអាធ្រាត្រហើយ ។ លេចពន្លឺ "ហ្វា" ឡានមួយចាំងវន្លាលអំពីចម្ងាយ មកពីខាងក្រោយ ។ បុរសងាកមុខទៅរកពន្លឺ សង្កេតមើលមួយសន្ទុះហើយបើកទ្វារចូលទៅអង្គុយនៅមុខចង្កូតឡានរបស់ខ្លួនវិញ ។ ពន្លឺ "ហ្វា" កាន់តែជាលមកជិតយ៉ាងលឿន ។ ឡានទីពីរបង្អង់ល្បឿន ហើយឈប់ជ័ក់នៅជាប់ពីក្រោយឡានទីមួយ ។ ប្រុសពីរនាក់ចេញអំពីរថយន្តដែលទើបនឹងមកដល់ហើយដើរឆោះទៅកាន់អ្នកបើកឡានទីមួយ ។

- ខ្ញុំបាទបើកឡានរក "តេជះគុណ" ពេញតែក្រុងសៀមរាប ឥតស្មានថាតេជះគុណមកខាងណោះសោះ !
- ម៉េចក៏សុតឯងដឹងថាខ្ញុំមកឯណោះ ?

- ប៉ូលីសនៅដើមស្ពាន ប្រាប់ខ្ញុំបាទថា ឃើញឡានតូចសមួយមានអ្នកបើកតែម្នាក់ឯងបានចេញមកតាមផ្លូវនេះ ។ ខ្ញុំបាទនឹកសង្ស័យក៏នាំគ្នាបើកតាមមកលមើល ប៉ុន្តែមិននឹងស្មានថា តេជៈគុណអញ្ជើញមកឆ្ងាយដល់ម្ល៉ឹងសោះ !

- ខ្ញុំបើកលេងៗមក ខ្យល់ក៏ត្រជាក់ ទេសភាពក៏ល្អ ជ្រុលមកដល់វាលនេះមិនដឹងខ្លួន ។ ចុះសុតឯងនាំគ្នាមកតាមខ្ញុំធ្វើអ្វី ?

- លោកសុតឈរអឹមអៀមអើតកទៅជិតទ្វារឡាន ជំរាបទៅចៅហ្វាយធំវិញដោយស្ញើស្ញាក់

- ខ្ញុំបាទនាំក្មេងស្រីពីរនាក់មកជាមួយ ក្រែងតេជៈគុណអញ្ជើញដើរលេងតែម្នាក់ឯងមិនសូវសប្បាយ !

បុរសអស់សំណើច ល្ហកដៃទៅទះស្មាសុត ហើយលាន់មាត់ថា ៖

- ខ្ញុំផ្តាំថាកុំឱ្យសុតឯងរវល់នឹងខ្ញុំអី ។ បើខ្ញុំប្រាថ្នាយ៉ាងហ្នឹង តើខ្ញុំទៅលាក់ធ្វើអ្វី ខ្ញុំក៏ធ្លាប់ដើរលេងដែរ សុតឯងក៏ធ្លាប់ដឹងមកស្រាប់ហើយ ។

- ខ្ញុំបាទក៏យល់យ៉ាងដូច្នេះដែរ ប៉ុន្តែខ្ញុំបាទហៅគេមកនេះដើម្បីគ្រាន់តែកុំឱ្យតេជៈគុណស្ងាត់ពេក ។

បុរសមិនចេញស្តី សំដីចុងក្រោយបំផុតរបស់សុតហាក់ដូចជាធ្វើឱ្យចិត្តនឿយណាយរបស់អ្នកចូលស្ទុងទៅក្នុងសេចក្តីពិចារណា. . . . “ ដើម្បីគ្រាន់តែកុំឱ្យតេជៈគុណស្ងាត់ពេក !. . . . រូបទាំងនេះគ្រាន់តែជាគ្រឿងបញ្ឆោតចិត្ត. . . . រឿងរ៉ាវដដែលៗ បម្រុងនឹងកើតមានឡើងមិនចេះចប់. . . . ” ។ ប៉ុន្តែក្រោយនោះមួយភ្លែតមក អ្នកនឹកឃើញភ្លាមឡើងវិញថា សុតនៅឈរជិតខ្លួន ទើបប្រញាប់តបទៅវិញដោយរួសរាន់ ។

- ចិត្តសុតឯងពិតជាគាប់ប្រសើរ ខ្ញុំអរគុណហើយ ប៉ុន្តែខ្ញុំសព្វថ្ងៃកាន់តែពិបាកនឹងដើរលេងជាមួយនឹងពួកស្រីទាំងនេះណាស់

- នៅក្មេងដូចតេជៈគុណ ដូចជាគ្មានខ្លងអ្វីទេ យូៗទៅតេជៈគុណ បានអញ្ជើញមកសៀមរាបម្តង, ការដើរលេងនៅពេលក្រៅម៉ោងរដ្ឋការ ជារបស់ធម្មតាទេ ។

ម៉្យាងទៀតទីកន្លែងសប្បាយក៏មានច្រើន  ហើយនៅឆ្ងាយៗពីទីក្រុងផង  មិនអាចនឹងអ្នកណា  គេចាប់ថ្នឹកបានឡើយ ។

ភ្ញៀវពិសេសរបស់លោកសុត  មិនសូវយកចិត្តទុកដាក់នឹងសំដីទាំងនេះទេ  ប៉ុន្តែឈានជើង  ចុះពីឡានបណ្ដើរនិយាយបណ្ដើរ ៖ “ ណ្ហើយចុះខ្ញុំសុំទៅមើលមុខបន្តិចមើល  តើកូនក្រមុំរបស់សុតជងទាំងពីរនៅឆើតឆាយយ៉ាងណាទៅ ? ”

ភ្ញៀវនេះ  ដើរទៅជិតឡានខាងក្រោយ  ឱនមុខទៅក្នុងរថយន្ត  ឃើញនារីពីរនាក់នៅ  ក្មេងប្រហែលៗគ្នា  នៅត្រៀមចាំមិនចេញស្ដី  ម្នាក់អង្គុយខាងមុខ  ម្នាក់អង្គុយខាងក្រោយ ។ នាងទាំងពីរជំរាបសួរតួថ្មីដោយសោះកក្រោះ  ត្លួនេះក៏វាចារាក់ទាក់  ទៅរកនាងខាងក្រោយ ៖

-នាងឯណោះរាងមាំល្អណាស់  មើលទៅមុខដូចជាសប្បាយ  យើស !  កាត់សក់ខ្លីមើល  តែប្រុសតែម្ដង !

នាងនោះងាកមុខចិញ្ចាចមករក  ហើយតបមកវិញដោយអង់អាច

- ខ្ញុំចាំសប្បាយជាមួយតែលោកមួយទេ !

អ្នកប្រុសអស់សំណើចពួសខឹក  ហើយលាន់មាត់ថា ៖ “ ខ្ញុំក៏ចាំតែនាងមួយដែរ !” រួចក៏ភ្ញាត់មាត់សើចលាន់ទាំងអស់គ្នា ។

នារីដែលអង្គុយខាងមុខមិនតបតសម្ដីអ្វីសោះ ។ លុះអ្នកប្រុសដើរទៅជិតនាង  នាងងើប  មុខឡើងទទួលដោយធម្មតា ។

អ្នកប្រុសយកដៃអង្អែលសក់វែងរបស់នាងបន្តើរពីលើមកដល់ស្មា  នាងគ្រាន់តែញោចខ្លួន  បន្តិចហើយញញឹមមិនចេញស្ដី ។ បុរសបើកទ្វារឡាន  ដឹកដៃនាងឱ្យចេញមកក្រៅ

- ហេតុអ្វីក៏នាងដូចជាស្រងូតស្រងាត់ជាងគេ ?

- ចាស៎ ! ខ្ញុំឥតមានស្រងូតស្រងាត់អ្វីទេតេជៈគុណ

សម្លេងនេះស្រាល  ហើយដូចជាផុសចេញមកអំពីអារម្មណ៍ដែលនៅឆ្ងាយ ។ សំពត់ខ្មៅ  រលោង  និងអាវសដាក់ខ្សែរពីក្រោយខ្នង  បញ្ចេញរាងខ្លួនរៀវស្ដើង  លើកលំអដោយ  សាច់សស្រអែម  ឬត់ខៃរបស់នាង  នាងឈរទៅទ្រង់ទាប  ជាងអ្នកប្រុសបន្តិច ។

អ្នកនិយាយចំអន់លេងនឹងនាង

- ទឹកមុខហ្នឹងគួរឱ្យស្រឡាញ់ណាស់ ! ប៉ុន្តែបើខ្ញុំស្រឡាញ់ គេគ្រប់គ្នាក៏ស្រឡាញ់ដែរ ហេតុដូច្នេះខ្ញុំមុខជាគ្មានសំណាងទេ ។

នាងសម្លឹងមើលមុខគេមិនចេញស្តី គេបន្ថែមសំដី ទៅឱ្យនាងទៀត

- ខ្ញុំជាមនុស្សក្រៅបញ្ជីទេ មែនទេ ! ពីព្រោះនាងទាំងពីរនាក់បានគ្រប់គ្នាជាមួយនឹងលោកសុត និងលោកថៃទៅហើយ ដូច្នេះក្នុងពេលនេះខ្ញុំសុំដលខ្លួនចេញទៅចុះ ខ្ញុំគ្រាន់តែទៅជាមួយដើម្បីនឹងជួយអបអរសាទរបានហើយ ។

លោកសុតនិងលោកថៃ ស្រែកតវ៉ាព្រមគ្នាថា សូមប្រគល់នាងខាងមុខនេះជូនលោកប្រុសហើយ ។ លោកប្រុសខាល់គំនិតក៏ងាកបែរមកសួរចំអន់នាងទៀត

- ចុះនាងវិញមិនតូចចិត្តនឹងផ្លាស់ប្តីមួយទៀតទេឬអ្វី ?

នាងតបទៅវិញដោយសម្លេងស្ទើរតែស្តាប់ពុំឮ

-ចាស៎ ! ខ្ញុំជារូបឥតវិញ្ញាណ តាមតែផ្លាស់ប្តូរទៅឯណាក៏បានដែរ !

សំដីរបស់នាងប៉ះទង្គិចជាខ្លាំងដល់ចិត្តរបស់អ្នកប្រុស, ប៉ុន្តែអ្នកមិនចេញស្តីគ្រាន់តែដោះដៃចេញពីនាង ហើយដើរឆ្ពោះទៅកាន់រថយន្តរបស់ខ្លួន ។ មិនដឹងជាអ្នកត្រូវខឹង ឬអាណិតរូបស្រីនេះ ។ នាងដើរតាមពីក្រោយហើយចូលទៅជិះទន្ទឹមនឹងគេទៀត ។

នាងឮគេសួរទៅឡានខាងក្រោយ

- ម៉េចសុត ! ទៅខាងណាវិញ ?

ឮសំលេងលោកសុត ឆ្លើយមកវិញដោយស្និទ្ធនិងគោរព ៖

- បាទស្រេចតែតេជៈគុណទេ អញ្ជើញទៅបារាយណ៍ទឹកថ្លាវិញក៏បាន ទៅចំការខ្ញុំបាទក៏បាន សូមតេជៈគុណអញ្ជើញមុនខ្ញុំបាទបើកតាមក្រោយ ។

រថយន្តទាំងពីរបត់ត្រឡប់មកក្រោយវិញ ។ ក្នុងឡានខាងក្រោយឮសួរមាត់សើច ។ ឯឡានខាងមុខស្ងាត់មាត់ឈឹង អ្នកប្រុសក៏ស្ងៀម នាងក៏ស្ងៀម បរិយាកាស

ដូចជាផ្ទន់ ។ គេបិទ "ហ្វា" ហើយបើកតែចង្កៀង "ឌីមី" មើលពីក្នុងឡានទៅហាក់ដូចជារសត់ស្ងួនឡ ។ នាងអត់ទ្រាំសួរមិនបាន

- បើបិទភ្លើងអស់យ៉ាងហ្នឹង តើមើលផ្លូវឃើញដែរបង ?

- ខ្ញុំបើកព្រាវៗទៅណា ! នាងភ័យឬ ? បើភ័យនាងទៅជិះបានខាងក្រោយវិញក៏បានដែរ ល្ងាចនេះខ្ញុំនិងនាងមិនបាច់ជួបគ្នាទេ ជួបធ្វើអ្វីបើរូបនាងជារូបឥតវិញ្ញាណ

ពន្លឺព្រះចន្ទចាំងលើកញ្ចក់ឡានខាងមុខ ចោលរស្មីមកឃើញសម្រស់ភ័ក្ត្រនាងក្មេងខ្ចីរីងរីតតែល្អ និងភ្នែកស្រឡះថ្លាឈ្វេង ។ នាងកើយក្បាលទៅលើពូកបង្អែកសម្លឹងមើល ទៅទេសភាពខាងក្រៅ ។ ទ្រូងនាងដូចជាដង្ហើមញាប់ជាងធម្មតា ។ ក្រោយបន្តិចមក សម្លេងស្រាលរបស់នាងលេចឮឡើង

- អ្នកដូចជាចម្លែកក្នុងខ្លួនណាស់ ! ចំពោះប្រុសនានា អ្នករូបឥតវិញ្ញាណគេនិយាយថា អ្វីឱ្យអ្នកក៏អ្នកឈប់ចាប់អារម្មណ៍ទៅហើយ ។ ប៉ុន្តែសំដីរបស់បងតែបន្តិចមុន ហេតុដូចម្ដេចក៏ធ្វើឱ្យអ្នកខ្មាសនិងតូចចិត្តដល់ម្ល៉ឹង ? សូមបងអភ័យទោសឱ្យអ្នកផងចុះ សំដីរបស់អ្នកបម្បាញ់មិញនេះស្ទុះចេញមក រកតែទប់មិនបាន អ្នកមិនត្រូវហ៊ានវាចាផ្ដេះទៅរកបងឡើយ ។

រួចក៏ស្ងាត់ស្ងៀតទាំងអស់គ្នានៅវិញ ។ អ្នកប្រុសមិនចង់យល់អ្វីច្រើនអំពីនាងទេ អ្នកចេញមកដើរលេងតែម្នាក់ឯងសោះ ហេតុអ្វីក៏លោកសុតទៅនាំនាងមកជួបនឹងអ្នក ។ អ្នកកាត់ចិត្តនិយាយរឿងនេះឱ្យបានខ្លី

- ខ្ញុំមិនដែលប្រកាន់អ្វីនឹងស្ត្រីដូចនាងឡើយ ។ ប៉ុន្តែបើនាងប្រកាន់នឹងខ្ញុំ ខ្ញុំសុំបញ្ជាក់ថែមទៀតថា ខ្ញុំមិនមែនបកកេរ្តិ៍នាងកណ្ដាលផ្សារទេ ខ្ញុំនិយាយសប្បាយតែរង្វង់មិត្តយើងដែលជិតស្និទ្ធ ដែលបានដឹងការទាំងអស់គ្នា ដែលស្គាល់នាងជាក់ច្បាស់ណាស់ទៅហើយ ។ ម្យ៉ាងទៀត នាងទៅចង់លាក់ធ្វើអ្វីជាមួយនឹងពួកខ្ញុំ ដែលតែងតែបានដឹងថាពួកនាងរាល់គ្នារមែងផ្លាស់ប្ដីជាច្រើនដងពីមួយថ្ងៃទៅមួយថ្ងៃ ។ បើនាងសុខចិត្តទទួលកាន់មុខរបរនេះទៅហើយ រឿងខ្មាសរឿងអៀននេះវាគ្មានឱ្យសម្បើមអ្វីដល់នាងទេ !

ពាក្យរបស់អ្នកប្រុសរណ្តំដាច់ពីគ្នាម៉ាត់ៗ អ្នកប្រុសក៏ទឹកឆ្ងល់នឹងខ្លួនឯងដែរថា ហេតុអ្វី ក៏ខ្លួនមកប្រកាន់ខឹងនឹងនាងនេះ ។ ឡានខាងក្រោយតិតតែសើចសប្បាយ ឯឡានខាង មុខតិតតែពីឈ្លោះគ្នាតឹងឡើងៗ ។ នាងរកឆ្លើយអ្វីមួយម៉ាត់ក៏ពុំរួច ចំពោះសំដីចុងក្រោយ បំផុតរបស់ប្រុស ដែលខុសពីគេឯងនេះ ។
លុះនាងយកកន្សែងមកផ្ចិតទឹកភ្នែក ទើបគូជម្លោះរបស់នាងដឹងថានាងយំ ហើយយល់រឿងនេះមានទំនងប្លែកពីប្រក្រតី ។ ប្រហែលជាគូនេះគេអាណិត នាងខ្លះដែរមើលទៅ, ពីព្រោះគេស្រវាកៀកនាងឱ្យខិតមកជិត ។ ឯនាងវិញ ក៏ដូចជាត្រេកអរចម្លែកនឹងសេចក្ដីមេត្តាប៉ុណ្ណឹងរបស់គេ ។ ក្លិនទឹកអប់ក្រអូបស្រាល សាយអំពីសក់វែងរលូនដែលខ្យល់ឡានបក់ផាត់មកម្ដងៗ មកប៉ះនឹងខ្លួនអ្នកប្រុស ។

រឿងឈ្លោះក្លាយទៅជារឿងអាណិត ទឹកភ្នែកបង្កើតជាអនុស្សាវរីយ៍ដែលគួរឱ្យស្រណោះ ។ ប៉ុន្តែឋានៈនិងជីវភាពរបស់អ្នកទាំងពីរមានសភាពផ្ទុយគ្នាស្រឡះ !

រំលងប្រហែលជាប្រាំបីគីឡូម៉ែត្រមក រថយន្តទាំងពីរបង្អង់ល្បឿន
កាច់ចេញពីផ្លូវជាតិ ចូលទៅខាងឆ្វេង ឆ្លងកាត់ចង្អូរទឹកមួយតូច តាមស្ពានមួយខ្លី ធ្វើដោយមែកឈើក្រង ភ្ជាប់គ្នា បរកាត់ទ្វាររបងដែលបើកចំហ,
ហើយចូលជ្រៅទៅក្នុងចំការដូងដែលមាន ឯផ្ទៃដីរាបស្មើ ដុះស្មៅខ្ចី ៗ ។

ចម្ងាយប្រហែលមួយរយម៉ែត្រពីផ្លូវចូល លេចឃើញតួរាងផ្ទះឈើមួយតូចល្មម សង់ខ្ពស់ស្រឡះពីដី ។ រថយន្តទាំងពីរឈប់ចតតំរៀបគ្នានៅមុខផ្ទះ ។ លោកសុត ស្ទុះទៅរោងខាងក្រោយដាស់កម្មករយកកូនសោ ។ មនុស្សប្រុសពីរនាក់មាឌមាំៗ ភ្ញាក់ក្រោកសើងម៉ើង រត់ឡើងទៅបើទ្វារបណ្ដើរស្រែកសួរគួរសមមកកាន់អស់លោក បណ្ដើរ... ដោយសម្លេងយ៉ាងរដឹន

- ចុះគេជះគូន "អ៊ុយ" អញ្ជើញមក "ពា" ឯណាបានជាថ្មើរណោះទើបនឹងមកដល់ ?

លោកសុតឆ្លើយកំប្លែង

- ទើបនឹងមកពីចាប់កណ្ដូបណាំពួ "អ៊ុយ !"
- ចុះចាប់បានប៉ុន្មានដែរ ? ហ្នឹង !

លោកសុតតបថា ចាប់បានតែពីរទេ ប៉ុន្តែធំៗណាស់ ។

ចៅហ្វាយលោកសុតសើចកាច់កកាច់ស្រង់ ហើយលាន់មាត់ថា ៖

- យីស ! ចង្រៃសុតនេះ ! ចេះតែរកឃើញប្លែកៗមិនចេះចប់ ! អញចង់តែ បន្ថែមអីឡូវហ្នឹង ! ។ នេះចេះចាប់បានពីរ, ចុះបើចាប់បានតែមួយវិញ តើគេត្រូវ ថាយ៉ាងដូចម្ដេចទៅ ?

លោកសុតចង្អុលទៅនាងសក់ខ្លីដែលជិះឡានក្រោយ

- បាទត្រង់ហ្នឹងខាល់តែអានីទើបចេះនិយាយ ។ អានីមិនខាន់យល់អីច្បាស់លាស់ដែរ ប៉ុន្តែដោយវាចេះតែរអិល វាក៏បំពងសម្លេងឡើងភ្លាម ៖

- យី ! ទៅពិបាកអ្វី ! គេត្រូវថាចាប់បាន "កណ្ដួបមួយ" ទៅណា៎ !

ប្រុសសើចតឹល ទាំងពួកអស់លោក ទាំងពួកកម្មករ ។ ស្រីៗធ្វើភ្នែកឡឹងឡង់ ប៉ុន្តែបន្តិចមក មិនដឹងថាគាត់យល់ថាយ៉ាងដូចម្ដេចដែរ ស្រាប់តែអានីស្ទុះមកគក់លោកសុតថ្ងូកៗ នាំឱ្យពួស្សរមាត់សើចលាន់ម្ដងទៀត ។ ភ្ញៀវទាំងអស់នាំគ្នាឡើង

ខ្សៀវខ្សារទៅខាងលើ ។ រានហាលខាងក្រៅខ្វាលាយល្វើងចែកជាពីរថ្នាក់ ថ្នាក់ទីមួយជាប់នឹងផ្ទះធំជារានហាល មានដំបូល មានព្រៃនាមបូស្សីមួយធំដាក់ជាប់ទៅនឹងជញ្ជាំង ។ ថ្នាក់ទីពីរនៅខាងមុខបំផុត ទាបជាងបន្តិចឥតដំបូលហើយមានរៀបកៅអីផ្ដៅបីបួនធំៗសម្រាប់អង្គុយលេង ។ នៅជុំវិញផ្ទះសុទ្ធតែដើមដូង ។

អស់លោកលាន់មាត់គ្រប់គ្នា

- យី ! ផ្ទះសុតជងហ៊ីហាមែន ! មានសព្វមានគ្រប់ ! ... អស្ចារ្យហើយ ! មានទាំងអច្រើងថែមទៀតផង ចងឱ្យយ៉ាងស្រេច ! ... ។

ទាំងប្រុសទាំងស្រី ប្រសេចប្រសាច ខ្លះរត់ទៅអង្គុយលើកៅអីលមើល ខ្លះទៅឈរលេង តាមបង្កាន់ដៃរានហាល ដើរចុះដើរឡើង មើលទៅខាងនេះបន្តិច មើលទៅខាងនោះ បន្តិច... ចេះតែសរសើរថាផ្ទះនេះស្រួលណាស់ ។

លោកសុត គួសឈើគួសអុជចង្កៀងប្រេងកាតមួយឆេះព្រឹមៗនៅកៀនសសរទ្រូង រួចចាក់សោបើកបន្ទប់ខាងក្នុង ប្រគល់ជូនចៅហ្វាយ ៖ ពួកភ្ញើយមានហើយស្រេច ព្រមទាំងភួយដែលយកមកតាមឡាន ។ នារីសក់វែងជួយរៀបចំគ្រែ ផ្លាស់កំរាលថ្មី ទុកដាក់អីវ៉ាន់និងខោអាវអ្នកប្រុស ។

រួចគេនាំគ្នាទៅអង្គុយលេងនៅរានហាលខាងមុខបង្អស់ ។ ខែជ្រេទៅទិសខាងលិច ចោលរស្មីត្រជាក់មកលើធម្មជាតិ សន្សើមធ្លាក់ចុះបន្តិចៗ ។ នៅក្រោមពន្លឺព្រះចន្ទ អ្នកប្រុសសង្កេតមើលមុខនារីដ៏ល្អចម្លែក ដែលនៅអង្គុយជិតអ្នកលើកៅអីថ្តៅ គន់ឱ្យសព្វៗទៅឃើញហាក់ដូចជាកូនកាត់លាវ ។ ទើបអ្នកសួរទៅនាង

- អូនឯង មុខដូចកូនកាត់លាវ ?

នាងសើចហើយជំរាបទៅវិញ

- ចាស អូនខ្មែរទេបង ម៉េចក៏បងឆ្ងល់អីចឹង ?
- មកអំពីខ្ញុំធ្លាប់ស្គាល់លាវខ្លះដែរ
- ប្រហែលជាបងធ្លាប់ស្គាល់ស្រីលាវច្រើនហើយ មើលទៅ !
- ស្រីក៏ស្គាល់ប្រុសក៏ស្គាល់
- ស្រីលាវយ៉ាងណាដែរបង ?
- ស្រីលាវដូចអូនឯងអីចឹង !

សំដីនេះហាក់ធ្វើឱ្យនាងទើសទាល់បន្តិច

- ដូចអូនត្រង់ណាខ្លះទៅបង ?
- ខ្ញុំពិបាកនឹងនិយាយណាស់

ថាហើយអ្នកប្រុសក្រោកទៅឈរនៅបង្កាន់ដៃរានហាល ជិតមាត់ជណ្ដើរចុះទៅដី ។ នាងក្រោកទៅតាម

- បងមានប្រសាសន៍អម្បាញ់មិញមិនទាន់ចប់នៅឡើយទេ...សូម...
- អូនចង់ដឹងធ្វើអ្វី បើអូនមិនមែនជាកូនលាវទេ !

នាងងើយភក្ត្រទៅជិត ហើយញញឹមសម្លឹងគេដោយទឹកមុខដែលពិបាកនឹងសន្និដ្ឋាន

- បងឯងចម្លែកណាស់ !
- ចម្លែកយ៉ាងម៉េច ?

នាងមិនឆ្លើយ ហើយផ្អែកក្បាលទៅលើទ្រូងប្រុសដែលងងឹតឱ្យនាងតាមអង្វរ ។ នាងក៏ពេញចិត្តនឹងអង្វរគេដែរ, ហើយបណ្ដោយខ្លួនឱ្យគេអោប ឱ្យគេរិត គេថ្នាក់គេថ្នម ពីព្រោះប្រុសហ្នឹងចេះធ្វើឱ្យនាងចូលចិត្តប្លែកពីគេពីឯង ។ នាងមិនអាចនឹងប្រកែកអ្វីបានឡើយ គេថើបថ្ពាល់នាង នាងអៀនសប្បាយ គេថើបមាត់នាង នាងស្ទើរតែបាត់ព្រលឹង ។ គេថើបរួចម្ដងៗ នាងស្រវាបោសអង្អែលគេដោយ

ត្រេកអរ ហើយថ្លេចនេត្រានៀលសិរសាទៅលើស្មាគេ ប្រាថ្នាឱ្យគេថ្នាក់ថ្នមនាង ឱ្យយូរជាងនេះទៅទៀត ។

បន្តិចក្រោយមក នាងលាន់មាត់សាជាថ្មី

- បងឯងអីចម្លែកអ្វីម្លេះទេ !

សម្លេងប្រុសឆ្លើយថ្នមទៅវិញ

- អូនឯងចេះតែថាចម្លែក បងដូចជាទឹកអៀនខ្លួនណាស់ មិនដឹងជាបងធ្វើឱ្យអូនធុញទ្រាន់នឹងបងចម្លែកជាងគេយ៉ាងម៉េចក៏មិនដឹង !

នារីយាត់បង្អាក់វាចាប្រុសសម្លាញ់ ជាសញ្ញាថាមិនមែនដូច្នោះទេ ហើយនាងឆ្លើយបញ្ជាក់ទៅអ្នកវិញដោយសម្លេងស្រាល

- ចម្លែកត្រង់រូបបង ចេះធ្វើឱ្យរូបអូនមានវិញ្ញាណឡើងវិញ ឱ្យអូនចេះឈឺចាប់នឹងសម្ដីបង ឱ្យអូនចេះភ័យខ្លាចបងមិនពេញចិត្តនឹងអូន....... ។

អ្នកប្រុសទឹកអាស្ចារ្យដល់សំដីទាំងនេះណាស់ ពីព្រោះជាសម្ដីមិនទាន់ដឹងក្ដីដែលហូរចេញ មកដោយស្មោះ ។

រសជាតិវាចារៀបរាប់ឆ្លើយឆ្លង បានជ្រាបចូលដោយស្ងប់ស្ងាត់ទៅក្នុងដួងចិត្តអ្នកទាំងពីរ ។ នាងស្រីចាប់អារម្មណ៍ទៅលើឫកពាខ្ពង់ខ្ពស់របស់អ្នកប្រុសចម្លាយដែលនាងមិនស្គាល់ នាងទន់ចិត្តនឹងឃើញគេរាប់រកនាងគ្មានសេចក្ដីមើលងាយ ។ គេក៏នៅក្មេងនៅឡើយផង មុខគេក៏ស្រស់ សម្ផស្សគេក៏ល្អ គេសើចរួសរាយរកនាងជានិច្ច គេ-ង គេងិច បន្តិចបន្តួចធ្វើឱ្យនាងចេះតែនឹងភ័យ ។ បុណ្យស័ក្តិរបស់គេក៏ប្រហែលជាមិនតូចឡើយ នាងទឹកអៀនខ្មាសនឹងមាយាទឯងដែលជាស្ត្រីផ្កាមាស ។

នៅក្រុមម្ខាងទៀតឯណោះ គេកំពុងតែជជែកគ្នាហ៊ឹមៗដែរ ។ ស្រាប់តែឮស្នូរមាន់ស្រែក ខ្ទក! ខ្ទក! នៅក្រោមផ្ទះ ។ សម្លេងលោកថៃលាន់ឮឡើង

“ ចោរលួចមាន់ ! ចោរលួចមាន់ ! ”

សម្លេងមួយទៀតសើចខ្ញីរ ហ៊ាស់ ! ហ៊ាស់ ! តមកពីក្រោម ។ អ្នកប្រុសស្គាល់សម្លេងក៏បន្ថែមទៅឱ្យ

- “ ស៊ុតទៀតហើយ ! ចុះស៊ុតឯងទៅធ្វើអ្វីវាហ្នឹង ? ឬមួយក៏នាំគ្នាទៅធ្វើអី ! អី ! នៅជិតវាបានជាវាស្រែកម្ល៉ឹងៗ !

- បាទ ! ខ្ញុំបាទកំពុងតែឱ្យពួកគាត់ចាត់ចែងបបរមាន់មួយឆ្នាំង

- ម្ល៉ឹងៗ ចា៎ !

លោកស៊ុតនិងកម្មករពីរនាក់កំពុងតែពព្រួសប៉ប្រាស់វំងំៗ ជាមួយនឹងមាន់

- “ អាចង្រៃ ! ឯងចង់ឱ្យវាស្លាប់ វាចេះតែស្រែក ! ”

បន្ទាប់មកឮស្នូរជើងមនុស្សដើរស្រឹបៗ ចូលទៅរោងចង្ក្រានខាងក្រោយ ។ មិត្តនារីអ្នកប្រុសដកដង្ហើមធំ

- ដោយសារតែយើង បានជាគ្នាត្រូវស្លាប់ ណា៎បង

អ្នកប្រុសតបទៅវិញដោយសង្វេគ

- បើសិនជារូបយើង មានវាសនាជាមាន់វិញ...

នាងស្រវារឹតអ្នកដោយស្មោះ

- សំដីរបស់បង អីក៏ដូចគ្នានឹងចិត្តរបស់អូនអីម៉្លេះទេ !

រាត្រីកាន់តែកន្លងចាកអាធ្រាត្រទៅហើយ អ្នកទាំងពីរបណ្ដើរគ្នាចូលទៅក្នុងបន្ទប់ ។ នាងផ្លាស់សារុងបត់ខោតួនាងដាក់ទៅចុងជើង លើងអាវព្យួរទៅបង្គោលគ្រែ ។ តួនាងបិទទ្វារដាក់កន្លឹះពីក្នុង ហើយលើកត្រកងនាងផ្ដេកទៅលើគ្រែ

- អូនឯងកាត់លាវមែនឬទេ ?

- ចា៎សបង ថាមិនមែនក៏ដូចជាមែនដែរ ។ បងប្រសប់សង្កេតណាស់ អូនមិនចង់លាក់នឹងបងទេ ពិតមែនតែអូនមិនដែលហ៊ានប្រាប់អ្នកឯណាសោះ ។

- អូនខ្លាចអ្វី ?

- អូនខ្លាចគេស្គាល់ភូមិកំណើត និងគ្រួសាររបស់អូន

- អូនធ្លាប់មានប្ដីហើយឬនៅ ?

- ចា៎ស អូនមិនដែលមានប្ដីទេ

- អូននៅស្រុកណាដែរ ?

- អូនឈ្មោះ ខាន់-យ៉ាហាន ។ អូននៅក្រចេះ ឪពុកអូនខ្មែរ, ម្ដាយអូនក៏ខ្មែរដែរ ប៉ុន្តែកាត់លាវ ។ សូមបងកុំមានប្រសាសន៍ប្រាប់អ្នកឯណាឱ្យសោះណា៎បង !

- ចុះបើបងជ្រុលនិយាយប្រាប់គេទៅ ?

- នោះអូននឹងត្រូវរលាត់ឆ្ងាយ អំពីទីនេះទៅទៀតហើយ ។ រាល់ថ្ងៃគេហៅអូនតែ "អារ៉ុម" ដែលមិនមែនជាឈ្មោះពិតរបស់អូនឡើយ ។

- អូនជងខំលាក់ម្ទឹងៗ គឺដើម្បីឱ្យរស់នៅបានសប្បាយយូរក្នុងជីវភាពសព្វថ្ងៃនេះមែនទេ ?

ទឹកមុខនាងប្រែជាស្រពោន

- ពីផ្ទុយស្រឡះណាបង សព្វថ្ងៃអូនស្អប់អូនខ្ពើមរូបខ្លួនជងណាស់ អូនមិនចង់ឱ្យរូបថោកទាបរបស់របស់អារ៉ុមនេះរស់នៅតទៅទៀតទេ ។ រូបនេះអូនបានផ្ដាច់ចេញស្រឡាស់អំពីរូបយ៉ាហាន ដើម្បីកុំឱ្យកេរ្តិ៍ឈ្មោះរបស់យ៉ាហានដាមប្រឡាក់កខ្វក់ដោយសាររូបអារ៉ុម ។ លុះថ្ងៃមួយ រូបអារ៉ុមនេះរលាយបាត់ទៅ កេរ្តិ៍ឈ្មោះល្អរបស់យ៉ាហាន នឹងបានឋិតថេររយូតតទៅ ។ អូនខំលាក់បាំងយ៉ាងនេះគឺ ដើម្បីការពារកិត្តិយសដ៏ល្អពិតរបស់យ៉ាហានតែប៉ុណ្ណោះ ! ។

អ្នកប្រុសផ្ដេកខ្លួនក្រកងនាងនរីងនឹងថ្នង

-បងនឹកអាស្ចូរដល់យ៉ាហានណាស់ បងចង់ឱ្យបុព្វេបង្វិលខ្សែជីវិតសាដើមវិញដើម្បីឱ្យបងបានទៅជួបនឹងយ៉ាហាន ។

នារីត្រេកអរនឹងសំដីសប្បុរសរបស់គេដែលបន្ទន់ចិត្តនាង បិទភ្នែកស្រមៃវិស័យដូចកាលនាងនៅក្រមុំ ។ នាងសប្បាយនឹងដៃគេថ្នាក់ថ្នមខ្លួននាងស្និទ្ធឥតមានឆ្លងត្រេកត្រអាល នឹងគេបបោសអង្អែល ស្ទាបច្របាច់សាច់ឈាមនាងឱ្យស្រៀវស្រាញគ្រប់កន្លែង ធ្វើឱ្យនាងហត់ ឱ្យនាងដង្ហក់ ឱ្យនាងភ័យផងអរផង ។ មាត់គេថើបបន្ទើរមក សសៀរមកដល់មាត់នាង ។ បន្ទាប់ពីនោះមកនាងដូចជាភាន់អស់រលីង គ្រាន់តែដឹង ច្បាស់ថា ខ្លួននាងទាំងអស់ជារបស់គេថាខ្លួនគេទាំងអស់ជារបស់នាង ។

លុះគេឆ្អាញ់ខ្ជាំងនឹងកំដៅសម្ផស្សរបស់នាង នាងស្រវាឱបរឹតគេវិញចេញវាចារវើរវាយ : "បង !... បងមកដល់យ៉ាហានហើយ បងយកចិត្តយ៉ាហានទាំងអស់ចុះចិត្តហ្នឹងអូនមិនទាន់ដែលប្រគល់ឱ្យអ្នកជណាឡើយ... "

នាងមិនដែលស្លុងទៅជាមួយប្រុសណាយ៉ាងដូច្នេះទេ សព្វដងនាងធ្លាប់តែធុញធ្លាប់តែ បណ្ដោយកេរ្តិ៍ខ្មាសឱ្យប្រុសទាំងទើសទាល់ ធ្លាប់តែប្រុសធ្វើឱ្យនាងទ្រាន់ចុះម្ដងនេះ ហេតុអ្វីក៏នាងមិនចេះគ្រប់ចិត្តនឹងសេចក្ដីអាណិតរបស់គេសោះ ! ។ គេរឹតរួតនាង កាន់តែហួសកម្រិត នាងរឹតតែពេញចិត្តអណ្ដែតអណ្ដូងរមួលញ័រសព្វសាច់ភ្លេចអស់របស់ដែលនៅជុំវិញខ្លួន... ។ ... មិនដឹងជារយៈពេលប៉ុន្មានបានកន្លងផុត

ទៅហើយទេ, ប៉ុន្តែលុះប្រុសគេរំសាយដៃចេញពីនាង នាងចាប់ហាត់គេមិនឱ្យឃ្លាតចេញពីខ្លួននាង ហើយថ្ងូរអង្វរញ័រចំប្រប់នៅជាប់នឹងខ្លួនគេ ៖ “ ម្តេចក៏បងឆាប់អស់ចិត្តនឹងអូនម៉្លេះ ! ... បងអាណិតអូនទេ ... ”
សម្លេងប្រុសឆ្លើយថ្នមនៅជាប់នឹងថ្ពាល់នាង

- “បងអាណិតអូនណាស់... រូបកាយយើងទាំងពីរមាននិស្ស័យនឹងគ្នាពិត” ។

នាងស្របទាំងស្រុងនឹងចម្លើយនេះ ពីព្រោះនាងស្រវាឱបគេ ហើយវាចាល្ងើយដូចជំនោរដែលបក់ស្រាលទៅឆ្ងាយ ។

- “ ឱបង ! អូនដូចជាវង្វេងអស់ហើយមិនដឹងជារូបអូនចប់ត្រឹមណា មិនដឹងជារូបបងផ្តើមឡើងត្រឹមណា ! អូនច្រឡំចូលគ្នាអស់ហើយ ! ឱបង ! ម្តេចក៏បងមានប្រសិទ្ធិភាពអ្វីម៉្លេះមកលើរូបអូន អូនមិនដែលដូច្នេះទេ ! មិញហ្នឹងខ្លួនអូនញ័រខ្លាំងអស់ ខ្លួនអូនដូចជាស្រាលហាក់ដូចជាបងបានដកយកព្រលឹងរបស់អូនទៅអស់រលីង ! ” ។ នាងនៅទៀលក្បាលទៅនឹងអ្នក ហើយមិនយូរប៉ុន្មានក៏គេងលក់ឈឹងនៅជិតនោះទៅ ។ អ្នកប្រុសលាភួយដណ្តប់ឱ្យនាង ហើយក្រោកចេញថ្នមៗទៅអង្គុយម្នាក់ឯងនៅក្រោមពន្លឺព្រះចន្ទ : “ យ៉ាហាន... អារ៉ុម... ការពិតនៅត្រង់ណា... ម្តេចក៏រឿងយ៉ាហានឱ្យកំណើតមកដល់រឿងអារ៉ុម... រូបតែមួយហេតុអ្វីក៏ជាប់រឿងគ្នាជាពីរ ?... ចំពោះរូបខ្ញុំ តើនាងជាអារ៉ុម ឬជាយ៉ាហាន ! ” ។

អ្នកប្រុសភ្ញាក់ព្រើតដោយភ័ក្ត្រមួយមកលបថើបអ្នកពីខាងក្រោយ ហើយសើចកក្អឹក

- បងភ័យឬទេ បើស្រីលបស្រឡាញ់អីចឹង ?
- បងវិសតែលោះព្រលឹងដោយត្រេកអរពេក

រួចនាងមកអង្គុយលុតចង្គង់ នឹងក្តារនៅមុខកៅអីរបស់អ្នក
ដៃនាងទាំងពីរស្រាក់ឱបចង្កេះប្រុសសម្លាញ់

- បើបងឥតគេងសោះយ៉ាងហ្នឹង ស្អែកឡើងអស់កម្លាំងស្លាប់ហើយ !
- គេងទៅក៏មិនបានប៉ុន្មានដែរ ពីព្រោះមាន់រងាវទៅហើយ ។ បន្តិចទៀតបងត្រូវរៀបចំវិលទៅភ្នំពេញវិញហើយ ។

នាងដកដង្ហើមធំ ទ្រោបក្បាលទៅលើភ្លៅបុរស

- អូនដូចជាទើបនឹងភ្ញាក់ពីយល់សប្តិ រូបបងនឹងត្រូវរបូតផុតអំពីដៃរបស់អូននៅពេលដែលព្រះអាទិត្យរះឡើងវិញ ។ អូននឹងត្រូវស្រវាចាប់តែស្រមោលដែលរលាយបាត់ទៅជាមួយនឹងរាត្រី ។

អ្នកអង្អែលសក់នាង

- ថ្ងៃមួយគង់តែបងត្រឡប់មកវិញទេ ។

សំដីនេះ ធ្វើឱ្យនាងក្រោកឡើងអោបកស្លួបញ្ឈក់ទៅអ្នកវិញ ៖

- ប្រាកដមែនបង ? ថ្ងៃណា ! ទើបបងអញ្ជើញមកវិញ ? អូននឹងនៅរង់ចាំបង ។

អ្នកត្រវីក្បាលតិចៗ

- ទំរាំតែបងត្រឡប់មកវិញ ប្រហែលជាខ្មោចខ្ចីអស់ទៅហើយ ! មិនដឹងជាអូនយល់សប្តិលប្បាយជាមួយនឹងស្នេហាប៉ុន្មានរយនាក់ទៀតទៅហើយ !...។

សម្លេងកំប្លែងធ្វើជាចិនរត់តុរបស់លោកសុតនិងលោកថៃ លាន់ឮបន្តួចមកពីខាងក្រោយ

" បបរមាន់ក្ដៅៗអាមួយអើយ... ហោជាក់ចោលណាំងចាយ ជាមីកាយ ជាក់នំធំរបស់អាទី "

ឮស្នូរអាទីពក់ក្អកៗ ឮស្នូរលោកថៃ ថែមទៅវិញ ៖

" កុំអាលធ្វើមុខស្អែតយ៉ាំងហ្នឹង អាទីអើយ ចាំអញដកមេឱ្យ ! ឯងញុំតែបបរមាន់មួយចានទៅ មុខជាញញឹមដាក់អញទៀតហើយ " ។

អាទីជួយលើកបបរឡើងមកលើ ។ នាងរ៉ុមក្រាលកន្ទេលរៀបចានជូតកែវ ។ បបរមាន់មួយចានដៃកធំ នៅហុយចំកណ្ដាលរង់បណ្ដែតក្លិនគួរឱ្យចង់សាកមួយចាន ។

នាងរ៉ុមញញឹកញញ័កនឹងអ្នកប្រុសជាច្រើន ថែមបបរហើយតឿនគេឱ្យញុំ

" បងញុំបន្តិចទៀតទៅ ! បងឥតបានពេងផង តែខំមុខជាអស់កម្លាំងហើយ "

លោកសុតងាកមើលមកឃើញយ៉ាងនេះ ចេះតែញញឹម ប៉ុន្តែមិនហ៊ានថាអ្វី ។

លោកធំសង្កេតយល់ដល់ចិត្តកូនចៅក៏ជំរុញឱ្យ

- ម៉េចសុត ! ចេះតែញញឹមខុកធ្វើអ្វីហ្នឹង ? ចង់ថាអ្វីក៏ថាទៅ ។

លោកសុត យកដៃខិបចង្កង់ធ្វើអឹមអៀនហើយកំប្លែងថា ៖

- តេជ:គុណអើយ លាក់បាំងអ្វី បើខ្ញុំបាទបានតែប៉ាណ្ឌឹងមុខជាសុខចិត្តលក់ពោមួយនឹមហើយ ! ។

ចៅហ្វាយអស់សំណើចចង់ឈ្លក់បបរ នាងរ៉ុមអៀនមុខឡើងក្រហម ទើបលោកសុតបន្តទៅទៀត

" អាទីរបស់ខ្ញុំបាទវាមិនអីចឹងសោះ ! មួយថ្ងៃៗ ខ្ញុំបាទត្រាំខ្លួននឹងដៃវាពក់ " រួចលោកសុតបែរទៅបញ្ឆក់នឹងអាទីទៀត

- ម៉ែមីនាងឯង ចង់ឱ្យអញឆាប់ងាប់ណាស់ទៅឬអ្វី ? ប្រញាប់ទៅរកអ្នកណាឱ្យមកដកមេទៀតឬអ្វី ?

- ចាំស ពីព្រោះ "ជួស" បងឯងខ្ញុំញុំទៅវាមិនស្រវឹងសោះ !

- ធ្វើម្ដេចនឹងស្រវឹង បើអាទីឯងវាដុះមេខ្លាំងណាស់ទៅហើយ !

ពួកប្រុសៗ ហោទះដៃព្រេវ ។

“ ឆ្ងាញ់ណាស់សុត ! សុតឯងសងឆ្ងាញ់ណាស់ ! អានីដួលដួចតោដឹងសៀង ! ”

ខទួលខានបបររួច បែបផ្ចន់ពោះផង ហើយអស់អស់កម្លាំងណាស់ផង ស្រាប់តែនាំគ្នាដួលរដ្ឋកស្រមុកកខេរ, ខ្លះនៅលើគ្រែឫស្សី ខ្លះនៅលើអង្រឹង ។ នាងរ៉ុមខាញដៃប្រុសសម្លាញ់ទៅកាន់បន្ទប់ : “ បងជិតបែកពីអូន ហើយ, ឱ្យអូនសុំនៅជិតបងឱ្យបានយូរបន្តិច ”

ទ្វារក៏បិទជិតទៅ ។

អាកាសកាន់តែព្រជាក់រងាកាន់តែខ្លាំង ។ ខ្យល់បក់ស្លឹកដូងលាន់ស្រើបៗ ច្រឡំនឹងទឹកភ្លៀង ។ ខែជ្រេទាបទៅលិចណាស់ទៅហើយ ។ នាឡិកាប៉ោលកញ្ចាស់លោកសុត វាយម៉ោងបួនបង្អួលដួចចង់ដាច់ខ្យល់ ។

មាន់រងាវជិតភ្លឺហើយ ប៉ុន្តែយប់នៅវែងឆ្ងាយណាស់នៅឡើយ ។ លោកធំដាស់លោកសុតឱ្យរៀបចំឥវ៉ាន់ស្ងាត់ៗដាក់ឡានលោក

“ សុតឯងកុំចាំបាច់ដាស់ពួកហ្នឹងធ្វើអ្វី ទុកឱ្យគ្នាដេកចុះអាណិតគ្នា ។ បើអារ៉ុមភ្ញាក់ឡើងសួររកខ្ញុំ សុតឯងប្រាប់វាផងថា កុំឱ្យទឹកនាដល់រូបខ្ញុំធ្វើអ្វី ពីព្រោះខ្ញុំមានសង្សារបញ្ចាំជីវិតរួចទៅហើយ ឈ្មោះ យ៉ាហាន បើទោះជាយ៉ាងណាក៏ខ្ញុំមិនអាចបំភ្លេច យ៉ាហាន បានឡើយ ” ។ លោកសុតធ្វើ មុខមីងមាំង ពីព្រោះដូចជាមិនសូវយល់រឿងបណ្តាំរបស់លោកនេះសោះ ។ លោកធំឃើញយ៉ាងហ្នឹងក៏បញ្ជាក់ថែមទៅទៀត

“ សុតឯងប្រាប់វាតែតាមពាក្យខ្ញុំផ្តាំហ្នឹងទៅបានហើយ ទង់តែវាយល់ ទេ កុំឆ្ងល់អ្វី ! ហើយសុតឯងទុកប្រាក់ប្រាំរយរៀលនេះឱ្យវាផង ”

រួចលោកបញ្ឆេះរថយន្តចេញឆ្ពោះទៅកាន់ផ្លូវភ្នំពេញ ។ បន្ទាប់នោះភ្លាម នាងរ៉ុមរត់ចុះមកដល់ក្រោម ៖

លោក ! ឯណាឡានលោកធំ ?

លោកអញ្ជើញទៅភ្នំពេញហើយ

នាងរ៉ុមបាត់មាត់ឈឹង ទឹកភ្នែកនាងមិនដឹងជាហូរចេញភ្លាមមកពីណា ហូរស្រក់រហាមមកលើកំភ្លួ ។ នាងអត់ទ្រាំមិនបាន ខាំមាត់យកកន្សែងខ្ទប់មុខយំទៅនឹងតល់ដួង

“ ហេតុអ្វីក៏មុននឹងចេញទៅ បងមិនសម្លាប់អូនតែម្តងទៅ ! ពីព្រោះតង់តែអូនស្លាប់ដដែល ! . . . . ”

លោកសុតទប់ទឹកភ្នែកមិនបាន ក៏យំតាមនាងដែរ ៖

. - លោកបានផ្ដាំនឹងខ្ញុំថា . . .

នាងស្ទុះមករកលោកសុត

- ផ្ដាំថាម៉េចខ្លះ ? លោក !

- ថាលោកមានសង្ខារបញ្ចប់ជីវិតហើយ ឈ្មោះយ៉ាហាន សុំនាងកុំទឹកដល់លោកធ្វើអ្វី ពីព្រោះលោកមិនអាចនឹងភ្លេចនាងយ៉ាហានបានឡើយ ។

មុខនាងរីកស្រស់បន្តិចឡើងវិញ នាងសួរបញ្ជាក់ទៅលោកសុតថែមទៀត ពិតជាលោកបានផ្ដាំយ៉ាងហ្នឹងមែនឬលោក ?
ឃើញកិរិយាចម្លែករបស់អារ៉ុមបែបនេះ លោកសុតរឹតតែលែងយល់ ទៅទៀត ហើយយកដៃញីថ្ងាស

“ ចៅហ្វាយអញ យូរៗទៅបែបនាំអញទៅតាខ្មៅហើយមើលទៅ ! ”

# ជំពូក២ ៖ បំណុលវាស្នា

រថយន្តឈ្នួលកំពូងនៃនារីអនាថា បរលឿនស្ទើរដំដៅទៅភ្នំពេញ ។ អ្នកប្រុសបណ្ដោយឱ្យអ្នកបើកបរកាន់ចង្កូត ដើម្បីឱ្យអ្នកបានសម្រាកបន្តិច នៅនឹងពួកបង្អែកខាងមុខ ។ ក្បួនឡានទឹកស្ពាយទឹកដីសៀមរាប ដែលកាន់តែឃ្លាតទៅឆ្ងាយ ស្ពាយចំការដូង រត់ទៅដល់យ៉ាហាន ។ ខ្យល់បក់ចូលតាមកញ្ចក់ចំហៀង សួរសំណួរត្រសៀកមកបំពេរអារម្មណ៍ ដែលនៅសោកស្ដាយ ។ រឿងដែលកន្លងផុតទៅកំពុងតែរត់ច្រាសសាដើម ឡើងវិញច្រឡូកច្រឡំគ្នា

" ដល់យ៉ាហានភ្ញាក់ឡើង ប្រហែលជានាងខឹងនឹងខ្ញុំខ្លាំង ?... ចាំបាច់លាគ្នាធ្វើអ្វី ពីព្រោះថ្ងៃនេះគង់តែគេបានប្ដីថ្មីទៀតទៅហើយ " ។ រឿងនាងជាមួយនឹងអ្នក គ្រាន់តែជារឿងតូចមួយនៅក្នុងចំណោមរឿង "មួយពាន់មួយយប់" របស់នាងតែប៉ុណ្ណោះ ! ប៉ុន្តែចម្លែកត្រង់ស្ត្រីនេះហាក់ដូចជាទើបនឹងភ្ញាក់ស្គាល់ស្នេហាជាគ្រាដំបូង ! ។

ទៅដល់ភ្នំពេញ រថយន្តបត់ចូលទៅក្នុងភូមិគ្រឹះមួយស្អាតតូចល្មម ប្រកបទៅដោយវត្ថុជាតិម្ហូបខ្ទឹមខ្ទៃ ។ នារីម្នាក់សក់វែងដល់ចង្កេះពាក់អាវរ៉ូបយ៉ាងខ្លីបំផុត រត់ចេញមកក្រៅហើយស្រែកប្រាប់ទៅក្នុងផ្ទះ

" ម៉ាក់អើយ ! បងស៊ី ឈឿន ត្រឡប់មកវិញហើយ " រួចនាងខ្ទេតទៅរកបងជីដូនមួយដែលទើបនឹងមកដល់ ៖

" បងឯងរវល់តែនឹង "ត្លុរណោ" ខ្ញុំចោលសំបុត្រគេអញ្ជើញអស់ពីរបីកុំឱ្យបានចេញមុខ ចេញមាត់អ្វីនឹងគេកើត ! "

ស៊ី ឈឿន កំពុងតែមិនស្រួលក្នុងចិត្តផង ក៏តបដោយខ្ទោះទៅវិញ

- យី ! ចុះជើងចំនីឯងមកជាប់អ្វីនឹងខ្ញុំ ចង់ទៅណាក៏មិនទៅៗ យើងមិនមែនជាប្ដីប្រពន្ធនឹងគ្នាឯណា ? !

ចំនី ង ខ្ទើតចូលទៅក្នុងវិញ

- ម៉េច ! ម៉ាក់ឯង ជួយលុយឱ្យគេទៅរៀនស្រុកបារាំង ឥឡូវគេសង គុណវិញយ៉ាងហ្នឹងណ៎ា !

ស៊ី ឈឿន ចូលទៅក្នុងជំរាបសួរម្ដាយមីង ហើយយួរ "វ៉ាលីស" ឡើងហួសទៅបន្ទប់ខ្លួននៅជាន់ខាងលើ ចាក់សោ បើកទ្វាររួចបិទមកវិញ ដាក់គន្លឹះពីក្នុង ហើយប្រះពេងសន្ទឹងសន្ធៃនៅលើគ្រែ : " ចុះអញត្រូវសងគុណគេប៉ុន្មានទៅទៀតទើបគ្រប់ ? ជំពាក់អ្វីក៏ច្រើនសន្ធឹកសន្ធាប់ម្ល៉េះ ? សងរាប់ឆ្នាំមិនចេះចប់ " ! " សោហ៊ុយទៅរៀនឯស្រុកបារាំង

ជាអាហារូបករណ៍ ដែលរដ្ឋាភិបាលបានផ្តល់អោយអញទេ ។ ក្នុងរយៈពេលប្រាំមួយឆ្នាំ ដែលអញនៅឯបារាំង ក៏ដូចជាមិនបានទទួលប្រាក់អ្វីក្រៅពីលុយដែលម្តាយមីងផ្ញើទៅឱ្យទិញឥវ៉ាន់ឱ្យនាងចំន្ទីនោះដែរ .... ”

“កាលពីម្តាយខ្លួនឈឺ ហើយទទួលអនិច្ចកម្មទៅសោតទៀត សោហ៊ុយពេទ្យនិងធ្វើបុណ្យធ្វើទានទាំងប៉ុន្មាន ក៏ខ្លួនបានសងគេរួចអស់ទៅហើយ ។ ឥឡូវនេះវានៅជំពាក់ត្រង់ត្រូវរៀបការជាមួយនឹងចំន្ទី ដែលអញពុំគិតមិនបាននេះថែម ទៀត ” ។ “ បើនៅផ្ទះតប់ប្រមល់យ៉ាងហ្នឹង ដើរ “គួរណេ” ទៅវាចំណេញការរវល្អការជាង ហើយធូរទ្រូងផង ! ដេកនៅលើផ្ទះគេធំទូលាយ ប៉ុន្តែគ្មានទូលាយចិត្តសោះ ! ”

លុះដល់ម៉ោងដប់ ស៊ី ឈឿន មុជទឹកស្លៀកពាក់ស្អាតបាត កាន់កាបូបយួរចុះទៅក្រោម ។ ចំន្ទីរង់ចាំឱ្យតែឃើញអ្នកចុះមកវិញ

- ម៉េច ! អញ្ជើញទៅណាទៀតហើយ !

- បងទៅមើលប៊ុយរ៉ូមួយភ្លែត ទៅពិនិត្យសំណុំរឿងនិងដាក់ការឱ្យគេធ្វើខ្លះពីព្រោះចោលបុគ្គលិកពីរបីថ្ងៃទៅហើយ ។

- បើមិនគួរណេ ! ប៊ុយរ៉ូ ! បើមិនប៊ុយរ៉ូ ! គួរណេ ! ល្ងាចហ្នឹង០ចង់ទៅរាំនៅវង្គសាល ម៉េចជូនទៅបានទេ ?

- ជំរាបប្រសាសន៍ បាន

- ព្រឹកនេះប្រញាប់មកញ៉ាំបាយវិញផង ធ្វើការហួសម៉ោងច្រើនពេកដល់ឈឺទៅគ្មានអ្នកណាអាសូរទេ !

- បើចាំយូរ អូនជាងញុាំមុនចុះ

- កុំកាច់រាងពេក ! បងជាងនេះចូលចិត្តឱ្យស្រីអង្វរណាស់ !

ទៅដល់កន្លែងធ្វើការនាយកការិយាល័យពីរបីនាក់កណ្តៀតសំណុំរឿងមួយតៗម្នាក់មកជូនលោក ស៊ី ឈឿន ដែលសន្ទនារួសរាយជាមួយនឹងអស់លោកក្រោមបង្គាប់

- បើចេញទៅប្រតិបត្តិការតែមួយអាទិត្យ ប្រហែលជាសំណុំរឿងឡើងដល់ចង្កេះហើយមែនទេ លោកសឿន ?

- ប្របាទ ប្រហែលជាដល់ហើយ មើលទៅ ។

ស៊ី ឈឿន ចាត់ការមិនបង្អង់យូរ ។ ដល់ម៉ោងជិតមួយរសៀល តំនរក្រដាសដូចជាស្បើយគួរសមអំពីលើតុ ។ ទូរស័ព្ទរោទិ៍រ៉ឹង លោកចាប់លើកឡើងសួរ,

- អាឡ៉ូ ! អ្នកណាហ្នឹង ? ... សៀមរាបឬ ... អ្នកណា ! ? ។

សម្លេងពីសៀមរាបឆ្លើយតបមកវិញ

- អាឡូ ! តេជះគុណអធិការឬ ?

- បាទ ខ្ញុំហ្នឹងហើយ

- អាឡូ ! ខ្ញុំបាទ... សុត

- អ្ហ៎ ! សុត... ម៉េចទៅសុត ! មានការអ្វី ?

- បាទ ! ខ្ញុំបាទសូមជំរាបបន្តិច ៖ ក្រោយដែលតេជះគុណអញ្ជើញចេញផុតបន្តិចមក ដើមដូងខ្ញុំបាទមានសំណាងដល់ហើយ ! ត្រូវបានស្រោចសុទ្ធតែនឹងទឹកភ្នែក

- ខ្មោច ! ខ្ញុំមិនយល់ទេ ! ចង់ថាអីហ្នឹង ?

- បាទ កូនចៅស្រីផ្ទាល់របស់តេជះគុណ យំសម្បើមណាស់ ឡើងត្រជាក់ខ្លួនទាល់តែគ្រាហ៍យកទៅផ្ទះ ។

ស៊ី ឈឿនក្តុកក្តួលក្នុងចិត្ត

- រួចចុះ យ៉ាងម៉េចទៅសុត ?

- បាទមិនអីទេ ប៉ុន្តែទឹកមុខដូចជាអស់សង្ឃឹមខ្លាំងណាស់

- សុតឯងឧស្សាហ៍ទៅមើលគ្នាផង គួរឲ្យអាសូរដែរ ! ចុះសុតឯងមានប្រាប់តាមបណ្តាំខ្ញុំទេ ?

- បាទប្រាប់ហើយ ប៉ុន្តែខ្ញុំបាទឆ្ងល់ណាស់ ដល់ប្រាប់យ៉ាងហ្នឹងទៅស្រាប់តែដូចជាមុខរីកបន្តិចឡើងវិញ ។

ស៊ី ឈឿន អស់សំណើចនឹងលោកសុត

- សុត ឯងកុំយល់ធ្វើអ្វីច្រើនពេក គ្រាន់តែទៅប្រាប់នាងវិញថារលឹកណាស់ ។

សម្លេងលោក សុត ឆ្លើយកខិបកខុបអំពីចម្ងាយមកវិញ

- ឱ ! មុខជាគ្នាអរស្លាប់ហើយតេជះគុណអើយ សូម្បីតែខ្ញុំបាទក៏ដូច ជាត្រេកអរដែរ... ។

---------------------------------------

យប់ម៉ោងប្រាំបី ស៊ី ឈឿនស្លៀកពាក់ជូននាងប្អូនចៅហ្វាយម្ចាស់ទៅរាំ ។ ចន្ទីលាបបបូរមាត់លឿងស្វាំង វង្វង់ភ្នែកខៀវស្លែត គូររោមភ្នែកវែងខ្មើតហើយលើកសក់ដូចកំពូលចេតិយ ។

ស៊ី ឈឿន តឹងទ្រូងជិតដាច់ខ្យល់ នឹកឆ្ងល់ថាចុះម្នាក់ហ្នឹងម្តេចក៏ឈ្លើយហួសហេតុម្ល៉េះ ?

ចន្ទីបញ្ឆេញឡាន "ហ្វីយ៉ាត់" បើកដំបូលរបស់គេមករោទ៍ព្ញសូរង៉ោងៗ

ហើយសើចស្រាញមករកបងជីដូនមួយ

- ថ្ងៃហ្នឹងឲ្យអូនកាន់ចង្អុតណាំបង ? អូនសុំបណ្ដើរបងឯងម្ដង ។

ស៊ី ឈឿន តបមកវិញដោយទ្រាន់

- កាន់ទៅចុះ គ្មាននរណាគេជ្រៀតជ្រែកទេ កុំតែបើកពារគេពារឯងដូច ថ្ងៃមុនទៀត !

- ចុះបងឯងនៅជិតអូនស្រាប់ហើយ ម្ដេចមិនជួយមើលអូនផង !

- មើលយ៉ាងម៉េច បើខ្លួនធ្វើស្រេចតែនឹងក្បាលចិត្តយ៉ាងហ្នឹង !

រោងរាំត្រជាក់យ៉ាងប្រណិត មានភ្ញៀវពេញ ទាំងខ្មែរទាំងបរទេស ។ ភ្លើងពណ៌ចោលរស្មីស្រគាំ មើលទៅរូបស្រីៗ ឃើញដូចជាសុទ្ធតែស្រស់គ្រប់គ្នា ទាំងអស់ ។ ភ្លេងប្រគំរងំពិរោះ នាំជំហានគូរាំដែលកំពុងតែរំពើននៅលើផ្លារាំ ។

ច័ន្ទី កៀកដៃ ស៊ី ឈឿន បណ្ដើរជិតមួយជុំសាល នៅតែមិនទាន់រក កន្លែងបានអង្គុយ ! ... ត្រង់នេះមិនស្រួល... ត្រង់នោះមិនត្រូវចិត្ត... នាំឲ្យភ្ញៀវឯទៀតចាប់អារម្មណ៍ ងាកមកមើលច្រើនគ្នា ... ខ្លះជំរាបសួរ និងហៅរករាក់ទាក់ទៅកាន់ ស៊ី ឈឿន ។

ច័ន្ទីមិនទាន់គ្រប់គ្រាន់ក្នុងចិត្ត ក៏ក្និកក្នក់ដាក់អ្នកប្រុសទៀត

- បងឯងគេស្គាល់ច្រើនណាស់ ប៉ុន្តែបងឯងគ្មានបង្ហាញអូនទៅអ្នកណា ម្នាក់សោះ ធ្វើម៉េចគេនឹងបានស្គាល់អូនដែរ ... ប្រយ័ត្នគេច្រឡំថាអូនជាស្រី អ្នកស៊ីណាំ !

ស៊ី ឈឿន ហួសចិត្ត

- នែ៎ ! ស្រីឯងដូចជាល្មមហើយណាំ ! កុំធ្វើដូចនៅក្នុងផ្ទះខ្លួននោះ ! គិតថាមិនប្រាប់ !

ត្រូវមាត់ប៉ុណ្ណឹងទៅ ច័ន្ទីដូចជាអន់សាច់គួរសមដែរហើយរកកន្លែងបាន អង្គុយនៅជិតទីរាំ ។

ឆា-ឆា-ឆា ក៏នាងរាំ តង់គ្នោក៏រាំ ទ្វីសក៏រាំ គិតទៅគ្មានខាតពេលបន្តិច សោះ ។ ស៊ី ឈឿន មិនជាចិត្តអាក្រក់ទេក្នុងរឿងនេះ ។ រូបឆោមរបស់ ច័ន្ទីក៏មិនមែនជាអន់ដែរ ផ្សំនឹងឫកផុកផឹក់បន្តិចទៅ មិនសូវខុសគ្នានឹងអ្នកច្រៀង ប៉ុន្មានទេឡើយ ។

មកដល់បទ "ស្លូ" អ្នកប្រុសដឹកដៃនាងឡើងរាំទៀត ។ គូទាំងពីររឹតគ្នាយ៉ាង ស្និទ្ធ ច័ន្ទីពេញចិត្តណាស់

" បងឯងរឹតអូនឲ្យខ្លាំងជាងហ្នឹងបន្តិចទៀតមក អូនធ្មេចភ្នែកហើយ ... បងឯងនាំអូនទៅចុះ " ។

នាងផ្ទេកថ្ពាល់ទៅលើស្មាគូរាំ បណ្ដែតទៅតាមរលកបទភ្លេង ។

យប់កាន់តែជ្រៅទៅ មិនដឹងជានៅឯសៀមរាប រាត្រីនេះមានសកម្មភាពយ៉ាង ណាដែរទេ ... ។ ដើមដូងត្រូវបានដោកទៅដោយទឹកភ្នែក ... នារីម្នាក់បានយំ ដោយស្ងប់ស្ងាត់ ។ ឯសៀមរាប ជាស្រ្តីដើរលេង ... ឯភ្នំពេញជាស្រ្តីវង្វេងនឹង សម័យ ... ឯណោះទាក់នឹងចិត្ត ... ឯណេះទាក់នឹងករណីកិច្ច ... ស៊ី ឈឿន ឯងដោះស្រាយចុះ ! ពីព្រោះដូចជាមាននិស្ស័យនឹងស្រីៗគ្រាន់បើ ។

ថ្ងៃអាទិត្យ ។ ប្រាំមួយថ្ងៃកន្លងទៅហើយ តាំងពី ស៊ី ឈឿន ត្រឡប់មកពីសៀមរាបវិញ ។ រាល់ថ្ងៃ ស៊ី ឈឿន ធ្វើការទាំងព្រឹកទាំងល្ងាចសឹងតែឥតមានពេលសម្រាក ។ រាល់អាទិត្យ អ្នកតែងតែទៅរកកន្លែងស្ងប់ស្ងាត់មានធាតុអាកាសល្អនៅឯចំការភូមិកំណើតរបស់អ្នកខាងស្រុកស្អាង ប្រហែលជាងម្ភៃគីឡូម៉ែត្រពីភ្នំពេញ នៅតាមផ្លូវកោះធំ ស្ងួចត្រីក៏សប្បាយ អុំទូកលេងក៏សប្បាយ ។

ថ្ងៃនេះ តាំពីម៉ោងប្រាំបីព្រឹក ស៊ី ឈឿន ស្លៀកពាក់ស្អាតបាតចេញពីបន្ទប់ចុះមកក្រោម ហើយសួរទៅក្មេងស្រីបំរើដែលកំពុងតែជូតឥដ្ឋ

- អាម៉ុន ! ម៉ាក់មីងអញ្ជើញទៅណាទៅ ?

- ចាំស អុំស្រីគាត់នៅឯក្រោយ កំពុងតែធ្វើស្លាធម៏ ។

ស៊ី ឈឿន ដើរចេញទៅក្រោយ ជួបនឹងម៉ាក់មីង

- ម៉ាក់មីង ! ធ្វើស្លាធម៏អ្វីទៀតហើយហ្នឹង ?

- អើ ! ថ្ងៃហ្នឹង មីងគិតទៅវត្តបន្តិចណ៎ា !

- ក្រែងមិនមែនថ្ងៃសីលទេ ថ្ងៃហ្នឹង ! ម៉ាក់មីង !

- អើ ! ចាំបាច់តែថ្ងៃសីលអ្វីលោកក្មួយ ។

ម៉ាក់មីងពាក់វ៉ែនតាសធ្លាក់ដល់ចុងច្រមុះ កំពុងតែស្លាបអង្រែលម្អូរដោតដាក់ ស្លាធម៏ ។ គាត់គ្មានប្រញាប់ប្រញាល់អ្វីទេ ពេលវេលាគាត់មានគ្រប់គ្រាន់ជានិច្ច គាត់ទុកដាក់រៀបចំមិនចេះចប់ ចេះតែមានការធ្វើរហូត រើពីនេះដាក់ទៅឯណោះ រើពីណោះដាក់មកឯណេះ មួយថ្ងៃៗ ស្ងាប់តែនឹងចន្លីរអ្វី ។

ស៊ី ឈឿន នឹកឆ្ងល់នឹងបាត់មិនឃើញ ចន្ទី

- ចន្ទី ទៅឯណាទៅហើយ ម៉ាក់មីង ?

- វាថាទៅធ្វើសក់ ។

ស៊ី ឈឿន ភ្ញាក់ប៉ុនគេចោល

- ធ្វើសក់អ្វីទាំងព្រហាមអុលយ៉ាងហ្នឹង ម៉ាក់មីង ! គេប្រុងនឹងទៅណា គេហ្នឹង ?

- ចុះក្មួយឯងមិនដឹងទេឬ ! ប្អូនឯងនោះ ! ក្មួយឯងមិនសង្កេតឃើញអ្វីប្លែកឬទេសព្វថ្ងៃ ?

- បាទ ម៉ាក់មីង ខ្ញុំឃើញកាន់តែប្លែកឡើងៗដែរ
- ប្លែកជាមួយនឹងក្មួយឯងហ្នឹងណ៎ា
- ខ្ញុំដូចជាមិនច្បាស់លាស់ដែរម៉ាក់មីង !
- អើ សព្វថ្ងៃហ្នឹង វាដូចជាកាន់តែប្រចណ្ឌខ្លាំងណាស់នឹងរូបក្មួយឯងនេះ ។ ព្រឹកមិញ មីងប្រាប់វាថា ឲ្យវានឹងក្មួយឯងទៅវត្តជាមួយនឹងមីង ដើម្បីឲ្យលោកស្រោចទឹកឲ្យទាំងពីរនាក់ ។ ស្រាប់តែវាថារត់ទៅធ្វើសក់សិន ពីព្រោះវាត្រូវទៅជាមួយនឹងបងឈឿនវាផង ! វាប្រឹងតែងខ្លួនក៏ដោយសារតែចង់ឲ្យពេញចិត្តក្មួយឯងប៉ុណ្ណោះ ។

ស៊ុ ឈឿន រង់ចាំកន្លែងនេះយូរហើយ អ្នកដឹងថាគង់តែមកដល់ត្រង់ហ្នឹង ទេ ។ ហើយក៏ជំរាបម្ដាយមីងដោយស្រងូតស្រងាត់ថា ៖

- ម៉ាក់មីងជាអ្នកមានស្ដុកស្ដម្ភ ច័ន្ទក៏មានរូបឆើតឆាយ របៀបតែងខ្លួនរបស់គេក៏ទាន់សម័យ ។ ខ្ញុំជឿថា មិនមែនមានតិចទេ អស់លោកធំៗ ដែលចង់ស្ដីដណ្ដឹងច័ន្ទ ។ ប៉ុន្តែវាទាស់គេមកឃើញខ្ញុំមកទៅខាំក្រាបលើផ្ទះម៉ាក់មីង ជាហេតុនាំឲ្យគេទើសទាល់មិនសួរហ៊ានប្រថុយ ។

ម្ដាយមីងងើបមុខឡើងមើលក្មួយដោយញញឹម

- ទេ ! ម៉ាក់មីងមិនចង់ឲ្យវាទៅលោកណាទេ ម៉ាក់មីងចង់ផ្ញើវាស្មារបស់វាមកលើក្មួយឯង ដើម្បីកុំឲ្យខុសបណ្ដាំរបស់ម្ដាយឯង ដែលមុននឹងស្លាប់បានផ្ដាំឲ្យ មីងថែរក្សាក្មួយឯង ហើយឲ្យផ្សំផ្គុំជាមួយនឹងច័ន្ទ ។

ស៊ុ ឈឿន ជញ្ជីងគិតមួយស្របក់ធំ អ្នកដូចជាមិនដែលបានឮអ្នកឯណាម្នាក់និយាយអំពីបណ្ដាំនេះសោះ ។ អ្នករកស្មានមិនដល់ទេ ត្រង់ថានៅថ្ងៃមួយអ្នកនឹងបានទៅជាប្ដីរបស់ច័ន្ទ

- ម៉ាក់មីង ! ខ្ញុំនឹងច័ន្ទ ដូចជាមានគំនិតនិងការរស់នៅផ្សេងពីគ្នាច្រើនណាស់ណ៎ាអ្នកមីង ! ក្រែងមិនស្រួលទេដឹង ?

- ប្រពន្ធវាស្រេចតែនឹងប្ដីទេ ក្មួយអើយ ក្មួយឯងបុណ្យស័ក្ដិធំម្ល៉េះៗនោះ ! នំវាមិនធំជាងនាលិទេ

ស៊ុ ឈឿន រកទុកចិត្តមិនបានសោះ

- នំមិនដែលធំជាងនាលិឯណា ! បើសព្វថ្ងៃច័ន្ទធំជាងម៉ាក់មីងឯងណាស់ ទៅហើយ

- អើ ! ម៉ាក់មីងវាល្ងង់ បានជានិយាយទៅ វាមិនស្ដាប់ ។ ក្មួយឯងជាអ្នកចេះដឹងច្រើន មុខជាវាខ្លាចមិនខាន បើបានប្ដីក្រៅពីក្មួយឯង ក្រែងវាមិនស្ដាប់គេនាំឲ្យឈ្លោះប្រកែកបាក់បែកគ្នា ។ ក្មួយឯងអាចចេះអត់ឱនអោយវា អាចជេរស្ដី ឲ្យវាបានអាចកែវាបាន អាចសុខនឹងគ្នា ។ ហេតុនេះហើយ បានជាម៉ាក់មីង

មិនចង់ឲ្យវា ទៅអ្នកណាក្រៅពីក្មួយឯងសោះឡើយ ។

ស៊ុី ឈឿន ពិចារណាឲ្យសព្វៗទៅ ឃើញថាសំដីម៉ាក់មីងដូចជាសមណាស់ ដែរ

- បើអ៊ីចឹង ម៉ាក់មីងឯងគិតប្រគល់គុណវិបត្តិរបស់ច័ន្ទីទាំងស្រុងមកឲ្យខ្ញុំទទួលខុសត្រូវទាំងអស់ទៅ ?

- ចុះវាទាស់អ្វី ? បងប្អូនឯងនុ៎ះ ! វាមូលទ្រព្យសម្បត្តិផង !

- ទេម៉ាក់មីង ក្មួនពេទ្យថាមិនស្រួលសោះណា៎ ដែលមកយកបងប្អូនឯងសាច់ជិតគ្នាអ៊ីចឹងនោះ ពីព្រោះដល់បានជាកូនមកវាកាត់ទៅ កំហុសម៉ែកំហុសឪទាំងអស់ !

ម៉ាក់មីងយកដៃរឹតទ្រូង

" ព្រះអើយព្រះ ! បើអ៊ីចឹងមីងនិងពូឯង យកគ្នាជាប្ដីប្រពន្ធកើតឬទេសុទ្ធតែជាជីដូនមួយនឹងគ្នាដែរ ! "

ស៊ុី ឈឿន នឹកក្នុងចិត្តថា

" ព្រោះតែអ៊ីចឹងហើយ បានជាច័ន្ទីវាទឹកកន្ទះក្ដមយ៉ាងហ្នឹង, ម្ល៉ឹងហើយនៅតែមិនទាន់ដឹងខ្លួនទៀត ! " ។

ពួស្សរស្បែកជើងស្រីកិបៗចូលមក

- យី ! បងប្រុសខ្ញុំថ្ងៃនេះស្រស់ណាស់ហ្ន៎ !

- ស្រស់មិនដល់ច័ន្ទីឯងទេ ពីព្រោះបងគ្មានទៅផ្ដុំសក់ ផ្ដុំអីឯណា !

ម៉ាក់មីងតឿនកូនស្រី ៖ " នែ ! មីនាង មើលរួតរះឡើង រៀបចំឥវ៉ាន់ទៅថ្ងៃណាស់ហើយ បងឯងគេមកចាំយូរបន្តិចហើយ " ។

ច័ន្ទីចាប់ឲ្យចត្រកដាក់កន្សែង សារុង និងដបទឹកពីរបីយួរទៅក្រៅដៃម្ខាងស្ទាបក្បីតសក់ រួចពិនិត្យមើលក្រចកដៃដែលទើបនឹងផុសខាត់លាបថ្មីៗ ។ ស៊ុី ឈឿន ឈរសម្លឹងដោយទើសចិត្ត

" ហ្នឹងហើយ លោកស្រី ស៊ុី ឈឿនក្នុងអនាគត ! "

ស៊ុី ឈឿនឡើងទៅបន្ទប់ខ្លួនខាងលើវិញ ផុតធូបបីសរសៃដោតបួងសួងធាតុម្ដាយនៅលើខ្នងទូ

" អ្នកម្ដាយជាទីស្រឡាញ់ បើអ្នកម្ដាយបានផ្ដាំឲ្យកូនយកច័ន្ទីមែនកូននឹងទទួលធ្វើតាមទាំងអស់ពិតមែន តែអាពាហ៍ពិពាហ៍នេះ មិនអាចនឹងមានសុភមង្គលដល់យើងទាំងពីរអ្នកកើតឡើយ ។ ប៉ុន្តែបើរឿងបណ្ដាំនេះជានយោបាយអកុសលនៃអ្នកមីង ដើម្បីនឹងចងភ្ជាប់ជាមួយនឹងកូនស្រីគ្រាសកន្ទេររបស់គាត់ទេនុ៎ះសូមឲ្យកូនរកឃើញនូវសេចក្ដីស្នេហាពិតប្រាកដ ទោះបីស្នេហានោះនៅក្នុង ទីណាឬក្នុងឋានៈណាក្ដី ។ សូមឲ្យសេចក្ដីបួងសួងរបស់កូនបានសម្រេច

ដូចក្តីប្រាថ្នា " ។

ឮស្នូរមាត់ហៅរន្ថើនមកពីខាងក្រោម ៖

- បងឈឿន ! នៅធ្វើអ្វីខាងលើហ្នឹង ! ក្រែងទៅវត្តឬ ?

- ឈប់ ! ចាំបងបិទបង្អួចបន្ទប់ឲ្យស្រួលបួលមួយភ្លែតក្រែងភ្លៀងសាច ។

រួចអ្នករត់ចុះមកក្រោមវិញ

- ម៉េចចន្ធី រៀបចំតវ៉ាន់សព្វគ្រប់អស់ហើយឬនៅ ?

- ដឹងអីបងឯង ចំណែកឯងខ្ញុំៗបានយកត្រកមួយនេះចេញមកក្រៅរួច ហើយ ។

ស៊ី ឈឿន អត់ទ្រាំមិនបាន ក៏ទ្រគោះទៅឲ្យវិញ ៖

- យីអើ ! មួយព្រឹកទៅហើយ នៅតែត្រកមួយដដែលហ្នឹង ! គិតថាមួយជីវិតហ្នឹង កុំឲ្យបានការអ្វីសោះទៅឬអ្វី ?

អ្នកកំលោះយកត្រកបោះព្រួសទៅក្នុងឡាន ហើយយកតវ៉ាន់ឯទៀតៗរៀបដាក់ទៅក្នុងឃ្លុបក្រោយបណ្តើរ ស្តីបន្ថែមទៅឲ្យចន្ធីបណ្តើរ ៖

- បើសិនជានាងឯងទៅនៅជាមួយនឹងខ្ញុំវិញ ខ្ញុំនឹងឲ្យនាងឯងដើរកាត់វាលស្រែកណ្តាលថ្ងៃក្តៅឲ្យបានយ៉ាងតិចប្រាំមួយប្រាំពីរគីឡូម៉ែត្រឲ្យបានដឹងខ្លួនម្តង ។

ចន្ធីឆាល់មករកវិញដោយសម្លេងតឹង ៖

- ទៅ ! ទៅ ! ទៅឲ្យស្រីឯណាទៀតគេដើរទៅ ! បងឯងមិនបានជាមកប្រើខ្ញុំយ៉ាងហ្នឹងកើតទេ ខ្ញុំមិនបានជាទៅលន់តួសុំនៅបម្រើបងឯងយ៉ាងហ្នឹងទេ !

ស៊ី ឈឿនអត់ទ្រាំមិនបាន ៖

- ខ្ញុំក៏រឹតតែអរ ពីព្រោះខ្ញុំមិនមែនកើតមកសម្រាប់នៅបម្រើចន្ធីឯងដែរ ។

- គ្រាន់បើណាស់ហើយ បានជាជៀសផ្ទះខ្ញុំមិនរួច !

ស៊ី ឈឿនក្តៅណាស់ស្ទុះទៅចាប់ដៃចន្ធីទាញមកជិតចង់តែដាក់មួយកំផ្លៀងឲ្យផ្ទប់ទៅនឹងឡាន ប៉ុន្តែដូចជានឹកគិតទាន់ថា ឋានៈប្រហែលអ្នក មិនត្រូវទៅតបតនឹងស្ត្រីគ្រោសកន្ទងយ៉ាងនេះឡើយ ទើបអ្នកកំលោះគ្រាន់តែចំអកយ៉ាងធ្ងន់ ទៅឲ្យវិញ ៖

- នែ ! នាងចន្ធី ! បើនាងឯងជាស្ត្រីថ្ងៃថ្នូរ អំពីថ្ងៃនេះតទៅ គោងតែនាងឯងជៀស ស៊ី ឈឿនឲ្យរួច ។ ចំណែកឯង ស៊ី ឈឿនវិញ មុខជានឹងជៀសដំបូលផ្ទះរបស់នាងឯងឲ្យទាល់តែផុតជាមិនខាន ។

ឮសំឡេងឈ្លោះគ្នាខ្លាំងៗ ម៉ាក់មីងប្រវេប្រវារត់ចេញមកក្រៅ ។ ក្មួយប្រុសក៏ដំរាបទៅគាត់ភ្លាម ៖

" ម៉ាក់មីងឯងអញ្ជើញទៅវត្តជាមួយនឹងចន្ធីចុះ មិនចាំបាច់ជ្រោចទឹកឲ្យខ្ញុំទេ

ពីព្រោះខ្ញុំឥតមានវិកលចរិតអ្វីឡើយ " ។

ម៉ាក់មីងស្ងើសស្ងាស មិនដឹងជាត្រូវធ្វើដូចម្ដេច ណាកូនស្រីវារុញស្វាធម៌របស់គាត់ដួលច្រងាប់ច្រងិលពេញតែឡាន ណាក្មួយប្រុសគេខឹងគេ គេដើរតយង៉យបាត់ទៅខាងក្រោយ ។

" មីហ្នឹងវាចង់ឲ្យជងងាប់ឆាប់ហើយមើលទៅ ! ហងជងទាល់តែម៉ែស្លាប់បាត់ទៅ ទើបដឹងខ្លួន " ។ គាត់រើសស្វាធម៍យកទៅតំរៀបក្នុងឃ្លុបឡានខាងក្រោយហើយរអ៊ូទៀត ៖

" ក្មេងឥឡូវវាមិនដឹងបាប មិនដឹងបុណ្យទេ ! ស្វាធម៍ជងខំធ្វើមួយព្រឹកមើលចុះបាក់ស្វាបាក់ម្ជូរអស់រលីង ! " ។ គាត់ខឹងផង រកកលចង់យំបន្តិចផង ។ ស៊ី ឈឿន មិនដាច់ចិត្តក៏ត្រឡប់ចូលមកជួយរៀបចំគាត់ដែរហើយពន្យល់គាត់ថា ៖

- ម៉ាក់មីងជងកុំថ្នមចំនីជ្រុលពេក មនុស្សយើងទាល់តែបណ្ដោយឲ្យវា ធ្លាក់លំបាកធ្លាប់ប៉ះនឹងគេធ្វើបាបខ្លះផង ទើបវាដឹងខ្លួនខ្លះ ! បើម៉ាក់មីង ជងចេះតែតត្រុកបំរើវាបំពេញចិត្តវាសព្វយ៉ាងហ្នឹង វានៅតែគ្មានដឹងអីដូច សព្វថ្ងៃតទៅទៀត ! មិនដឹងជាអ្នកណាមកយកស្រីរបៀបហ្នឹង ទៅធ្វើប្រពន្ធ យ៉ាងដូចម្ដេចកើតទេ មិនដឹងជាឲ្យវាជួយធ្វើអ្វីកើតទេ ! ខ្ជិលក៏ខ្ជិល ! សប្បាយក៏សប្បាយ ! ដូចជាគ្មានដឹងអ្វីទាល់តែសោះ ! បើនៅជាមួយនឹងខ្ញុំមើលទៅខ្ញុំអត់មិនបានទេ ! " ។

ម្ដាយមីងដឹកដៃក្មួយប្រុសនិងកូនស្រីឲ្យចូលក្នុងឡាន គាត់អង្គុយនៅខាងក្រោយជាមួយនឹងអាម៉ុន ជក្រមុំកំលោះទាំងពីរជិះទន្ទឹមគ្នានៅខាងមុខ ។ ស៊ី ឈឿន បរឡានចេញមិនបង្អង់ មិនខ្ចីងាកមើលមុខអ្នកអង្គុយជិត ។ ក្នុងអារម្មណ៍អ្នកមានកំនិតមួយផុសឡើង ៖ " មើលទៅមុខក្រញូវ ត្រូវនឹងសំលៀកបំពាក់តែងខ្លួនឈ្លើយទៅទៀត ឃើញប្រហែលគ្នានឹងស្វា ! " ។ អ្នកចង់តែថាឲ្យឮៗ តែម្ដងប៉ុន្តែណើ្លយចុះទុកចាំសាក្រោយ ។

រថយន្តឆ្លងស្ពានព្រះមុនីវង្ស ទៅតាមផ្លូវអ្នកលឿងផុតជ្រោយអំពិល ហួសឃុំដីឥដ្ឋរហូតទៅដល់ច្រកចូលវត្ត " ចន្ទរង្សី " ទើបបត់ទៅស្ដាំ តាមផ្លូវលើកថ្មីមួយធំចម្ងាយប្រហែលជាពីរគីឡូម៉ែត្រ រួចទៅឈប់នៅនឹងស្ពានឈើមួយវែងខ្ពស់ប្រកបទៅដោយជណ្ដើរថ្មនៅចុងទាំងសងខាង ។ ខ្យល់បក់ខ្លាំងមនុស្សដើរឆ្លងស្ពានតោងយកដៃទប់សំពត់ ទប់សក់កុំឲ្យប៉ើង ខាំងពេក ។ ទឹកព្រែកនៅជ្រៅសន្ធឹង ខាងក្រោមមានរលកវេញៗ ។ ក្រឡេកទៅនាយឃើញវិហារបុរាណមួយចាស់ទ្រុឌទ្រោម លេចឡើងស្កឹមស្កៃលើកំពូលដីទួលខ្ពស់ត្រដែតចោតគ្រេងនៅចំកណ្ដាលស្រះមួយក៏ធំជ្រៅ ។

ទីអារាមស្ងាត់ជ្រងំ សូរស័ព្ទកណ្តឹងលាន់ឮព្រមគ្នាម្តងៗ ទៅតាមសន្សាប ព្រះវិហារ ។ យាយជីបីបួននាក់ស្លៀកពាក់ស អង្គុយប្រជុំគ្នាដោយស្ងប់ស្ងាត់ រៀបចំបង្អាន់នៅលើសាលាឈើគ្រាំគ្រា ធំស្រឡះល្វឹងឥតជញ្ជាំង ។ សភាពទូទៅហាក់ដូចជានៅឆ្ងាយដាច់សង្វែងអំពីស្រុកភូមិរបស់មនុស្ស ។

គ្រួសារម៉ាក់មីង ដើរត្រសងដំដៅទៅកុដិលោកតាសារ៉ាយ នៅជិតដើមពោធិខាងជើងព្រះវិហារ ហើយនាំគ្នាឡើងទៅអង្គុយនៅរានហាលខាងក្រៅ ។ ក្មេងម្នាក់ស្លៀកខោខ្លី បង់កសំពត់ឆ្នូតលឿងប្រផេះ យកទឹកតែមួយប៉ាន់ចេញមក ជូនភ្ញៀវ ។ បន្ទាប់មកលេចឃើញលោកតានិមន្តចេញមកគង់នៅនឹងមាត់ទ្វារដែលបើកចេញមកកាន់រានហាលក្រៅ ។

បន្ទាប់បីភ្ញៀវបានថ្វាយបង្គំនិងប្រគេនចង្ហាន់មក, ការសំណេះសំណាលរវាងលោកតានិងញាតិញោមក៏ចាប់ផ្តើមឡើង !

- ញោមស្រី ថ្ងៃនេះលោតែបានគ្នាច្រើន !

- នេះក្មួយប្រុសខ្ញុំព្រះករុណា នេះកូនស្រី នោះក្មេងនៅជាមួយ

- ចម្រើនពរ អាត្មាប្រហាក់ប្រហែលថាជាកូនស្រីរបស់ញោមដែរ ពីព្រោះមុខមាត់ដូចញោមណាស់ ។

- ខ្ញុំព្រះករុណាបានតែក្តីមួយហ្នឹង តាំងពីឪពុកវាស្លាប់ទៅ ខ្ញុំព្រះករុណាឡេះឡះតែម្នាក់ឯង ទល់គ្នានឹងក្មួយប្រុសវិស្វករនេះ គេត្រឡប់មកពីស្រុកបារាំងវិញទើបបានធូរគ្រាន់បើ ។

- ឱ ! លោកចៅឯណេះជាវិស្វករផង ! អញ្ជើញមកពីស្រុកបារាំងវិញប៉ុន្មានឆ្នាំហើយ ?

- ពិតព្រះពុទ្ធដីកា ប្រាំឆ្នាំហើយ

លោកតាញញឹម សំឡឹងទៅចៅប្រុស

- ចៅមានគ្រួសារបានកូនបានចៅប៉ុន្មានទៅហើយ ?

- ព្រះករុណា មិនទាន់មានគ្រួសារនៅឡើយទេ លោកតា ។

លោកតាភ្ញាក់ព្រើត

- យី ! ចុះម៉េចអីចុះ ? ប្រាំឆ្នាំទៅហើយ !

ម៉ាក់មីងឆ្លើយកាត់ ៖

- លោកតាអ៊ីយ ! រឿងរ៉ាវនោះវាយ៉ាងដូច្នេះ ៖ កាលពីម្តាយក្មួយឯណោះស្លាប់ទៅ បានផ្តាំថាឲ្យខ្ញុំព្រះករុណារៀបការក្មួយនេះនឹងមីនាងកូនខ្ញុំព្រះករុណា ។ កាលពីឆ្នាំដែលក្មួយឯណោះទើបនឹងត្រឡប់មកអំពីស្រុកបារាំង, មីនាងវាទើបនឹងអាយុបានជាងដប់បីឆ្នាំ ។ ក្មួយគេថានៅក្មេងពេក ក្បួនពេទ្យគេហាមមិនទាន់ឲ្យរៀបការទេ ។ ដល់មកឥឡូវនេះ ក្មួយគេជាក្បួនពេទ្យហាមថា មិនឲ្យយកបង

ប្អូនដីដូនមួយមួយឯងទៀតហើយ ។ ឥឡូវវាចេះតែរកាំរកូសមិនចេះចប់ បានជាមកសុំលោកតាឲ្យជួយសូត្រមន្តស្រោចទឹកបង្រួបបង្រួមចៅទាំងពីរឲ្យចេះតែពេញចិត្តនឹងគ្នារហូតតទៅ ។

លោកតាងក់ព្រះកេសតិចៗ ប្អូនប្រាំផង ហើយសម្លឹងមើលទៅចៅទាំងពីរ ឃើញចៅប្រុសឱនមុខមិនចេញស្តី ឃើញចៅស្រីមើលមិនដាក់ភ្នែកទៅលើចៅប្រុស ។ លោកតាដូចជាយល់អាការៈនេះគួរសមដែរ ទើបមានព្រះពុទ្ធដីកាថា ៖

- ញោមមករកអាត្មាហើយ អាត្មាចេះតែជួយ ជួយឲ្យបានសេចក្តីសុខទាំងពីរនាក់ ។ ប៉ុន្តែត្រង់ចិត្តគំនិតរបស់គេអាត្មាមិនអាចនឹងសន្យាថាដូចម្តេចកើតឡើយ ។

រួចហើយលោកតាឲ្យក្មេងដងទឹកមួយក្អម អុជទៀននិងធូបមួយសំណុំ រួចសូត្រក្លួរទឹកបែកពពុះមាត់ ជិតកន្លះម៉ោងទើបឲ្យចៅប្រុសចៅស្រីផ្លាស់សារុងមកអង្គុយទន្ទឹមគ្នា ឲ្យលោកតាស្រោចទឹកឲ្យ ។

មុននឹងថ្វាយបង្គំលាត្រឡប់ទៅវិញ ម៉ាក់មីងសុំលោកតាទាយលេខឲ្យយុវជនទាំងពីរនាក់ ។ លោកតាស្រង់លេខឆ្នាំខែនិងថ្ងៃ គូសវាសៗអស់ពីរក្តារឆ្នួន រួចទំនាយថា ៖

" ចៅប្រុសមាននិស្ស័យធំណាស់ ឯចៅស្រីក៏មានសេរីភាពច្រើនដែរ ។ លេខទាំងពីរគួបគ្នាទៅ ត្រូវចំព្រះពោធិសត្វនឿយណាយនិងរាជសម្បត្តិ បានសេចក្តីថា ៖ ខាងផ្លូវចិត្តដូចជានៅឆ្ងាយពីគ្នាបន្តិច ។ លេខទំនាយថា និស្ស័យរបស់ចៅប្រុសបានត្រូវទេពអប្សរយកទៅថែរក្សា ចំរើនបារមី នៅលើភ្នំហេមពាន្ត " ។

ដំណើរត្រឡប់មកវិញមានសភាពស្ងប់ស្ងាត់ ពីព្រោះទំនាយរបស់លោកតានាំអោយកើតពិចារណាគ្រប់ៗគ្នា ។

តមក ស៊ី ឈឿន មិនដាច់ចិត្តចោលម្តាយមីងទៅរកផ្ទះដទៃទៅ ពិតមែនតែអ្នកមានប្រាក់កាសគ្រប់គ្រាន់ដើម្បីនឹងចាត់ចែងការនេះបាន ។ ម្តាយមីងអ្នកសោតទៀតក៏តែងតែអង្វរអ្នកកុំឲ្យទៅណា ពីព្រោះគាត់ដូចជាគ្មានសង្ឃឹមទៅលើកូនស្រីរបស់គាត់សោះ ។ គាត់កាន់តែចាស់ណាស់ទៅហើយ ពេលឈឺថ្កាត់, យប់អាធ្រាត្របាន ស៊ី ឈឿន ជាប្រុសម្នាក់កំដរផ្ទះសំបែងចាត់ចែងរកពេទ្យរកឬ ដែលច្រើនតែជាមិត្តភ័ក្តិរបស់អ្នកថែមទៀតផង ។ អ្នកប្រុសគ្មានខ្វាចអ្វីដល់ចិត្ត ច័ន្ទីទេ ប៉ុន្តែអ្នកមិនសូវបន្ទុកបង្អាប់នាងពេកដែរ ដោយអាសូរទៅដល់ម្តាយមីង ពីព្រោះកូនស្រីនេះមិនសូវហ៊ាននឹងបងជីដូនមួយមែនពិត ប៉ុន្តែពេលងងឹត ច្រើនតែទៅធ្វើទុក្ខម្តាយរំអុកឲ្យគាត់បង្អាប់ ស៊ី ឈឿន ឲ្យបំពេញចិត្តរាយមាយ របស់ខ្លួន ។ ស៊ី ឈឿន អាណិតម្តាយមីងក៏ច្រើន តែប្រតិបត្តិតាមទាំង ទើសទាល់ ។ តាមពិតច័ន្ទីស្រឡាញ់និងប្រច័ណ្ឌបងជីដូនមួយជាច្រើន ប៉ុន្តែសេចក្តីស្នេហារបស់នាងនេះមានសភាពជាវិកលចរិត ។ យូរៗទៅ ស៊ី ឈឿនកាន់តែទ្រាន់ក្នុងចិត្តដែរ ។ អ្នកអាចជួយថែទាំច័ន្ទីបាន ប៉ុន្តែបើឲ្យអ្នកទៅរៀបអាពាហ៍ពិពាហ៍ជាមួយនឹងនាងគឺប្រាកដជាទទួលមិនកើត ។ ត្រង់នេះម៉ាក់មីងដូចជាគ្មានចិត្តមេត្តាដល់អ្នកសោះ ។

រាត្រីបន្ទាប់មក ពេលអាធ្រាត្រ ស៊ី ឈឿន គេងមិនលក់នៅសំកុកនឹងមាត់បង្អួចកេះចាប៉ុព្ទស្លូររងំៗ ។ ទំនាយរបស់លោកតាច័ន្ទរស្មី ធ្វើអ្នករសាប់រសល់ក្នុងចិត្ត ។ រឿងសៀមរាបក៏ចេះតែវិលវល់ត្រឡប់មកវិញមិនឈប់ឈរ ។ អ្នកដូចជានឹកខឹងនឹងខ្លួនឯងថា មិនសមបើនឹងរឮកទៅដល់ពួកស្រីដើរលេងអនាថាយ៉ាងហ្នឹងសោះ ។ បើទោះជាច័ន្ទីមិនសូវដឹងអី ក៏នាងជាស្ត្រីមានត្រកូលត្រឹមត្រូវ មិនដែលដើរលេងរាយប៉ាយផ្តេសផ្តាសទេ ។ ពាក្យវិកលចរិតជាពាក្យអ្នកបន្ថែមខ្លួនឯងទៅលើនាង ដើម្បីឲ្យវាកាន់តែធ្ងន់ទៅទៀតតែប៉ុណ្ណោះ តាមពិតច័ន្ទីគ្រាន់តែមានពួកពាលនៅក្មេងពេក ប៉ុន្តែនាងជាក្រមុំបរិសុទ្ធសាច់ឈាមនៅណែនតឹងកំពុងពេញវ័យដប់ប្រាំបីឆ្នាំ ។ អ្នកប្រុសប្រហែលជាមានសមត្ថភាពនឹងអាចកាច់ពុតស្ត្រីនេះតទៅថ្ងៃមុខបាន ។

កំពុងតែអារម្មណ៍ ទៅក្នុងការពិចារណាយ៉ាងនេះ ស្រាប់តែឮសូរស័ព្ទគោះទ្វារតិចៗពីខាងក្រៅ ៖

" តុក ! តុក ! តុក ! "

ស៊ី ឈឿន ឆ្ងល់ណាស់ ងាកចេញពីបង្អួចផ្ទៀងត្រចៀកស្តាប់

" តុក ! តុក ! តុក ! " សាជាថ្មីទៀត ។

អ្នកដើរថ្នមៗទៅជិតទ្វារ ផ្ទាប់ក្បាលទៅជាប់នឹងជញ្ជាំង ហើយប្រថុយសួរតិចៗ

- អ្នកណាហ្នឹង ?

- ខ្ញុំ ណ៎ា បង ! ខ្ញុំ ! ច័ន្ទី

- ចុះអូនឯងឡើងមកធ្វើអ្វីថ្មើរហ្នឹង ?

- បងបើកទ្វារឲ្យអូនសិន សឹមអូនប្រាប់

- អូនឡើងមកជាមួយនឹងអ្នកណា ?

- ចាំស អូនមកតែម្នាក់ឯងទេ

- ទេ ! អីចឹង មិនកើតទេ !

សំលេងខាងក្រោយតឿនដោយអង្វរ

- អាណិតបើកទ្វារឲ្យអូនផងបង ! អូនវិលមុខណាស់

ស៊ី ឈឿន ដាច់ចិត្តបង្អើបទ្វារ ខ្លួនច័ន្ទីដួលផ្អែកទាំងស្រុងមកលើអ្នក ។ អ្នកត្រូវតែត្រកងនាង ដើម្បីកុំឲ្យដួលទៅលើឥដ្ឋ ។ ខ្លួននាងដែលមានសារុងសូត្រនិងអាវត្រនាប់ស្ដើង ក៏ស្រាប់តែមកជឺតនៅជាប់នឹងខ្លួនអ្នក ។ អ្នកលើកនាងទៅផ្អែកលើគ្រែ ហើយបញ្ឆាក់សួរ

- ចុះអូនឯងវាម៉េចក្នុងខ្លួន ?

- អូនតឹងទ្រូងណាស់ បងរឹតទ្រូងអោយអូនសិន

ស៊ី ឈឿន ភ័យណាស់ស្ទុះទៅបើកភ្លើង ។ នាងប្រញាប់ស្រែកឃាត់ទៅវិញដោយថ្ងូរ ៖

- ទេ ! ទេ ! កុំបើភ្លើង វិលមុខណាស់ ។

អ្នកបិទភ្លើងហើយស្ទុះមករកនាងវិញ ៖

- បើអីចឹង បងទៅដាក់ម៉ាក់មីងសិន

នាងរឹតតែថ្ងូរថែមទៅទៀត

- ទេ ! ទេ ! កុំដាក់គាត់ធ្វើអ្វី គ្មានបានការអ្វីទេ ! បងជួយអូនសិនឆាប់ឡើង អាល័យតែច្រួលច្រាលអីចឹងដាច់ខ្យល់អូនឥឡូវហើយ រឹតទ្រូងអោយអូនសិន !

អ្នកប្រុសយកដៃលាបទឹក "អាល់កុលដឺម៉ង់" លូករឹតទ្រូងនាងខាងក្រោមអាវ ។ សាច់នាងណែនរលីងនៅផ្ទាល់នឹងដៃអ្នក ។ អ្នកគោងតែរឹងឲ្យបានសព្វកន្លែង កន្លែងខ្លះធ្វើឲ្យអ្នកព្រឺព្រួចក្នុងខ្លួន ធ្វើឲ្យនាងស្រៀវសរសៃចេញវាចា ៖

- អូនបានធូរបន្តិចហើយ សូមបងរឹងឲ្យអូនទៀត ប៉ុន្តែបងទៅបិទទ្វារឲ្យជិតសិន កុំឲ្យម៉ាក់គាត់ឮ ក្រែងគាត់យល់ច្រឡំ គាត់ថាយើងផ្ដេសផ្ដាស ។

ស៊ី ឈឿនបិទទ្វារចាក់សោ ហើយចូលមកជិតនាងវិញ ។ នាងអង្វរថែមទៀត

- សូមបងដោះអាវអូនចេញទៅ រឹតទាំងអាវអីចឹងពិបាកណាស់ !

យប់ងងឹតសូន្យ ពន្លឺភ្លើងឯថ្នល់ឆ្លាយខាងក្រៅចាំងចូលព្រាលៗ បាំងនឹងស៊ីក

ឈើមកតាមបង្អួច មើលរូបរាងមនុស្សឃើញស្រមោល ។ ដងខ្លួនច័ន្ទីដែលនៅទទេដូចអង្គុលបុប្ផាកំពុងញ័រក្តៅក្នុងដៃអ្នកប្រុស ។ សារុងសូត្ររបស់នាងក៏នាំឲ្យតែពិបាកដែរ ដូច្នេះនាងបណ្តោយឲ្យអ្នកបងទាញហូតរបូតដោយថ្នមឲ្យកាន់តែស្រឡះចុះទៅក្រោមទល់គ្នានឹងផុតចុងជើង ។ ជីងចក់យំម្តងៗ ! យប់ហ្នឹងវាចម្លែកនឹងក្លិនមនុស្សដែលវាមិនធ្លាប់ស្គាល់ ... ។

ពេលម៉ោងបួនជិតភ្លឺ ទ្វារបន្ទប់ស៊ុ ឈឿន របើកហើយបិទទៅវិញ ។ ស្រមោលស្ត្រីម្នាក់ ចុះស្រាលតាមជណ្តើរមកជាន់ខាងក្រោម ហើយចូលទៅក្នុងបន្ទប់ច័ន្ទី ។ រូបនេះឡើងទៅប្រះខ្លួនគេងលើគ្រែ ហើយស្រវាខ្នើយឱបមកគេងរឹតដោយក្តាញ់ ។

តាំងអំពីថ្ងៃនោះមក ច័ន្ទីហាមឃាត់នាង ម៉ុន មិនឲ្យចូលទៅបោសច្រាសក្នុង បន្ទប់ស៊ុ ឈឿនទៀតឡើយ សុខចិត្តទៅរៀបចំផ្ទាល់ដោយខ្លួនឯង ។ ហើយបើជួនជាមានអ្នកប្រុសនៅជាមួយក្នុងនោះដែរ ការរៀបចំនេះច្រើនតែប្រព្រឹត្តទៅដោយបិទទ្វារបន្ទប់ជិតក្នុងរយៈពេលយូរៗផង ។

# ភ្នំគូលែន

សៀមរាប រាត្រីមួយនៅមាត់ស្ទឹង ។ នៅក្នុងក្នុងផ្ទះសម្រាប់កំសាន្តមួយ ឆ្ងាយបន្តិចពីទីក្រុង គេឮសូរមាត់មនុស្សហោកញ្ជ្រៀវចំអេសចំអាសលាយឡំសម្លេងប្រុសនិងសម្លេងស្រី ។ ទ្វារបន្ទប់នាងនោះបើកឡើង ប្រុសនិងស្រីមួយគូដើរចេញមកធ្វើដើយដាក់គ្នា ហើយយកដៃរៀបសក់ឲ្យស្រួលបួលឡើងវិញរៀងៗខ្លួន ។ គូមួយទៀត រួសរាន់ដឹកដៃគ្នាចូលដោយស្និទ្ធស្នាលទៅក្នុងបន្ទប់ដែលទើបនឹងប្រើប្រាស់រួច ។ ទ្វារខាងណោះរបើកឡើងមួយទៀត ប្រុសម្នាក់ចេញមកមុនដោយអង់អាច ។ ក្រោយមកមួយសន្ទុះធំ ទើបឃើញស្រីដើរចេញមកតាមក្រោយត្រុនៗមុខឡើងស្វាំង ។ ស្រាប់តែលេចប្រុសម្នាក់ចេញមកតាមក្រោយទៀតលើកដៃហាត់ប្រាណដកដង្ហើម យកខ្យល់វែងៗ ។ ពេលដែលគូនីមួយៗចេញចូលម្តងៗ អ្នកដែលនៅសង្កេតការណ៍ពីខាងក្រៅ សុទ្ធតែបានធ្វើអត្ថាធិប្បាយកំប្លែងថោកទាបជាទីបំផុត ។ ការប្រកួតបីនាក់ជាន់ក្រោយបានទទួលសេចក្តីសរសើរកងរំពងយ៉ាងអប្រិយអំពីក្រុមសង្កេតការណ៍អាសអាភាសនេះ ។

នៅលើគ្រែរបងខាងក្រៅ ដែលក្រាលពូករនាម លោកពីរនាក់ទៀតផ្ទប់គ្នាប្រកៀកប្រគងលើស្រីម្នាក់ ដែលមានទឹកមុខមិនសូវសប្បាយ ។ លោកខាងឆ្វេងចេះតែឱនទៅចាប់ថើបមាត់នាងស្រី ។ នាងនោះចេះតែគេចចេញ

- ខ្ញុំឥតចេះថើបតាមបារាំងទេអីចឹង! សោះទេលោក ! អាណិតខ្ញុំទៅ !
- អារ៉ុមឯងស៊ើកម្ល៉េះ ! ព្រោះតែមិនចេះបានជាអញបង្រៀន
- ទេ ! ខ្ញុំមិនចង់ចេះទេ ទៅបង្រៀនគេផ្សេងទៀតចុះ ។

លោកនោះក្តៅច្រមុះ ក៏ស្រែកឡើង

- វាកាន់តែបានចិត្តហើយមីហ្នឹង !

ថាហើយ លោកក្រោកដើរចេញទៅដោយតក់ម៉ក់ ។ លោកដែលនៅគេងជិតនាងនៅឡើយ ខ្សឹបប្រាប់នាងថា ៖

- អារ៉ុមឯងធ្វើយ៉ាងហ្នឹង ជាមួយនឹងលោក "សែប" ប្រយ័ត្នមិនសុខខ្លួន !

នាងរ៉ុមតបទៅវិញទាំងក្តៅចិត្ត

- លោក "សែប" ហ្នឹងប្រើវិធីផ្តាច់ការណាស់ ខ្ញុំប្រាប់ថាខ្ញុំមិនស្រួលខ្លួន គាត់ចេះតែឲ្យគ្នាគាត់បង្ខំឲ្យយកខ្ញុំមក ។ គាត់ថាបើខ្ញុំឈឺគាត់មិនធ្វើអ្វីទេ ឲ្យខ្ញុំគ្រាន់តែមកកំដរគាត់ឲ្យបានសប្បាយក៏បានដែរ ។ ស្រាប់តែមកដល់កន្លែងនេះ

គាត់បង្គាប់ឲ្យខ្ញុំចូលគេងឲ្យគាត់មើល ជាមួយនឹងប្រុសម្តងពីរនាក់ បីនាក់ទាំងគាត់ តើឲ្យខ្ញុំបំពេញចិត្តគាត់យ៉ាងម៉េចកើត ! ខ្ញុំមិនចេះនិយាយបាតដៃជាខ្នងដៃដូចគាត់ទេ ហើយខ្ញុំមិនមែនជាសត្វធាតុទេ !

លោកនោះរំឭកនាងថែមទៀត

- ប៉ុន្តែ មិញហ្នឹង អារ៉ុមឯងមិនទាំងឲ្យគាត់ថើបផង !

- ទេ ! ខ្ញុំមិនទៅជញ្ជក់មាត់សំអុយហ្នឹងទេ !

នៅពេលនោះ លោកម្នាក់ផុះពោះស្អុយ កំហែងស្រែកហៅអារ៉ុម ពីខាងភានបាលផ្ទះទឹកមកវិញ

- អារ៉ុម ! លោក "សែប" មានប្រសាសន៍ ! ឆាប់ឡើង !

នាងរ៉ុមដើរចូលទៅមិនទាន់ទាំងដល់ផង លោកសែបស្ទុះមកដាក់មួយកំផ្លៀង ទ្រេតតើតៗ ទៅផ្ទប់នឹងជញ្ជាំង ហើយបន្ថែមវាចាថា ៖

" ហាងឯងអាងរូបល្អ ! អាងគេចូលចិត្តច្រើនឬអ្វី ? "

នាងរ៉ុមស្ទុះទៅឱបប្រុសម្នាក់ទៀតមាឌធំ ហើយស្រែកយ៉ាងខ្លាំង

" មិនគួរបងញៀមឯងបណ្តោយឲ្យលោកហ្នឹងមើលងាយបងឯង ហើយវាយខ្ញុំ នៅមុខបងឯងយ៉ាងហ្នឹងសោះ ! បងឯងឃើញទេ ! គាត់ប្រច័ណ្ឌនឹងបងឯង គាត់បញ្ឈឺចិត្តបងឯង ខ្ញុំមិនស្រឡាញ់អ្នកណាក្រៅពីបងញៀមឯងទេ "

បរិយាកាសប្រែជាអ័ព្ទអួមួយរំពេច លោកញៀមទាញដៃនាងរ៉ុមមកក្រោយខ្នង ហើយនិយាយយ៉ងតឹងទៅកាន់លោកសែប

- លោកសែបឯងវាយស្រីវាបានការអ្វី ? យើងមកលេងសប្បាយ កុំឲ្យវានាំ ឮស្ងួរមាត់អាក្រក់ ។

លោកសែបប្រតេប្រតី ដើរចុះដើរឡើងឆ្ងាយពីលោកញៀមបន្តិច

- មកពីមានអ្នកកាន់ជើងវា បានជាមីហ្នឹងវាឡឹតណាស់ ។ ឯងមិនយល់សោះ អ្នកណាទ្រេបាតជើងស្រី !

- ល្មមបានហើយ សែបអើយ ! ខ្ញុំគ្មានទ្រមឺហាងណាទេ ! កុំមកទាស់គ្នា ដោយសារស្រីអីចឹង ! ខ្ញុំខំនាំវាមកឲ្យហើយ នៅតែអាក្រក់ទៀត ! បើសែបឯង ចែចង់គេមិនដោយឲ្យខ្ញុំធ្វើម៉េច ?

- អារ៉ុមទឹកមុខនឹងលោកញៀម ដែលបាននាំនាងយកមកស្ទូកចិត្តលោកសែប ។ នាងធ្វើឫកជាខ្សឹកខ្សួល

- ខ្ញុំស្រឡាញ់តែបងញៀមឯង មិនគួរបងញៀមឯងនាំខ្ញុំមកឲ្យគេឯទៀតសោះ ។ លោកសែបរឹតតែខឹង

- ខ្ញុំមិនខ្វីស្រីរបស់ញៀមឯងទេ ! យកទៅវិញចុះ ។

លោកញៀមទាញដៃនាងរ៉ុមទៅឡើងឡាន ហើយផ្ទៀតសម្រួលមុននឹងចេញទៅ

- ថ្ងៃក្រោយកុំឲ្យអារ៉ុមមកទៀត វានាំតែរឿងអីចឹង !

លោកសែបឆ្លើយទាំងទ្រគោះទៅវិញ

- ណើយ ! មិនចាំបាច់ដោះស្រាយអ្វីទេ នាំយកទៅចុះ ទៅៗឲ្យមីហ្នឹងកោរឲ្យរលីងសក់ក្បាលទៅ !

នៅតាមផ្លូវ លោកញៀម ផ្ទៀតកេះកៀវអារ៉ុម

- យើងគិតទៅលេងឯណាតែពីរនាក់ មែនទេអារ៉ុម ?

នាងរ៉ុមប្រញាប់ដោះសាភ្លាម

- ចាំថ្ងៃក្រោយទៅបង ! ខ្ញុំចង់ដើរលេងជាមួយនឹងបងណាស់ ប៉ុន្តែចង្រៃថ្ងៃហ្នឹងវាមិនស្រួលខ្លួនសោះ !

- បងឮថា អារ៉ុមឯងចេះតែឈឺ ប្រហែលជិតពីរអាទិត្យហើយ ។ អារ៉ុមឯងទៅនៅជាមួយនឹងបងទៅ បងរកជួលផ្ទះមួយឲ្យនៅ ។

នាងឆ្លើយបួកជាសប្បាយណាស់

- បងឯងចិត្តល្អមែនន ! ប៉ុន្តែកុំអាលសិនពីព្រោះខ្ញុំឮថាប្រពន្ធបងឯងកាច ណាស់ រូបខ្ញុំទាល់តែមួយនឹងមួយទើបបាន ។

លោកញៀមមិនបានបង្ខំ ដោយនៅមានសង្ឃឹមច្រើននៅឡើយ ហើយគ្រោងការនៅក្នុងគំនិត

" អញកុំអាលបង្ខំវា ! វាគង់តែធ្លាក់មកក្នុងកណ្តាប់ដៃអញទេ ទឹកលុយអញអាចទាញទឹកចិត្តវាឲ្យមកជាប្រពន្ធចុងរបស់អញតែម្នាក់ឯងបាន ។ រូបនិងបួករបស់វាគួរឲ្យល្អមប្រថុយចំណាយខ្លះដែរ " ។

គ្រាន់តែរថយន្តមកដល់មុខផ្ទះនៃក្រុមនាងភ្លាម នាងរ៉ុមរៀសវៃលាលោកញៀម ហើយដើរចូលទៅក្នុងរបងផ្ទះ ប្រទះនឹងនាងនី ដែលដើរចេញមកត្រហេបត្រហប ៖

- បងចាំតែអារ៉ុមឯងមក នឹងអាលបបួលគ្នាទៅ . . .

- ទេ ! គ្មានទៅណាទៀតទេ !'នាងរ៉ុមឆ្លើយដោយដាច់អលង្ការ់. . . គ្នាឈឺរកតែពេលមើលខ្លួនមិនបានផង !........ ខ្ញុំកាន់តែធុញទ្រាន់នឹងរស់នៅ

ដូចជាសត្វធាតុយ៉ាងហ្នឹងទៀតហើយ !

នាងរ៉ុមដើរលឿនចូលទៅក្នុង តែមើលក្រោយ ។

នាងនី ឈរពេបមាត់មួយស្របក់ ក៏ចូលទៅតាម ។

នាងរ៉ុមប្រះខ្លួនគេងលើគ្រែ

- លើគ្រែហ្នឹងក៏ខ្ញុំមិនចង់គេងដែរ ។ អាណាក៏មកដេកនៅកន្លែងនេះដែរ ! ខ្ញុំខ្ពើមនឹងប្រះខ្នងណាស់ ! ។

អានី សួរបញ្ជាក់ដោយថ្នមថា ៖

- បើអីចឹង យប់ហ្នឹង អារ៉ុមឯងលែងទៅណាទៀតហើយឬ ?

- ចុះខ្ញុំប្រាប់បងនីឯងហើយតើ ថាខ្ញុំឈឺ បងនីឯងចង់ទៅណាក៏ទៅចុះ ។ ខ្ញុំលេបលុយពួកអាអស់ហ្នឹងមិនរួចទេ !

អានីប្រថុយប្រាប់ជាបង្ហើយ

- កាលពីម៉ោងប្រាំបី គ្រាន់តែអារ៉ុមឯងចេញទៅផុតបន្តិចទៅ លោកសុតបានជូនលោកដែលយើងស្គាល់នៅចំការដូងមករកអារ៉ុមឯង ។

សម្ដីនេះកន្ត្រាក់នាងរ៉ុម ឲ្យភ្ញារខ្លួនមួយរំពេច

- លោកណា ?... លោកដែលនៅភ្នំពេញហ្នុងឬអ្វី ?

- ហ្នឹងហើយ ! លោកដែលជាចៅហ្វាយធំរបស់លោកសុត នុ៎ះណ៎ា !

នាងរ៉ុមស្ទុះក្រោកអង្គុយ ខិតទៅជិតនាងនី

- រួចបងនីឯងជំរាបលោកថាខ្ញុំនៅឯណា ?

- ថាពួកលោកសែប មកយកទៅបាត់ហើយ ។

នាងរ៉ុមនឹកមួមួយរំពេច

- យីស ! បងនីឯងខ្វះពាក្យនិយាយណាស់ទៅឬអ្វី ? រួចពួលោកមានប្រសាសន៍ថាយ៉ាងម៉េចទៅ ?

នាងនីដែលធ្លាប់តែត្រង់នឹងអារ៉ុម ក៏បញ្ចេញអស់គ្មានសល់

- បងពួលោកសុតគាត់ថា ៖ " ស្រេចហើយ ! ទៅជានឹងលោកសែបផងច្បាស់ជាដល់ភ្លឺហើយ ! " រួចពួលោកធំគាត់បន្ថែមថា ៖ " ណ្ហើយ ! ទំរាំនឹងត្រឡប់មកវិញ វាបែកអេកបែកម៉ាំអស់ទៅហើយ ! ផាត់អារ៉ុមមួយចោលទៅវាអស់ផ្លូវទៅហើយ !" ។

នាងរ៉ុមសឹងតែរលេះដើមទ្រូង

- យីស ! ខ្ញុំមិននឹកស្មានថាបងនីឯងសត្វធាតុយ៉ាងហ្នឹងសោះ !

នាងនីឆ្លើយមកវិញទាំងអស់សំណើច

- សព្វធាតុយ៉ាងម៉េច ? បើគេថាហ្នឹងវាត្រូវមែន !

នាងរ៉ុមទន្ទ្រាំជើងបើកភ្នែកធំៗ សម្លុតមកវិញ

- យីស ! នៅថាត្រូវទៀត ! បើគេថាវាមិនមែន ! រួចបងនីឯងឮលោកមានប្រសាសន៍យ៉ាងម៉េចទៀត ?

នាងនីចេះតែឆ្លើយឲ្យរង់កម្ដចជាកូនក្មេងដែលម្ដាយយករំពាត់មកកំហែងសួរ

- បងឮលោកធំគាត់បន្ទោសលោកសុតថា " សុតឯងនាំខ្ញុំមកឲ្យអន់សាច់ជាមួយនឹងអារ៉ុម... ខំបបួលគ្នានាំខ្ញុំមកសួរដំងីវា ឥឡូវវាមានឈឺអ្វីវា ! វាឈឺតែម្យ៉ាងហ្នុង ! វាឈឺតែឃ្លានប្រុសហ្នុង ! ឃើញទេវាដើរទៅដេកនឹងសាហាយវាទៅហើយ !

នាងរ៉ុមដូចជាអស់កំលាំងរលីងពីខ្លួន ។ ពាក្យពីរបីម៉ាត់ខាងក្រោយនេះជាមុខអាវុធដែលធ្លាក់មកចំរបួស ដែលធ្វើឲ្យនាងក្រៀមក្រំពីរអាទិត្យរួចមកហើយ ។ នាងរលីងរលោង ហើយបន្ទោសសម្លាញ់ថា ៖

- បងឯងនិយាយតែផ្ដេសផ្ដាស ម្ដេចក៏មិនជំរាបលោកថាខ្ញុំប្រុងនឹងត្រឡប់មកវិញ ?

នាងនីប្រកែកដោយត្រង់

- បងឥតបានដឹងសោះថាអូនឯងប្រុងនឹងត្រឡប់មកវិញ ។

- ចុះបងនីឯងមិនឮទេឬ ដែលខ្ញុំប្រាប់ពួកលោក... សែបថាខ្ញុំទៅបានតែមួយភ្លែតទេ ពីព្រោះខ្ញុំមិនស្រួលខ្លួន ។

- យី ! អូនឯងនិយាយតែជាមួយនឹងគេ រួចឲ្យបងទៅដឹងផងយ៉ាងម៉េចកើត ! ។

នាងរ៉ុមអន្ទះសាក្រោកទៅមុជទឹក ហើយស្លៀកពាក់តែងខ្លួនយ៉ាងស្រស់ ។ អានីអត់ទ្រាំសួរមិនបាន

- រៀបចំទៅណាហ្នឹង ? លោកណាផ្ដាំឲ្យទៅជួបឬ ? ចុះអូតថាខ្លួនឈឺ ! ។

នៅមុខកញ្ចក់នាងរ៉ុមលាបបបូរមាត់បណ្ដើរ ឆ្លើយបណ្ដើរ

- បើទោះជាឈឺ ក៏គង់តែនៅដើររួចដែរ ។ បងនីឯងទៅជាមួយនឹងខ្ញុំណា៎

ដើម្បីឲ្យបានជាគ្នាពីរនាក់ ពីព្រោះបងនីឯងមានបានគ្រាន់បើ មិនសូវខ្វាចអ្នកណា... បងនីឯងធ្លាប់ដើរតួជាប្ដីខ្ញុំស្លាប់ហើយ ។

រួចនាងរ៉ុមដឹងដៃនាងនីស្រឡើតអំប៉ិតចេញទៅដល់ថ្នល់ ហើយនាំគ្នាហៅរ៉ឺម៉កម៉ូតូមួយជិះទៅកាន់ផ្សារ ។ នាងរ៉ុមចូលទៅសួរគ្រប់តែផ្ទះដែលចិញ្ចឹមស្រី ផ្កាមាស ។

ទៅដល់ផ្ទះមួយ

" បងឯងមានឃើញលោកសុតមករកស្រីឯណឹងទេ ? "

ទៅដល់ផ្ទះមួយទៀត

" ស្រីរបស់ថៃឯង ល្ងាចនេះមានទៅជាមួយនឹងលោកសុតទេ ? "

.

.

.

គ្រប់តែផ្ទះ គេឆ្លើយថាមិនបានឃើញលោកសុតទេ ទ្រូងនាងរ៉ុមដូចជាបាន ធូរបន្តិច សំដីនាងក៏កាន់តែទន់ភ្លន់ ។ នាងនីគ្រវីក្បាល លាន់មាត់ថា ៖

" អារ៉ុមឯងដល់ពេល "តុកស៊ិក" អាក្រក់អាក្រីណាស់ !" ។

ទាំងពីរនាក់ឡើងរ៉ឺម៉កតទៅទៀត ។ នាងនីធ្លាប់ស្គាល់ធ្លាប់ស្រឡាញ់ចិត្ត ពួកម៉ាកក៏ចេះតែតស៊ូទៅជាមួយ ពិតមែនមិនយល់ច្បាស់ដែរថា គេបម្រុងនឹងទៅខាងណាទៀត ។ ផុតផ្សារផុតសណ្ឋាគារធំ ទៅតាមមាត់ស្ទឹងដែលកាន់តែស្ងាត់ ពីព្រោះម៉ោងជិតដប់យប់ទៅហើយ ។ ភ្លាមនោះនាងរ៉ុមស្រែកប្រាប់ទៅពូរ៉ឺម៉កថា ៖

" ឈប់ពូ ! ឈប់ ! ឈប់ ! ឈប់ត្រង់ហ្នឹងសិន ! "

រ៉ឺម៉កម៉ូតូទប់ហ្វ្រាំងង៉ក់ ! ចង់ចាក់ចោលអ្នកជិះធ្លាក់ទៅដី ។

នាងនីស្រែកយ៉ៃ ឯពូរ៉ឺម៉កក៏សួរជាបន្ទាន់

" ស្អីអ្នក ! ជ្រុះអ្វីឬ ? "

- ទេ ! ពូ អត់អីទេ ប៉ុន្តែឈប់សិន ! ។

នាងរ៉ុម ងាកបែរទៅក្រោយសម្លឹងក្នុងងងឹតទៅរករថយន្តមួយដែលចតអែប នៅនឹងជញ្ជើមថ្នល់ ហើយនិយាយតិចៗប្រាប់ទៅសម្លាញ់ស្រី

" បងនី ! ហ្នឹងហើយឡានលោកសុត មែនទេ ? "

នាងនីសង្កេតមួយសន្ទុះហើយតបមកវិញ

" អ៊ីដូចជាហ្នឹងមែន ភ្នែកអារ៉ុមឯងបងស្ទើចហើយ ! "

នាងរ៉ុមដូចជាបុកពោះភ្លុកៗភ័យផងអរផង ។ បន្តិចមកឃើញប្រុសៗពីរបីអ្នកចេញពីរបងផ្ទះសំដៅមករឡាន ពួមាត់លោកសុតស្រែកផ្តាំទៅអ្នកផ្ទះ

" ឆាំឯងកុំភ្លេចណា៎ ! រៀបចំឲ្យស្រេចអំពីល្ងាចនេះទៅ ស្អែកព្រឹកម៉ោងប្រាំមួយគត់ខ្ញុំមកដល់ កុំឲ្យលោកធំចាំ ពីព្រោះគាត់តែងតែក្រោកពីព្រលឹមណាស់ ។ យើងគិតលៃលកឲ្យម៉ោងប្រាំបួនព្រឹកទៅដល់លើភ្នំគូលេនកុំអោយក្តៅទាន់ " ។

នាងរ៉ុមកាត់ចិត្តចូលទៅស្ទាក់ជួបនឹងលោកសុត ។

- លោក

- អ្នកណាហ្នឹង ? អារ៉ុមឬ ?ចា៎ស !

- ស្លាប់ហើយ ! អារ៉ុមឯង ! ខ្ញុំខំដើររកអស់មួយល្ងាច

- ឮថាលោកធំគាត់អញ្ជើញមកមែនឬ ?

- បាទ គាត់អញ្ជើញមកពីល្ងាច ។

- លោកអញ្ជើញទៅឯណាទៅហើយ ?

- លោកទៅឯផ្ទះទឹក ឯបារាយណ៍ទឹកថ្លាឯណោះ ។

- ខ្ញុំខំដើររកលោកមួយល្ងាចទៅហើយដែរ ។

លោកសុតស្ងៀមបន្តិច ទំនងដូចជាគិត រួចនិយាយតទៅទៀត

- បើទុកជា អារ៉ុម ឯងរកលោកក៏ដូចជាឥតអំពើដែរ ពីព្រោះលោកធំដូចជាមិនចង់ជួបនឹង អារ៉ុម ឯងទៀតទេ ។

នាងរ៉ុមបាត់មាត់ ហើយដើរតាមលោកសុតទៅជិតឡាន ។

នាងកាត់ចិត្តសួរបន្តិចទៅទៀត

- ប្រហែលជាលោកធំ មានស្រីកំដរច្រើនហើយមើលទៅ !

លោកសុត ឆ្លើយបញ្ឆោកមកវិញ

- យប់នេះលោកមិនឲ្យស្រីណាទៅកំដរទាំងអស់ពីព្រោះលោកមិនសប្បាយចិត្តនឹងសម្តីការីរបស់អារ៉ុមឯង ។ ម្យ៉ាងទៀតលោកចង់ធ្វើកិច្ចការឲ្យបានច្រើនពីព្រោះស្អែកត្រូវឡើងភ្នំគូលែនផង ។

នាងអង្វរ

- ខ្ញុំសុំទៅជួបនឹងលោកតែមួយភ្លែតក៏បានដែរ, ម្យ៉ាងទៀង ធ្មើរណោះប្រហែលជាលោកចប់កិច្ចការ រួចអស់ទៅហើយ ! ។

- ខ្ញុំមិនហ៊ានទេ ពីព្រោះលោកផ្តាំថាកុំឲ្យហៅអារ៉ុមឯងមកទៀត
- ប្រហែលជាលោកធំខឹងនឹងខ្ញុំខ្លាំងហើយមើលទៅ !
- ខ្ញុំមិនសូវដឹងដែរ ។ ខ្ញុំលាហើយ ប្រញាប់ទៅជួបនឹងលោកវិញ ។

សំដីរបស់លោកសុត ដូចជាកំបុតៗ ខ្លាំងណាស់ ។ បើកូនចៅម្ទឹង ទៅហើយ ! តើដល់ទៅចៅហ្វាយធំវាយ៉ាងដូចម្តេចទៀតទៅ ! ។ រថយន្តបិទទ្វារគ្រឹបៗ បើកភ្លើងបរចេញទៅ, ចោលរូបស្រីពីរនាក់នៅឈរកណ្តាលយប់ជាមួយនឹងវ៉ុម៉ែកម៉ូតូ ។ ឮវ៉ុម៉ែកគាត់តឿនមិនប្រណី " ម៉េចអ្នក ! ទៅរកម៉ូយឯណាទៀត ? បើចង់ឲ្យបានឆាប់ ខ្ញុំជូនទៅសណ្ឋាគារ "សន្តិចភាព" ។

នាងរ៉ុមទឹកខ្សួរក្នុងចិត្ត ខឹងនឹងលោកសុតក៏មិនកើត ខឹងនឹងឮវ៉ុម៉ែកក៏មិនសម ខឹងតែនឹងខ្លួនឯង ខ្លួនឯងជាស្រីផ្កាមាស ខ្លួនឯងដែលគ្មានសិទ្ធិនឹងស្រឡាញ់បុរសដែលធ្វើឲ្យរពួកឃើញមិនចេះដាច់ ។ នាងត្រូវតែអង្វរឮវ៉ុម៉ែកទៀត

" ឮ ! ឮឯងអាណិតខ្ញុំទៅ បើឮឯងជួយខ្ញុំបានក្នុងយប់នេះ ខ្ញុំនឹងដឹងគុណឮឯងអស់មួយជីវិត ។ ឮឯងអាណិតជូនខ្ញុំទៅរកលោកឯបារាយណ៍ទឹកថ្លាបានមួយភ្លែត ឮឯងគិតទាំងថ្លៃទៅទាំងថ្លៃត្រឡប់មកវិញឲ្យស្រេចទៅចុះ រួចខ្ញុំមុខជាថែមជូនឮឯងថែមទៀត " ។

ឮវ៉ុម៉ែក ឆ្លើយដោយទឹទើជាខ្លាំង

- ថ្មើរនេះហើយ ! អ្នកអើយ ! កុំទៅស្វែងអ្វីឆ្ងាយពេក ! អ្នកឯងគិតទៅមើល ! មិនមែនជិតទេណាំ បារាយណ៍ទឹកថ្លានោះ !

នាងរឹតតែអង្វរឡើងទៀត

- ឮឯងអាណិតតែខ្ញុំទៅ ខ្ញុំសំពះឮឯង បើឮឯងជួយខ្ញុំឲ្យខ្ញុំបានជួបនឹងលោក ខ្ញុំសុំឲ្យទេព្ដាមួយខេត្តសៀមរាបជួយឮឯងឲ្យបានឡើងជាថៅកែវ៉ុម៉ែកម៉ូតូទៅថ្ងៃក្រោយ ។

ឮវ៉ុម៉ែកដូចជាទន់ចិត្តដែរ ណាមួយដូចជានឹងចង់ធ្វើថៅកែបន្តិចផង ក៏ដាច់ចិត្តជូននាងទាំងពីរទៅបារាយណ៍ទឹកថ្លា ។ វ៉ុម៉ែកបត់ក្បាលត្រឡប់ក្រោយវិញ បរកាត់ក្រុងសៀមរាប ឆ្លងស្ពានថ្មខ្ចី ហើយចេញលឿនស្ទៅទៅតាមផ្លូវស៊ីសូផុន ។ កណ្តាលយប់ស្ងាត់ សូរស័ព្ទម៉ាស៊ីនលាន់ឮទៅដល់អាកាស ។ ខ្យល់បក់ខ្លាំងផាត់សក់អ្នកជិះស្ទើរតែត្រង់ទៅក្រោយ ។ យូរៗលេចរថយន្តមួយ

ជូន "វ៉ា" មកពីក្រោយ ជូនបរជ្រួស គ្នាមកពីមុខ ។ ថ្ពាល់ទូលាយស្រឡះឆេងគួរតែសប្បាយ ប៉ុន្តែនាងរ៉ុម ប្រែជានឹក អាសូរខ្លួន មិនដឹងជាទៅដល់ត្រូវលោករុញច្រានចោលដូចម្តេចឡើយ ។ ពីរអាទិត្យ មកហើយ ! ស្ទើរបាយ ស្ទើរទឹក ស្ទើរដេក ស្ទើរដើរ... " តាំងអំពីបងឃ្លាត ចេញទៅ... អូនរស់នៅស្ទើរតែពុំកើត "

រ៉ឺម៉កបត់ចូលតាមផ្លូវគ្រហឹកក្រហុក បង្ខំប្រឹងឡើងទៅលើទំនប់រួចចុះលឿនទៅក្នុងមហាកំពែងបារាយណ៍ទឹកថ្លា ហើយបរកុងតិចៗ តាមឆ្នេរខ្សាច់ ។ ភ្លើង "ហ្វា" ចាំងទៅឯនាយ ឃើញផ្ទះទឹកមួយស្ងាត់ជ្រងំ មានរថយន្តតូចៗ បីនៅចត ទន្ទឹមគ្នាបែរទៅមាត់ទឹក ។

ស្រីទាំងពីរនាក់ដើរចូលទៅ រ៉ឺម៉កនៅឈប់ចាំ ។ បុរសម្នាក់ដើរចេញមកពីផ្ទះទឹកឡើងមកលើគោក ។ ទាំងបីនាក់ជួបសម្តី ឈរនិយាយរអ៊ុះៗ រួចនាំគ្នាចុះទៅក្នុងផ្ទះទឹក ។ នៅល្វែងក្រៅ វង់អុកចត្រង្គកំពុងដាក់ផ្ទៃផ្កា ឲ្យគ្នាមិនឈប់មាត់ ។ អស់លោកពីរបីនាក់ដែលសំរាន្តលេងនៅឯរានហាលក្រៅ លុះឃើញស្រីៗចូលទៅដល់ក៏ក្រោកមកសួរ ។ លោកសុតភ្ញាក់ខ្លួនមុនគេ

- ចុះអារ៉ុមឯងមកនឹងអ្វី ?
- ចាំស ! មកនឹងរ៉ឺម៉កដដែលហ្នឹង ។
- ស្លាប់ហើយ ! យប់ជ្រៅហ្នឹង ! ។ កុំអាលសិន លោកធំនៅធ្វើការក្នុងបន្ទប់នៅឡើយ ចាំខ្ញុំចូលទៅជំរាបលោកសិន ។

លោកសុតចេញមកវិញ ធ្វើមុខស្មើ ហើយប្រាប់នាងរ៉ុមតិចៗ

- មិនស្រួលទេ ! លោកមានប្រសាសន៍ថាមិនបាច់ជួបនឹងលោកទេ ។

នាងរ៉ុម ធ្លាក់ទឹកមុខ ឈរជញ្ជឹងអស់ចិត្ត ទើបជំរាបទៅលោកសុតវិញ

- សូមលោកកុំទើសទាល់នឹងខ្ញុំ ខ្ញុំគ្រាន់តែសុំនៅរង់ចាំលោកធំក្នុងទីនេះផងបានឬទេ ?

លោកសុតញញឹមស្ងួត ហើយលើកៅអីផ្តៅព្រមទាំងពូករនាបមួយ មករៀបនៅនឹងគ្រែតូចដែលមានស្រោប់នៅចំពីមុខបន្ទប់លោកស៊ុ ឈឿន ។

- វាពានមកលើរូបអារ៉ុមឯងទៅហើយ ខ្ញុំពិបាកនឹងប្រកែកដែរ ខ្ញុំនឹងទុកអារ៉ុមឯងឲ្យដូចជាស្រីឯទៀតទៅ ក៏វាមិនសមដែរ ។

នាងរ៉ុមអរគុណនឹងលោកសុត ហើយប្រាប់នាងនីឲ្យយកប្រាក់មួយរយរៀលទៅ

ឲ្យញ៉ីម៉ក ប្រាប់គេឲ្យត្រឡប់ទៅវិញចុះ ។

ខ្យល់បក់កាន់តែខ្លាំង ។ នៅខាងក្រៅពួស្សុរលកវាយផ្ទប់មកនឹងក្បូនផ្ទះទឹក ដែលយោលរំពើកបន្តិចៗ ។ គេដេកអស់ស្ងាត់សូន្យ ។ ស៊ី ឈឿននៅអង្គុយ សរសេរតែម្នាក់ឯង ។ អ្នកតប់ប្រមល់នឹងភ្នំពេញ ទើបរត់មករកលំអស្ងប់ស្ងាត់នៃ ខេត្តសៀមរាប ។ សេចក្ដីសង្ឃឹមនេះក៏រលាយអស់រលីង ។ អ្នករកមធ្យោបាយ នឹងបំភ្លេចរឿងចំបែងចិត្ត ដោយយកការរាជការមកធ្វើបន្ទប់ ។ យប់ណាស់ទៅ ហើយ អ្នករៀបចំក្រដាសសំណុំរឿងដាក់ស្រួលបួលទៅក្នុងកាបូបយួរ ហើយចេញ ទៅមើលកូនចៅ ដែលនៅសម្រាកខាងក្រៅនិងក្នុងបន្ទប់ឯទៀត ។ អ្នកប្រុសទុច នៅនឹងមាត់ទ្វារ ។ រូបរាងស្ត្រីពីរនាក់លេចឡើងព្រាលចំពោះមុខអ្នក ក្រោមពន្លឺ យ៉ាងតិចបំផុតនៃចង្កៀងយួរដែលព្យួរផ្លុងៗនៅនឹងរត ។ អានីដេកក្រវៀននៅលើ គ្រែតូច ។ នាងរ៉ុមអង្គុយលក់ទាំងអាវ ទាំងស្បែកជើង ទាំងកាបូបនៅក្នុង កៅអីផ្ដៅ ។ ស៊ី ឈឿនទឹកអាសូរដល់ទឹកមុខនាងដែលស្រពោន និងរូបកាយ ដែលស្គមជាងពីមុន ។ លំអរបស់នាង ប្រែទៅជាមានន័យមួយទៀត ដែលអ្នក ទើបនឹងយល់ក្នុងពេលនេះ ។

អ្នកកំលោះចូលថ្នមទៅអង្គុយលើគ្រែ ជាប់ជិតនឹងកៅអីផ្ដៅដែលនាងស្រីកំពុង អង្គុយគេងលក់ ។ បបូរមាត់នាងក្រហមស្រស់ នាងដកដង្ហើមស្រាល " គួរឲ្យ អាណិតដែរ... សុខចិត្តនៅទ្រាំចាំ !" ។ ស៊ី ឈឿនយកដៃអង្អែលភ័ក្ត្រដែល អ្នកអាណិត ។ នាងបើកភ្នែកឡើងរកជឿខ្លួនឯងសឹងតែពុំបានកើត... ហើយស្រវា អោបរឹតបុរសដែលផុសឡើងអំពីក្នុងយល់សប្តិ ។ អ្នកប្រុសគយគន់មើលមុខនិងថ្នាក់ ថ្នមរាងកាយរបស់នាង រួចចេញវាចាដោយរំភើប

- ហេតុអ្វីក៏អូនស្គមជាងមុនច្រើនម៉្លេះ ?

ទ្រូងនាងរ៉ុមអួលណែនមួយរំពេច ទឹកភ្នែកហូរសស្រាក់ នាងឱបគ្នាកំសត់យំដោយ ខ្សឹកខ្សួល

- អូនរលឹកបងណាស់ អូនឈឺជាងដប់ថ្ងៃហើយ

ស៊ី ឈឿនចំអកឲ្យនាងវិញ

- រពូកណាស់ ! បានជាល្ងាចមិញឆ្លៀតទៅកំសត់ជាមួយនឹងគេបាត់ !

នាងបញ្ជាក់ទៅអ្នកវិញតាមការពិត

- ពួកហ្នឹងវាបញ្ឆោតយកអូនទៅ អូនគេចរួចមកវិញភ្លាម អូនឥតបានគេង

ជាមួយនឹងអ្នកណាឡើយ ។ អូនរពួកបងណាស់ ។

នាងរ៉ុម សម្ងឹងមុខ ស៊ី ឈឿនដោយស្រណោះស្រណោក ។ អ្នកប្រុសអង្អែលថ្ពាល់ អង្អែលបបូរមាត់ក្រហមស្រស់ដែលនាងបានថែរក្សាឲ្យនៅបរិសុទ្ធតាំងអំពីចំការដូងមក ។

- បបូរមាត់ហ្នឹង បងនឹកឃើញជានិច្ច !

នាងញញឹមបង្ហាញទឹកចិត្តដែលទោរទន់ខ្លាំងណាស់ទៅហើយ ទៅបុរសដែលនាងប្រាថ្នាដូចផ្កាយនៅលើមេឃ ។ ប៉ុន្តែបន្ទាប់មក តួនាងឱនមកជិត ហើយនាងក៏ប្រឹងលោខ្លួនទៅរកគេ ។ ដែសង្សារទាំងពីរស្រវាំរឹតរួតប្រាណគ្នាទៅវិញទៅមក ។ អ្នកប្រុសថើបញាក់ញីនាងអស់ពេលក៏យូរ នាងនៅតែមិនរបេះដៃចេញពីប្រុសនាង ។ ការស្និទ្ធស្នាលសំណោះសំណាលនេះ ធ្វើឲ្យភ្ញាក់នាងនីដែលបើកភ្នែកឡើងប្រឹងងើបក្បាលបន្តិចសង្កេតមើលរួចក៏ធ្វើជាធ្មេចដេកទៅវិញ ។

តួទាំងពីរក្រោកចាកគ្រែតូច កៀកគ្នាចេញទៅរៀនហាលនាងក្រៅ ។ លុះលោកសុតចូលមកវិញ ស្រាប់តែបាត់ម្នាក់ក៏បញ្ជាក់សួរអ្នកដែលនៅសល់ ។ នាងនីខ្សឹបប្រាប់ថាគេត្រូវគ្នាវិញហើយ ។ លោកសុតថា " បើដូច្នោះ អានីឯងហើយនិងអញត្រូវតែចុះ"អាតាស៊ីវិល"សាជាថ្មី " ។ កៅអីផ្តៅនឹងគ្រែតូច ត្រូវគេរត់ចោលអស់រលីងទៅរកកន្លែងស្ងាត់រៀងៗខ្លួន ។

នៅរៀនហាលខាងក្រៅ រាងប្រុសនិងរាងស្រីមួយគូឈរកៀកគ្នាដោយកំសត់មើលឆ្ពោះទៅវាលទឹកងងឹតធំធេង រលកគគ្រេងប្រៀបបាននឹងសមុទ្រដលធី ។ ផ្កាយភ្លឺពេញមេឃ ផ្លុះស្រមោលញ័រចំប្រប់មកលើផ្ទៃគង្គាដែលរំជួលខ្លាំង ។ ស័ព្ទសន្ធឹកខ្យល់លាយនឹងសូរទឹករលកផ្សំនឹងមេឃឥតពពកបង្ហាញគ្រាប់ពេជ្រតារាបន្ទន់ចិត្តនារីឲ្យផ្តេកសិរសាទៅលើទ្រូងប្រុសសម្លាញ់ ហើយចេញវាចាដោយអណ្តែតអណ្តូង " ល្ងាចនេះ ចិត្តអូនរំជើបរំជួលដូចគ្នានឹងធម្មជាតិដែលនៅជុំវិញខ្លួនយើងទាំងប៉ុន្មាន " ។ សំដីនេះរសាត់បាត់ទៅតាមខ្យល់ផ្តល់សំលេងមួយទៀតដែលអណ្តែតមកតាមក្រោយ " នៅកណ្តាលធម្មជាតិយ៉ាងខ្វល់ខ្វាយយ៉ាងនេះបងចង់ឲ្យរូបកាយរបស់អូនស្ថិតនៅជាប់ជានិច្ចជាមួយនឹងសាច់ឈាមរបស់បង " ។

មាត់នាងរកឆ្លើយអ្វីពុំរួច គ្រាន់តែថ្ងូរថា ៖ " បង ! ជីវិតរបស់អូន !"។ មាត់ហ្នឹង ប្រុសនាងថើបហើយថើបទៀត ។ រួចពីថើបម្តងៗ នាងនទៀលដោយពេញចិត្តទៅអរគុណនឹងទ្រូងគូជីវិត ។ កាន់តែរងា នាងឱបរឹតសង្សារកាន់តែ

ស្អិត ។ ប្រុសសម្លាញ់សួរនាងដោយចំណង់ខ្លាំង “ អូនទៅគេងជាមួយបងនឹងបងណា ! ”

នាងឆ្លើយតបដោយត្រេកអរ “ ចាស ! ”

អ្នកសួរបញ្ជាក់នាងថែមទៀត “ អូនមិនខ្លាចបងធ្វើបាបទេអូនខ្លាំងទេឬអ្វី ? ”

នាងឆ្លើយតបទៅវិញដោយក្អាញ់ “ អូនសប្បាយណាស់នឹងទទួលទារុណកម្មយ៉ាងធ្ងន់របស់បង ! ”

រួចនាងផ្ទមទាញដៃប្រុសបងចូលទៅក្នុងបន្ទប់ ។ យប់ហ្នឹងនាងវង្វេងវង្វាន់ជាច្រើនដង ។ នាងសែនក្អាញ់នឹងគូនាង ។ ជួនកាលសប្បាយខ្លាំងពេកទៅនាងទៅជាខិបសង្សារយំដោយរំភើបចិត្ត ។

បារាយណ៍ទឹកថ្លា ! អ្នករលកបក់បោកគគ្រឹកគគ្រេងតទៅទៀតចុះ ! មនុស្សលោកចេះតែមានដំណើរតទៅមុខជានិច្ច...........

ម៉ោងប្អូនជិតភ្លឺលាន់ឮញៀចញ៉ាច ដោយគេនាំគ្នាក្រោករៀបចំឥវ៉ាន់ភ្ជួយកន្ទេលខ្នើយដាក់ឡាន“ឡង់រ៉ូវែរ”យកទៅភ្នំគូលែន ។ ឡាន “កាំមីញ៉ូណែត”មួយទៀតនៅរង់ចាំងផ្ទះដាំចាំដឹកម្ហូបអាហារឆ្នាំងអំបែងខ្លះយកទៅជាមួយផង ។ ព្រឹកនេះជាថ្ងៃអាទិត្យ ដល់ថ្ងៃចន្ទត្រូវឈប់បុណ្យមួយថ្ងៃទៀតអាឱ្យសង្ឃឹមថា មានពេលល្មមនឹងដើរលេងទៅមក បានតាមសម្រួល មិនបាច់ប្រញាប់ប្រញាប់ពេកឡើយ ។

នាងរ៉ុមក្រោកឡើងមុខរីកបំព្រង ជួយរៀបចំប្រដាប់របស់អ្នកប្រុសឥតឈប់ដៃមិនបាច់ឱ្យលោកសុតខ្វល់ឡើយ ។ យប់មិញមិនសូវបានគេងប៉ុន្មានទេ បានទំនេរសម្ងំលក់តែមួយស្រឡេតជិតភ្លឺ ប៉ុន្តែហាក់ដូចជាពេញចិត្តស្កប់ស្កល់ ។ ស៊ី ឈឿនសួរនាងថា ៖ មិនអស់កម្លាំងពេកទេឬអ្វី ? នាងឆ្លើយថា ៖

“កាលណាអូននៅជិតបង អូនដូចជាភ្លេចនឹកទៅដល់រឿងអស់កម្លាំងទាំងប៉ុន្មាន” ។ ស៊ី ឈឿនពេញចិត្តនឹងនាងមួយយប់ទាល់ភ្លឺ ! ដល់ព្រលឹមឡើងហើយក៏នៅតែមិនធុញទ្រាន់នឹងនាងទៀត ។

លុះនាងរត់ចេញទៅជួយរៀបចំប្រដាប់ប្រដាអស់លោកនៅខាងក្រៅ ស្រាប់តែឮសួរនាងភ្ញាក់ភ្ញាត់មាត់ឡើង

<>

"ហ៎ាក ! ពូរ៉ីម៉ែកនៅសំរាន្តឯណឹងដែរ ?"

- បាទ ! អ្នក ! យប់ពេកទៅ ខ្ញុំមិនហ៊ានវិលទៅវិញ ។ អស់លោកមានកន្លែងស្រួលដែរ ខ្ញុំក៏សុំសំណាក់តែម្តងទៅ ។

ស៊ី ឈឿនស្ទុះចេញតាមទៅមើល ។ នាងស្រីសរសើរអ្នករ៉ីម៉ែកប្រាប់សង្សារ

- ពូនេះគាត់បានសង្គ្រោះអូនពីយប់មិញ បើកុំតែបានគាត់ អូនមិនអាចនឹងមកដល់បងឡើយ ។

ពូរ៉ីម៉ែកលើកដៃសំពះលោកប្រុស

- តេជៈគុណអឺយ ខ្ញុំមិនដឹងអីទេ ! ឃើញតែស្រីៗមិនបានដឹងថាអ្នកណានាងណា របស់លោកណាទេ បើមានថ្នាំថ្នងអ្វី សុំកុំប្រកែប្រកាន់នឹងខ្ញុំ ។

ស៊ី ឈឿន ស្ទុះទៅចាប់ដៃគាត់ដោយស្និទ្ធស្នាល

- ពូអើយ ! គ្មានអ្នកណាគេប្រកែប្រកាន់អ្វីទេ ត្រូវតែនាងឯណោះទេវិញដែលត្រូវដឹងគុណពូឯង ។

- លោកបាំងអ្វី ល្ងាចមិញនេះខ្ញុំគ្មានចង់មកសោះ ប៉ុន្តែដល់ឃើញនាងឯណោះដូចជាឡេះឡះខ្លាំងពេក ខ្ញុំក៏សុខចិត្តជូនមកដោយប្រផុយ ។ តាមខ្ញុំស្មានទៅអ្នកឯណោះដូចជារពួកលោកសម្បើមណាស់ ។

នាងរ៉ុមអៀនពេកក៏ចូលទៅខាងក្នុងវិញ ។

លោកប្រុសសួរឈ្មោះពូរ៉ុម៉ែក គាត់ឆ្លើយថាឈ្មោះ ញឹប ។

- ពូញឹបឯងដែលទៅភ្នំគូលែនឬទេ ?

- ខ្ញុំមិនដែលទៅទេ

- ពូឯងចង់ស្គាល់ឬទេ ?

- បាទ បើលោកឱ្យទៅនឹងគេ ខ្ញុំក៏ដូចជាចង់ស្គាល់ម្តងដែរ ។

- បើអីចឹង ពូឯងទៅលេងនឹងគេម្តងទៅចុះ សោហ៊ុយបាយទឹកអ្វីៗ ស្រេចនៅលើពួកខ្ញុំទាំងអស់ ។

នាងរ៉ុមរៀបអីវ៉ាន់បណ្តើរ ប្រុងចាំស្តាប់ការសន្ទនារបស់ប្រុសនាងបណ្តើរ ។ លុះឮថាលោកប្រុសឱ្យពូញឹបទៅលេងភ្នំគូលែនជាមួយដែរ នាងលបញញឹមតែម្នាក់ឯង រីតតែមានកម្លាំងធ្វើការថែមទៀត ។ នាងក៏មិនដែលស្គាល់ភ្នំគូលែនដែរ ។

<>

ម៉ោងប្រាំគត់ ឥវ៉ាន់ទាំងអស់បានរៀបចំហើយជាស្រេច ។ ឡានទាំងប៉ុន្មានប្រុងប្រៀបចេញអំពីបរាយណ៍ទឹកថ្លា ។ រ៉ឺម៉កពូញ៉ឹបក៏រៀបនឹងចេញទៅវិញដែរ ។ គេណាត់ជួបគ្នាម្តងទៀត នៅផ្ទះលោកឆាំ ឯក្រុងសៀមរាប ដើម្បីនឹងចេញទៅភ្នំគូលែនទាំងអស់គ្នា ។

នៅពេលភ្លឺព្រាងៗ ផ្ទះលោកឆាំមានសភាពអ៊ូអរ ។ អ្នកដំណើរទាំងប៉ុន្មានមកដល់ជុំគ្នាអស់ហើយ សុទ្ធតែប្រដាប់ដោយសំលៀកបំពាក់សម្រាប់ដើរព្រៃ ។ គេនាំគ្នាចាប់ភ្នែកជាច្រើនទៅលើការតាក់តែខ្លួនរបស់នាង រ៉ុម ដែលស្លៀកខោជើងកំប៉ុងបៃតងខ្ចី ពាក់អាវសឺមីល័សដៃវែង និងមួកកន្ទេលថ្មីហាមធំវ័ណ្ណបួពណ៌កូឡាប ។ ល្មមទេលោកសុត គាត់ថាគួឱ្យស្ញប់ស្ញែងលក់គោមួយនឹមមែន !

ឡាន "ឡង់រ៉ូវែរ" ចេញទៅមុន ។ នៅជួរខាងមុខ លោកថៃ កាន់ចង្កូត នាងរ៉ុមអង្គុយកណ្តាល ស៊ី ឈឿន អង្គុយខាង ។ ពូញ៉ឹបអង្គុយនៅខាងក្រោយជាមួយនឹងអស់លោកប្រាំនាក់ទៀត ។ ភួយ ពូករនាបនឹងខ្នើយនៅគរតាមចន្លោះកណ្តាល ព្រមទាំងទឹកក្រូចនិងទឹកសូដាពីរបីឡាំង សម្រាប់សម្រន់ការស្រេកតាមផ្លូវ ។ លោកសុតបើកឡាន "កាមីញ៉ូណែត" មកតាមក្រោយ មាននាងនីនិងលោកឆាំនៅអែបជាមួយនៅជួរមុខ ព្រមទាំងអស់លោកបីនាក់ និងអ្នកបើកបរពីរនាក់ទៀតនៅអង្គុយខាងក្រោយ ។

រថយន្តទាំងពីរបរតាមផ្លូវអង្គរវត្ត កាន់អង្គរធំ រួចចូលទៅតាមផ្លូវ "ព្រះដាក់" បណ្តែតសម្លេងច្រៀងនិងសើចសប្បាយក្អាកក្អាយនៅជាប់តាមផ្លូវ ។

ពូញ៉ឹបសប្បាយណាស់ គាត់ញញឹមញញែមហើយកំប្លែងរហូត ផុតពីរឿងមួយទៅដល់រឿងមួយទៀត ធ្វើឱ្យអស់លោកសើចលាន់ៗនៅខាងក្រោយ ។ ស៊ី ឈឿន ញញឹមងាកមើលមុខ នាងរ៉ុម ដែលបែរញញឹមទៅរកអ្នកវិញ ហាក់ដូចជាមានន័យថា ៖

"ពូញ៉ឹបគាត់ជួយអរនឹងយើងបានជួបគ្នា យើងក៏អរនឹងឃើញគាត់បានសប្បាយដោយសារយើងដែរមែនទេ ?"

ដំណើរកាត់ភូមិ "ព្រះដាក់" បានទទួលការចាប់អារម្មណ៍ជាច្រើនអំពីក្មេងអ្នកស្រុក ដែលរត់តាមមើលប្រសេចប្រសាចអឹងកងសប្បាយនឹងឃើញរថយន្តទាំងពីរផ្សាយសម្លេងចម្រៀងលាន់ឮមកពីចម្ងាយ ។ ក្រមុំៗអើតមើលមកអំពីមាត់ទ្វារខាងលើ ។

<>

នៅតាមរបងខាងក្រៅតាមបណ្ដោយផ្លូវ ចង្កោមផ្លែគូលែន ផ្លែគុយនិងផ្ទៀវនៅព្យួរ រណែងរណោងហូរហែបង្អួតអ្នកដំណើរ ។

នាង រ៉ុម ប្លែកភ្នែកណាស់ ចេះតែសាកសួរប្រុសនាងដោយចង់ដឹង "ផ្លែអ្វីហ្នឹងបង ?... យី ! ច្រើនណាស់... អ៊ុំ ! នៅឯណោះកាន់តែច្រើនជាងនេះទៅទៀត ហើយដូចជាទុំល្អជាងឯណោះផង !... " រថយន្តឈប់សួរឯអាយបន្តិច ឯនាយបន្តិច ទាំងប្រុសទាំងស្រីចុះស្រទៅរើសរកទិញចង្កោមណាល្អៗ ដើម្បីយកទៅទទួលទានលើភ្នំ ។

ស៊ី ឈឿន ដើរប្រមូលផ្លែឈើឱ្យនាងស្រីជញ្ជូនយកទោដាក់ឡានដោយរីករាយ "តែប៉ុណ្ណឹងយើងលែងខ្វះបង្អែមទៀតហើយណាំបង !" ។ នាងភ្លេចខ្លួន នឹងស្មានថា ស៊ី ឈឿន ជាប្ដីពិតប្រាកដរបស់នាង ។ ស្រីៗដែលបានប្ដីបណ្ដើរប្រហែលជាសប្បាយដូចនាងដែរមើលទៅ ! ។

" ហ៎ា ! ធ្លាយើងទៅមុខទៀត ប៉ុណ្ណឹងបានហើយ !"

គឺជាសម្លេងលោកសុតដែលលាន់រំពងឡើង ធ្វើឱ្យអ្នកដំណើរទាំងឡាយ ប្រញេយប្រញាយរត់ទៅឡើងឡានវិញ ។ រថយន្តចេញលឿនហុយដីសំពោង កាន់តែឆ្ងាយទៅ ហើយលិចបាត់ទៅនឹងព្រៃខាងចុងផ្លូវបត់ឯនាងនាយសន្ទឹម ។

ផុតស្រុក ផុតភូមិ ព្រឹក្សាធំៗរុលសិប់គ្របមកលើផ្លូវដែលមានទឹកដក់ដោយកន្លែង ។ នាងរ៉ុម ស្រៀវខ្លួននឹងដំណើរមកក្នុងព្រៃដាច់សង្វែង នាងនឹកត្រេកអរនឹងបានលោកប្រុសមកនៅនែបនិត្តជិតខឹងខ្លួននាង ។

ពូញ៉ឹប បិទមាត់មិនជិតទេ ចេះតែស្ងាញនៅខាងក្រោយជាមួយនឹងអស់លោកដែលចូលចិត្តកំប្លែងជាមួយនឹងគាត់ណាស់ដែរ ។ ស៊ី ឈឿន ងាកមកសួរគាត់តាមកញ្ចក់ខ័ណ្ឌទៅក្រោយដែលបើកចំហ

- ម៉េចពូញ៉ឹបសប្បាយទេ ?

គាត់សើចចិញ្ចាច ហើយឆ្លើយទៅវិញ

- សប្បាយណាស់តេជ:គុណអើយ ! ខ្ញុំមិនដែលដើរលេងអីឱ្យសប្បាយដូចម្ដងហ្នឹងទេ !

ស៊ី ឈឿនចំអន់លេងថា ៖

- មានតែអារ៉ុមមួយទេដែលមិនសប្បាយនឹងគេមែនទេ ពូញ៉ឹប ?

<>

ពូញ៉ិបសើចខ្ជប់មាត់ នាងស្រីលបក្តិចអ្នកប្រុស ឯលោកថៃក៏ញញឹមមិនចេញស្តី សម្លឹងមើលទៅផ្លូវដែលនៅឆ្ងាយនៅឡើយ ។

ប្រកកាត់ព្រៃដូចជាកាន់តែរួមតូច ព្រឹក្សានិងវល្លិនៅរុំជុំជិតរកមើលចន្លោះមេឃស្ទើរតែពុំឃើញ ។ ថ្មភ្នំលឿងប្រផេះធ្លាក់រាយប៉ាយមកលើផ្លូវ ផ្ទាំងសិលាខ្លះធំសម្បើមទ្រេតទេរដូចជាជញ្ជាំងដែលប្រុងនឹងរលំមកលើអ្នកដំណើរ ។ សម្រែកសត្វចម្លែកៗលាន់ចេញខ្ទរពីកណ្តាលទ្រូងព្រៃ “តាក់ ! តាតា !…តាក់ ! តាតា ! …” ឮឡើងរំពង ។ នាងរ៉ុមខិតទៅប្រជ្រៀតនឹងលោកប្រុសដែលមានប្រសាសន៍ថា ៖

- អូនឯងខ្លាចអ្វី ចេះជាសម្លេងសត្វទទា ដែលវាយំឆ្លងដូចនៅក្នុងចម្រៀងរាំវង់អីចឹងដែរ ។

នាងរ៉ុម ពិតក្បាលទៅនឹងស្មាលោកដោយអស់សំណើច

- អូនឥតស្មានថាសត្វទទាវាយំឮសូរអីចឹងទេ !
- អូនស្មានថាវាយំកាបកាប ដូចទាសម្លអីចឹងឬអី ?
- អូនស្មានតែវាយំដូចតាវ៉ៅ អីចឹងណ៎ា !

លោកថៃសើចខឹកៗ ពួកជួរមុខសើចទាំងអស់គ្នា ។ ហ្នឹងហេតុតែមិនដែលស្គាល់ព្រៃ ។

ផ្លូវកាន់តែលំបាកគ្រហិកគ្រហុក បត់បែនមិនចេះចប់ ។ រថយន្តប្តូរដាក់លេខពីរប្តូរដាក់លេខមួយ ប្រឹងបរលើងដោយលំបាក ។ អ្នកជិះដូចជាហត់ផ្លូលឡាន ខំប្រឹងឡើងរឹងសរសៃ ។ បាត់សូរមាត់មនុស្ស ឮតែស៊ំឮម៉ាស៊ីនដែលរោទ៍ង៉ោងៗ វារតើមឡើងភ្នំ ។ គួរឱ្យបារម្ភខ្លាចក្រែងតែម៉ាស៊ីនរលត់នាំឱ្យឡានរត់ថយក្រោយ ធ្លាក់ចូលទៅក្នុងជ្រោះចំហៀងភ្នំ ។ គ្រាត់តែផុតអំពីផ្លូវបង់ដែលចោតខ្លាំងម្តងៗ គេហាក់ដូចជាដកបន្ទាពីទ្រូង ! កន្លែងចោត កន្លែងបត់លំបាក កន្លែងប្រឹងខ្លាំង ចេះតែមាននៅមានបន្តបន្ទាប់គ្នា មិនដឹងជាកាលណានឹងផុត ។

ពូញ៉ិប ឈប់កំប្លែង មុខគាត់ឡើងស្លាំង គាត់នឹកថា បើដឹងជាលំបាកម្ល៉ឹងៗប្រហែលជាមិនប្រថុយមកទេមើលទៅ ! ។ គាត់ចេះតែសម្លឹងមើលមុខពយកអស់លោកមិនចេញស្តី ទំនងជាចង់សួរថា “ផ្លូវតពីនេះទៅ បែបសុទ្ធតែរបៀបហ្នឹងហើយមើលទៅ !” ។ កន្លែងខ្លះដែលតឹងពេលទៅ ធ្វើឱ្យអ្នកជិះខាងក្រោយខ្លះលោតចេញទៅក្រៅ រកដុំថ្មយកមកកល់កង់ឡាន កុំឱ្យថយក្រោយ ដើម្បីនឹងជៀសវាងគ្រោះថ្នាក់

ដែលអាចចូលមកដល់គ្រប់ពេលវេលា ។ គេនាំគ្នាប្រឹងឃាត់ពួញីបកុំឱ្យឆ្លេឆ្លាឱ្យគាត់នៅស្ងៀម ទុកឱ្យគេ អ្នកដែលធ្លាប់ដើរផ្លូវនេះគេចាត់ចែងតែគ្នាគេបានហើយ ។ <>

ស្រាប់តែផ្លូវប្រែជារាបស្មើ គ្រាន់តែបត់ពេនចុះពេនឡើងបន្តិចបន្តួច ។ រថយន្តបរលឿនរឹងផាត់អាកាសត្រជាក់ចូលមកត្រសៀកធ្វើឱ្យមានកម្លាំង ។ ចម្រៀងក៏លាន់ឮឡើងសាជាថ្មី អ្នកណាច្រៀងក៏ច្រៀង អ្នកណាទទួលទានផ្លែឈើក៏ទទួលទាន ឃើញបោះសំបកផ្លៀវនឹងគូលែនចេញរពុយតាមសងខាងឡាន ។ បរិយាកាសសប្បាយរីករាយលេចឡើងមកវិញ ពីព្រោះគេបានមកដល់ផ្ទៃរាបស្មើរាបនៃខ្នងភ្នំគូលែនហើយ ។

បន្ទាប់ពីបានឆ្លងកាត់ភូមិមួយតូចដាច់ស្រយាលប្រកបទៅដោយផ្ទះតែបួនប្រាំមក រថយន្តបត់ចុះតាមផ្លូវយ៉ាងពិបាកដែលមានផ្ទាំងថ្មបែកក្រហែងធំៗ ដែលត្រូវប្រយ័ត្នកុំឱ្យធ្លាក់កង់ឡានចូល ក្រែងបោកបែកម៉ាស៊ីនពីខាងក្រោម ។

ឮសូរសន្ធឹងទឹកធ្លាក់ខ្លាំង ។ នៅឯខាងចុងផ្លូវចុះដែលបត់ទៅឆ្វេង ទ្រូងព្រៃប្រែជាស្រឡះល្វឹង បង្ហាញផ្ទាំងទឹកសសំពោង ដែលហូរពីថ្នាក់ថ្មខ្ពស់មកលើផ្ទៃថ្មខាងក្រោម រីចេញជាលានតង្កាធំទូលាយហូរលឿនត្របាញ់ គួរឱ្យចាប់អារម្មណ៍ ។

គេចាប់រៀបកន្លែងសំរាប់សួដណ្តាំ និងទទួលទានបាយនៅមាត់ទឹក ក្រោមម្លប់ឈើត្រឈឹងត្រឈៃ ។ ពួកចង្ក្រានជើងឆ្នាំង ចាប់ចាត់ការមិនបង្អង់យូរ ។ ភ្លើងចាប់ឆេះហុយផ្សែងទ្រុប កន្ទេលកន្ទែងធំៗក៏បានលាផ្ទូនភ្ជៀវជាពីរវង់ជាប់គ្នា ដែលមានចំនួនមនុស្សទាំងអស់ដប់ប្រាំពីរនាក់ ។ ធុងទឹកកក ឡាំងសូដា ទឹកក្រូចនិងស្រាខ្លះក៏បានយកមកតំរៀបបម្រុងជាស្រេច ។

នាងរ៉ុមនិងនាងនី រត់ធ្វើការរវាមមិនចាំបាច់តឿន ចាក់ស្រាបៀរជូនលោកប្រុស ចាក់ស្រាជូនអស់លោកឯណោះ ទឹកតែទឹកកកជូនអស់លោកឯណោះ រួចផ្លៀតទៅជួយសួនិងអាំងមាន់ថែមទៀត ។

លោក សុតនិងលោកថៃប្រាប់នាងរ៉ុមថា “មិនអីទេ អារ៉ុមឯងទៅនៅជិតលោកធំទៅ នៅមើលបំរើលោកកុំឱ្យមានខ្វះអ្វី រឿងខាងណោះស្រេចតែពួកខ្ញុំចុះ” ។ នាងស្រីក៏ត្រេកអរនឹងបានទទួលភារៈត្រូវបំរើលោកប្រុសផ្ទាល់ ។

ស៊ី ឈឿនផ្លាស់ខោ រួចដឹកដៃនាងរ៉ុមចុះទៅមុជទឹកភ្នំគូលែន ។ នាងចោមពុងសារុងសូត្រ ដើរញញើតញញើមទោតាមសង្សារដែលកម្លាថា ៖

<>

- កុំខ្លាចអ្វី ! ខ្ញុំកាន់ដៃហើយតើ
- អូនឥតខ្លាចទេ ប៉ុន្តែដូចជាចេះតែស្ញើប ។

អ្នកទាំងពីរលុយទឹកហូរត្រឹមជង្គង់សន្សឹមៗ រហូតទៅដល់កន្លែងទឹកធ្លាក់ ស័ព្ទសូរទ្រហឹងរកស្តាប់អ្វីសឹងតែមិនឮ ។ បើនិយាយគ្នាទាល់តែស្រែកខ្លាំងៗ ទៅជាប់នឹងត្រចៀកទើបអាចស្តាប់បាន ។ អ្នកមុជហ៊ានចូលតែមួយភ្លែតៗ ទៅចំពីក្រោមទឹកដែលធ្លាក់បែកខ្ចាយមកលើខ្នងសឹងតែបាក់ឆ្អឹង ។ នាងរ៉ុមចេះតែស្ទុះមកតោង ស៊ី ឈឿន សប្បាយនិងភ័យលាយគ្នា រងាផង ចង់មុជលេងតទៅទៀតផង ។ អ្នកកំលោះដឹកដៃនាងចេញមកវិញ នាំគ្នាដើរបន្តិចៗទៅតាមបណ្តោយទឹកហូរ ។ ដើមឈើធំៗសម្បើម លូតឡើងទៅរកអាកាសបែកមែកខ្ពស់សន្ធឹម មានបញ្ញើក្អែកកញ្ចុំ "ទ្រនំព្រះរាម" ដុះប្រតោងទំលាក់រំយោលស្លឹកស្រយាលមកក្រោម ។ នាងស្រីរងាឱបដៃឡើងស្វាំងបបូរមាត់ ។ ស៊ី ឈឿន ហុចកន្សែងពោះគោទៅឱ្យនាងដណ្តប់ហើយចំអន់ថា ៖

"បើអូនឯងរងាខ្លាំង ចាំល្ងាចនេះបងនឹងសងអូនវិញ" ។

នាងសប្បាយនឹងការរាក់ទាក់ស្និទ្ធស្នាលរបស់ប្រុសសម្លាញ់ជាពន់ពេក ។ ក្រោយនោះបន្តិច ស៊ី ឈឿន ចាប់ដៃទប់នាងឱ្យប្រយ័ត្ន នៅប្រហែលជាបួនប្រាំជំហានពីខាងមុខនាង ផ្ទៃទឹកនិងផ្ទៃថ្មទាំងមូលដែលនាងដើរពីលើ ស្រាប់តែផុតបាត់ទៅក្នុងមហារណ្តៅធំល្ហល្ហេវរកបាតមិនឃើញ លេចតែចុងព្រឹក្សាដែលនៅជ្រៅគួរស្ញើបឯខាងក្រោម ។ នាងក្រឡេកមើលទៅវិលមុខចង់ធីងរោង ។ ស៊ី ឈឿន ទប់នាងជាប់ហើយប្រាប់ថា ៖

"នេះហើយជាជ្រោះភ្នំគូលែន ជ្រោះនេះជ្រៅណាស់ ទឹកទាំងអស់ដែលអូនទើបនឹងមុជ ហូរធ្លាក់ទៅតាមជ្រោះនេះ ដែលជ្រៅពេកទៅ រកស្តាប់សូរទឹកធ្លាក់នៅខាងក្រោមនោះមិនទាំងឮផង ។

នាងសួរដោយរន្ធត់

- ប្រសិនជាយើងជ្រុលជើងធ្លាក់ចុះទៅ

អ្នកកំលោះតបមកវិញដោយសង្វេគ

- នោះរូបនិងវិញ្ញាណរបស់យើង នឹងត្រូវនៅថែរក្សាជ្រោះភ្នំគូលែននេះរហូតរៀងទៅ ។

<>

នារីទឹកអាណោចអាធម្មក្នុងចិត្តហើយរបូតមាត់ថា ៖

- ប្រសិនបើបងបោះបង់អូនចោល ប្រហែលជាអូននឹងមកនៅថែរក្សាជ្រោះភ្នំគូលែននេះហើយ ។

អ្នកប្រុសយកដៃខ្ទប់មាត់នាងកុំឱ្យនិយាយតទៅទៀត ។ ទឹកធ្លាក់ខ្ទីររំពងព្រៃលាន់ឮលប់មកលើពាក្យសំដីដែលទើបនឹងវាចាទៅផុត... ។

មុជទឹករួចគេនាំគ្នាបាយនៅមាត់ជ្រោះភ្នំគូលែន មាន់អាំងជាច្រើនអាំងកំបុតត្រូវរលស់ផុតក្នុងរយៈពេលដ៏ខ្លី ។ ប្រហុកគ្រៀងពីរកញ្ចប់ផ្ទាប់នឹងត្រសក់ខ្ចីពីរចានលាយជាមួយស្ពៃក្តោបនិងខ្ទឹមបារាំងស្រស់ ក៏ចេះតែបាត់អស់ទាំងចាស់ទាំងថ្មី ។ ឯសម្លម្ជូរដើមចេកក្តៅៗ បង់អ្នមយ៉ាងចាស់ក៏គោកទឹកញឹកណាស់ដែរ ធ្វើឱ្យនាងរ៉ុមជាអ្នកស្លូ សប្បាយនឹងជួសថែមដើម្បីបំពេញចិត្តអ្នកប្រុស ។

បាយហើយ ក្រោយពីសម្រាកបន្តិច គេមុជទឹកមួយសាទៀត រួចរៀបចំឥវ៉ាន់ដាក់ឡានឡើងទៅលើវិញ ។ ថ្ងៃជ្រេទាបបន្តិចទៅហើយ ។

រថយន្តឡើងសំដៅទៅកំពូលភ្នំគូលែន ទៅឈប់ក្បែរសាលាឈើមួយ ឋិតនៅជិតជណ្តើរភ្នំដែលនាំឡើងខ្ពស់ទៅទៀត ។ ស៊ី ឈឿនចាត់គ្នាជាពីរក្រុម ។

ក្រុមទីមួយមានគ្នាប្រាំបីនាក់ ដែលធ្លាប់ស្គាល់ភ្នំគូលែនពីមុនមកហើយ មានលោកសុតជាអ្នកដឹកនាំ ត្រូវឡើងឡាន "កាមីញ៉ូណែត" ទៅបោះជំរំនៅកន្លែងជិតមាត់ទឹកមួយទៀតនៅខាងមុខ ។

ក្រុមទីពីរមានគ្នាប្រាំបួននាក់ មានលោកថៃជាអ្នកនាំផ្លូវ ត្រូវឡើងជាមួយនឹងស៊ី ឈឿន ទៅកាន់តំបន់អាស្រមកម្មដ្ឋាន ។ ក្នុងក្បួនដង្ហែគ្នាឡើងទៅ ឃើញលោកថៃដើរមុខ ស៊ី ឈឿនកាន់ដៃនាងរ៉ុមដើរបន្ទាប់ ជាមួយនឹងនាងនី ។ ពូញ៉ឹបនិងអស់លោកឯទៀតដើរជុំគ្នាតាមក្រោយ ។ ដល់ទៅលើផ្លូវដែលទូលាយ ត្រូវបត់ទៅស្តាំចូលតាមច្រកសិលាខ្ពស់ចង្អៀង មានព្រឹក្សាដុះពាក់ព័ន្ធពីខាងលើ គ្របជាម្លប់ដល់ផ្ទៃក្រោមដែលនៅសើមដុះស្លែបៃតងស្រងាត់ ។ ផ្លូវតទៅទៀតក្រងិកក្រងក់ជួនភ្លឺស្រឡះទទេពីខាងលើ ប៉ុន្តែខាងក្រោមរួមតូចតាមចន្លោះផ្ទាំងថ្ម ។ ទីជុំវិញស្ងាត់ឈឹងឮតែរៃកណ្តឹងដែលចាប់យំនៅដើមរផ្លូវប្រាំង ។ ពេលដែលសម្លេងរៃរលត់បាត់សូន្យទៅម្តងៗ គេដូចជាឮស្នូរជើងមនុស្សរត់មកតាមពីខាងក្រោយ ធ្វើឱ្យអ្នកដំណើរស្រៀវខ្នង ចេះតែរុលទៅខាងមុខ ។ បន្តិចមក នាងស្រីជំរាបលោកប្រុសថា

ដូចជាជុំក្លិនអ្វីផ្ទៀមម្ទេះ ប៉ុន្តែ ស៊ី ឈឿនងាកទៅមើលនៅជុំវិញនោះ ដូចជាគ្មានឃើញអ្វីប្លែក ក្រៅអំពីផ្លូវជើងមួយតូចទក់ៗ ដែលចេញទៅខាងឆ្វេងដំដៅទៅ <> ក្រហែងថ្មមួយងងឹត ។ គេនាំគ្នាចូលទៅទាំងបារម្ភ តាមក្លិនផ្ទៀមដែលកាន់តែជុំឆ្ងួលខ្លាំងឡើងៗ ។ លេចឃើញពាងទឹកមួយតូចនៅជាប់នឹងច្រកចូល ។ លុះសម្លឹងយូរទៅខាងក្នុង ក៏ឃើញជារាងមនុស្សស្លៀកពាក់ស អង្គុយពែនភ្នែនផ្អែកទៅនឹងជញ្ជាំងរូងភ្នំ បែរមុខចំហៀងទៅរកព្រះពុទ្ធរូបឈើមួយអង្គដែលផ្សែងធូបកំពុងតែហុយស្រាលជុំព័ទ្ធជុំវិញ ។ នាងរុំមទាញដៃប្រុសបងឱ្យចូលទៅជាមួយ “សូមបងជូនអូនទៅមើលឱ្យជិតបន្តិច” ។

នាងចូលទៅឈរប្រហែលបួនម៉ែត្រពីអ្នកសច្ចំដែលនៅតែបិទភ្នែកសំរឹងទៅក្នុងភាវនា ។ នាងសង្កេតយូរ ហើយបែរមកមើលមុខលោកប្រុសហាក់ដូចជាចង់សួរថាតើយោបល់របស់បងយ៉ាងម៉េច ។ ស៊ី ឈឿនបង្ហាញទឹកមុខពិបាកនឹងយល់ទៅរកនាងវិញ ។

ឃើញនាងភាំងយូរពេក អ្នកប្រុសខ្សឹបប្រាប់នាងថា ៖

- “ល្មមហើយ យើងត្រូវធ្វើដំណើរតទៅទៀត” ។ គេនាំគ្នាចេញមកវិញដោយស្ងៀមស្ងាត់ ។ មកដល់ខាងក្រៅអ្នកប្រុសអង្អែលស្មានាង សួរដោយថ្នម

“អូនឯងដូចជាមានទឹកមុខប្លែកណាស់ល្ងាចនេះ”

- ចាំស ! អូនឃើញអីចឹង ដូចជាលន្លង់លន្លោចក្នុងចិត្តពន់ពេក ។ ទីនេះប្រហែលជាមិនងាយនឹងមានអ្នកឯណាបានមកដល់ឡើយ ។ ប៉ុន្តែបើរួបណាមកនៅក្នុងកន្លែងនេះហើយ ក៏សន្មតថា ដូចជាស្លាប់បាត់បង់សង្ខារចំពោះបងប្អូនកូនចៅញាតិមិត្រទាំងប៉ុន្មាន ។

ផ្លូវចុះឡើងលើថ្មឆ្ងាយទៅទៀត មានសភាពកាន់តែចម្លែកឡើង ។ នៅតាមជម្រាលភ្នំ ដើមម្នាស់ព្រៃដុះដេរដាស ផ្លែទុំក្រហមតូចៗប៉ុនកដៃ ។ សភាពក៏អស្ចារ្យមួយលេចឡើងនៅចំហៀងខាងមុខ ថ្មភ្នំឯនាយរីកចេញខ្ពស់ឡើងរាងដូចជាក្លស់មួយធំសម្បើម ដែលមានក្លស់តូចៗច្រើនជាន់ត្រួតពីលើ ។ លោកថៃលើកដៃចង្អុរប្រាប់ភ្ញៀវ

"ស្នាដៃដ៏វិចិត្រនៃធម្មជាតិខាងមុខនេះ មានឈ្មោះថា "រូងឥសី" ។ ពូញឹប លាន់មាត់មុនគេថា ៖ "អូ ! មែន ដូចរ៉ូងឥសីមែន ដូចសុទ្ធៗតែម្តង !" ។ អ្នកឯទៀតក៏ឆ្ងល់ងមាត់ទៅតាមពូញឹបដែរ ។

ថ្នាក់ថ្មបីបួនកាំនាំអ្នកដំណើរឡើងចូលទៅក្រោមរូងឥសីដែលជាផ្ទាំងថ្មគ្របពីលើ ជាដំបូលមួយធំធុះជាប់មួយចំហៀងទៅនឹងជញ្ជាំងភ្នំ ហើយរីកចេញមួយចំហៀងទៀត លៀនសំប៉ែតមកខាងក្រៅដូចជាផ្សិត ។ នៅជុំវិញគល់ផ្សិតថ្មដ៏សម្បើមមានអាសនៈ តាំងព្រះពុទ្ធរូបច្រើនព្រះអង្គ ប្រកបទៅដោយសំណុំទៀនធូបដែលធូលីរុំព័ទ្ធកកពីលើ ។ សម្លេងអ្វីអរនៃភ្ញៀវដែលទើបនឹងចូលទៅដល់ ធ្វើឱ្យលេចចេញដូនជីម្នាក់អំពីក្រហែងថ្មខាងក្នុង ។ លោកយាយមានប្រសាសន៍សួរដោយរាក់ទាក់

- លោកចៅទាំងអស់គ្នាអញ្ជើញមកយូរហើយឬ ?

ភ្ញៀវទាំងអស់លត់ជង្គង់ព្រមគ្នាគោរពដូនជី

- បាទ !... ចាស !... លោកយាយ យើងខ្ញុំទាំងអស់គ្នាទើបតែនឹងមកដល់មុននេះបន្តិច

- សូមចៅទាំងអស់គ្នា អុជធូបបូជាព្រះពុទ្ធដើម្បីសុំសេចក្តីសុខ ណា៎ !

ការគោរពនមស្ការក៏ប្រព្រឹត្តទៅព្រមគ្នាដែរ ។ នាងរ៉ុមខិតចូលទៅជិតលោកយាយហើយជំរាបសួរថា ៖

- ជំរាបប្រសាសន៍លោកយាយ ហេតុអ្វីបានជាលោកយាយដាច់ចិត្តអញ្ជើញមកចំរើនភាវនាអ្វីក៏ឆ្ងាយដាច់ស្រយាលខ្លាំងម្ល៉េះ ?

លោកយាយដូចជាស្ងួងយូរទៅក្នុងការត្រិះរិះរកអនុស្សាវរីយ៍ ដែលកន្លងផុតឆ្ងាយណាស់ទៅហើយ ។ បន្ទាប់មកក៏មានវាចាញ័រៗ

- ដើមឡើយ យាយមានរូបឆោមនៅស្រស់ខ្ចីដូចជាចៅដែរ ប៉ុន្តែរូបនេះបានឱ្យទុក្ខជាច្រើនដល់រូបយាយ យាយក៏ដាច់ចិត្តមកជ្រកកោននឹងព្រះធម៌ព្រះសម្មាសម្ពុទ្ធរហូតមកដល់សព្វថ្ងៃ ។

និ ! លោកយាយ ចុះទុក្ខនោះជាទុក្ខអ្វីទៅ ?

លោកយាយញញឹមដោយសង្វេគ ហើយងាកមើលទៅចៅប្រុសដែលបត់ជើងជិតចៅស្រី បណ្តាយឱ្យនាងស្រីងាកតាមមើលទៅលោកប្រុសដែរ ។ លោកយាយមានប្រសាសន៍សួរថា ៖

- ចៅប្រុសនេះជាប្តីរបស់ចៅស្រីឬ ?

- ចា៎ស ! លោកយាយ (នាងស្រីមិនហ៊ានឆ្លើយថាទេ ដើម្បីកុំឱ្យខ្មាសនឹងសម្តីលោកយាយ)

ពូញ៉ឹបងាកមើលមុខលោកថៃ លោកថៃងាកមើលមុខតទៅអ្នកដែលនៅខាងក្រោយខ្នង ។

លោកយាយមានប្រសាសន៍តទៅទៀត

- ចៅទាំងពីរមានរូបរាងសមគ្នាមែន ចៅស្រីទំនងដូចជាស្រឡាញ់ចៅប្រុសណាស់ បើចៅបានសុភមង្គលយ៉ាងនេះទៅហើយ ចូរចៅកុំចង់ដឹងរឿងរបស់យាយឡើយ ។ ប៉ុន្តែយាយគ្រាន់តែសុំផ្តាំថា បើថ្ងៃណាចៅអស់សង្ឃឹមនឹងមនុស្សលោក សូមចៅកុំភ្លេចថា ព្រះធម៌របស់ព្រះសម្មាសម្ពុទ្ធជាផ្លូវដ៏ត្រជាក់សម្រាប់ជួយរំលត់ទុក្ខទាំងពួង ណា៎ចៅណា៎ ! ។

នាងស្រីលើកដៃសំពះ "ចៅនឹងរំឭកជានិច្ចនូវបណ្តាំរបស់លោកយាយ" ។

នាងស្រីយកត្រកដែលពូញ៉ឹបយកមកតាម... ស្រាយយកម្ហូបនឹងផ្លែឈើថ្មីៗរៀបដាក់ជូនលោកយាយ ព្រមទាំងក្រមាពានា ដែលនាងសូមបូជាចំពោះព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ សម្រាប់ជូនលោកយាយដណ្តប់កុំឱ្យរងាក្នុងវេលាយប់ ដែលខែនេះតែងតែត្រជាក់ខ្លាំងនៅលើកំពូលភ្នំគូលែន ។

សេចក្តីជ្រះថ្លារបស់នារីដ៏ល្អប្រិមប្រិយ នាំចិត្តលោកយាយឱ្យចង់ស្គាល់វង្សត្រកូលដ៏ប្រសើររបស់នាង ។ លោកយាយមានប្រសាសន៍សាកសួរដោយសប្បុរស

- តើចៅប្រុសមាននាមជាអ្វីទៅ ?

- បាទ ខ្ញុំឈ្មោះ ស៊ី ឈឿន លោកយាយ

- ចុះចៅស្រី ?

- ចា៎ស ចៅឈ្មោះ យ៉ាហន លោកយាយ

ឈ្មោះចម្លែកនេះធ្វើឱ្យលោកថៃ ភ្ញាក់ព្រើតនឹកឃើញហើយយល់ទៅដល់រឿងចំការដូង ។ លោកយាយសួរទៅទៀត

- តើចៅស្រីជាកូនចៅលោកណា អ្នកណាទៅ ឱ្យយាយដឹងផងបានឬទេ ?

សំណួរនេះធ្វើឱ្យនាងស្រីពិបាកនឹងឆ្លើយក្រៃពេក ។ នាងឱនមុខមិនចេញស្តី ។ ស៊ី ឈឿន នឹកអាសូរចិត្តក៏ឆ្លើយកាត់ដោយក្បោះក្បាយ

- ជំរាបប្រសាសន៍លោកយាយ អូនយ៉ាហាន ជាប្អូនជីដូនមួយនឹងខ្ញុំ ។ ម្ដាយខ្ញុំនិងម្ដាយនាងបានផ្សំផ្គុំគ្នាតាំងតែពីចៅទាំងពីរនៅតូចៗម្ល៉េះ ។ ប៉ុន្តែម្ដាយនាងបានស្លាប់ចោលទៅតាំងតែអំពីនាងនៅក្មេងខ្ចី ។ នាងជាកូនកំព្រាឪពុកម្ដាយតាំងតែពីតូច ហេតុនេះហើយបានជាដល់លោកយាយសួររឿងនេះ នាងខ្សឹកខ្សួលរកឆ្លើយអ្វីមិនរួច ។

យ៉ាហានចង់ស្ទុះទៅឱបរឹតបងនៅនឹងមុខគេឯង ។ នាងមិនដែលបានទទួលកិត្តិយសខ្ពង់ខ្ពស់ដល់ម្ល៉េះទេ នាងមិនបានគិតថាប្រុសនេះ ចេះធ្វើឱ្យនាងស្រឡាញ់លង់ជីវិតដល់ម្ល៉េះឡើយ ។

លោកយាយសរសើរថា ៖ "ល្អណាស់ចៅប្រុស ចៅចិត្តល្អណាស់ យាយសូមចងដៃចៅទាំងពីរឱ្យចេះតែរឭកនឹកឃើញគ្នារហូតរៀងទៅ"

ថាហើយលោកយាយ ហូតយកសរសៃឈើឆ្មារជ្រលក់ទឹក ហើយរុំចងដៃអ្នកប្រុសនឹងនាងស្រីព្រមទាំងឱ្យពរសព្វសាធុការជាច្រើនចំពោះគូទាំងពីរ ។ ពីធីនេះក្លាយទៅជាអាពាហ៍ពិពាហ៍ក៏កណ្ដោចកណ្ដែងកណ្ដាលព្រៃ មានលោកថៃ ពូញ៉ឹប នាងនី... នឹងបក្សីបក្សាទាំងឡាយបានដឹងឮជាមួយនឹងព្រឹក្សាបព្វតាសិលាភ្នំគូលែន ។

លុះចប់ពីធីហើយ ទាំងអស់គ្នាសំពះលាលោយយាយទាំងអាឡោះអាល័យ ។ ដល់ចេញផុតឆ្ងាយពីនោះបន្តិចមក សង្សារទាំងពីរងាកបែរទៅក្រោយវិញ ហើយយ៉ាហានចេញវាចាដោយក្រៀមក្រំទៅរកសង្សារ "បង ! នៅកន្លែងនេះពាក្យថាលាហើយ ដូចជាមានន័យថាលារហូតលែងវិលវិញ..." ។

រួតឥសីកាន់តែឃ្លាតឆ្ងាយទៅ សម្លេងរបស់លោកយាយដូចជានៅតែនឹងត្រចៀកនាងយ៉ាហាននៅឡើយ ។

ចេញផុតពីច្រកចូលទោជំរំកម្មដ្ឋាន អ្នកដំណើរទៅដល់ចំពោះមុខផ្ទាំងសិលាមួយទៀតខ្ពស់លើសពីមុន ប្រកបដោយជណ្ដើរដែកចោតត្រេង មានបង្កាន់ដៃពីរបីបត់នាំឡើងឆ្ពោះទៅកាន់វិហារឈើដែលសង់នៅចំពីលើកំពូល ។ គេសប្បាយរញ៉ េចឡើងជណ្ដើរបន្តគ្នាដោយប្រយ័ត្នប្រយែង ។ ស៊ី ឈឿនឱ្យយ៉ាហានឡើងទៅមុនខ្លួនឯងឡើងបន្ទាប់តាមជាប់ពីក្រោយជួយទប់ក្រែងនាងរបូតដៃ ។ ក្រឡេកមើលអំពី

កំពូលសិលាដែលខ្ពស់ដាច់គេ ទេសភាពជុំវិញភ្នំគូលែនបង្ហាញព្រៃព្រឹក្សាបៃតងស្រងាត់ដុះខ្មាន់ខ្មាប់ចុះរាលទៅឆ្ងាយ ចាំងរលុបព្រាលៗនឹងពពកចុះអ័ព្ទដែលអណ្តែតជាស្រទាប់ៗ នៅពេលល្ងាចថ្ងៃគងភ្នំ ។ នៅខាងក្នុងវិហារ ព្រះអង្គធំចូលនិព្វានឆ្លាក់ជាប់នឹងកំពូលសិលាតែម្តង ទ្រង់ផ្ទំសណ្តូកសន្ធឹងពេញបណ្តោយវិហារទាំងមូល ប្រវែងប្រហែលម្ភៃម៉ែត្រ ទឹកព្រះភ័ក្ត្រស្ងាត់ស្ងៀមមិនដឹងជាប៉ុន្មានពំណសតវត្សមកហើយ ! ។ ជើងធូប ផ្កាស្រស់ ផ្កាស្រពោននិងផ្កាក្រដាសជាច្រើននៅតម្កល់ដោតនិងព្យួរគ្រប់កន្លែងសម្តែងសេចក្តីគោរព រំឭកគុណអំពីជនទានុជនគ្រប់ឋានៈ ដែលបានចូលមកបួងសួងសូមជ្រកកោនក្រោមម្លប់បារមីព្រះអង្គ ។

ស៊ី ឈឿន នាងយ៉ាហាន និងអស់លោកដែលមកជាមួយទាំងប៉ុន្មាន លូនចូលដោយគោរពនៅក្រោមព្រះភ័ក្ត្រនិងព្រះបាទព្រះអង្គធំ នាំគ្នាអុជទាន អុជធូបបូជាគ្មានចន្លោះម្នាក់ ។ សង្សារទាំងពីរបត់ជើងទន្ទឹមគ្នានៅខាងមុខ ហើយយ៉ាហានតាំងសច្ចាបួងសួងអស់អំពីដួងចិត្ត

“សូមព្រះអង្គដ៏មានឫទ្ធិបារមី សូមធម្មជាតិ ព្រឹក្សព្រៃ និងទឹកជ្រោះភ្នំគូលែន ជាសាក្សីនៃសេចក្តីបួងសួងរបស់ខ្ញុំម្ចាស់ដែលសូមតាំងចិត្តសច្ចាស្មោះចំពោះលើបុរសតែម្នាក់គឺរូបបង ស៊ី ឈឿន លុះត្រាជីវិតបង់ ។ ខ្ញុំម្ចាស់សូមផ្តាច់ចោលនូវឈ្មោះ “រ៉ុម” តែត្រឹមណេះ ។ អំពីថ្ងៃនេះតទៅ ខ្ញុំម្ចាស់ជានាង “ខាន់ យ៉ាហាន” ពិតប្រាកដចំពោះបុរសតែមួយ ដែលខ្ញុំម្ចាស់ស្រឡាញ់លើសពីខ្លួនឯង ។ បើថ្ងៃណាគួជីវិតរបស់ខ្ញុំម្ចាស់ ភ្លេចខ្ញុំម្ចាស់ហើយ សូមឫទ្ធិអំណាចព្រះអង្គនិងវត្ថុស័ក្តិសិទ្ធិនៃភ្នំគូលែនទាំងប៉ុន្មាន មេត្តាផ្តាច់ជីវិតរបស់ខ្ញុំម្ចាស់ សុំកុំឱ្យនៅរស់រងកម្មយូរក្នុងការព្រាត់ប្រាស ដែលខ្ញុំម្ចាស់មិនចង់យល់ឃើញសោះឡើយ” ។

ព្រះអង្គធំទ្រង់គង់ឈឹងមិនមានបន្ទូលអ្វី ហាក់ដូចជាសព្វព្រះទ័យយល់ព្រមចំពោះពាក្យសច្ចារបស់យ៉ាហាន ។ គេដូចជាព្រឺខ្លួនគ្រប់គ្នានឹងកម្រិតដ៏ធ្ងន់របស់នាង ។ ពួញីបអោនក្រាបទៅដល់ឥដ្ឋ ពិចារណាទៅដល់ជីវិតរបស់នារីដែលគាត់ចាត់ទុកអំពីថ្ងៃនេះទៅ ថាជាចៅហ្វាយស្រីរបស់គាត់ដែរ ។

បន្ទាប់មក យ៉ាហាន យកកន្ត្រៃមកកាត់សក់នាងដែលវែងជិតដល់ចង្កេះអស់មួយចង្អាមបូជាដល់ព្រះអង្គ ។ សក់នេះនាងរាយទម្លាក់ពីថ្នាក់ដៃពីខាងលើនៃព្រះវិហារ

ទៅតាមវាយោពេលល្ងាចដែលបក់ផាត់មកខ្លាំង រាយកំទេចកេសីឱ្យរសាត់បាត់ទៅឆ្ងាយពាសពេញកំពូលភ្នំគូលែន ។

ពេលព្រលប់ណាស់ទៅហើយ ទើបគេចាកចេញពីព្រះអង្គធំ ។

ល្ងាចនេះជាថ្ងៃទីក្ខត្តឫក្ស សប្បាយជួបជុំនៅជំរំភ្នំគូលែន ។ ម្ហូបអាហារបានត្រូវរៀបចំហើយជាស្រេច រង់ចាំតែសង្សារទាំងគូមកដល់ដើម្បីនឹងផ្ដើមបាយទឹក ។ ចម្រៀង "ម៉ង់សុង" ពីរបំភ្លឺទីប្រជុំដែលមានបទភ្លេងលាន់ឮរងំ អំពីវង់កំប្លែងរបស់លោកសុត ។

គេបានរៀបចំពោះ "តង់" ជម្រកបីនៅហែតាមមាត់ទឹក ។ "តង់"ធំៗពីរនៅសងខាងសម្រាប់អស់លោកទាំងប៉ុន្មាន ឯ"តង់"តូចមួយនៅកណ្ដាលសម្រាប់អ្នកប្រុសនិងនាងស្រីដែលគេចាប់ទម្លាប់ហៅឈ្មោះ "យ៉ាហាន"គ្រប់គ្នាតាំងអំពីល្ងាចនេះទៅ ។ រថយន្តទាំងគូនៅចតអមជំរំ ឯចម្រៀង "ម៉ង់សុង"មួយទៀតគេដុតដាក់នៅលើដំបូលឡាន "ឡង់រ៉ូវែរ" ដើម្បីឱ្យភ្លឺទៅឆ្ងាយ ។

គេនាំគ្នាទទួលទានគ្មានរារែក ពីព្រោះម្ហូបអាហារឥតខ្វះខាតឡើយ ខ្វះទង្គិចផ្ដិលខ្វះទង្គិចកែវ និងជបសូដាទៅវិញទៅមក ជាសញ្ញាអបអរសាទរចំពោះដំណើរកំសាន្តនិងជោគជ័យនៃសេចក្ដីស្មោះរបស់គូទាំងពីរ ។ លោកសុត និងនាងនីចេញតួអាយ៉ៃយ៉ាងស្រស់ ត្រូវពួញីបបំភ្លែបន្ថែមគ្មានសំចៃធ្វើឱ្យឮសូរសប្បាយទះដៃជាចង្វាក់ញាក់ទទ្រើត ។

លុះយប់ជ្រៅបន្តិចទៅ របាំកំប្លែងចេះតែបាត់ស្ងាត់ហើយលេចឮសូរចំរៀងមួយសែនពីរោះខ្ពស់គ្រលួចដែលហាក់ធ្វើឱ្យស្រណោះអស់ទាំងព្រៃភ្នំគូលែនទាំងមូល ។ សម្លេងឯទៀតបាត់សូន្យឈឹង ស្ដុងចាំស្ដាប់បទលន្លង់លន្លោចដែលនាងស្រី ខាន់យ៉ាហាន ច្រៀងផ្ដោះផ្ដងចំពោះស្នេហាដែលនៅខ្ពស់ហួសដៃនាងឈោងដល់ ។ ស៊ី ឈឿន រំជួលចិត្តនឹងសម្លេងល្អគ្មានខ្ចោះដែលកំពុងរាយទំនុក មានន័យដូចជារឿងកំសត់របស់ខ្លួន ។

កាត់តែជិតអាធ្រាត្រ លើភ្នំកាន់តែស្ងាត់ បាត់រឿងកំប្លែង បាត់ឮសូរភ្លេង ។ គេរៀបចំចូលដំណេករៀងៗខ្លួន បន្ទាប់ពីបានបង្កភ្លើងមួយភ្លក់ធំទុកឱ្យឆេះរហូតដល់ភ្លឺ ។

យ៉ាហាន ច្រៀងបំពេប្រុសសម្លាញ់ ដោយសប្បាយនិងក្តុកក្តួល ។ សម្លេងក៏ពីរោះរបស់នាងរសាត់ទៅជាមួយនឹងស័ព្ទទឹកហូរសួរស្រាលចុះតាមជម្រាលភ្នំ ។ យប់នេះត្រជាក់ណាស់ នាងបណ្តោយឱ្យប្រុសបងរឹតរួចខ្លួននាងដោយស្នេហា នាងស្រវាំងទៀលទៅជិតហើយគិតទៅឆ្ងាយ ទឹកបារម្ភក្រែងសេចក្តីសប្បាយមិនបានឋិតថេរទៅយូរប៉ុន្មាន ។ យប់នេះនាងដូចជាស្រឡាញ់គេរឹតតែខ្លាំង នាងអង្វរឱ្យគេស្រឡាញ់នាងច្រើនលើសអំពីធម្មតា នាងចង់ឱ្យសេចក្តីជិតស្និទ្ធនៅបន្តរហូតមិនចេះចប់ មិនចង់ឱ្យយប់ត្រឡប់ទៅជាភ្លឺ មិនចង់ឱ្យឮអ្វីក្រៅអំពីសំដីថ្នាក់ថ្នមរបស់គូជីវិត ។ ពេលដែល ស៊ី ឈឿន រលាដៃចេញពីនាងម្តងៗ នាងចាប់ទាញដៃនេះឱ្យឱបរឹតនាងមកវិញ ឱ្យសាច់ឈាមរបស់នាងនៅជាប់ជានិច្ចនឹងសាច់ឈាមរបស់ប្រុសនាង ។ នាងថើប នាងរឹងសង្ស័យខុសពីធម្មតា ។ ជួនកាលនាងថ្ងូរថា ៖

"អូនស្រឡាញ់រសជាតិរបស់បងពន់ពេកណាស់ អូនមិនចង់ឱ្យស្រីឯណាបានស្គាល់រសជាតិហ្នឹងទៀតឡើយ" ។

អាធ្រាត្រកណ្តាលភ្នំត្នោលែន ស្លឹកឈើជោគទឹកសន្សើមធ្លាក់ជាដំណក់ អាកាសខាងក្រៅត្រជាក់ជ្រាបដល់ឆ្អឹង ។ ទឹកហូរមិនចេះហត់ថ្នាក់លើថ្ម ធម្មជាតិខ្លះស្ងៀមខ្លះកំរើករំពើកគ្រប់កន្លែង ។ ព្រះអង្គធំទ្រង់គង់ជាទីពឹងក៏ស្ងប់ស្ងាត់នៃមនុស្សនិងសត្វផងទាំងឡាយ ដែលដេកលង់លក់នៅក្រោមបារមីព្រះអង្គ ។

នៅរសៀលថ្ងៃចន្ទ រថយន្តផ្ទុកឥវ៉ាន់រួចសព្វគ្រប់ ឆ្វេលមួយជុំជំរំកំសាត់ ហើយចុះចាកភ្នំត្នោលែន លឿនស្ទៅសំដៅមកក្រោម ចោលព្រះអង្គធំ ចោលលោយយាយរួតឥសី ចោលព្រៃ និងទឹកជ្រោះនៅខ្ពស់ឆ្ងាយឯខាងក្រោយ ។ លាហើយភ្នំត្នោលែន លាកន្លែងដែលបានផ្សំផ្គុំ ស៊ី ឈឿន នឹង នាងយ៉ាហាន ។

គេឯទៀតអស់កម្លាំង គេនាំគ្នាដេកអស់រលីង ឯយ៉ាហាន គ្មានសំណាងនឹងអាចផ្ទេចនឹងគេកើតឡើយ ពីព្រោះអនាគតរបស់នាងរឹងរឹតតែវិលវល់មិនយល់កោះត្រើយ ។ មិនដឹងជាលោកប្រុសបានសម្រេចចិត្តយ៉ាងណាទេ ! នាងមិនហ៊ានជំរាបសួរលោកសោះ ។ សេចក្តីសង្ឃឹមនៅលើភ្នំត្នោលែនធ្លាក់ចុះលឿនជាមួយនឹងឡានវិលទៅវលាយអស់រលីងជាមួយនឹងភូមិស្រុក ផ្ការកុះករដែលបានធ្វើឱ្យនាងអភ័ព្វ ។ គេរាល់

គ្នាគេសប្បាយនឹងបានមកដល់ផ្ទះសម្បែង ឯរូបនាងវិញត្រូវវិលមកជួបនឹងភាពថោកទាបដដែល ។

មកដល់សៀមរាបពេលព្រលប់ យប់នេះត្រូវបែកគ្នា ។ យ៉ាហន គ្មានហើបមាត់អ្វីសោះ និយាយយ៉ាងដូចម្ដេចកើតមិនដឹងជាលោកប្រុសទុកនាងជាអ្វី សួរទៅនាំឱ្យខ្មាសសំដី បើលោកឆ្លើយថាមិនអាណិត តើស្ដាយទឹកចិត្តយ៉ាងណាទៅវិញ ។ ត្រូវតែលោកសួរនាង ត្រូវតែលោកបញ្ជាមកនាង នាងនៅរង់ចាំតែធ្វើតាមបង្គាប់របស់លោកទាំងអស់ បើទោះបញ្ជានោះតឹងយ៉ាងណាក៏ដោយ ។

រថយន្តមកឈប់នៅមុខផ្ទះ ដែលនាងធ្លាប់រស់នៅជាស្រីផ្កាមាស ។ ស៊ី ឈឿនប្រាប់ទៅនាងដោយសោះកក្រោះ “យើងលាគ្នាតែត្រឹមណេះ ចាំថ្ងៃក្រោយសឹមជួបគ្នាទៀត”

នាងងាកបែរទៅសម្លឹងមើលមុខលោក ដោយហួសចិត្តហើយឆ្លើយទាំងសោះកក្រោះទៅវិញដែរ

- ខ្ញុំមិនចូលផ្ទះនេះទៀតទេ សូមបងយកខ្ញុំទៅបោះចោលនៅមាត់ស្ទឹងសៀមរាបចុះ ខ្ញុំនឹងចុះទៅដេកនៅបាតស្ទឹងតែម្ដង ! ។

ស៊ី ឈឿន មិនដែលឮនាងខឹងឆ្លេះឡើយ នាងក៏មិនដែលវាចាយ៉ាងឆ្លេះជាមួយនឹង ស៊ី ឈឿនដែរ ។ លោកថៃនិងអស់លោកដែលនៅជាមួយក្នុងឡានទាំងប៉ុន្មានបាត់មាត់ស្ងាត់រង់ចាំតែស្ដាប់សេចក្ដីបង្គាប់របស់លោកប្រុស និងដំណើររឿងតទៅមុខទៀត ។ ឮញីបញ្ចេញពោះក្អកៗនឹងឆ្ងល់ថាមិនសមបើលោកប្រុសឥតមេត្តាដល់ម្ល៉ឹងសោះ !

ស៊ី ឈឿន ប្រាប់លោកថៃអោយបរទៅផ្ទះលោកឆាំ ។ រថយន្តទាំងពីរចូលទៅក្នុងបរិវេណផ្ទះនោះ ដែលមានទីស្រឡះពីខាងមុខ ។ គេនាំគ្នាចុះស្រីករាយនឹងបានមកដល់វិញដោយសុខសាន្តមុនពេលយប់ ។ ស៊ី ឈឿន ចុះពីឡានដឹកដៃនារីកំសត់ឱ្យចុះមកជាមួយ បណ្ដើរនាងទៅដល់កណ្ដាលវង់គ្នាឯងហើយនិយាយចំអន់ថា ៖

- កនយើង ! គួរឆ្ងល់ឬទេ ! ត្រឡប់អំពីភ្នំគូលែនមកវិញស្រាប់តែម្នាក់នេះចង់សុំទៅគេងនៅបាតស្ទឹងសៀមរាបតែម្ដង ! ។

គេនាំគ្នាលាន់មាត់ថា “យី ! ម៉េចអីចឹង !” លោកសុតបន្ថែមថា ៖

- ខ្ញុំបាទធ្លាប់តែឮថាព្រះអង្គធំភ្នំគូលែនពូកែណាស់ ស្រីៗណាដែលបានទៅដល់ តែសតិមិនរឹង ដល់ត្រឡប់មកវិញច្រើនតែធ្វើទុក្ខអីចឹង ។

ប៉ុន្តែ ស៊ី ឈឿន និយាយលើកទឹកចិត្តនាងទៅវិញ

- គួរឱ្យអាណិតណាស់ ! មិញនឹងប្រហែលជាខឹងនឹងខ្ញុំខ្លាំងហើយមើលទៅ ! មិនអីទេ បើនាងឈប់ចូលផ្ទះសាធារណៈនោះទៀតហើយ ទ្វារផ្ទះរបស់ពួកយើងនឹងបើកជូននាងដោយរីករាយ ។ បើរូបនាងត្រូវទៅគេងនៅបាតស្ទឹង រូបរបស់ខ្ញុំក៏សុំកុំឱ្យមានជីវិតតទៅទៀតដែរ ។

នាងផ្ដេកក្បាលទៅលើទ្រូង ស៊ី ឈឿន អរគុណនឹងសំដីដ៏ត្រជាក់ចុងក្រោយនេះ ។ នាងទន់ខ្លួនអស់កំលាំងណាស់ទៅហើយដោយវិលវល់តប់ប្រមល់ខំប្រឹងទប់ខ្លួនទប់ចិត្តតាំងអំពីថ្ងៃរសៀល នាងទន់ជង្គង់ស្រុតខ្លួនដល់ដីនៅនឹងជើងសង្ហារកំសត់ ។

អស់លោកឯទៀតឆោឡោ លោកប្រុសបីត្រកងនាងឡើងទៅលើផ្ទះដាក់នៅលើគ្រែ យកប្រេងកូឡា ប្រេងខ្យល់កោសរឹតឱ្យដោយថ្នាក់ថ្នម ។ ពូញ៉ឹបគ្រវីក្បាល គាត់អត់និយាយមិនបាន

- អ្នកស្រីខ្ញុំអើយ ខ្ញុំសង្ស័យថាមុខជាមិនស្រួលខ្លួនដែរ ព្រោះឃើញមុខកាន់តែស្លាំងឡើងៗនៅពេលដែលយើងកាន់តែជិតមកដល់សៀមរាបវិញ ។ នេះបានពេញជាហៅថាស្រឡាញ់មែន !

ស៊ី ឈឿន ញញឹមទៅរកពូញ៉ឹប ។ គ្រប់គ្នាក៏គិតដូចពូញ៉ឹបដែរ ។ គេចាត់គ្នាឱ្យដាំបបរ ឱ្យដុតត្រីងៀត ឱ្យរៀបចំបាយទឹក ។

ស៊ី ឈឿន អង្គុយលើគ្រែកំដរស្រីយ៉ាហានដែលមិនទាន់ដឹងខ្លួននៅឡើយ ប៉ុន្តែដូចជាស្រស់មុខមាត់បន្តិចឡើងវិញ ។ រហាត់ទឹកនៅតាមមាត់ស្ទឹងហូរតិចៗក្រោមពន្លឺព្រះច័ន្ទ ។ ភ្នែកយ៉ាហានបើកឡើងវិញ ប្រទះនឹងសម្រស់ទឹកមុខបុរសដែលនាងប្រាថ្នាទាំងអស់សង្ឃឹម

- បងអញ្ជើញទៅញ៉ាំបាយចុះ បងឯងឃ្លានបាយហើយកុំរវល់នឹងអូនអី អូនគ្រាន់តែអស់កម្លាំងប៉ុណ្ណឹងទេ អូនឥតឈឺអ្វីទេណាបង ។

សំដីហ្នឹង សម្លេងហ្នឹង ជ្រាបចូលជ្រៅទៅក្នុងបេះដូង ស៊ី ឈឿន

- បងមិនទាន់ឃ្លានទេ គេកំពុងតែរៀបចំហើយ អូនញុំាបាយបបរឬ ? បងឱ្យគេដាំប្រហែលជាជិតឆ្អិនហើយ ។

នាងញញឹម ទឹកភ្នែករលីងរលោង

- បងធ្វើឱ្យអូនរឹតតែស្រឡាញ់ រឹតតែរពួក មិនដឹងជាអូននឹងអាចរស់នៅឆ្ងាយអំពីបងយ៉ាងដូចម្ដេចកើតទេ !

- គង់តែយើងនឹងបាននៅនៅជិតគ្នាទេ អូនទ្រាំបន្តិចទៅ

- បើនៅជាមួយនឹងបង អូនចេះតែមានកំឡាំងអាចធ្វើអ្វីកើតទាំងអស់ ។ បើឥតអំពីបងទៅ អូនមិនដឹងជានឹងយ៉ាងដូចម្ដេចទេ !

យ៉ាហានខំក្រោកឡើង

- អូនទៅរៀបបាយជូនបង

ស៊ី ឈឿនឃាត់នាង

- អូនគេងចុះមិនអីទេ មានគេធ្វើច្រើននាក់ហើយ ។ នាងរត់ទៅផ្ទះបាយជួយចាត់ចែងរៀបចំម្ហូប ។

ពេលបាយបបរចុងក្រោយបំផុតនេះ គួរឱ្យលន្លង់លន្លោចណាស់ មានការផ្ដាំផ្ញើនឹងគ្នាទៅវិញទៅមកជាច្រើន ពីព្រោះសមាជិកនៃក្រុមនេះទាំងមូល មានការជិតស្និទ្ធដឹងចិត្តគ្នាគ្រប់គ្រាន់ ។ យ៉ាហាន ត្រូវនៅសំណាក់ជាបណ្ដោះអាសន្ននឹងផ្ទះលោកឆាំសិន ទំរាំ ស៊ី ឈឿនរៀបចំសម្រួលកិច្ចការឯភ្នំពេញរួច នឹងផ្ដាំឱ្យលោកសុតជូននាងទៅតាមក្រោយ ។ នាងនីបានទៅយកសំពត់អាវយ៉ាហាន អំពីផ្ទះចៅកែអារ៉ុមប្រគល់ឱ្យមិត្រនារីឯនេះអស់ហើយ ។ បើមានការអ្វីសូមឱ្យពួញីបនាំដំណឹងទៅជំរាបលោកឯភ្នំពេញផង ។

ញុំាបាយរួច យ៉ាហាន អង្វរសង្សារឱ្យទៅលេងមាត់ស្ទឹងជាមួយនឹងនាង ។ នាងថើប នាងឱប នាងរឹតប្រុសបងមិនចេះចប់

- អូនពិបាកចិត្តអ្វីម៉េះទេ ! អូនមិនដែលស្មានថា អូនអាចស្រឡាញ់ជាប់ចិត្តនឹងអ្នកណាដល់ម្ល៉េះឡើយ ។ បងអញ្ជើញទៅ បងមាននឹកអូនខ្លះទេ ?

- បើអូននឹងបងយ៉ាងណា បងក៏នឹកអូនយ៉ាងនោះដែរ

- សុំបងកុំភ្លេចអូនណ៎ា ! អូនមានទីពឹងតែលើបងមួយទេ ពីព្រោះអូនលែងជាម្ចាស់លើខ្លួនឯងហើយ ។ ចិត្តរបស់អូនវាស្ដាប់បង្គាប់តែរូបបងមួយទេ បងជាម្ចាស់

របស់វាហើយអំពីថ្ងៃនេះទៅ បងអាចធ្វើអោយវាសប្បាយ ឱ្យវាកើតទុក្ខ ឬឱ្យឆ្កួតក៏បាន ណាំបងណាំ ។

ស៊ី ឈឿន អង្អែលថើបសក់ ថើបថ្ពាល់ ថើបបបូរមាត់នាងជិតស្និទ្ធជាយូរ ។

ក្រោយបន្តិចមក រថយន្ត ៤០៤ ថ្មីស្រឡាងរៀបចំបញ្ឆេះម៉ាស៊ីន នៅមុខផ្ទះលោកឆាំ មានពួកអស់លោកនៅរោបព័ទ្ធជុំវិញ ។ យ៉ាហានមុខស្រងូតឈរពិតខ្លួននឹងទ្វារឡានមិនអស់ចិត្តនឹងសង្សាររបស់នាង ។ រថយន្តបរចេញទៅបន្តិចៗ ដៃ ស៊ី ឈឿន នៅជាប់នៅឡើយនឹងដៃយ៉ាហាន អ្នកប្រុសអើតចេញមកលា ហើយដៃទាំងពីរក៏របូតចេញពីគ្នា ។

ជំពូក ៤

# រំចង់និព្វ

ប្រាំឆ្នាំកន្លងផុតទៅ ។ រាត្រីមួយម៉ោងប្រាំបីយប់នៅផ្ទះនាងច័ន្ទី ។

វិទ្យុបន្លឺសម្លេងភ្លេងរាំវន្តាន់នៅក្នុងបន្ទប់ទទួលភ្ញៀវ ។ ច័ន្ទីអង្គុយក្រពាត់ជើងនៅលើកៅអី "សាឡុង" បើកមើលទស្សនាវដ្ដី "ភាពយន្ត" ទាំងកំរោលសង្កេតមើលរូប យូរៗ យកម្រាមដៃបើគ្រវាត់ទំព័រមួយចេញឮប្រាវៗ ស្ទើរតែដាច់សន្ធឹក រួចគ្រវាត់ចោលទៅលើតុវិញ ក្រោកឈរសម្លឹងទៅក្រៅតាមមាត់បង្អួចដែលចំហ ហើយបញ្ចេញវាចាមិនសប្បាយចិត្ត

- យីស ! លោក ស៊ី ឈឿន ហ្នឹងឥឡូវធ្វើស្រេចតែនឹងក្បាលចិត្តតែម្តង ចង់ទៅណាក៏ទៅទៅ ចង់ចូលផ្ទះថ្មើរណាក៏ចូលមក !

ម្ដាយនាងដែលកាច់បាយសីនៅជិតនោះដែរ ក៏ឆ្លើយផ្ទុញផ្ទាលអោយ

- អញប្រាប់ហើយថា កុំឲ្យផ្ទុញផ្ទាលជម្រុញឲ្យវាដើរលេងពេកក្រែងវាទៅតាមពាក្យ ឥឡូវបែបរកកលត្រូវដូចអញ ថាមែន !

ច័ន្ទី ទន្រ្ទាំជើងអុកគូថទៅលើកៅអីវិញ

- ខ្ញុំធុញនឹងម៉ាក់ឯងណាស់ ! ... បើគ្មានអ្នកណាស្រឡាញ់ខ្ញុំក៏ហីទៅ ប៉ុន្តែ "មីសំផឹង" ណាហ្នឹងវាគង់តែផឹងដៃខ្ញុំទេ ! ក្រែងតែផែនដីគ្របមុខច័ន្ទី ទើបហាងឯងរួចខ្លួន

ម៉ាក់មីងគាត់ភ័យគាត់ណាស់ ប្រឹងហាមប្រាមទៅកូនស្រី

- នែ ! មីនាងឯងមិនមែនធ្វើដូចគេកើតទេណា៎ !

- ម៉ាក់ឯងកុំមើលងាយខ្ញុំពេក ខ្ញុំធ្វើអ្វីក៏កើតទាំងអស់ ចំពោះមីហាងណាដែលវាហ៊ានលួចគូដណ្ដឹងរបស់ខ្ញុំ ។ ប៉ុន្តែ ខ្ញុំរកមុខវាមិនទាន់ឃើញច្បាស់ទេតើ ! ។

- ឮសូររថយន្តមួយឈប់នៅមុខផ្ទះ បន្តិចមកកណ្ដឹងនៅក្នុងផ្ទះរោទិ៍ឡើងជាសញ្ញាគេចុចហៅពីខាងក្រៅ ។ ក្មេងបំរើម្នាក់រត់ចេញទៅ ។ ច័ន្ទីឆ្វេឆ្វារៀបឫកដើម្បីរង់ចាំបងជីដូនមួយប្រុសចូលមកដល់ ។ ក្មេងបំរើរត់ចូលមកវិញទៅជំរាប ម៉ាក់មីង

- លោក អ៊ុំ មានលោកម្នាក់ថាឈ្មោះ "សែប" ចង់សុំជួបនឹងលោកអ៊ុំ

ច័ន្ទីគ្រវីក្បាលមុខក្រញូវឡើងវិញ

- នៅតែមិនទាន់មកដល់ទៀត ! មើលទៅដល់ភ្លឺហើយយប់ហ្នឹង !

ម៉ាក់មីងនឹងឆ្ងល់ណាស់ ពីព្រោះគាត់មិនដែលស្គាល់លោកណាឈ្មោះសែបសោះ យប់ថ្មើរនេះផងដូចជាគួរឲ្យបារម្ភដែរ ។ ច័ន្ទីហូតយកកាំភ្លើងតូចអំពីហោប៉ៅយួរមួយដាក់ក្នុងហោប៉ៅខោហើយស្រែកប្រាប់ទៅក្មេងបម្រើវិញ !

- ឯងបើទ្វារឲ្យគេចូលមកចុះ ។

រថយន្ត "រ៉ូឡែរ" មួយធំចង្គ្រាងបើកចូលមកឈប់ទល់នឹងមាត់ទ្វារផ្ទះខាងក្រោម ។ បុរសម្នាក់មានឧតំដើរចូលមកដោយឥតញញើតញញើម ហើយជំរាបសួរលោកអ៊ុំស្រីនិងអ្នកនាងច័ន្ទីដោយក្បោះក្បាយ ។ គឺជាមនុស្សចំណាស់ប្រហែល ៣៥ឆ្នាំ ឫកពាជាអ្នកធំស្លៀកពាក់ខ្ញង់យ៉ាងទំនើប ។ ច័ន្ទី អញ្ជើញលោក "សែប"ឲ្យអង្គុយកៅអី "សាឡុង" ដាក់បារី ឈើគូសហើយ ថយទៅអង្គុយលើកៅអីចំពីមុខដោយប្រុងប្រយ័ត្ន ចំពោះកាយវិការគ្រប់នាទីរបស់បុរសនោះហើយផ្ដើមសួរឡើង

- លោកអញ្ជើញមកមានការអ្វីដែរ ។

- បាទ ! ខ្ញុំមកនេះដូចជាអៀនខ្លួនបន្តិច ពីព្រោះមិនមែនជាការផ្ទាល់ខ្លួនទេ ។
ប៉ុន្តែខ្ញុំធ្លាប់ស្គាល់អ្នកនាងដែរដោយធ្លាប់បានឃើញ
អញ្ជើញទៅរាំលេងញយៗឯវង្គសាល "សេហេ" ជាមួយនឹងបងអ្នកនាង លោកអធិការ ស៊ុ ឈឿន។

- ចាស អីចឹងមែន ! ប៉ុន្តែខ្ញុំដូចជាមិនបានចំណាំមុខលោកសោះ

- ខ្ញុំធ្លាប់បានឮខ្លះដែរថាលោក ស៊ុ ឈឿនជាគូដណ្តឹងរបស់អ្នកនាង ។ អ្នកនាងនឹងលោកពេញជាសមនឹងគ្នាណាស់ពីព្រោះពូជពង្សខ្ពង់ខ្ពស់ដូចគ្នា...

ច័ន្ទីចាប់អារម្មណ៍មួយរំពេច ចំពោះចំណុចខ្សោយរបស់នាង ។ ត្រូវបានឮគេសរសើរថាពូជខ្ពង់ខ្ពស់ក៏ដូចជារកកលចង់ហើបជើងផុតពីដី ។ លោកក៏ចម្លែកនោះចេះនិយាយណាស់ មិនសូវប្រញាប់ប្រញាល់អ្វីទេ គាត់បន្ទុយពាក្យមួយម៉ាត់ៗ ហើយចាំសង្កេតមើលចម្លើយអំពីទឹកមុខរបស់នារី ។ លុះឃើញច័ន្ទីសម្លឹងមករកគាត់ដោយយកចិត្តទុកដាក់គាត់ក៏បន្តទៅទៀត

"... ប៉ុន្តែខ្ញុំដូចជាគួរឲ្យនឹកឆ្ងល់ រកគិតពុំយល់ដោយឃើញលោក ស៊ុ ឈឿន ទម្លាក់សាច់ចោល
ហើយស្រវាទៅយកស្រមោល ទៅវិញ" ។

ច័ន្ទី នឹងឆ្ងលក្នុងចិត្ត ចំណែកឯលោកភ្ញៀវនោះវិញក៏ស្រាប់តែឈប់ត្រឹមនោះសិន ឆ្មៀតសុំទោសនាងស្រីហើយឱនទៅហូតយកបារីមួយពីក្នុងកញ្ចប់ ដែលដាក់នៅក្នុងពានព្រាក់នៅលើតុ រួចគាន់គូសឈើគូសអុជតាមសម្រួលបីផ្សែងយ៉ាងវែង ហើងអង្គុយចោលយ៉ាងខ្ពស់ ។ ច័ន្ទីនឹងឆ្ងលក្នុងចិត្ត រង់ចាំដោយតក់ក្រហល់នូវសេចក្តីបន្ថែមទៅលើរឿងដែលធ្វើឲ្យនាង រមួលពោះរៀនអស់មួយយប់ទៅហើយ ។ លុះឃើញលោកនោះនៅតែមយឺមយាទៀត នាងក៏សួរបង្ខំថា ៖

- រឿងរបស់លោកចប់តែប៉ុណ្ណេះហើយឬ ? បើមានតែប៉ុណ្ណឹងទេ ដូចជាគ្មានអ្វីចម្លែកឡើយ ពីព្រោះខ្ញុំក៏បានដឹងរឿងហ្នឹងដែរ ។

លោក “សែប” ធ្វើជាអស់សំណើចតិចៗ ហើយនិយាយតទៅទៀត

- បើដូច្នោះ អ្នកនាងបានស្គាល់គូប្រជែងរបស់អ្នកនាងច្បាស់ណាស់ហើយឬអ្វី ? ខ្ញុំកោតតែអ្នកនាងអត់ទ្រាំបានទេ ! គេកំពុងតែសប្បាយ អ្នកនាងកំពុងតែកើតទុក្ខ ។ គេមុខរីក ចិញ្ចាច អ្នកនាងគិតតែពីក្រៀមក្រំ ។

សំដីនេះប៉ះចំទៅលើកន្លែងឈឺរបស់ច័ន្ទី ដែលច្រឡោតភ្នាម

- លោកស្គាល់ស្រីនោះច្បាស់ណាស់ទៅឬអ្វី ?

លោក “សែប” លើកដៃទាំងពីរទៅលើរបៀបជាហួសចិត្ត

- ប្រុសណាក៏ស្គាល់ស្រីហ្នឹងដែរ អ្នកនាង ! វាដើរលក់រាយអស់ចិត្តនៅសៀមរាប ខ្ញុំកោតតែលោក ស៊ុ ឈឿន ដាច់ចិត្តបន្ថោកខ្លួនទៅយកស្រីសំណល់ពីគេនោះមកធ្វើជាបណ្តូលចិត្តទេ !

លោក “សែប” សង្កត់ពាក្យឲ្យសមនឹងចិត្តកំរោលរបស់គាត់ដែលនៅតុំជាប់ជានិច្ចនឹងចៃចង់អារ៉ុមមិនដោយ ។

ច័ន្ទីកាន់តែស្ទុះស្អាប់ក្នុងខ្លួនពេកណាស់ ។ រឿងនេះវាដូចជាសមនឹងសេចក្តីស្មានរបស់នាងមែន ។ ក្នុងប៉ុន្មានឆ្នាំក្រោយនេះ ស៊ុ ឈឿន មិនសូវនៅផ្ទះសម្បែងសោះ ចេះតែមានការទៅនៅខាងក្រៅ ម្តងថាគេអញ្ជើញទៅជប់លៀង ម្តងថាជាប់ទៅស៊ីការគេ ជួនកាលថាត្រូវទទួលអស់លោកមកពីខេត្ត ថាត្រូវទៅជួយមើលខុសត្រូវចំពោះទីកន្លែង ដែលត្រូវរៀបចំឲ្យគេនៅ គិតទៅស្ទើរតែរាល់យប់មិនសូវដែលបាននៅផ្ទះទេ ។ ឯការសម្រេចពីរឿងគូស្រករវវាងនាងនិងអ្នកក៏ដូច ជាលែងឮនឹងនាសោះ ។ ពីមួយខែទៅមួយខែ ពីមួយឆ្នាំទៅមួយឆ្នាំ រឿងនេះគ្មានការបោះជំហានទៅមុខសោះ មានតែដើរថយក្រោយវិញផង !

ចន្ទីក្រៅឈរជ្រែងហោប៉ោខោ ទៅច្រត់ដៃនៅនឹងមាត់បង្អួចនឹកឃើញតែអំពីរឿងសងសឹក រកកលនឹងភ្លេចថាមានបុរសកំណាចម្នាក់ នៅអង្គុយសង្កេតមើលដោយចេតនាទូវរាងរូវមូលក្លំពីក្រោយរបស់នាង ដែលធ្វើឲ្យប្រុសនោះក្តៅសាយសព្វសាច់ដល់ចុងជើង ។ មួយនាទីក្រោយមកនាងបែរខ្លួនផាំងមកវិញហើយបោះសំដីថា ៖

- លោកដឹងថាស្រីនោះនៅឯណាទេ ?

- ខ្ញុំជាអ្នកធ្វើការខាងស៊ើបអង្កេតរមែងតែបានដឹងខ្លះដែរចំពោះរឿងអាថ៌កំបាំងរបស់ជនភាគខ្លះ ។

- លោកជូនខ្ញុំទៅជួបនឹងវាឥឡូវនេះបានឬទេ ?

ម៉ាក់ម៉ុងស្ទុះក្រោកឡើង ទាញដៃកូនស្រីទៅខ្សឹប

- នែ ! មីទូច ! យប់ថ្មើរនេះ ! ចង់ទៅណា ? ម្តេចក៏ឆាប់ទៅទុកចិត្តលើលោកអីគេហ្នឹង ដែលឯងមិនដែលស្គាល់សោះនោះ! អញមើលទៅឫកពាគាត់ ដូចជាមិនសូវឲ្យកក់ក្តៅអ្វីសោះ !

- ខ្ញុំគ្មានខ្លាចអីទេម៉ាក់ ! ម្ល៉េះទៅហើយ ! ឲ្យតែបានសងសឹកនឹងមីឈាមរាវដែលវាហ៊ានលួកថ្មើមប្រមាត់ខ្ញុំ, ដើម្បីឲ្យអា "តាប៉ិ" ឈឿនហ្នឹងក្ទួតឈាមនឹងមី "ខ្ញី" ម្តងវិញ !

លោក "សែប" ធានាជូននាងទៅ ឯនាងវិញក៏ដាច់ចិត្តទៅជាមួយនឹងមនុស្សមិនដែលស្គាល់នោះ ដោយមិនចាំបាច់ឲ្យអ្នកណាទៅជាមួយទាំងអស់ ។ ទាំងពីរនាក់ជិះឡានទន្ទឹមគ្នានៅខាងមុខ ។ រថយន្តចេញរឹងទៅតាមផ្លូវពោធិចិនតុងបរទៅហួសវាលយន្តហោះ ហួសផ្លូវបែកទៅកំពតនិងកំពង់ស្ពឺ ។ ច័ន្ទីដែលប្រាស់ប្រាល់ចង់តែឃើញមុខគូសត្រូវឆាប់ៗ ចេះតែតឿនសួរដោយមិនទុកចិត្តថា

- មីហ្នឹងវានៅឯណា ? ម្តេចលោកបើកមកឆ្ងាយម្ល៉េះ ? លោកបានប្រាប់ខ្ញុំថាវានៅក្នុងភ្នំពេញទេ ឥឡូវម្តេចហួសពោធិចិនតុងទៅទៀត

លោកនោះងាកមកញញឹម កាច់រាងដាក់

- យើងជិះលេងបន្តិចសិន អ្នកឯងកុំប្រញាប់ពេក បើទោះជាយ៉ាងណាក៏បងមិនឲ្យអ្នកឯងខកចិត្តដែរ ។

ច័ន្ទី នឹកខ្ចល់នឹងសំដីរំលោភមើលងាយភ្នាមៗ របស់លោកតម្រាំងចៃតនេះ ប៉ុន្តែនាងប្រុងស្មារតី ដើម្បីចាត់ការសំខាន់ឲ្យបានសម្រេចសិន ហើយខំប្រឹងវាចាដោយស្រួលទៅកាន់លោក "សែប" វិញ

- បើលោកអាចបង្ហាញភ័ស្តុតាង ឲ្យខ្ញុំឃើញច្បាស់ពិតប្រាកដក្នុងល្ងាចនេះ ខ្ញុំនឹងជឿសំដីលោក បើពុំដូច្នេះទេ ខ្ញុំសន្មតថារឿងរបស់លោកនេះ ជាការប្រឌិតគ្រាន់តែឲ្យខូចឈ្មោះរបស់បង សីឈឿន របស់ខ្ញុំប៉ុណ្ណោះ

សំដីនេះធ្វើឲ្យលោក "សែប" ភ័យខ្លួននឹកថា វរៗរបួតទាំងត្រីទាំងទន្សាយ ទើបគាត់ប្រឹងកែសម្រួលថា ៖

- អ្នកឯងកុំប្រញាប់ពេក បើទោះជាយើងទៅដល់កន្លែងនោះថ្មើរនេះក៏សហាយទាំងពីរនោះ គេមិនទាន់មកជួបគ្នាដែរ នាំឲ្យតែបែកការធ្វើឲ្យគេដឹងខ្លួន ហើយឲ្យខូចបំណងរបស់យើងជាមិនខាន ។

ច័ន្ទីត្រូវទ្រាំទទួលឲ្យលោក "សែប" ហៅអ្នកពេញមាត់ នឹកទៅគួរឲ្យរឹងរឹតតែនឹង "មីសំពីង" ដែលលួចប្រុសគេ ។ មិនតែប៉ុណ្ណោះលោក "សែប" ចេះតែលៃកេះកៀវ បន្តិចប៉ះដៃបន្តិចប៉ះស្មា យូរៗរកកលចង់សសៀរមកកៀកកទៀត ។

ក្នុងពេលរាត្រីដំណាលគ្នានោះ ចំណែកនៅខាងមាត់ទន្លេវិញកុងតាមតិរវិថីព្រះស៊ីសុវត្ថ បបរសណ្តែកឮគ្រលួចរវែងល្វើយពីផែមួយទៅផែមួយ ។ ភ្លើងជ្រោយចង្វាភ្លឺព្រិចៗបន្តិចៗ គេឮសន្ធឹកម៉ាស៊ីន "គ្រុយ" លើកឥវ៉ាន់ចេញអំពីឃ្លុបនាវាសមុទ្រពីរ ដែលបោះកយុថ្កាចតទ្រឹងសន្ធឹងកណ្តាលទន្លេ កំពុងរើទំនិញទាំងយប់លើកផ្ទុកមកក្នុងកប៉ាល់ និងទូកប៉ុកចាយដែលនៅចតអមចាំទទួល ។ ភ្លើងឡានរត់ប្រដេញគ្នាតាមមាត់ច្រាំងភ្នំពេញ ជួនកាលឃើញដូចជាហើរឡើងតាមស្ពានឆ្លងទៅជ្រោយចង្វា ។ វាយោនាំសួរចង្វាក់ប្រគំតន្ត្រីសែនពីរោះ

ហាក់ផុសអំពីផ្ទៃទឹកអណ្ដែតឡើងមកអំពីស្ថានភុជង្គនាគ ។ គឺជាសម្លេងវង់ភ្លេងសម័យនៃភោជនីយដ្ឋានទឹក "វិចង់ទិញ" ដែលកំពុងតែបំពេញចិត្តភ្ញៀវធ្វើឲ្យមានសូរទះដៃរំពងនៅពេលបញ្ចប់បទនីមួយៗ ។ សភាពនៅក្នុងភោជនីយដ្ឋានគួរឲ្យចាប់ចិត្តគ្រប់កន្លែង មានរបៀបតុបតែងរុក្ខជាតិធ្វើឲ្យទឹកស្មានថាដូចជានៅក្នុងព្រៃព្រឹក្សា មានផ្កានិងដើមចេកស្រស់ល្វតលាស់បាំងសសរ ។ ចង្កៀងពណ៌ភ្លឺស្រគាំ បង្ហាញអ្នកច្រៀង ដែលឈររាំខាងមុខវង់តន្ត្រីនៅក្នុងខ្នមកំសត់ ដែលហាក់ដូចជាកើតឡើងដោយនិមិត ។ មានភ្ញៀវអង្គុយពេញស្ទើរតែគ្រប់តុ អ្នកបំរើរត់ម្នីម្នាចុះឡើងបំពេញចិត្តឲ្យបានគ្រប់កន្លែង ។

បន្តិចក្រោយមក មកដល់បទ "សម្ផស្សបុប្ផព្រៃភ្នំ" គេឃើញនារីម្នាក់សក់វែងរលូនជិតដល់ចង្កេះ រូបរាងល្អស្រឡះ តាក់តែងកាយសមចម្លែកដោយសំពត់និងអាវហូលពណ៌ស្រស់រឹតរាងចង្កេះរៀវក្លំ ដើរចេញរម្យទមអំពីខាងក្រោយឆាកតន្ត្រីមកចាប់ហ្វូតមីក្រូអំពីជើងទ្រហើយផ្ដើមចម្រៀងដោយទឹកមុខប្រិមប្រិយ ។ ភ្ញៀវទាំងអស់ភ្លេចទទួលទាន ដាក់កែវសមស្លាបព្រាគ្រប់ៗគ្នា យកចិត្តទុកដាក់ចំពោះតួអ្នកច្រៀងដែលទើបនឹងចេញមកដល់ ។ សម្លេងនាងអណ្ដែតម្ញូលពីរោះ ស្ដាប់ទៅមានសភាពយោលស្រោល ធ្វើឲ្យស្រមៃឃើញដូចជានាងកំពុងតែយោលទោងលេងល្ងើយៗ ក្រោមខ្យល់ត្រសៀកសែនសប្បាយដូចនៅក្នុងបទចម្រៀង ។ មុខនាងនៅក្មេងប្រហែល ១៨-១៩ ឆ្នាំ បបូរមាត់ក្រហមខ្ចី សើចខ្ទបឃើញធ្មេញល្អចិញ្ចាចភ័ក្ត្រស្រស់ហាក់ដូចជាគ្មានអ្វី នឹងអាចមកធ្វើឲ្យនាងកើតទុក្ខបាន ។ នាងច្រៀងបណ្ដើរ គយគន់ទៅគ្រប់តែតុភ្ញៀវបណ្ដើរ ហាក់ដូចជាពេញចិត្តនឹងមនុស្សគ្រប់គ្នាទាំងអស់ ឬក៏មានបំណងនឹងរកស្វបណាមួយដែលនាងមិនទាន់ឃើញមកដល់ ។ ច្រៀងៗទៅ មុខនារីនោះដូចជាកាន់តែក្រៀមក្រំទៅវិញបន្តិចម្ដងៗ ហើយប្រែជាបែរទៅមើលទឹកទន្លេធ្វើព្រងើយ ហាក់ដូចជាលែងចង់ឃើញអ្នកឯណាទៀតហើយ។

ភ្ញៀវទាំងអស់រកកល់ចង់ភ្លឹក ម្នាក់ៗប្រហែលជាបន់ឲ្យមានសំណាង នឹងបាននាងញញឹមមករកម្ដង ។

ស្រាប់តែឮស្នូរជើងមនុស្សច្រើននាក់ទើបនឹងដើរចូលមកដល់ក្នុងភោជនីយដ្ឋាន ។ នារីចម្រៀងក្រឡេកមើលទៅតាមស្នូរចម្លែកនោះ នាងសម្លឹងមើលតាម... យូរបន្តិច ហើយប្រែទឹកមុខជារីថ្លាឡើងវិញ ។ នាងចោលភ្នែកជាប់ទៅលើអ្នកដែលទើបនឹងមកដល់ ស៊ុ ឈឿនដើរមុខ លោកសុត លោកថៃ និងពូញ៉ឹប ចូលបន្ទមកតាមក្រោយ ។ ទាំងអស់គ្នាចូលទៅអង្គុយផ្លូវខាងក្រៅជិតមាត់ទឹក នៅតុទីបីបន្ទាប់ពីខាងមុខ ។ ស៊ុ ឈឿន អង្គុយបែរចំទៅរកឆាក ។ ចម្រៀង "សម្ផស្សបុប្ផាព្រៃភ្នំ" បន្តទៅទៀតយ៉ាងពីរោះ ហើយបញ្ចប់ក្រោមស្នូរទះដៃលាន់ទ្រហឹងជាប់យ៉ាងយូរ ។ ភ្ញៀវទុកថ្មីអបអរសាទរខ្លាំងជាងគេ ចំណែកឯអ្នកចម្រៀងក៏ដូចជាមិនដែលបានត្រេកអរអ្វីឲ្យខ្លាំងជាងនេះដែរ តាំងពីក្បាលព្រលប់មក ។ បោយពីរនាក់ចូលមកដល់ភ្ញៀវទុកថ្មី ស៊ុ ឈឿន ហៅម្នាក់មកប្រាប់ថា "ឲ្យខ្ញុំសុំបទមួយអំពីនាងដែលទើបនឹងច្រៀងរួចអម្បាញមិញ" ។

បោយបញ្ជាក់សួរលោកវិញ

- ឲ្យច្រៀងបទអ្វី តេជះគុណ ?

- បទអ្វីដែលនាងពេញចិត្តជាងគេ គ្រាន់តែប្រាប់ថាភ្ញៀវចំការដូងឲ្យសុំមុខជានាងយល់ហើយ ។

បោយបោលយ៉ាងលឿនទៅដល់ទាន់ចិត្ត ។ តន្ត្រីចាប់ប្រគុំគ្រប់គ្នាប្រុងចាំអ៊ុតថា តើនាងនឹងច្រៀងបទអ្វី ? នាងហួតមីក្រូឡើងសាជាថ្មី ចម្រៀងស្រណោះ "ចំការសំរោង" ក៏អណ្ដែតឡើង ។ ភ្ញៀវតុថ្មីពេញចិត្តណាស់នាំគ្នាទះដៃឡើងប្រាវ នាំភ្ញៀវឯទៀតឲ្យទះតាមដែរ ។ ឯនារីចម្រៀងក៏ងាកញញឹមមកចំតួឯកនៅតុទីបី ។

ច្រៀងរួចសឹងតែមិនទាន់ នាងចុះតម្រង់មករកតុនោះសំពះសួរលោកសុត និងលោកថៃ ដោយរាក់ទាក់ ។ ពូញ៉ឹបជំរាបសួរសុខទុក្ខនាងដោយស្និទ្ធស្នាល ។

រមែងលបសរសើរក្នុងចិត្តថា លោកគ្រូរបស់នាងពិតជាជំនាញសព្វគ្រប់មែន ធ្វើឲ្យសិស្សឆ្លួតចិត្តអស់រលីង !

ល្ងាចនេះដោយបានជួបជុំគ្នា យ៉ាហានមិនទាន់វិលទៅផ្ទះវិញនៅវេលាម៉ោងដប់យប់នេះទេ ។ លុះចប់ភារៈរបស់នាងជាអ្នកចម្រៀងហើយ នាងក៏ក្លាយទៅជាភ្ញៀវដូចគេឯង មកនៅអង្គុយកំដរប្រុសសម្លាញ់របស់នាង ជាមួយនឹងមិត្តជិតដិតឯទៀតដែលទើបនឹងមកដល់ពីសៀមរាបថ្ងៃមិញ ។ ល្ងាចនេះ យ៉ាហានបានត្រូវប្រញាប់បន្តិចផងពីព្រោះថ្ងៃស្អែកត្រូវប្រឡងសាកល្បងខាងគណនេយ្យ... ។

លោកសុតដែលបានដំណឹងនេះអំពីលោក ស៊ី ឈឿន កាលពីថ្ងៃដែរ ក៏បន្ទយពាក្យទៅនាងដោយដឹងទុក្ខធុរៈ

- បើអ្នកនាងរវល់ប្រឡងក្នុងថ្ងៃស្អែក
សុំកុំឲ្យអ្នកនាងទើសទាល់ អ្វីនឹងពួកយើង
សុំអ្នកនាងអញ្ជើញទៅមុនជាមួយនឹងលោកប្រុសមុនចុះ
ពីព្រោះពួកយើងជាអ្នកស្រែចូលក្រុង មុខជាសុំនៅយូរបន្តិចហើយ ។

ស៊ី ឈឿន សម្រេចថា ៖

- ព្វញ៉ីបងឯងយកឡានជូនខ្ញុំទៅផ្ទះ យ៉ាហាន សិន សឹមត្រឡប់មកវិញ ។ ល្ងាចនេះសុតឯងទុកឡានខ្ញុំប្រើប្រាសចុះ ឲ្យតែជិតភ្លឺយកទៅឲ្យខ្ញុំនៅឯផ្ទះ យ៉ាហាន វិញ ។

លោត សុតប្រកែកថាមិនអីទេ ប៉ុន្តែ ស៊ី ឈឿន ចេះតែប្រគល់ឲ្យ ។ អស់លោកសៀមរាបក៏ទទួលអបអរសាទរ នឹកក្នុងចិត្តថា “ចៅហ្វាយដឹងចិត្តកូនចៅបែបហ្នឹង មើលទៅប្រហែលជារកមិនបានទៀតឡើយ” ។

គេនាំគ្នាជូនលោកប្រុសនិងតារាឯក “រំចង់ទិព្វ” ទៅដល់ខាងលើ ។ ភ្ញៀវឯទៀតងាកតាមមើលដោយចាប់អារម្មណ៍ជាច្រើន ។

គ្រាន់តែឡាន ស៊ី ឈឿន ចេញទៅផុត ឡានលោក “សែប” ជូនចំនីមកដល់ល្មម ដូចជាគេលេងបិទពួន ។

លោក សុត ក្រឡេកអំពិចម្ងាយទៅ ស្គាល់មុខលោក “សែប” ហើយដូចជាចំណាំមុខថាស្រីដែលជិះជាមួយនោះប្រហែលជាប្អូនជីដូនមួយលោក ស៊ី ឈឿន ។ លោកសុតក្តុកក្នុងចិត្តនឹកសង្ស័យថាប្រហែលជាមានការអ្វីចម្លែកហើយមើលទៅ ក៏គេចខ្លួនទៅក្នុងកន្ទែងងងឹតមួយនឹងលោកថៃ ចាំពិនិត្យមើលព្រឹត្តិការណ៍ថ្មី ។ ឃើញច័ន្ទីបើកទ្វារចុះព្រួសពីលើឡានហើយដើរឆ្វេងឆ្វា ទៅសង្កេតមើលគ្រប់រថយន្តទាំងប៉ុន្មានដែលនៅចតជាជួរតាមមាត់ច្រាំង នៅមុខភោជនីយដ្ឋានទឹក “វិចង់ទិញ” ។ កិរិយានេះធ្វើឲ្យរឹតតែគួរឲ្យសង្ស័យទៅទៀត មិនបង្អង់យូរ ច័ន្ទី ចុះបណ្តើរសំដៅទៅកាន់ភោជនីយដ្ឋាន លោកសែបប្រឹងស្រូតទៅតាមក្រោយ ។

រឿងនេះដូចជាមិនស្រួលសោះ ! លោកសុតចាត់លោកថៃភ្លាមឲ្យទៅនៅចាំឯច្រកក្រៅ ចាំមើលពួញ៉ឹប ដល់ឃើញគាត់ត្រឡប់មកវិញ ត្រូវឃាត់គាត់កុំឲ្យយកឡានលោក ស៊ី ឈឿន ចូលមកខាងក្នុងឲ្យសោះ ហើយឲ្យលោកថៃ នាំគាត់គេចទៅឈប់ចាំឲ្យផុតភ្នែកនៅឯច្រកផ្លូវទីមួយខាងជើងភោជនីយដ្ឋាននោះទៅ ។

ចំណែកឯលោកសុត ខ្លួនឯងក៏ស្រូតទៅតាមក្រោយលោក “សែប” ដោយស្ងាត់ដើម្បីយកការ ។

លោកសែបនាំច័ន្ទី ទៅរកតុមួយអង្គុយនៅជិតភ្លេងហើយបក់ដៃហៅ “បោយ” មកសួរចុះសួរឡើងជាយូររួចគយគន់រកមើលគ្រប់តែតុ ។

បន្តិចមកឃើញ “បោយ” ចង្អុលទៅរកតុទីបីដែលពួកលោក ស៊ី ឈឿន ទើបតែនឹងដើរផុតទៅ ។

ទឹកមុខអ្នកទាំងពីរផ្លូមជាមួម៉ៅខ្លាំង ។ លោកសុតកាន់តែច្បាស់ការ យល់ថារឿងនេះអាចក្លាយទៅជាធំបាន ពីព្រោះមានអាមនុស្សខូចពីក្រៅម្នាក់ទៀត ដែលជាសត្រូវចាស់របស់ យ៉ាហាន បានមកចូលលាយឡំផង ។

< tr>

ចំនួនម្ភៃនាទីក្រោយមក រថយន្តលោកសែបនាំចំនួនចេញទៅវិញ ។ លោកសុតប្រញាប់ប្រញាល់ដើរទៅរកលោកថៃនិងពូញឹបដែលឈប់ឡានចាំនៅចំកន្លែង ដែលបានណាត់គ្នារួចមកហើយ ។ ទ្វារឡានបិទគ្រិបៗ ពូញឹបបញ្ឆេះរថយន្តបើកចេញវឹងសំដៅទៅក្រោយពេទ្យព្រះសង្ឃ ។

ផ្ទះយ៉ាហន ជាល្វែងថ្មជាន់ទីមួយខាងលើ ផ្លូលដាច់តែឯងមានចង្ក្រាននិងបន្ទប់ទឹកនៅខាងក្រោយ និងរានហាលស្រឡះនៅខាងមុខលំអទៅដោយដើងផ្កាជាច្រើន ។ តួផ្ទះធំតែងសំអិតសំអាងយ៉ាងវិចិត្រដោយរូបភាព និងគ្រឿងបុរាណផ្សេងៗ ។ នៅជិតមាត់ទ្វាររានហាលមានតុមួយផ្ទុកសៀវភៅពីរតំនរ ឈរចំមុខក្តារខៀនធំដែលព្យួរនៅជាប់នឹងជញ្ជាំង ។ បន្ទប់គេងស្អាតឆ្វង់ ប្រកបទៅដោយគ្រែពូកនិងមុងស្បៃថ្ងៃៗ ត្រូវស្នាដៃ យ៉ាហន រៀបចំស្រឡះស្រឡំ គួរឲ្យស្រឡាញ់សម្រាប់ផ្គាប់ចិត្តបុរស ដែលនាងថ្នាក់ថ្នមមិនដែលឲ្យមានថ្នាំងថ្នាក់ ។ គួរឲ្យស្ងើចនឹងស្ត្រីនេះដែលចំនួនបួនឆ្នាំមកហើយមិនដែលឲ្យលោកប្រុសព្រួយបារម្ភ បង្ហៀតចង្អុលអ្វីនឹងចំណាយឈ្នួលផ្ទះព្រមទាំងសោហ៊ុយតុបតែងចាយវាយផ្សេងៗ ដែលនាងសុំទទួលរ៉ាប់រងលើខ្លួនឯងទាំងអស់ ដើម្បីកុំឲ្យប៉ះពាល់ទៅដល់ប្រាក់ខែលោកប្រុស ដែលនាងចង់ឲ្យនៅពេញលេញគ្រប់ចំនួនរៀងរាល់ខែ ។ នាងសុខចិត្តយកកម្រៃប្រាក់ចម្រៀងរបស់នាងទាំងអស់មកទប់ទល់មុខចំណាយរបស់នាងទាំងប៉ុន្មាន ។

យប់នេះនិស្សិតយ៉ាហន ដែលបានប្រឡងជាប់មធ្យមសិក្សាប័ត្រទីមួយ ជិតពីរឆ្នាំរួចមកហើយ កំពុងពិនិត្យមើលសាដើមឡើងវិញនូវមេរៀនខាងវិជ្ជាគណនេយ្យដែលនាងត្រូវប្រឡងសាកល្បងក្នុងព្រឹកស្អែក ។ ស៊ី ឈឿន កំពុងសរសេរពន្យល់ថែមលើក្តារខៀននូវចំណុចសំខាន់ៗដែលត្រូវចាំ ។ យ៉ាហនពេញចិត្តនិងស្តាប់លោកគ្រូដែលប្រសប់ពន្យល់ធ្វើមេរៀនពិបាកឲ្យទៅជាងាយអស់រលីង ។ ស៊ី

ឈឿន ក៏ស្ងើចសរសើរការតស៊ូ និងប្រាជ្ញារៀងវៃនៃនិស្សិតកំសត់របស់ខ្លួនណាស់

< tr> - បងសុំសរសើរអូនឯងហើយ អូនឯងរៀនរហ័សណាស់ ។ កាលទើបនឹងមកដល់អំពីសៀមរាប អូនឯងគ្រាន់តែជាសិស្សចាស់នៃថ្នាក់ទីបីសោះ ! រៀនទាំងត្រដេត្រដរចំនួនបីឆ្នាំក៏ស្រោប់តែប្រឡងជាប់មធ្យមសិក្សាប័ត្រនឹងគេដែរ ឥឡូវនេះជិតចប់សាលាជំនួញទៅទៀតទៅហើយ ! រួចចុះនៅប៉ុន្មានខែទៀតទើបប្រឡងចេញ ?

- ចាំស ! ជិតណាស់ហើយបង ! នៅមិនដល់មួយខែទៀតផង អូនភ័យណាស់ !

- អូនកុំគិតច្រើនពេក ខំទេរៀងនៅ ។ បើជាប់ គិតទៅធ្វើអ្វី ?

- ចាំស ! អូនមិនដឹងជាទៅធ្វើអ្វីទេ ប្រហែលជាទៅរកការក្នុងក្រុមហ៊ុន ឯណាមួយហើយមើលទៅ ។

- មិនអីទេ ចាំបងជួយផ្តាំធ្វើនឹងគេឲ្យ ។

យ៉ាហានដាក់ "ស៊ីឡូ" នៅលើសៀវភៅ ហើយក្រោកទៅទាញដៃលោកប្រុសឲ្យមកអង្គុយជិត

- បងឯងមានគុណនឹងអូនច្រើនណាស់ អូនមិនដឹងជាមានអ្វីនឹងតបស្នងសងគុណបងទេ !

ស៊ី ឈឿន អោនទៅថើបថ្ពាល់ សរសៀវមកដល់ចង្កា នាងស្រវាឱប ឲ្យមាត់ទៅប្រុសសម្លាញ់ សង្សារទាំងពីររឹតរួតគ្នាមិនរសាយ ។ នាងក្អាញ់នឹងអ្នកប្រុស

- ម្តេចក៏បងឯងធ្វើឲ្យអូនស្រឡាញ់អីម្ល៉េះ ! មិនដឹងជាស្រឡាញ់ត្រង់ណាខ្លះទេ ! មុននឹងបានមកជួបនឹងបង អូនមិនដឹងច្បាស់ថាស្រឡាញ់នោះយ៉ាងដូចម្តេចផង ។

- អូនឯងភូតបងទេមើលទៅ អូនឯងធ្លាប់ដើរលេងជាមួយនឹងប្រុសៗដែរ និយាយយ៉ាងហ្នឹងឲ្យបងជឿម្តេចកើត !

- អូនធ្លាប់ដើរលេងមែន ប៉ុន្តែអូនធុញណាស់ជាមួយនឹងប្រុសទាំងនោះ ។ ដល់មកជួបនឹងបង បងឯងខុសគេណាស់ អូនដឹងថាចិត្តអូនមិនអាចរស់នៅឆ្ងាយអំពីបងកើតទេ... ។

ស្រាប់តែឮសូរគេគោះទ្វារខាងក្រៅតុកៗ ។ យ៉ាហាន ឈប់និយាយហើយប្រុសស្តាប់ "តុកៗ" ម្តងទៀត ។

ស៊ី ឈឿន សួរនាងថា ៖

"អ្នកណាហ្នឹង មានអ្នកណាធ្លាប់មកថ្ងើរហ្នឹង ឬ" ?

- ចាស ! ដូចជាចម្លែកដែរ ។

នាងចេញផ្ទមទៅបើបង្អើបទ្វារ ឯស៊ី ឈឿន ឈរអែបជាប់នៅខាងក្រោយនាង...

"អូ ! លោកទេ !" សម្លេងនាងលាន់ឡើង ទ្វារក៏បើកធំស្រឡះមួយរំពេច ហើយលោកសុតនិងលោកថៃចូលមកទ្រង់ប្រញាប់ប្រញាប់ ។

យ៉ាហានត្រេកអរណាស់ ប្រឹងអញ្ជើញលោកឲ្យចូលមកអង្គុយលេងក្នុង សាឡុង កណ្តាលបន្ទប់ ។

- អញ្ជើញចូលមកលោក ខ្ញុំមិននឹកស្មានថាឆាប់អញ្ជើញមកសោះមកវិញយ៉ាងហ្នឹងឡើយ ។

លោកទាំងពីរចូលទៅអង្គុយហើយ បេះតែឆ្មៀតសម្លឹងទៅរកស៊ី ឈឿន ដែលចាប់ឆ្ងល់បន្តិចដែរ ទើបធ្វើជាប្រើយ៉ាហានឲ្យទៅយក "ស្រាបៀរ" ពីរបីដបទៅរៀបចំកាប់ទឹកកកត្រាំឲ្យត្រជាក់នៅឯផ្ទះបាយ ។ យ៉ាហានម្ទីម្ទារធ្វើតាមបញ្ជាលោកប្រុស ។ លុះនាងចេញផុតទៅខាងក្រោយ លោកសុតនិយាយតិចៗជំរាបលោក ស៊ី ឈឿន តាមដំណើរពីដើមដល់ចុង ហើយបន្ថែមយោបល់ផ្ទាល់ខ្លួនថា ៖

"ខ្ញុំបាទយល់ថាមិនគួរឲ្យអ្នកនាង យ៉ាហាន នៅទៅច្រៀងឯភោជនីយដ្ឋាន "វិចង់ទិព្វ" តទៅទៀតទេ ពីព្រោះអាចឲ្យមានគ្រោះថ្នាក់ដល់ខ្លួន ! តេជះគុណគង់តែជ្រាបស្រាប់ហើយ អំពីគោលបំណង

របស់លោក "សែប"ក្តី និងចិត្តគំនិតរបស់អ្នកនាងច័ន្ទីក្តី ។ ខ្ញុំបាទដូចជាមានបារម្ភណាស់ !

ស៊ី ឈឿន ឆ្លើយទៅវិញ

- មិនអីទេ ខ្ញុំយល់ហើយ ប៉ុន្តែយើងគួរកុំឲ្យយ៉ាហានដឹងរឿងមិនល្អនេះ ដើម្បីកុំឲ្យវាមានព្រួយបារម្ភ ពីព្រោះជិតដល់ពេលប្រឡងចេញណាស់ទៅហើយ ។ ចំណែកឯរឿងធ្វើការនៅឯភោជនីដ្ឋាននោះមិនអីទេចាំខ្ញុំលៃលកពន្យល់យ៉ាងម៉េចឲ្យវាឈប់ទៅច្រៀងផង ហើយកុំឲ្យវាដឹងថាមានគេចង់ធ្វើបាបវាផង ។

លោក សុត មិនមែនបារម្ភតែចំពោះនាងយ៉ាហានប៉ុណ្ណោះទេ លោកដូចជាព្រួយណាស់ដែរ ចំពោះសន្តិសុខរបស់ចៅហ្វាយប្រុសជាទីស្រឡាញ់របស់លោក ។ ហេតុដូច្នេះហើយបានជាលោកសម្រេចចិត្តថា យប់នេះលោកមិននាំគ្នាដើរលេងទេ សុខចិត្តត្រឡប់មកទទួលទានដំណេកជុំគ្នាទាំងអស់នៅផ្ទះអ្នកនាងយ៉ាហាន ។ យប់នេះត្រូវបញ្ចូលឡានឲ្យផុតបាត់ទៅខាងក្រោយផ្ទះ កុំឲ្យទុកចោលនៅខាងក្រៅតាមចិញ្ចើមថ្នល់ដូចរាល់ថ្ងៃទៀត ។

នៅក្នុងបន្ទប់ចង្ក្រានខាងក្រោយ យ៉ាហានរៀបចំដាក់ចេះនៅក្នុងធុង កាប់ទឹកកកដាក់ជាច្រើន ហើយចាក់ទឹកចូលបន្តិចឲ្យឆាប់ត្រជាក់ រួចនាងដុតសាច់ងៀត សម្រាប់ឲ្យអស់លោកផ្ទាប់ជាមួយ "ស្រាបៀរ" ។ ក្លិនសាច់គោដុតដុចជាធ្វើឲ្យនាងឆ្ងើមប្លែកអំពីប្រក្រតី ។ នាងសង្ស័យថា ប្រហែលជាសាច់ងៀតនេះមិនសូវល្អប្រឹងយកមកពិនិត្យមើលឃើញស្អាតក្រហមឆ្អៅ ។ លុះនាងយកសាច់គោមួយដុំមកហិតមើលដូចជារឹតតែឆ្ងើមរកកលចង់ចង្អោរបណ្តាលឲ្យអស់កម្លាំងល្វើយមួយរំពេច ។ នាងនឹកថាប្រហែលជាខ្យល់ចាប់ហើយមើលទៅ ។

យ៉ាហាន លើកធុងចូលមកក្នុងដាក់ជិតតុអស់លោកដែលកំពុងតែបឹតបារី ជជែកសើចលេងសប្បាយ ។

ស៊ី ឈឿន ស្ទុះមកជួយដាក់ធុងទឹកកក

- អូនឯងមិនគិតប្រាប់បង ចេះតែប្រឹងយួរខ្លួនឯង !

- មិនជាធ្ងន់អ្វីប៉ុន្មានទេបង អូនធ្វើម្នាក់ឯងបានហើយ ។

នាងរវៀសរវៃទៅបើកទូកញ្ចក់ យកចាសទ្រព្រមទាំងកែវនិង កន្សែងជូតដៃថ្មីៗមករៀបជូនភ្ញៀវ ។ កន្សែងហ្នឹងជុំឆ្អើមទៀតហើយ! ដូចជាមិនទំនងសោះ ! នាងយកកន្សែងទាំងឡូនោះមកជូនលោក ប្រុសមើល

- បង ! កន្សែងនេះយើងដូចជាមិនទាន់ដែលប្រើទេ មែន ទេបង ?

- មែនហើយអូន យើងសម្ពោធជាលើកដំបូង ជាកិត្តិយស អ្នកសៀមរាបតែម្តងទៅ !

នាងមិនថែមថយអ្វីទេ ចេះតែរៀបចំតទៅទៀត ហើយដើរចូល ទៅក្នុងបន្ទប់គេងតែម្នាក់ឯង ដើម្បីពិចារណាបន្តិច ក្លិនអ្វីក៏ដូចជាចេះ តែធ្វើឲ្យនាងចង់ឆ្អើមទាំងអស់ ។ នាងដូចជានឹកចង់លាបទឹកអប់ ។ ទាល់តែយកទឹកអប់មកលាបមុខបន្តិចទៅ ទើបដូចជាស្វាងមានកម្លាំង ឡើងវិញគ្រាន់បើ ។ នាងនឹងឆ្ងល់និងជំងឺមយីមយាថ្មីៗរបស់នាង ប៉ុន្តែនាងមិនទាន់ហ៊ានជំរាបលោកប្រុសទេ ។

នាងត្រេកអរណាស់ បានឮថាពួកអស់លោកសៀមរាបមក សំណាក់នៅផ្ទះនាងទាំងអស់គ្នាក្នុងល្ងាចនេះ ។ នាងរាំចារំពូករឿង ចាស់ថា ៖

- ខ្ញុំនឹកឃើញអស់លោកមកជួបជុំយ៉ាងនេះ ចេះតែនឹកឃើញ ទៅដល់ចំការដូង ។

លោក សុត សើចហើយចំអន់ដោយស្មោះថា ៖

- ខ្ញុំក៏នឹកទៅដល់ភ័ព្វវាសនា របស់ដើមដូងខ្ញុំដែលបានស្រោច នឹងទឹកភ្នែករបស់អ្នកនាងដែរ ។

នាងតបទៅវិញដោយស្រងេះស្រងោច

- កាលណោះ ខ្ញុំនឹកស្ញើច នឹងសង្សាររបស់ខ្ញុំដែលដាច់ចិត្ត មេត្តាលបចេញទៅចោលស្ត្រីអភ័ព្វ ដែលផ្ចូលចិត្តទៅលើគេច្រើនណាស់ទៅហើយ !

ស៊ី ឈឿន ប្រឹងព្រញាប់ដោះស្រាយដោយសុទ្ធចិត្ត

- បងរពូកអូនពេកទៅ ទៅជាមិនហ៊ានលាអូន ក្រែងរកឈានជើងចេញទៅពុំរួច ។ ម្យ៉ាងទៀតបានជាបងមិនទាន់លាអូនក្នុងពេលនោះ ពីព្រោះបងមិនចង់ឲ្យរឿងយើងចប់នៅក្នុងរាត្រីនេះឡើយ ។

យ៉ាហន នឹកស្ញើចនឹងលោកប្រុសរកចម្លើយនេះទាន់ ។ នាងនឹកវែងឆ្ងាយទៅឃើញថា សំដីរបស់សង្សារនាងដូចជាបរិសុទ្ធមែន ។

នាងឥតទំនេរដៃ រត់ទៅរៀបដំឡើងគ្រែសំពត់បី ដាក់ខ្នើយចងមុង ទុកជូនមិត្រទាំងពីរនិងពួញ៉ប ។

ក្នុងរាត្រីនោះសង្សារទាំងពីរគេងថ្នាក់ថ្នម បបោសអង្អែលគ្នាដូចជាខ្លាប់បាត់ត្លកំសត់របស់ខ្លួន ពីព្រោះម្នាក់ៗសុទ្ធតែមានលាក់រឿងអាថ៌កំបាំង ដែលមិនទាន់បញ្ចេញប្រាប់គ្នាទៅវិញទៅមក ដើម្បីកុំឲ្យរំខានទៅដល់គូជីវិតដែលខ្លួនអាណិតហើយស្រឡាញ់ផង ។

ក្នុងរាត្រីនោះដែរ ច័ន្ទីគេងរោលរាលមិនអស់មិនហើយបន់ឲ្យតែឆាប់ភ្លឺ ដើម្បីនឹងដើររកកញ្ជោកបោកបាចឲ្យសមនឹងកំហឹងចិត្ត ។ ចាប់តាំងអំពីថ្ងៃស្អែកនេះទៅ នាងនឹងដាក់គ្នាឲ្យទៅឃ្លាំចាំមើលឯ "រំចង់ទិព្វ" ឲ្យទៅលមមើលឯ "ប៉ុយរ៉ូ" អធិការដ្ឋាន ហើយនិងឲ្យតាមដាន ស៊ី ឈឿន ជានិច្ច ដើម្បីឲ្យដឹងគំនិតរបស់បងជីដូនមួយនិងឲ្យបានស្គាល់ផ្ទះស្រីកំណាន់របស់គាត់ ។

ស្អែកឡើង ស៊ី ឈឿន ទៅដល់ "ប៊ុយអ៊ូ" ដប់ប្រាំ "មីនុត" មុនម៉ោងប្រាំពីរព្រឹក ហើយចាប់ធ្វើការមិនឲ្យខាតពេលវេលា ។ ក្រោយនោះបន្តិច ស្រាប់តែទ្វារបន្ទប់របើកឡើងដោយឥតអ្នកណាគោះ ឬឲ្យដំណឹងអ្វីសោះ ឃើញចន្ទីចូលមកដល់ ឈរទ្រឹងធ្វើមុខសម្ញើម។

នាងចូលផុតួចរុញទ្វារបិទទៅវិញទាំងកំហឹង

- នែ ! លោកប្រុស ! បាត់មួយយប់ទើសភ្លឺ សប្បាយណាស់ទៅឬអ្វី ?

ស៊ី ឈឿន ធ្វើដូចជាឆ្ងល់ណាស់ ហើយឆ្លើយតបទៅវិញដោយមឹងមាំង

- យី ! ស្អីទៀតហើយអីចេះ ! បាត់អ្នកណាមួយយប់ទើសភ្លឺ ?

- នែ ! លោកប្រុស "រំចង់ទិព្វ" កុំធ្វើពើ ! ក្រែងយប់មិញទៅបណ្ដើរមីស្រីចម្រៀងនៅ "បារ" "រំចង់ទិព្វ" ឬអ្វី ?

- ទេ ! គ្នាទើបតែនឹងមកដល់អំពីសៀមរាបព្រឹកមិញទេតើ ! មានទាំងអស់លោកពីរបីនាក់មកជាមួយផង ! ម្ដេចក៏ស្រាប់តែមកបានរឿងភ្នំពេញឯណោះទៅវិញ ?

ស៊ី ឈឿន ក្រោកអំពីកៅអីមកទាញដៃប្អូនស្រីជីដូនមួយឲ្យអង្គុយនិយាយគ្នាសិនកុំអាលឲ្យខឹងពេក ។

នាងកន្ត្រាក់ដៃចេញ

- កុំមកកាន់លួងចិត្តធ្វើអ្វី ! ខ្ញុំដឹងច្បាស់ណាស់ !

អ្នកកំលោះបញ្ចាក់សួរទៅវិញ

- ដឹងច្បាស់ថាម៉េច ? អ្នកណាប្រាប់អ្វីអូនឯង ?

- មិនចាំបាច់អ្នកណាប្រាប់ទេ ខ្ញុំដឹងអស់ទៅហើយ បងឯងស្មានថាលាក់រឿងប៉ុនៗណឹងវាជិតឬអ្វី ?

- ខុសហើយ ! ច្បាស់ជាមានមនុស្សវាបង្កាប់តែម្ដង ! ។ បងនឹកឆ្ងល់ដែរចុះវាបង្កាប់ប្រាថ្នាយកប្រយោជន៍អ្វី ? ប្រហែលវាចង់បំបែកបំបាក់អូនឯងហើយនឹងបងហើយមើលទៅ ។ បើមនុស្សនោះជាស្រីប្រហែលជាដោយការច្រណែន បើមនុស្សនេះជាប្រុសវិញបងជឿជាក់ថា គឺប្រាកដជាវាចង់ប្រាថ្នាមើលងាយអូនឯងតែម្ដង ។

ចន្ទីនៅទ្រឹងដូចជាស្ដាប់បាន ។ ស៊ី ឈឿន ចាប់ស្មៀតនាងទាន់ ប៉ុន្តែនាងស្ទាបរកកន្លែងខ្សោយរបស់អ្នកតទៅទៀត

- ល្ងាចមិញខ្ញុំទៅដល់ "រំចង់ទិព្វ" ណាំ លោកប្រុស !

- បើអូនឯងទៅដល់វាំតែច្បាស់ណាស់ទៀតទៅហើយ តើបានធ្វើឃើញអ្វីខ្លះ ?

- ខ្ញុំមិនចង់និយាយទេ !

- អើ ! ធ្វើម៉េចនឹងចង់និយាយ ! បើវាឥតមានអ្វីនឹងនិយាយផង ! បើពីរបីខែបងមិនទាន់ទាំងទៅអើត "រំចង់ទិព្វ" ម្ដងផង !

ចន្ទីអស់សំណើច ប្រែទឹកមុខស្រស់ឡើងវិញ

- បើអីចឹង បងឯងទៅណាពីយប់មិញ !

- ល្ងាចមិញបងគេងលើឡាន រង់ាករង្ញើកពីសៀមរាបមកភ្នំពេញ !

- ចុះល្ងាចនេះទៅឯណាទៀត ?

- ល្ងាចហ្នឹងមានទៅណាក្រៅពីនៅផ្ទះ ជាមួយនឹងអូនឯង

ចន្ទីនៅមានសង្ស័យជាខ្លាំងចំពោះអាថ៌កំបាំងរបស់ ស៊ី ឈឿន ដែលនាងចាប់ភ័ស្តុតាងមិនទាន់បាន ។ ប៉ុន្តែសំដីរបស់អ្នក ធ្វើឲ្យនាងសុខចិត្តធូរស្រាលមួយគ្រាដែរ ។ ម្យ៉ាងទៀតបងជីដូនមួយរបស់នាងជាបុរសប្រសប់បង្វែររឿងធំឲ្យទៅជាតូច ធ្វើរឿងមួម៉ៅឲ្យទៅជាសើចបាន ។ ចន្ទីសុខចិត្តសើចម្ដងទៀតចុះ ជាល្បិចឲ្យ ស៊ី ឈឿន ភ្លេចខ្លួន ដើម្បីនាងនឹងជាន់កែងឲ្យទាល់តែបាន ជាមួយនឹងស្ត្រីដែលនាងតាំងគំនុំចងកម្មពៀរ ទល់គ្នានឹងមេឃរលំភ្នំរលាយ ។

ចន្ទីចេញទៅផុត ស៊ី ឈឿន ឆ្លៀតពេលចេញទៅផ្ដាំផ្ញើនឹងយ៉ាហានមួយភ្លែត ពីព្រោះល្ងាចនេះមិនបានជួបគ្នាទៀតទេ ដោយត្រូវជាប់ជាមួយនឹងចន្ទី ។ យ៉ាហានភ្ញាក់នឹងឃើញអ្នកវិលត្រឡប់ទៅដល់ផ្ទះនាងវិញនៅវេលាម៉ោងដប់ព្រឹក នៅពេលដែលនាងកំពុងតែបោសប្រាសសំអាតផ្ទះ ផ្លាស់កម្រាលពូកនិងស្រោបខ្នើយ យកអាចាស់ទៅត្រាំទឹក ដើម្បីនឹងបោកបាលឲ្យស្រេចមុនពេលបាយ ។ ស៊ី ឈឿន នឹកអាស្វរសង្សារជាខ្លាំង ឃើញនាងធ្វើការរៀបចំគ្រប់ចំពូកតែម្នាក់

ឯង នៅរៀនផង ទៅច្រៀងផង កុំឲ្យដែលព្រួសរត្នញត្រៃមួយអីះ ។ ម្ដឹងហើយនៅតែមានគេចង់ព្យាបាទទៀត ! បើដូច្នោះឲ្យអ្នកដាច់ចិត្តចោលដូចម្ដេចបាន !

យ៉ាហាន រត់មកទទួលលោកប្រុស ដោយឆ្ងល់ផងអររផង

- ហេតុអ្វីក៏បងប្រញាប់ចេញម្ល៉េះថ្ងៃនេះ ?

ស៊ី ឈឿន តបមកវិញ

- អូនធុញណាស់ទៅឬអ្វី ដែលឃើញបងចេះតែមករកញយៗយ៉ាងនេះ ?

នាងសើចហើយឆ្លើយថាំអកដោយក្ដាញ់ ដៃនាងស្រវាំឹតសង្វារ

- ចាំស ! អូនធុញណាស់ ពីព្រោះអូនស្អប់បងឯងពេក !

- បើអូនស្អប់បង ប្រហែលជាផិតខានឃើញមុខគ្នាហើយមើលទៅ ។

ស៊ី ឈឿននិយាយលេង ប៉ុន្តែក្នុងចិត្តដូចជាចេះតែឲ្យមានប្រផ្នូលទៅតាមសំដី ពីព្រោះអ្នកនឹងបារម្ភទៅដល់អាកប្បកិរិយារបស់ចន្ទី ។ យ៉ាហានឈឺព្រួចក្នុងបេះដូង នាងចាប់ដៃអ្នកទាំងពីរយកទៅសង្កត់ផ្ទឹបនឹងទ្រូងរបស់នាងហើយឃាត់ថា ៖

- បងឯងនិយាយអ្វីយ៉ាងហ្នឹង !

រួចក៏នាំគ្នាទៅអង្គុយស្និទ្ធស្នាលនៅលើគ្រែ ។ ស៊ី ឈឿន អង្អែលស្មានាង ហើយវាចាដោយស្លូត

- បងគ្រាន់តែមកប្រាប់អូនថាល្ងាចនេះ បងមិនបានមកជួបទេ ដោយរវល់នៅឯផ្ទះច្រើនពេក !

បើរវល់ច្រើនបងទៅទទួលអូនឯ "រំចង់ទិព្វ" តែមួយភ្លែតក៏បានដែរ នៅវេលាម៉ោងដប់ ណាំបងណា ! អូនពិបាកចិត្តណាស់ បើកាលណាមិនបានឃើញមុខបងនៅកន្លែងដែលអូនច្រៀង !

- បើដូច្នោះ បងសុំឲ្យអូនឯងឈប់ទៅច្រៀងនៅកន្លែងនោះតែម្ដងទៅ ពីព្រោះអូនឯងនឿយហត់ខ្លាំងណាស់ទៅហើយ ។

យ៉ាហានដូចជាទើសទាល់នឹងសំដីរបស់លោកប្រុសដែលអាណិតនាង ។ នាងឆ្លើយដោះសាទាំងអឹងអៀន

- មិនអីទេបង ! អូនគ្មានឡើយហត់អ្វីទេប៉ុណ្ណឹង ! នៅផ្ទះក៏តង់តែអផ្សុកដែរ ធ្វើការផងទៅ អាចឲ្យបានប្រាក់កាសខ្លះគ្រាន់នឹងចាយវាយ ពីព្រោះសោហ៊ុយអូនដូចជាកាន់តែធំ តែខំមុខជាតឹងចិត្ត និងបន្ទុកធ្ងន់របស់អូនជាមិនខាន ។

ស៊ី ឈឿន បញ្ជាក់ទៅនោងវិញ

- សុំអូនកុំទើសទាល់ឲ្យសោះ បងធានារ៉ាប់រងលើបងទាំងអស់ អូនឯងគិតតែពីរៀនទៅ កុំនៅខ្វល់នឹងសោហ៊ុយប៉ុណ្ណឹងនោះ ។ គួរឈប់ច្រៀងតែម្តងទៅ ពីព្រោះជិតប្រឡងណាស់ទៅហើយ ម្យ៉ាងទៀត កន្លែងនោះវាមិនជាថ្លៃថ្នូរប៉ុន្មានផង ។

អ្នកប្រុសនិយាយយ៉ាងនេះ ដោយនឹកទៅដល់គ្រោះថ្នាក់ដែលអាចកើតមានចំពោះយ៉ាហាន នៅកន្លែងសាធារណៈនោះ ។ យ៉ាហានមិនយល់ន័យអាថ៌កំបាំងនៃសំដីនេះក៏តបត្រង់ធ្លូទៅវិញ

- ជំនាន់ឥឡូវ របរអ្នកច្រៀងមិនជាថោកទាបប៉ុន្មានទេបង ! ពីព្រោះជាផ្នែកសិល្បៈមួយដែលគេនិយមរាប់អានកាន់តែច្រើនណាស់ទៅហើយ ។

អ្នកប្រុសយល់ច្បាស់ថាអ្នកពិតជាមិនល្ងង់ ហើយមិនបុរាណជាងយ៉ាហានឡើយក្នុងរឿងនេះ ប៉ុន្តែអ្នកនឹកអៀនថា ដោយសារតែខ្លួនអាណិតគេពេកកបានជាយូរៗទៅ គេបែរជាយល់ថាខ្លួនជាមនុស្សបុរាណពេក... ទៅវិញ ទើបអ្នកបន្ថយសំដីតែម្តង ។

- អូនឯងវាសម័យជាងបង បានជាចេះយល់និងស្គាល់សិល្បៈចម្រៀងជាងបង ។ បងវាបុរាណបានជានឹកឃើញតែត្រឹមសេចក្តីសុខនិងថ្លៃថ្នូររបស់អូនតែប៉ុណ្ណោះ ។

ឮសំដីរបស់ ស៊ី ឈឿន ដូចជាតឹងបន្តិចជាងធម្មតា យ៉ាហានប្រញាប់អង្វរទៅវិញ

- បងឯងប្រញាប់តែប្រកាន់ខឹងនឹងអូនណាស់ ! បានជាអូនស៊ូនៅច្រៀងតទៅទៀត ក៏ដោយសារចង់សម្រាលបន្ទុករបស់បងផង ហើយនិងចង់ទំលាប់ខ្លួនឲ្យចេះរករស់ដោយខ្លួនឯងផង ណាំបង !

- គំនិតអូនប្រសើរដែរ ប៉ុន្តែកុំអាលឆាប់ពូកែតែម្នាក់ឯងពេក។ បងមិនឃាត់អូនឯងឲ្យឈប់សប្បាយនឹងដើរច្រៀងតាម "បារ" ទេ ប៉ុន្តែ បងថាឥឡូវវាជិតដល់ពេលប្រឡងណាស់ទៅហើយ បើបងសុំឃាត់អូន ឯងឲ្យបង្អង់ទៅច្រៀងសិនបានឬទេ ?

- តែឈប់ មុខជាម្ចាស់ហាងគេខឹងនឹងអូនហើយ ។ តិចលោ តែមានអ្នកឯណាគេមកចូលជំនួសថែមទៀត នោះអូនមុខជាពិបាក នឹងត្រឡប់វិលចូលទៅវិញហើយ ។

គិតទៅនាងខ្លាចចិត្តម្ចាស់ហាងជាងខ្លាចចិត្តរបស់ ស៊ី ឈឿន។ នាងស្តាយ "រំចង់ទិព្វ" ជាងសេចក្តីអង្វររបស់សង្សារ ។ "គ្រាន់តែ សុំឲ្យគេឈប់ច្រៀង គេមិនទាំងព្រមទៅហើយ ! ទំរាំដល់ទៅថ្ងៃ ក្រោយ លុះគេបានឡើងគ្រាន់បើជាងនេះទៅទៀត តើខ្លួនអាចនឹងទៅ ប្រាប់គេឲ្យធ្វើអ្វីតាមខ្លួនបាន ឬ ទេ ?" ។ ស៊ី ឈឿន សម្លឹងមើល មុខនាងហើយសួរដោយឆ្ងល់ថា ៖

- យ៉ាហានឯងស្រណោះ "រំចង់ទិព្វណាស់ទៅឬអ្វី ?"

នាងតបទៅវិញដោយអរាក់អរួល

- ហេតុអ្វីក៏បងមកប្រកាន់ខឹងនឹងអូនយ៉ាងហ្នឹង ? "រំចង់ទិព្វ" គេមានធ្វើអ្វីបង ? គួរតែបងយល់ថាភោជនីយដ្ឋានចេះបានផ្តល់ អាយុជីវិតឲ្យអូនណា៎ !

ស៊ី ឈឿនរកជឿត្រចៀកខ្លួនឯងសឹងមិនកើត ?

"អស្ចារ្យណាស់ ! ភោជនីយដ្ឋាន "រំចង់ទិព្វ" បានផ្តល់អាយុ ជីវិតដល់នាង ! ចុះស៊ី ឈឿន វាគ្មានបានការអ្វីចំពោះនាងសោះ ទៅឬអ្វី ?"

អ្នកកំលោះក្រោកឈរថយចេញឆ្ងាយពីនាង ហាក់ដូចជាខ្ពើម សំដីអកតញ្ញូហួសប្រមាណអម្បាញ់មិញនេះ ។ អ្នកសម្លឹងមើលមុខស្ត្រី អសប្បុរស រួចវាចាបញ្ជាក់ទៅវិញ

- សុំនាងកុំព្រួយ ខ្ញុំមិនផ្តាច់អាយុជីវិតរបស់នាងអំពី "រំចង់ទិព្វ" ទេ ! សូមនាងសង្ឃឹមលើ "រំចង់ទិព្វ" ចុះ តាំងអំពីថ្ងៃនេះតទៅមុខ។

នាងមិនទាន់ទាំងបានឆ្លើយថាអ្វីទៅវិញផង ស្រាប់តែ ស៊ី ឈឿន ស្ទុះសំដៅទៅមាត់ទ្វារ នាងស្ទុះទៅតាមស្រវាឱបដៃសង្សារ

– បង ! បង ! បង ! ...

ស៊ី ឈឿន កន្ត្រាក់ដៃរបូតចេញពីនាង ទាញទ្វារបើកចេញហើយឈានចុះជណ្ដើរពីរកាំម្ដង រហូតទៅដល់រថយន្តដែលអ្នកបញ្ជោះចេញទៅភ្លាមឥតរេរា ។

យ៉ាហានរត់ទៅតាមដល់ថ្នល់ ឃើញឡានចេញទៅផុត ឃើញប្រុសដែលនាងស្រឡាញ់ស្មើជីវិតចុះចាកផ្ទះនាងឥតងាកក្រោយ ។ កូននៅក្នុងផ្ទៃចាប់កំរើកជាលើកដំបូង ហាក់ដូចជាកន្ទោសថាហេតុអ្វីបានជានាងបណ្ដេញ "ឪពុក" ឲ្យរត់ទៅចោល ។ យ៉ាហានដើរឡើងមកលើផ្ទះវិញទាំងរសេះរសោះ ទៅឈរនៅមាត់បង្អួចសម្លឹងមើលទៅផ្លូវទទេ នាងនឹករអាណិតចិត្តសង្សារណាស់ ល្ងាចនេះគេមិនទៅរកនាងនៅ "រំចង់ទិព្វ"ទេ ប៉ុន្តែដល់ល្ងាចស្អែកប្រហែលជាគេបាត់ខឹងហើយគេនឹងទៅជួបនឹងនាងនៅភោជនីយដ្ឋាននោះទៀត ជាមិនខាន។

************

ស៊ី ឈឿន ត្រឡប់ទៅដល់ "ប៉ុយវ៉ូ" រសាប់រសល់មិនអស់មិនហើយ មិនយល់ច្បាស់ថាអម្បាញ់មិញនេះហេតុដូចម្ដេចបានជាយ៉ាហាន ហើយនិងអ្នកទៅជានិយាយស្ដាប់គ្នាមិនបានយ៉ាងដូច្នេះ ! ថាមានរឿងអ្វីធំដុំទៅក៏ដូចជាមិនមែនដែរ ប៉ុន្តែម្នាក់ៗដុចជាលែងយល់លែងថ្នមចិត្តគ្នាទៅវិញទៅមកអស់រលីង ។ រឿងនេះមិនលែងមានបុព្វហេតុជ្រៅនៅត្រង់កន្លែងណាមួយឡើយ ! ។

ថ្ងៃនេះចន្ទីសប្បាយចិត្តណាស់ បានបងស៊ី ឈឿន នៅជិតនែបនិត្យពេញមួយរសៀល ។ ទាំងពីរនាក់សុទ្ធតែលាក់គំនិតរៀងៗខ្លួន ស៊ី ឈឿន ចង់បង្វែងដានចន្ទី មិននឹកស្មានថា នារីដើរស្ទៀតពីរដែរទេ ។

ដល់ល្ងាចបន្តិច ស្រាប់តែឃើញមិត្តនារីរបស់ចន្ទីម្នាក់មកដល់ ហើយបបួលចន្ទីទៅស៊ីការពួកម៉ាក ។ ចន្ទីសុខចិត្តទៅជាមួយនឹងឡាន គេ ។ ឯ ស៊ី ឈឿន មិនអស់ចិត្តនឹង យ៉ាហាន ក៏ឆ្លៀតទៅរកនាង ឯ "វិចង់ទិព្វ" ម្ដងទៀត ។

ម៉ោងជិតដប់យប់ អ្នកកំលោះទៅដល់ភោជនីយដ្ឋានតែម្នាក់ឯង នឹកឆ្ងល់នឹងមិនឃើញយ៉ាហានចេញមកច្រៀងសោះ ។ ស៊ី ឈឿនហោងហោងលែងស្និទ្ធនឹងបរិយាកាសនៅ "វិចង់ទិព្វ" លែងទុកចិត្តលើមនុស្សទាំងអស់នៅកន្លែងនោះ ។ អ្នកបម្រើឲ្យពត៌មានថា យ៉ាហានទើបនឹងចេញទៅផុតមុននេះបន្តិច ។ គួរឲ្យចម្លែកណាស់ ម៉ោងមិនទាន់ទាំងដប់ផង ម្ដេចក៏យ៉ាហានប្រញាប់ចេញទៅផ្ទះម្ល៉េះ ? ប្រហែលជានាងមិនសូវសប្បាយចិត្តនឹងច្រៀងក៏មិនដឹង ពីព្រោះសង្សាររបស់នាងមិនបានមកជួយលើកទឹកចិត្ត ។ ស៊ី ឈឿន ផឹកតែទឹកក្រូចមួយកែវក៏ត្រឡប់ចេញទៅវិញ សំដៅទៅផ្ទះ ... យ៉ាហាន ។ ទៅដល់ឃើញបង្អួចនិងទ្វារបិទឈឹង នាងក្នុងបន្ទប់លត់ភ្លើងងងឹតទាំងអស់ ។ អ្នកឈរគោះទ្វារយ៉ាងយូរក៏ពុំឮមាត់ឆ្លើយ លុះសួរទៅអ្នកជិតខាង គេថានាងចេញទៅតាំងពីព្រលប់ដូចជាមិនទាន់ឃើញវិលត្រឡប់មកវិញឡើយ ។ ចុះទៅឯណា ? ចេញអំពី "វិចង់ទិព្វ" មកយូរ បន្តិចហើយ គួរណាស់តែមកដល់ហើយ ឬមួយក៏អាល័យតែចូលទិញ ឥ★ាន់នៅឯផ្សារ ? ។ ស៊ី ឈឿន បើកឡានចេញទៅលេងមួយជុំធំ ដើម្បីបន្លប់ពេល ពីព្រោះនៅរង់ចាំយ៉ាងនេះដូចជាតប់ប្រមល់ណាស់។ លុះបត់ឡានព័ទ្ធមកដល់មុខផ្ទះយ៉ាហានវិញ ក៏ឃើញនៅតែបិទភ្លើងបិទបង្អួចដដែល ។ អ្នកត្រឡប់ទៅផ្ទះវិញសិន ចន្ទីក៏មិនទាន់ឃើញមកដល់ដែរ ។ ប៉ុន្តែបើចន្ទីទៅឯណាក៏ទៅៗ ស៊ី ឈឿន ដូចជាគ្មាននឹកខ្វល់អ្វីទេ ពីព្រោះឮថាចន្ទីគេចង់នៅគេងយប់នេះឯផ្ទះពួកម៉ាក់គេផង យ៉ាងហ្នឹងក៏ស្រួលដែរ សោះនឹងទើសទាល់ក្នុងការចេញចូល។

ម៉ោងប្រហែលដប់ពីរអាធ្រាត្រ ស៊ី ឈឿន បើកឡានចេញសំដៅទៅផ្ទះយ៉ាហានម្ដងទៀត ។ ទីក្រុងស្ងាត់ឈឹង មានរថយន្តនិង

"តាក់ស៊ី ឡាំប្រេតា" មួយៗ ។ អ្នកកំលោះបើកតិចៗ ដើម្បីកុំឲ្យឆាប់ដល់ផ្ទះយ៉ាហានពេក ។ ទៅដល់ជិតផ្ទះនោះ ស៊ី ឈឿននឹកអររួចដោយឃើញភ្លើងភ្លឺនៅឯបន្ទប់ខាងលើ លុះងាកមកក្រោមស្រាប់តែចម្លែកនឹងឃើញរថយន្តមួយនៅឈប់ចំពីមុខច្រកចូល ។ អ្នកបើកហួសទៅឈប់ឆ្ងាយបន្តិចនៅក្រោមដើមឈើមួយដែលលឲ្យស្រមោលងងឹត

ហើយអង្គុយមើលទៅឯនាយសង្កេតពីក្រោយរថយន្តដែលឈប់ទន្ទឹមនឹងផ្ទះយ៉ាហាន ។ ជិតមួយម៉ោងក្រោយមកទើបឃើញប្រុសក្មេងម្នាក់ទុកសក់ "ស្តែក្តោប" ចុះមកកាន់ឡានដើរទន្ទឹមស្និទ្ធនឹងនាងយ៉ាហាន ។ បុរសនោះបើកឡានចេញទៅ ឯនាងយ៉ាហានក៏ត្រឡប់ទៀងទៅលើផ្ទះវិញ ។

ស៊ី ឈឿនចង់ស្ទុះឡើងតាមទៅសួរភ្លាម "យ៉ាងហ្នឹងហើយតើបានជាវាមិនសុខចិត្តបោះបង់រំចង់ទិញ" ! ជីវិតរបស់វាធ្វើនៅនឹងកន្លែងនោះមែន ។ ប៉ុន្តែអ្នកប្រុសមិនចង់ឲ្យយ៉ាហានដឹងខ្លួនទេ ទុកចាំចាប់ភ័ស្តុតាងឲ្យជាក់ស្តែងតែម្តង នៅថ្ងៃក្រោយ ។ ដូច្នេះអ្នកប្រឹងបើករថយន្តចេញទៅយកខ្យល់ដីសោះកក្រោះចំនួនជិតកន្លះម៉ោងទៀតសិន ទើបត្រឡប់មកផ្ទះយ៉ាហានវិញ ហើយឡើងទៅគោះទ្វារធ្វើដូចជាមិនដឹងអ្វីទាំងអស់ ។ ឮដូចជាយ៉ាហានដើរមកឈរស្តាប់នៅនឹងមាត់ទ្វារ រួចឮសម្លេងនាងសួរមកអំពីខាងក្នុង

- អ្នកណាហ្នឹង ?

អ្នកកំលោះប្រឹងឆ្លើយឲ្យដូចជាធម្មតា

- ស៊ី ឈឿន

នាងស្តាប់សម្លេងបាន ក៏ប្រញាប់ប្រញាល់បើកទ្វារហើយទាញដៃអ្នកឲ្យចូលទៅខាងក្នុងផ្ទះ

- អូនស្មានតែបងមិនអញ្ជើញមកទេល្ងាចនេះ

- បងមិនប្រុងនឹងមកទេ ពីព្រោះអូនមិនប្រុងនឹងរង់ចាំបងដែរ ! ។

- អូននៅរង់ចាំបងជានិច្ច

ប្រសិនបើគ្មានឧបទ្រវហេតុអកុសលថ្មីចូលមកដុតកំដៅបន្ថែមទេ សំដីរបស់យ៉ាហានប៉ុណ្ណោះអាចមានលទ្ធភាពនឹងរំលាយកំហឹងរបស់ ស៊ី ឈឿន ជាមិនខាន ។ ប៉ុន្តែរឿងលាក់លៀមដែលទើបនឹងឃ្លាំមើលឃើញថ្មីៗ ធ្វើឲ្យស៊ី ឈឿន រកទុកចិត្តមិនកើតចំពោះសំដីនិងអាកប្បកិរិយាខាងក្រៅរបស់នាងយ៉ាហានដែលគ្មានទាន់ព្ធហើបមួយម៉ាត់សោះ អំពីរឿងអាក្មេងប្រុសដែលនាងទើបនឹងបណ្តើជូនចុះពីលើផ្ទះ បណ្តោះឲ្យចេញទៅផុតមុននេះបន្តិច ។

ស៊ី ឈឿនក៏មិនសួរ រង់ចាំមើលតើយ៉ាហាន គេធ្វើពើយ៉ាងដូចម្តេចទៅទៀត ។ ដល់ឃើញ ស៊ី ឈឿនចេះតែធ្មឹងៗ យ៉ាហានមកនិយាយក្និកក្នក់រក ។

– បងឯងដូចជាល្ងើយនឹងអូនណាស់ល្ងាចហ្នឹង ! ។

ស៊ី ឈឿន មិនឆ្លើយតបហើយដើរទៅឈរទ្រឹងនៅនឹងមាត់បង្អួច "ប្រុសកំលោះដែលមានបុណ្យសក្តិដូចអញមិនគួរបណ្តោយឲ្យស្រី "សំផឹង" វាធ្វើបាបយ៉ាងហ្នឹងសោះ !"

យ៉ាហានចូលទៅអង្អូរឱបរឹត

– អូនស្តាយណាស់ ពីម្សិលមិញអូនមិនគួរនឹងធ្វើឲ្យបងខឹងសោះ

ស៊ី ឈឿន ឆ្លើយផាំងទៅតាមសន្ទុះចិត្ត

– កុំស្តាយ ! ស្តាយធ្វើអ្វី វាហួសជ្រុលអស់ទៅហើយ ! បើទោះជាស្តាយក៏គ្មានលុបលាងអ្វីជ្រះដែរ !

យ៉ាហាន មឹងមាំដូចជាឆ្ងល់ខ្លាំង

– បង ! បងខឹងអ្វីនឹងអូនក៏ខ្លាំងម្ល៉េះ ? ក្រែងបងមិនយល់ចិត្តអូនទេដឹង ?

ស៊ី ឈឿនផ្ទាន់ទៅវិញភ្លាម

– មកទល់នឹងត្រឹមណោះ បងប្រឹងយល់ច្រើនណាស់មកហើយ អំពីថ្ងៃនេះតទៅមុខ បងទុកឲ្យអូនយល់ខ្លួនឯងទៅចុះ ពីព្រោះបងជាប្រុសម្នាក់ដែលជាឧបសគ្គចំពោះសេចក្តីសប្បាយរបស់អូនឯង ។

យ៉ាហានរឹតតែរង្វេងនឹងសំដីទាំងនេះ

– បងឯងចម្លែកណាស់ថ្ងៃហ្នឹង បងឯងលែងស្តាប់អូនសោះទៅហើយ !

ស៊ី ឈឿនគេចខ្លួនចេញពីនាង

– បងចេះស្តាប់តែសំដីពិត បើគំនិតរបស់បងវាខុសពីអូនឯងយើងកុំចង់យល់គ្នាតទៅទៀតធ្វើអ្វី ។
យ៉ាហានឯងសព្វថ្ងៃក៏បានថ្កុំថ្កើង រុងរឿងច្រើនណាស់ទៅហើយ
ប្រុសណាក៏ប្រាថ្នាចង់បានយ៉ាហានឯង ដែរ
កុំឲ្យឱកាសវារសាត់ផុតពីដៃ !

នាងស្ទុះទៅរកអ្នកទៀត

– ទេ ! ទេបង មិនមែនយ៉ាងដូច្នេះទេ ! ប្រុសទាំងអស់នេះវាគ្មានន័យអ្វីចំពោះរូបអូនទេ ។ អូនបានថ្កុំថ្កើងរុងរឿងសព្វថ្ងៃក៏ដោយសារតែបង អូនរស់នៅសព្វថ្ងៃក៏សម្រាប់តែបងមួយដែរ ។

ស៊ី ឈឿនរលីងរលោងមិនចេញស្តី ។ ឯនាងស្រីក៏ទឹកភ្នែកតាមប្រុសកំសត់

– អូនមិនដែលធ្វើឲ្យបងលំបាកចិត្តដោយសារអូនឡើយ ។ ពេលនេះអូនខុសអ្វី ? បងជេរស្តីអូនចុះ ! អូនខុសត្រង់ណា សុំបងមេត្តាប្រាប់អូនមក អូននឹងធ្វើតាមបងទាំងអស់ ។

ស៊ី ឈឿននៅតែមិនចេញស្តី នឹងថាចាំបាច់ទោប្រាប់ទៅសួរគេធ្វើអ្វី បើគេត្រង់នឹងខ្លួនមុខជាគេរ៉ាយរ៉ាប់ប្រាប់រឿងទាំងអស់ជាមិនខានបើគេមិននិយាយគឺគេចង់លាក់នឹងខ្លួនហើយ បើខ្លួននៅតែចាប់ភស្តុតាងគេមិនទាន់បាន គេក៏នៅតែលាក់យ៉ាងហ្នឹងរហូត ដើម្បីទុកឲ្យខ្លួនចេះតែធ្វើអាវែកតទៅទៀតទៅ ។

អ្នកប្រុសប្រឹងទប់ចិត្ត ទាល់តែបែកញើសជោកខ្លួន ។ យ៉ាហានឃើញមុខ ស៊ី ឈឿនកាន់តែស្លេក ក៏ប្រឹងសួរហើយចាប់បង្ខំទាញដោះអាវ

– បងឯងមិនស្ទាវស្រួលខ្លួនហើយ ! សាច់ឲ្យត្រជាក់ស្រេបបងឯងគេងសិនទៅ អូនកោសខ្យល់ឲ្យ ។

ស៊ី ឈឿនលែងចង់ប្រះខ្លួនទៅលើគ្រែ ដែលមុននេះបន្តិចប្រហែលជាយ៉ាហាន បានបណ្តោយខ្លួនឲ្យប្រុសដែលទើបនឹងចេញទៅសង្កត់ផ្ទប់ញាក់ញីឥតប្រណីនៅពេញតែកន្លែងដែលអ្នកធ្លាប់ស្មានថាមានតែខ្លួនអ្នកមួយទេ ដែលនាងអនុញ្ញាតឲ្យចូលមកគេងដោយស្និទ្ធស្នាល ។ ប៉ុន្តែស៊ី ឈឿនដែលចិត្តច្រើនណាស់ដែរ មិនចង់មកប្រច័ណ្ឌនិងប្រឈ្លោះដណ្តើមស្នេហាដែលគេមិនដោយស្មោះយ៉ាងនេះសោះ ។ អ្នកគិតថា ខ្លួនបានជាសង្គ្រោះយ៉ាហានទៅហើយ បើយ៉ាហានសងគុណខ្លួនយ៉ាងដូច្នេះទៅវិញ ខ្លួនត្រូវតែថយចេញអំពីស្ត្រីនិងអំពីទីនេះទៅដោយថ្លៃថ្នូរ ។

គិតយ៉ាងនេះហើយ ស៊ី ឈឿន បណ្តោយខ្លួនឲ្យយ៉ាហានទាញចូលទៅគេងឲ្យនាងកោសខ្យល់ ។ យ៉ាហានថ្នាក់ថ្នមអ្នកប្រុសឥតមានឆ្អែង ដូចជាភ័យពិតៗ នឹងឃើញអ្នកមិនស្រួលខ្លួន ។ ស៊ី ឈឿនគិតថាស្រីនេះប្រសប់លាក់ពុតណាស់ បើកុំតែបានឃើញទាន់នឹងភ្នែកកុំអីរកស្មានរកសង្ស័យមិនកើតសោះតែម្តង ។

នាងកោសខ្យល់បណ្តើរ នាំអ្នកនិយាយលេងបណ្តើ

- បងទើបនឹងអញ្ជើញមកពីឯណាថ្មើរណឹង ?

- បងមកពីផ្ទះ

- ក្រែងទើបនឹងមកពីសប្បាយឯណាទេដឹង បានជាមកដល់អស់ កម្លាំងខ្យល់ចាប់តែម្តង !

- បងទៅសប្បាយឯណាកើត បើស្លាប់ចិត្តនឹងយ៉ាហានឯងទៅហើយ

- ស្លាប់ចិត្តណាស់ហើយ បានជាចោលអូនមួយល្ងាចកុំឲ្យមកអើត

- បងមិនចង់អើតញយពេក ដើម្បីទុកពេលឲ្យអូនឯងសប្បាយឲ្យបានច្រើននឹង "រំចង់ទិព្វ" ។

- អូនគ្មានសប្បាយអ្វីទេល្ងាចហ្នឹង តប់ប្រមល់សឹងតែនឹងស្លាប់អូនមិនចង់ទាំងទៅច្រៀងផង អូនត្រឡប់មកផ្ទះវិញតាំងអំពីមុនម៉ោងដប់ ។

មកដល់ត្រឹមនេះយ៉ាហានដូចជានិយាយរៀបរាប់សមតាមដំណើរទាំងអស់ ក៏ប៉ុន្តែ ស៊ី ឈឿន ចាប់អារម្មណ៍ជាច្រើនទៅលើសំដីចុងក្រោយបង្អស់របស់នាង ទើបអ្នកបញ្ជាក់សួរទៅនាងវិញ

– អូនបានអ្នកណាគេជូនមកផ្ទះវិញមុនម៉ោងដប់ ?

– ចាស ! អូនឲ្យស្រីម្នាក់គេជូនមក ។

ស៊ី ឈឿននឹកហួសចិត្ត "ឲ្យស្រីម្នាក់គេជូនមក ! បើកុំតែឯងឃើញ កុំអីជឿវាស្លុង ! ។ មិនដឹងជាវានាំគ្នាទៅសប្បាយអណ្ដែតអណ្ដូងឯណាខ្លះទេ... ពីព្រោះវាចេញអំពី "រំចង់ទិព្វ" ទៅតាំងពីមុនម៉ោងដប់ ទាល់តែដល់ម៉ោងដប់ពីរកន្លះរំលងអាធ្រាត្រទើបឃើញត្រឡប់មកដល់ផ្ទះវិញ ។ មកដល់ហើយវានៅមិនទាន់អស់ចិត្តទៀត វានាំគ្នាឡើងទៅសម្ងំមួយឯលើទាំងពីរនាក់អស់ជិតមួយម៉ោងទៀត ទេឱបឃើញបណ្ដើរគ្នាចុះមកវិញ ម៉្លឹងហើយវានៅប្រឹងលាក់ ហើយវាហ៊ានសួរឯងថាវាមានខុសត្រង់ណាទៀត !"

កោសខ្យល់ជួចហើយ យ៉ាហានអង្វរអ្នកប្រុសឲ្យនៅគេង ។ អ្នកទទួលទាំងក្ដៅចិត្ត មានបំណងនឹងចាត់ទុកយ៉ាហានក្នុងយប់នេះឲ្យពេញលក្ខណៈជាស្រីផ្កាមាស សម្រាប់បំពេញសេចក្ដីសប្បាយយ៉ាងចម្លែកៗ របស់អ្នកទៅតាមតែចិត្តពាលានៃភាពកំលោះ ដើម្បីឲ្យអស់ចំណង់ ឲ្យលែងចង់ ឲ្យលែងស្រណោះស្រីនេះតទៅទៀត ។

យប់នេះយ៉ាហានចម្លែកនឹងបងស៊ី ឈឿន ធ្វើឲ្យនាងស្គាល់សេចក្ដីសប្បាយប្លែកហួសពីធម្មតា នាងនឹកសរសើរថា ប្រុសហ្នឹងមិនចេះអស់ស្នៀតឡើយ គេចេះធ្វើឲ្យនាងរឹតតែស្រៀវស្រាញត្រឡប់ធាតុ ឲ្យកាន់តែមានចំណង់ទៅលើគេខ្លាំងឡើងៗ ។ នាងក្ដិច នាងខ្ទាំ នាងខាំគេដោយក្ដាញ់ នាងភ្ញាក់ដឹងខ្លួនឡើងម្ដងៗ ស្រវាត្រេកត្រអាលនឹងសាច់នឹងឈាមរបស់គេ ។

យប់នេះស៊ី ឈឿន គេងគ្មានលក់សោះបណ្ដោយឲ្យចិត្តដែលឈឺចាប់ប្រាប់បង្គាប់អ្នក ឲ្យដើរតួកំលោះ សម្ផស្សក្ដៅឲ្យពេញមួយយប់ទាល់ភ្លឺ ។ យ៉ាហានដូចជាគ្មានដឹងខ្លួនថាសេចក្ដីស្រឡាញ់ល្មុយឆ្ងាញ់ក្នុងរាត្រីនេះ ជារបស់និម្មិតមិនឋិតថេរសោះឡើយ ។ ពេលអស់

កម្លាំងខ្លាំងម្ដងៗ នាងគេងលង់លក់នៅក្នុងដៃសង្សារ ត្រេតអរនឹងបាន គេឱបថ្នាក់ថ្នមគួរឲ្យកក់ក្ដៅអស់មួយជីវិត ។

ដល់ម៉ោងប្រាំពីរព្រឹកហើយ នាងមិនទាំងដឹងថាភ្លឺផង ទាល់តែ ស៊ី ឈឿន ក្រោកទៅមុជទឹកស្លៀកពាក់រួចស្រេចទៅហើយ ទើបនាង ភ្ញាក់ស្ទុះភ័យញ័រនឹងឃើញប្រុសនាងដល់ពេលត្រូវត្រឡប់ទៅវិញទៅ ហើយ ។ នាងងឿងឆ្ងល់នឹងភាពស្រពាប់ស្រពោនមិនរសាយរបស់ លោកប្រុស ដែលប្រាប់នាងថាស្អែកមិនបានមកទេ ពីព្រោះជាប់ កិច្ចការច្រើន ។ ស៊ី ឈឿន ឈានជើងចេញទៅ នឹងថាផ្ទះនិង បន្ទប់នេះប្រហែលជាអ្នកលែងមកជាន់ទៀតហើយ ។

នៅពេលបែកគ្នា យ៉ាហានស្ទុះទៅដល់មាត់ទ្វារស្រវាឱបរឹត សង្សារជាខ្លាំង

- អូនមិនចង់ឲ្យបងត្រឡប់ទៅវិញទេ អូនស្រឡាញ់បងណាស់ អូនដូចជាពិភាល់ក្នុងចិត្តអ្វីម្ល៉េះទេ... ។

ស៊ី ឈឿនដោះដៃនាងចេញ ។ យ៉ាហានចម្លែកនឹងទឹកមុខ សោះអង្គើយរបស់សង្សារ នាងស្រែកផ្ដាំថែមទៀតថា ៖ "សូមបងកុំ ចោលអូនយូរពេកណា៎ អូនទៅរង់ចាំបងជានិច្ច" ។

ស៊ី ឈឿនបើកឡានចេញទៅវិលវល់សតិ មិនដឹងជាជឿត្រង់ ណា មិនជឿត្រង់ណា "យីអញ ប្រហែលជាត្រូវស្នេហ៍យ៉ាហានហើយ មើលទៅ ! ពីព្រោះអញរពុកគេកាន់តែខ្លាំង ហើយស្រឡាញ់គេកាន់ តែច្រើន... " ។

បុគ្គលិកនៅការិយាល័យអធិការដ្ឋានរបស់ស៊ី ឈឿន មាន សេចក្ដីងឿងឆ្ងល់នឹងឃើញថៅហ្វាយមានទឹកមុខស្រងូតស្រងាត់ខ្លាំង ណាស់ក្នុងថ្ងៃនេះ ។ លោកមិនសូវហៅអ្នកណាឲ្យទៅជិត មិនសូវ ពិគ្រោះសួរអ្វីឡើយ ច្រើនបញ្ជូនចេញតែការណាដែលប្រញាប់ជាបន្ទាន់ ហើយទុកការដែលស្មុគស្មាញខ្លាំងឲ្យនៅមួយអន្លើសិន ។ យូរបន្តិចមក ទើបលោកឲ្យហៅអស់លោកដែលទទួលខុសត្រូវផ្ទាល់ក្នុងការលំបាក ទាំងនេះមកប្រជុំសួរទាំងអស់គ្នាតែម្ដង រួចដល់គេចេញទៅវិញអស់ទៅ ទើបលោកសម្ងំបញ្ចប់ការទាំងនេះតែម្នាក់ឯង ។ គេសង្កេតឃើញថា

ចៅហ្វាយមានចេញវាចាខ្លះគួរឲ្យសង្ស័យ លោកប្រៀនប្រដៅឲ្យខំធ្វើគ្រប់ៗគ្នា ទោះជាលោកនៅក្តីឬឥតអំពីលោកទៅក្តី ។ គេរកគិតមិនលេចសោះអំពីរឿងក្រៀមក្រំរបស់លោក ។ បុណ្យស័ក្តិក៏ធំ រូបក៏ស្រស់ គ្រួសារក៏ខ្ពស់ សម្បត្តិក៏មាន បុគ្គលិកក៏ស្រឡាញ់គ្រប់គ្នា ស្រីៗចោមលបសរសើរ តើនៅខ្វះអ្វីទៀត ? ។ គិតទៅមនុស្សយើងមិនចេះគ្រប់គ្រាន់មែន ! ម្ល៉ឹងហើយនៅតែគ្មានសេចក្តីសប្បាយទៀត!

លុះដល់ម៉ោងចេញពី "ប៊ុយរ៉ូ" ស៊ី ឈឿនឆៀងចូលទៅផ្ទះម៉ាក់មីងមួយភ្លែត ទៅទទួលទានបាយយកតែនាម ពីព្រោះវាគ្មានឆ្ងាញ់អ្វីទៀតទេ នឹកឈឺចិត្តមិនដាច់ចំពោះសេចក្តីស្មោះត្រង់ឥតប្រយោជន៍របស់ខ្លួន ។

ស៊ី ឈឿនប្រាប់ច័ន្ទីថាខ្លួត្រូវទៅ "តួរណេ" ក្នុងថ្ងៃនេះ ។ នាងបញ្ជាក់សួរថា ៖

- បងអញ្ជើញទៅឯណា ថ្មើរណាទើបមកវិញ ?

- បងមិនដឹងជាត្រូវទៅឯណាខ្លះទេ ពីព្រោះត្រូវជូនអ្នកជំនាញការបរទេសទៅមើលច្រើនកន្លែង មិនទាន់ច្បាស់ថាទៅឯណាខ្លះដែរ មិនដឹងជាពេលណា ឬថ្ងៃណានឹងមកដល់វិញឡើយ ។

តាមពិតស៊ី ឈឿន មិនដឹងអ្វីមែន មិនច្បាស់ក្នុងចិត្តថាខ្លួនចង់ទៅឯណាប្រាកដឡើយ ។ "មើលទៅរកមិនឃើញទេកន្លែងលំហើយចិត្ត ។ មិនគួរឲ្យធ្លាក់ខ្លួនមកឈឺចាប់ដោយសារស្រីផ្កាមាសសោះ ! គួរឲ្យខ្មាសណាស់ជាតិនេះ !" ។

ស៊ី ឈឿនយករថយន្តផ្ទាល់ខ្លួនចេញទៅតែម្នាក់ឯង ។ ផ្លូវវែងណាស់តាមស្រុកចំការ តាមមាត់ទន្លេមេគង្គ អ្នកចង់តែបើលឡានឲ្យរហូត ឲ្យយ៉ាំងលឿន ឲ្យទាន់ចិត្ត ឲ្យឆាប់ចប់ជីវិតវេងកម្មនេះ ! ។

មួយថ្ងៃវាល់ល្ងាច ជិះឡានអត់បាយ ផឹកតែទឹក ឆ្លងសាឡាងអស់បី អ្នកលឿង ទន្លេបិទ ព្រែកក្តាម រួចមកដល់ភ្នំពេញវិញ ដដែល ។ ជៀសភ្នំពេញមិនរួច ! ចិត្តទាញទៅរកផ្ទះយ៉ាហាននិង "រំចង់ទិព្វ" ទៀត ! "ចិត្តហ្នឹងវាថោកមែន !" វាចង់ទៅសំពះបាទជើងគេឲ្យអាណិតដាក់ទានស្នេហាធុនថោកមកឲ្យទៀត !"

មកដល់ភ្នំពេញម៉ោងដប់មួយយប់ ទៅដល់ "រំចង់ទិព្វ" យ៉ាហានចេញផុត ទៅដល់ផ្ទះបាត់យ៉ាហានទៀត "គិតទៅគេសប្បាយមែន ! ឲ្យតែអ្នកមិនទៅ គេក៏លែលកខាងគេដែរ ! ប្រហែលជាគេលបសើចនឹងអ្នកធាប់ឆ្នាំរួចមកហើយ !"

ស៊ី ឈឿន ទៅឃ្លាំចាំមើលទៀត ។ ម្តងនេះម៉ោងបីភ្លឺទើបឃើញគេមកដល់ទាំងគូ ។ គេចង់ឡានហើយបណ្តើរគ្នាឡើងទៅខាងលើ សាហាយ... ប្រុសកៀកកយ៉ាហានយ៉ាងស្និទ្ធទំនងដូចជាររើករអឺននឹងគ្នាណាស់ ។

អាសូរទ្រូងសង្ស្សារអរភ័ព្វដែលអង្គុយរងាម្នាក់ឯងក្នុងរថយន្តនៅតាមចិញ្ចើមថ្នល់ ។ ឃើញភ្លើងចង្កៀងខាងបើកភ្លឺឡើងព្រោងព្រាត ។ ស៊ី ឈឿន ចង់ស្ទុះឡើងទៅតាមឲ្យទាន់ក្នុងពេលនោះតែម្តង ដើម្បីចង់ដឹងមើល តើគូប្រជែងនោះមានមុខមាត់យ៉ាងណាទៅ ម្តេចក៏មានភ័ព្វសំណាងខ្លាំងម្ល៉េះ ? "ប៉ុន្តែឈ្នើយចុះ ចាំមើលដល់វាចុះមកវិញសិន" ។ រយះពេលកន្លងទៅសែនយូរ ។ ស្វាត់ច្រៀបព្ទស្ងូរទៃខ្យល់បក់ស្លឹកឈើ និងមូសហើរ និងបេះដូងខ្លួនឯង ដែលដើរញ័រខ្លាំងដោយក្តៅចិត្ត ។ ស្រាប់តែពន្លឺភ្លើងនៅក្នុងបន្ទប់រលត់សូន្យទៅវិញ ។ ប្រហែលជាគេនឹងនាំគ្នាចុះមកវិញឥឡូវហ្នឹងហើយ ហើយយ៉ាហានមុខជានឹងជូនសហាយមកដល់រថយន្តជាមិនខាន ។ ស្វាត់ឈឹង ! ...ដប់នាទី ...ម្ភៃនាទី ...មួយម៉ោងកន្លងទៅ ឥតឃើញអ្នកចុះមកវិញសោះ ។ អារម្មណ៍ស៊ី ឈឿន ស្រមៃឃើញគ្រប់បែបទាំងអស់ "មិនដឹងជាយ៉ាហានកំពុងតែននៀលថ្នមយ៉ាងដូចម្តេចទៅ ! កន្លងមួយម៉ោងទៅហើយ ! ប្រហែលជានាងនៅគេងស្ពឹក ញញឹមពេញចិត្តនឹងជាតិប្រុសដែលចូលជោកពេញសាច់ពេញឈាមនាងអស់ទៅហើយ !" ស៊ី ឈឿន ចង់ស្ទុះឡើងទៅធាក់ទំលាយទ្វារឲ្យវាឃើញណាឃើញណីតែម្តង ។ "ម្ល៉េះទៅហើយនៅក្តើនៅខ្មាសអ្វីទៀត !"

អ្នកទ្រោបក្បាលទៅនឹងចង្កូតឡាន ដៃទាំងពីរក្តោបយ៉ាងតឹងដោយឈឺចិត្ត អ្នកស្រឡាញ់ហើយទុកចិត្តស្រីនេះណាស់ ! ...ឃើញ

ក្បត់ម្ដងនៅមិនទាន់ហ៊ានថា ប៉ុន្តែម្ដងនេះវាច្បាស់ណាស់ ! ...ស្រី ខូចវានៅតែខូចដដែល ! ...ស្រីល្អបរិសុទ្ធដូចជាចន្ទ័មិនសុខចិត្តយក!

ស៊ី ឈឿន សម្រេចចិត្តដោយខ្លោចផ្សារ

"ណ្ដើយចុះកុំទៅបំបែកបំបាក់កំណាន់ចិត្តរបស់គេ... ស៊ី ឈឿន មិនត្រូវការសុំទានស្នេហារបស់យ៉ាហានទេ ហើយ ស៊ី ឈឿន មិនទៅឈ្លោះដណ្ដើមចិត្តថោកទាបរបស់ យ៉ាហានឡើយ..."

គេគេងស្ដាប់ស្គាល់នៅឯលើផ្ទះ ។ ឯស៊ី ឈឿន ស្រាំងភ្នែក ល្ហិតល្ហៃក្នុងខ្លួន បើឡានចេញទៅវិញដូចជាបាត់ជីវិតរស់ជាងពាក់កណ្ដាល ។



ស៊ុំ ឈុំ

# ព្រះភ្នំគូលែន

ម៉ោងប្រាំពីរព្រឹក ចន្ធីភ្ញាក់ឡើងនឹកឆ្ងល់នឹងមិនទាន់ឃើញបងជីដូនមួយក្រោក ។ នាងឡើងអង្រន់ទ្វារ មិនឃើញចាក់សោក៏ចូលទៅមើល ។ អ្នកប្រុសនៅគេងនៅឡើយ ចន្ធីចូលទៅជិតគ្រែលូកទៅចាប់ដៃបងហើយលាន់មាត់ថា ៖

- យី ! បងឯងដូចជាក្តៅខ្លួនខ្លាំងណាស់ ល្ងាចមិញជិតភ្លឺណាស់ទៅហើយទើបឮស្គរត្រឡប់មកវិញ បងឯងធ្វើបាបខ្លួនយ៉ាងហ្នឹងមិនកើតទេ !

សំដីហ្នឹងគួរឲ្យស្រណោះណាស់ ! ចន្ធីនៅតែអាណិតអ្នកនៅឡើយ ស្រីម្នាក់ទៀតគេភ្លេចអ្នកបាត់ទៅហើយ !

ស៊ី ឈឿនប្រាប់ទៅនាងថា ៖

អូនឯងនិយាយទូរស័ព្ទទៅ " ប៉ិយរ៉ូ " បងផង ប្រាប់ថាបងមិនស្រួលខ្លួន មិនបានទៅធ្វើការទេនៅថ្ងៃនេះ បើមានការប្រញាប់ខ្លាំង សុំឲ្យគេយកសំណុំរឿងមកឲ្យបងឯផ្ទះចុះ !

ចន្ធីធ្វើតាមបង្គាប់បងប្រុស រួចយកថ្នាំមកឲ្យអ្នកផឹក ប្រឹងថ្នាក់ប្រឹងថ្នមរួចនិយាយលេងទៅរកធ្វើ ដូចជាមិនដឹង

- យី ! ល្ងាចមិញ បើកុំតែបងឯងទៅគួរណៅ កុំអីបានទៅស្តាប់ចម្រៀងទាំងអស់គ្នានៅ " រំចង់ទិព្វ " ហើយ ។ មីមួយនោះឈ្មោះយ៉ាហានវាច្រៀងពីរោះណាស់ ប៉ុន្តែឮគេនិយាយលាន់ៗថាវាប្រើសាហាយវិញក៏ច្រើនដែរ ឮថាវាយកលោកម្នាក់នោះមានបុណ្យសក្តិយ៉ាងធំ ធ្វើជាបង្អែករបស់វាសម្រាប់បោកយកប្រាក់ទៅចិញ្ចឹមសហាយក្មេងៗ ពីរបីនាក់ទៀត ។ គេថាវាកោរលោកនោះអស់ច្រើនណាស់ទៅហើយ ហើយលោកនោះនៅតែមិនទាន់ដឹងខ្លួនទៀត !

ស៊ី ឈឿនចង់ស្ទុះដង្ហើមប្រឹងធ្មេចភ្នែកធ្វើមិនដឹង រឿងនេះវាជ្រុលពេក ! " លោកដែលស៊ីកច្រើកនោះកំពុងតែដេកអស់សង្ឃឹមនៅជិតហ្នឹង ! "

អ្នកសញ្ជឹងគិតថា ៖ " យីបើរឿងនេះគេដឹងសុសសាយដល់ម្លឹងទៅហើយ គឺប្រាកដជាយ៉ាហានមិនមែនទើបនឹងមានសាហាយពីរបីថ្ងៃនេះទេ ! "

ដល់មិនព្របងឆ្លើយថាអ្វីសោះ ចន្នីប្រឹងបន្ថែមទៅទៀត

– គិតទៅធ្វើ " សំផឹង " មានសំណាងមែន មានគេអាណិតច្រើន ហើយធ្វើអ្វីក៏មិនចេះខុសទៀត បើធ្វើជាមនុស្សល្អវិញវាចេះមិនសមត្រង់ណោះ មិនសមត្រង់ណោះជានិច្ច ។

ស៊ី ឈឿនឆ្លើយសន្ទាប់បន្ទប់ទៅវិញ

– យី ! កុំទ្រឹស្តីអ្វីច្រើនពេក គ្នាកំពុងតែឈឺក្បាលជិតស្លាប់ឯណោះទៅហើយ គិតតែឡូៗ អំពីរឿង " មីសំផឹង " ឯណាឯណោះទៅវិញ ! ចន្នីឯងជាប់សាច់ជាប់ឈាមជាមួយនឹងវាដែរឬអ្វីបានជាយកចិត្តទុកដាក់នឹងរឿងហ្នឹងខ្លាំងម្ល៉េះ ?

ខ្ញុំគ្មានឈឺក្បាលនឹង " មីសំផឹង " ហ្នឹងទេ ប៉ុន្តែខ្ញុំចេះតែនឹងអស់សំណើចនឹងលោក " អាវែក " នោះមិនចេះចប់សោះ !

ស៊ី ឈឿន ត្រូវឆ្ងន់ពេកក៏បាត់មាត់ដូចគេចុក ជញ្ជឹងគិតទៅដល់ជីវប្រវត្តិរបស់អ្នកនិងស្ត្រីទាំងពីរូប ម្តាយចន្នីនិងចន្នីគេបានជួយទំនុកបំរុងអ្នកសព្វគ្រប់ តាំងអំពីបាយទឹកផ្ទះសម្បែង ការសុខទុក្ខនៅលើគ្រួសារនេះទាំងអស់... ឯ... យ៉ាហានវិញមិនដឹងជាទើបនឹងចេញមកអីពីឯណាទេ មកដល់ដឹងតែអំពីស្រួល អំពីស្រណុក ឲ្យអ្នកទំនុកបម្រុងសព្វបែបសព្វយ៉ាង ហើយបង្កើតតែបញ្ហាស្មុគស្មាញឲ្យអ្នកដោះស្រាយគ្រប់ពេលគ្រប់វេលា បន្តិចថាត្រូវរកផ្លូវចេញអំពីចៅកែស្រីខូច បន្តិចថាត្រូវរកផ្ទះមកនៅភ្នំពេញ បន្តិចត្រូវច្រៀងដើម្បីយកប្រាក់មកទ្រទ្រង់ជីវភាពឲ្យបានសមមុខនឹងគេ ។ ដល់បានសព្វបានគ្រប់ទៅ ស្រាប់តែនៅខ្វះសាហាយថែមទៀត ! គិតទៅគំនិតផ្កាមាសវាមិនចោលពុតមែន ។ យ៉ាហានជាទឹកថ្លាដែលមានពិសពុលចន្នី ជាថ្នាំល្វីងជូរចត់ដែលរក្សាសុខភាពឲ្យអ្នកបានរីករាយមកដល់សព្វថ្ងៃ ។ ចន្នីកាចឆ្នាស់ក៏ដោយសារតែសេចក្តីស្រឡាញ់ និងចិត្តស្មោះត្រង់ពិតប្រាកដជាមួយនិងអ្នកតែប៉ុណ្ណោះ ។ យ៉ាហានស្លូតបូតមិនសូវប្រកាន់ ក៏ព្រោះតែវាគ្រប់គ្រាន់នឹងសាហាយច្រើននាក់ ប្រចាំជីវិតរបស់វាទៅហើយ វាមិនសូវស្មុគស្មាញប៉ុន្មាននឹងស្នេហារបស់អ្នកឡើយ ។ គិតទៅគួរឲ្យអាសូរចន្នី ដែលសុខចិត្តទ្រាំទៅរង់ចាំអ្នក

យូរឆ្នាំណាស់មកហើយ ! បើសិនជាយ៉ាហានវិញមិនដឹងជាវាផ្លាស់ប្តូរ ផ្លាស់សាហាយស្មូចប៉ុន្មានត្រឡប់ហើយទេ ! ដល់អ្នកធ្លាក់ឈឺសោតទៀត គឺគ្មានឃើញមុខយ៉ាហានមកនៅទ្រាំទ្រងណាសោះដែរ ឃើញទេចន្ទីនិងម្តាយចន្ទីដដែល ដែលផ្តល់ការថែទាំព្រឹកល្ងាច ថ្នាំសង្កូវលំនៅស្ថាន សម្រាប់ឲ្យអ្នកបានធូរស្រាន្តអំពីជំងឺចិត្ត ។ ដូច្នេះអ្នកចង់បូជាជីវិតឥតន័យរបស់អ្នកចំពោះករណីកិច្ចដែលអ្នកត្រូវបំពេញចំពោះចន្ទី និងគ្រួសាររបស់នាងដោយត្រូវប្រឹងទម្លាប់ចិត្តនិងវាចារបស់អ្នក ឲ្យកំសត់ជាមួយនឹងចន្ទី ឲ្យនាងបានសប្បាយដោយសារអ្នកវិញម្តង ។ អ្នកត្រូវតែបង្ខំចិត្តខ្លួនឯងឲ្យប្រឹងដើរតួថ្មីនេះ ទល់គ្នានឹងចុកឈាមស្លាប់ ឲ្យឆាប់ស្រឡះ កុំឲ្យរស់នៅខ្មាសមុខយ៉ាហានតទៅទៀត ។

នៅព្រឹកជាមួយគ្នានោះ ពេលម៉ោងប្រាំមួយភ្លឺស្រាងៗ យ៉ាហានភ្ញាក់ដឹងខ្លួន នឹករលឹកទៅដល់ប្រុស ដែលនាងស្រឡាញ់ ។ ប៉ុន្មានថ្ងៃនេះទឹកមុខក្រៀមក្រំរបស់គូនាង ធ្វើឲ្យនាងមានបារម្ភជាច្រើន ។ នាងដឹងខ្លួនថានាងមានកំហុសដោយសារពុំទាន់បានឈប់ទៅច្រៀងនៅភោជនីយដ្ឋានទឹក ។ នាងប្រុងប្រៀបនឹងធ្វើតាមចំណង់របស់សង្សារនាងទាំងអស់ដល់កាលណាចប់កិច្ចសន្យាជាមួយនឹង " រំចង់ទិព្វ " នៅខែក្រោយ ពីព្រោះនាងបានជាប់ខ្ចីប្រាក់គេមុនជាច្រើន ដើម្បីយកទៅជួយដោះទុក្ខម្តាយ ។ ប៉ុន្តែរឿងកេរ្តិ៍ខ្មាសផ្ទាល់ខ្លួននេះ នាងមិនទាន់ដែលបានជំរាបលោកប្រុសឲ្យបានជ្រាបសោះដោយនាងនឹកខ្មាសលោកពេក ។ នាងស្រឡាញ់លោកពេកទៅ ទៅជាអៀនខ្លួនមិនចង់ហ៊ានជំរាបលោកអំពីទុក្ខក្នុងគ្រួសាររបស់ខ្លួន ខ្លាចក្រែងលោកធុញទ្រាន់នឹងនាង ។ ចំនួនប្រាំឆ្នាំមកហើយ នាងខំតស៊ូដោះស្រាយ ដោយស្វាត់អាចកំបាំងតែម្នាក់ឯង ។

នៅក្នុងបន្ទប់នាងដែលនៅងងឹតនៅឡើយ ឃើញស្រមោលមនុស្សជំទង់ម្នាក់ដើរចូលថ្នមៗ ទៅក្នុងដំណេកនាងទៅបើកបង្អើប

មុងឡើងហើយឱនទៅថើបនាងដោយស្និទ្ធស្នាល ។ ពូសំលេងយ៉ាហានរួសរាយទៅរក

– អីបងនីឯងភ្ញាក់ហើយ ! ម្ដេចក៏ប្រញាប់ក្រោកម្ល៉េះ អ្នកប្ដីសម្លាញ់ឯង ?

ពូសំលេងគួកំដរឆ្លើយតបមកវិញដោយកំប្លែង

– ចុះដេកធ្វើអ្វី បើប្រពន្ធគេដាក់ឯងក្រៅបន្ទប់ទៅហើយ !

ពូយ៉ាហានអង្វរទៅវិញជាល្បែង

– បើអីចឹងគេងមកអ្នកប្ដី ចង់ធ្វើអ្វីក៏ធ្វើមកឲ្យតែធ្វើកើត

នាងនីធ្វើជាកេះកៀវយ៉ាហាន ហើយសើចចំអន់គ្នាទៅវិញទៅមក

– អញមិនដឹងធ្វើយ៉ាងម៉េចកើតទេវ៉ី ជាមួយនឹងស្រីអីធ្មឹងៗដូចថ្មអីចឹង !

យ៉ាហានក្តិចសម្លាញ់ស្រី ហើយផ្ទុញផ្ទាលទៅឲ្យវិញ

– ជាងវាមិនកើត ទៅបន្ទោសដែក ! បើអ្នកប្រុសឯងវាសំប៉ាតឡាតអីចឹង ចង់ធ្វើឲ្យគេរំភើបញាប់ញ័រយ៉ាងដូចម្តេច កើត !... ។ មើល ! ឈប់និយាយលេង... ហេតុអ្វីក៏បងនីឯងគេងមិនលក់យប់មិញ ? ផ្ទះខ្ញុំវាមិនសមនឹងបងនីឯងឬអ្វី ?

– កុំនិយាយផ្ដេសផ្ដាសអីចឹង ! តាមពិតគឺមករំពឹបងនៅតែនឹកត្រេកអរនៅឡើយ នឹងបានអ្នកមីងម្ដាយយ៉ាហានឯងគាន់រួចរំពីទុក្ខទោសតាំងអំពីយប់មិញ ។

យ៉ាហានដកដង្ហើមធំ

– ហ៊ី ! ប្រាំឆ្នាំ ! បងនីអើយបងនី ! ប្រាំឆ្នាំនៅក្នុងឃុំឃាំងម្ដាយខ្ញុំគាន់ខ្លាសគេណាស់ ! ហ្នឹងពីព្រោះតែអាឌីចុងហានេយ្យរបស់ខ្ញុំ !

– ល្ហើយឥឡូវវារួចរាល់អស់ទៅហើយ កុំនឹកនាអីច្រើនទៀតអូនឯងក៏មិនខាតប៉ុន្មានដែរ ពីព្រោះរឿងអភ័ព្វនេះវាបាននាំអូនឯងឲ្យមករកឃើញសង្សារមួយយ៉ាងគាប់ចិត្តដែរ ។

យ៉ាហានដកដង្ហើមធំម្ដងទៀត

– ខ្ញុំអាណិតបង ស៊ី ឈឿន ណាស់ ឋានៈរបស់គាត់មិនសមនឹងមកយកស្ត្រីដែលខូចព្រហ្មចារីដូចរូបខ្ញុំសោះ !

– អូនឯងចោទបន្ទោកខ្លួនឯងខ្លាំងៗវាមិនសមទេ តោងអូនឯងគិតថា ព្រហ្មចារីនេះក៏មិនមែនអូនឯងបាត់បង់ដោយចេតនាឡើយ ។

– ចាំសបងនី តែខ្ញុំនឹកឃើញដល់រឿងអាឪចុងតិរច្ឆានហ្នឹងវាបង្ខំខ្លួនប្រាណខ្ញុំឡើង ខ្ញុំចង់តែទៅគាស់ខ្មោចវាយកមកចិញ្ច្រាំថែមទៀត ! បើសិនណាជាវាមិនទាន់ស្លាប់ ខ្ញុំមុខជាទៅសម្លាប់វាឲ្យទាល់តែបាន !

កំហឹងរបស់យ៉ាហានធ្លាយដូចបាក់ទំនប់ ហូរចេញមកអំពីអតីតកាល ។ នាងនីប្រឹងឃាត់ទៅទៀត

– ណ្ហើយវាហួសទៅហើយ ! អាចង្រៃហ្នឹងសោតទៀតក៏វាស្លាប់ហែហោងទៅហើយដែរ... ។

– ចាំស ប៉ុន្តែវាស្លាប់ ដោយទាញម្តាយខ្ញុំឲ្យចូលគុកជំនួសវា ។ ម្តាយខ្ញុំមិនគួរនឹងទៅជ្រលក់ដៃរបស់គាត់នៅក្នុងឈាមគគ្រិចរបស់អាមនុស្សថោកហ្នឹងសោះ ! នាំឲ្យតែជាប់ទោសដល់ខ្លួន !

– អើ ! មិនឲ្យគាត់រត់ចូលទៅជួយយ៉ាហានឯងយ៉ាងដូចម្តេចកើត ! គាន់ជាស្ត្រីគាន់គិតអ្វីទាន់ ! គាត់ឮសូរកូនស្រែកឲ្យជួយហើយគាត់ត្រូវតែប្រទះដៃនឹងរបស់អ្វីក៏ប្រើរបស់ហ្នឹងទៅ ! គាត់ចាប់បានញញួរ គាត់ពួយក្បាលអាហ្នឹងមួយញញួរដែរទៅ ! បើគាត់សំពងក្បាលវាតិចពេក វាមុខជាសំពងគាត់វិញជាមិនខាន ហេតុហ្នឹងហើយបានជាគាត់ពើតឲ្យល្មមតែវាគ្មានផ្លូវមកវិញកើត រួចវាជ្រុលដៃគាត់បន្តិចទៅ ... រួចវាងាប់ទៅ ! ...

– គួរតែដៃខ្ញុំវិញទេដែលត្រូវសម្លាប់វា ដើម្បីនឹងសងសឹកអានាគតរបស់ខ្ញុំដែលវាបានបំផ្លាញ ។ សូវឲ្យជាប់គុករូបខ្ញុំទៅចុះបំណាច់នឹងខូចព្រហ្មចារីយ៍អស់ទៅហើយ ! ឲ្យវាអាក្រក់ទៅឈើ្លប ម្នាក់ទៅចុះ ! ។ ម្យ៉ាងទៀតខ្ញុំនឹកឡើងខ្ពើមទៅដល់អ្នកសប្បុរសរបស់អ្នកជិតខាង ដែលគ្រាន់តែឃើញគ្រួសារខ្ញុំកើតរឿងនេះភ្លាម

ក៏ស្រាប់តែនាំគ្នាមើលងាយឥតពិចារណាមកលើរូបខ្ញុំនឹងរូបម្ដាយខ្ញុំ ដែលជាអ្នករងគ្រោះនុ៎ះ ! គេចោទថាខ្ញុំនិងរូបម្ដាយខ្ញុំមិនខុសអ្វីអំពីអាពុកចុងខ្ញុំទេ សុទ្ធតែមីស្រីចង្រៃ ម៉ែនិងកូនប្រកាប់ប្រចាក់ដណ្ដើមប្ដីគ្នា ធ្វើឲ្យខ្ញុំនឹកអស់សង្ឃឹម រកទីពឹងលើអ្នកឯណាឲ្យជួយការពារកេរ្តិ៍ខ្មាសរបស់ខ្ញុំបន្តិចបន្តួចគ្មាន ។ ខ្ញុំតាមអ្នកម្ដាយខ្ញុំទៅដល់ក្នុងគុក ខ្ញុំអង្វរគាត់កុំឲ្យព្រួយពេក ខ្ញុំនឹងធានារ៉ាប់រងរកមធ្យោបាយគ្រប់បែប ដើម្បីនឹងមកជួយរំដោះទុក្ខទោសរបស់គាត់ ឲ្យឆាប់បានស្រាលឲ្យទាល់តែរួចអំពីទីឃុំឃាំង ។ រូបខ្ញុំដែលជាស្ត្រីអស់ព្រហ្មចារីដែលគេលែងរាប់អានទៅហើយ តើខ្ញុំមានមធ្យោបាយអ្វីឲ្យទាន់ហន់ទាន់ចិត្តក្រៅអំពីទៅធ្វើ "សំផឹង" ដើម្បីនឹងរកប្រាក់ឲ្យបានឆាប់សម្រាប់យកមកជួយម្ដាយ ពិតមែនតែខ្ញុំខ្ចីមនិងមើលងាយភេទប្រុសជាខ្លាំងដែលខ្ញុំនឹកសុទ្ធតែប្រហែលៗគ្នានឹងអាឪចុងរបស់ខ្ញុំទាំងអស់ ។ ខ្ញុំទៅនៅសៀមរាបបានជាងកន្លះខែ ស្រាប់តែទៅជួបនឹងបង ស៊ីឈឿន ដែលធ្វើឲ្យខ្ញុំជួបប្រទះនឹងសេចក្ដីអាណិត សេចក្ដីស្រឡាញ់និងសេចក្ដីសប្បាយហួសវិស័យនឹងស្មាន ។ ខ្ញុំជាប់ចិត្តនឹងគាត់ទាល់តែភ្លេចពិចារណាថាខ្លួនជាស្ត្រីឥតព្រហ្មចារី ឥតមានអ្វីជាតម្លៃសម្រាប់ចិត្តគេបានឡើយ ។

នាងនីលើកខ្នើយឲ្យគ្រវាត់ទៅចុងជើង

- យី៎ះ ! យ៉ាហានឯងស្មុគស្មាញណាស់ ! ឲ្យតែលោកស្រឡាញ់ខ្លួន ចុះវាទៅទាស់អ្វីនឹងគ្មានព្រហ្មចារីនោះ ពីព្រោះលោកប្រុស គឺដូចជាមិនដែលពួសួរសួរកព្រហ្មចារីរបស់យ៉ាហានឯងដែរ ។ ស្ត្រីខ្លះមានព្រហ្មចារីសន្ធឹកសន្ធាប់ ប៉ុន្តែដល់រៀបការរួច ស្រាប់តែដើរផិតប្ដីទៅវិញក៏មានដែរ ។ កុំឆោតពេក ឲ្យតែគេស្រឡាញ់យើង ហើយយើងស្រឡាញ់គេវាគ្រប់គ្រាន់ទៅហើយ កុំទ្រើស្ដីព្រហ្មចារីអ្វីច្រើនពេក !

យ៉ាហានដូចជាធូរទ្រូងបន្តិចឡើងវិញ

- ខ្ញុំអរគុណហើយបងនី ។ ម្យ៉ាងទៀតប៉ុន្មានថ្ងៃនេះបងនីឯងដើរតួរប្រុសសមណាស់ បើកុំតែបានបងនីឯងដើរតួរជាប្ដីខ្ញុំ មិនដឹង

ជាខ្ញុំអាចមានអ្នកឯណាជាទុកចិត្តឲ្យជូនទៅស្អូម្ដាយខ្ញុំនៅក្នុងគុក ក្នុងពេលខ្លះបានឡើយ

– អូនឯងក៏ប៉ិនប្រសប់គិតការណាស់ដែរ ខាងផ្នែកតុលាការ លទ្ធផលក៏បានពេញចិត្តហើយ ។ អ្នកមីងក៏ទទួលប្រាក់កាសច្រើន គួរសមដែរ គាត់បានទៅជួបជុំនឹងកូនចៅគាត់ទាំងអស់នៅឯក្រចេះ វិញហើយ ។

យ៉ាហានបញ្ជាក់ទៅទៀត

– ដល់ឆ្នាំក្រោយ ខ្ញុំចង់អញ្ជើញគាត់មកនៅឯភ្នំពេញជាមួយ នឹងខ្ញុំដែរ ពីព្រោះដល់ខ្ញុំមានកូន មិនដឹងជាបានអ្នកណាជួយមើល ខុសត្រូវទេ

– ត្រូវហើយ គួរតែអញ្ជើញគាត់មកឯណោះដែរ ។

គាត់ក៏ដូចជាគ្មានចង់ទៅនៅឆ្ងាយពីយ៉ាហានឯងឡើយ ។

– ចាំស ! ឥឡូវឲ្យគាត់អញ្ជើញទៅនៅឯណោះសិនចុះ ដើម្បី ឲ្យរឿងនេះវាស្ងាត់បាត់បន្តិចទៅសិន ពីព្រោះឥឡូវនេះវាដូចជានៅ ថ្មីៗណាស់ កុំឲ្យបងស៊ី ឈឿនគាត់ខ្មាសគេដោយសារគ្រួសាររបស់ ខ្ញុំ ។

នាងនីរអាណិតយ៉ាហានណាស់ ធ្លាប់កំសត់កម្រជាមួយគ្នាតាំង អំពីសៀមរាប ជួយត្រេកអរនឹងឃើញមិត្តនារីបានមកជួបជុំជាមួយ នឹងលោកស៊ី ឈឿននៅឯភ្នំពេញ ហើយតែងតែមកជួយចាត់ចែង កិច្ចការផ្សេងៗ រាល់តែពេលដែលយ៉ាហានត្រូវការផ្ដាំឲ្យនាងមក ។ សព្វថ្ងៃនាងជាតួរងមួយរូបនៅក្នុងក្រុម "បច្ចុប្បន្នភាពយន្ត" ដែល កំពុងបង្កើនសកម្មភាពកាន់តែល្បីល្បាញ ។

កំពុងបង្កើនសកម្មភាពកាន់តែល្បីល្បាញ ។ ប៉ុន្មានថ្ងៃនេះនាងនីបាន ចេញមកដើរប្រុសការពារយ៉ាហានក្នុងឆាកជីវិតដោយអង់អាច បាន នាំនាងចូលទៅជួបនឹងម្តាយក្នុងពន្ធនាគារ ទៅគិតការខាងតុលាការ និងរត់ធ្វើសំបុត្រផ្សេងៗ ដើម្បីសម្រេចការដោះលែងម្តាយឲ្យរួចអំពី ឃុំឃាំង ។ ល្ងាចម្សិលមិញពេលម៉ោងមួយភ្លឺមិត្តនារីទាំងពីរនាក់ បានជូនអ្នកមីងម្តាយយ៉ាហាន ឡើងឡានទៅក្រចេះជាមួយនឹងបង ប្រុសរបស់យ៉ាហាន ព្រមទាំងបានប្រគល់ប្រាក់ជូនគាត់មួយម៉ឺនរៀល ផងសម្រាប់ការរស់នៅរបស់គាត់តទៅមុខទៀត ។ បងប្រុសយ៉ាហាន សព្វថ្ងៃក៏មានមុខរបររកទទួលទាន ហើយអាចជួយចិញ្ចឹមខែទាំម្តាយ បាន ទំរាំតែយ៉ាហានមានការងារនិងផ្ទះសម្បែងរឹងប៉ឹងខ្លួនឯងនៅ ភ្នំពេញ ។

ថ្ងៃបន្តបន្ទាប់មក នាងនីដែលឈប់ដើរតួប្រុសទៀតហើយ សុខចិត្តមកនៅកំដរយ៉ាហាន ដើម្បីជូនឡានមិត្តនារីពីផ្ទះទៅច្រៀង នៅ "រំចង់ទិព្វ" រៀងរាល់រាត្រី ។

ភ្ញៀវនៅ "រំចង់ទិព្វ" សង្កេតឃើញតួឯកចម្រៀងមិនសូវ រីករាយដូចពីដើមឡើយ ។ កាលណានាងច្រៀងបទ "ចំការសំរោង" ទឹកមុខនាងរឹតតែលន្លង់លន្លោចស្ទើរតែនឹងស្រក់ទឹកភ្នែក ។ នាង ច្រៀងរង់ចាំបុរសដែលនាងចេះតែ... សង្ឃឹមថាបន្តិចទៀតនឹងវិល ត្រឡប់មករកនាងវិញ ។ មួយរាត្រី... ពីររាត្រី... មួយអាទិត្យ... ពីរ អាទិត្យចេះតែកន្លងផុតទៅ សេចក្តីសង្ឃឹមក៏ចាប់រលាយ ធ្វើឲ្យភាព ងងឹតកាន់តែរាលចូលមកគ្របលើជីវិតរបស់នាង ។ "រំចង់ទិព្វ" ប្រែ ជាសោះកក្រោះ បាត់អស់នូវសេចក្តីសប្បាយ នាងកាន់តែស្អប់ ភោជនីយដ្ឋាននេះដែលបានពង្រត់គូរបស់នាង ។ សម្លេងភ្លេងធ្វើ ឲ្យរលឹកនឹកឃើញដល់គ្រាដែលនៅជួបជុំគ្នា ។ ជីងីដែលរកនិយាយ មិនកើតបានជ្រៀតចូលស៊ប់មកសម្ងំបន្ទុំពីស នៅក្នុងទ្រូងរបស់នាង។

ការច្រៀងនៅ "រំចង់ទិព្វ" អស់មានន័យអ្វីទៀតហើយចំពោះ យ៉ាហាន ។ ច្រៀងធ្វើអ្វី ! ច្រៀងឲ្យអ្នកណាស្តាប់ ! ច្រៀងផ្គាប់ចិត្ត អ្នកណា ? នាងនឹកអាសូរទៅដល់ពាក្យអង្វររបស់ ស៊ី ឈឿន

ដែលនាងមិនទាន់បានធ្វើតាមនៅឡើយ ។ នាងរង់ចាំឲ្យតែលោកប្រុសអញ្ជើញមក នាងនឹងសុខចិត្តលុតជង្គង់សុំទោសទទួលធ្វើតាមចិត្តលោកទាំងអស់ ។

រាល់ល្ងាចនាង នី ជូនយ៉ាហានត្រឡប់មកផ្ទះវិញនៅវេលាម៉ោងដប់យប់ ។ យ៉ាហានលែងសូវនិយាយស្ដីអ្វីឡើយ ច្រើនតែចេញទៅអង្គុយត្រមង់ត្រមោចតែម្នាក់ឯង នៅឯរានហាលក្រៅ ។ មួយម៉ោង ពីរម៉ោង នាងនៅតែអង្គុយមិននិយាយមិនស្ដី ។ ពេលវេលាមានដំណើរយឺតណាស់ នាងចេះតែទន្ទឹង "កាលណាទៅទើប ភ្លឺ កាលណាទៅទើបបងអញ្ជើញមក !" បើចេះតែនៅរង់ចាំយ៉ាង ហ្នឹង មិនដឹងជាកាលណា ទើបបានផុតមួយជាតិនេះ ? ។ សតិយ៉ាហានវិលវល់តប់ប្រមល់គ្មានស្រាកស្រាន្ត ថ្ងូរនាងក្ដៅស្នេញ នាងនឹករលឹកទៅដល់ដៃទន់ភ្លន់របស់ប្រុសដែលធ្លាប់ថ្នាក់ថ្នមនាងក្នុងពេលដែលនាងឈឺ ។ នាងស្ដាយណាស់នឹងសម្ដីងងឹតល្ងង់របស់នាង ដែលបានធ្វើឲ្យ ស៊ី ឈឿនអន់ចិត្ត ស្ដាយណាស់នឹងមិនបានទទួលធ្វើតាមពាក្យអង្វររបស់គេភ្លាមៗ ។ ថប់ណាស់តែនាងត្រូវស្ដាយកំហុសរបស់នាងអស់មួយជីវិត ! ។ ទឹកភ្នែកហូររហាមមកលើថ្ពាល់ មកលើបបូរមាត់ ស្រក់មកលើសំពត់ នាងយកដៃមកខាំទប់សេចក្ដីទុក្ខ ទុក្ខតែម្នាក់ឯង បន្ទោសតែខ្លួនឯង ។

នាងនីយកបបរចេញតាមទៅរានហាលក្រៅ

- អូនឯងអត់បាយអត់ទឹកយ៉ាងហ្នឹងមុខជាឈឺហើយ !

យ៉ាហាន យកដៃទប់ចានបបរ ដែលនាងនីលើកដាក់ទៅលើគ្រែរនាបជាមួយនឹងជ្រក់ត្រសក់ ។ ម្ហូបនេះ យ៉ាហាន ធ្លាប់តែចូលចិត្ត ប៉ុន្តែពីរបីថ្ងៃមកហើយ នាងញ៉ាំតែទឹកក្រូចច្របាច់បន្តិចបន្តួច ហើយកាន់តែព្រងើយកន្តើយនឹងម្ហូបអាហារដែលនៅជិតខ្លួនទាំងប៉ុន្មាន ។ នាងនីកាន់តែបារម្ភនឹងមិត្តនារីកំសត់កម្ររបស់នាង ។

- អាទិត្យក្រោយអូនឯងត្រូវប្រឡងផងណា ! ញ៉ាំអ្វីបន្តិចបន្តួចទៅ លោកប្រុសគង់តែវិលមករកអូនឯងវិញទេ ។

យ៉ាហានតបមកវិញដោយអស់សង្ឃឹម

- បងនី ! អូនគិតទៅឃើញថា អូនមានកំហុសធំណាស់ចំពោះបង ស៊ី ឈឿន គាត់អង្វរសុំចិត្តអូនចំពោះតែរឿងបន្តិចបន្តួចសោះ មិនគួរអូនទៅជាធ្វើជូនគាត់មិនកើត ល្មមឲ្យគាត់អន់ចិត្តខ្លាំងនឹងអូនដែរ ។

ថាតែប៉ុណ្ណោះនាងយំអណ្តើតអណ្តក ហើយបន្ទោសខ្លួនឯងតទៅទៀត "អូននឹកស្អប់ខ្លួនឯងណាស់បងនី... រូបហ្នឹងមិនសមនឹងនៅរស់តទៅទៀតទេ... " ។ នាងនីស្ទុះទៅអង្អែលល្អងលោមសម្លាញ់ដូចជាបងស្រីអង្វរប្អូនបង្កើត ៖

- អូនឯងកុំគិតអីចឹង ! កុំអាលអស់សង្ឃឹមអ្វីក្រែងលោកប្រុសមានកិច្ចរវល់អ្វីចំឡែកក៏មិនដឹង ចាំបងទៅស៊ើបសួរឲ្យ ។

មួយអាទិត្យកន្លងទៅទៀត នៅតែបាត់ដំណឹងឈឹង ។ ព្រឹកមួយយ៉ាហានត្រឡប់មកពីផ្សារវិញ ប្រញាប់ប្រញាល់រត់ឡើងទៅប្រាប់នាងនីដែលនៅចាំផ្ទះ

បងនី ! បងនី ! អូនប្រឡងជាប់ហើយ គេចាឲ្យអូនទៅធ្វើការក្នុងក្រុមហ៊ុនអាកាសចរណ៍នៅខែក្រោយ ។ អូនចង់ឲ្យបងឈឿនជ្រាបដំណឹងនេះណាស់ ពីព្រោះអូនបានរៀនសូត្រនិងបានធ្វើការត្រឹមត្រូវ ក៏ដោយសារតែគាត់ទាំងអស់ ។ រួចបងនីឯងជូនខ្ញុំទៅ "រំចង់ទិព្វ" មួយភ្លែតឥឡូវនេះ ទៅប្រាប់គេថាខ្ញុំចប់កិច្ចសន្យានៅថ្ងៃសៅរ៍ខាងមុខនេះហើយ ។ ចាប់អំពីថ្ងៃអាទិត្យក្រោយនេះទៅខ្ញុំលែងទៅច្រៀងទៀតហើយ ។ ខ្ញុំចង់ឲ្យបងឈឿនជ្រាបរឿងនេះដែរ ។

ទាំងពីរនាក់ក៏នាំគ្នាចេញប្រញាប់ប្រញាល់ទៅ ។

លុះត្រឡប់អំពី "រំចង់ទិព្វ" មកវិញ ម៉ោងប្រហែលជាដប់មួយព្រឹក នាងនីកំពុងតែរៀបចំបាយបង្ហឹឲ្យយ៉ាហានញុំា ស្រាប់តែលេចពូញ៉ិបទៅដល់ មានទឹកមុខចំណែក ។

យ៉ាហានសួរទៅគាត់មិនបង្អង់យូរ

- ពូញ៉ិបឯងមកជាមួយនឹងអ្នកណា ?

- បាទ ខ្ញុំមកតែម្នាក់ឯងទេ លោកសុតប្រើខ្ញុំឲ្យមកជំរាបអ្នកជាប្រញាប់ ។

- មានការអ្វីចម្លែកឬ ?

- បាទ !

- ពូឯងនិយាយឲ្យឆាប់ទៅមើល !

ពូញ៉ិបនិយាយទាំងរអាក់រអួល

- ចុះអ្នកស្រីឥតជ្រាបអ្វីចម្លែកទេឬ ?

- ចាស ! ចម្លែកខ្លះដែរ ពីព្រោះបាតលោកប្រុសជិតម្ភៃថ្ងៃទៅហើយ មិនដែលឃើញអញ្ជើញមកសោះ ពូញ៉ិបឯងដឹងការអ្វីឬ?

ទឹកមុខពូញ៉ិបធ្វើឲ្យយ៉ាហានឡើងស្លាំង បារម្ភក្រែងលោកប្រុសមានគ្រោះថ្នាក់អ្វី

- និយាយទៅពូញ៉ិប... ប្រាប់ខ្ញុំផង... វាយ៉ាងម៉េច ?

ពូញ៉ិបហុចសំបុត្រមួយមកនាង ។ យ៉ាហានហូតយកប័ណ្ណពីរផ្ទាត់ចេញពីក្នុងស្រោមមកលាមើលយ៉ាងយូរ នាងថ្លោះទឹកមុខមិនចេញស្តី ហើយដើរធឹងធោងចូលទៅក្នុងបន្ទប់គេង ទៅទ្រោបឃ្នំនៅលើគ្រែ ។ នាងនីដែលរត់ចូលទៅតាមប្រញាប់ទាញយកប័ណ្ណមកមើលឃើញថា ជាសំបុត្រអញ្ជើញភ្ញៀវទៅអាពាហ៍ពិពាហ៍លោកស៊ី ឈឿន និង នាងចន្ទី ដែលត្រូវធ្វើពិធីជប់លៀងនៅភោជនីយដ្ឋាន "វំចង់ទិព្វ" នៅល្ងាចថ្ងៃសៅរ៍ខាងមុខនេះ ។

នាងនីយល់ដល់ទំហំរឿងដែលទើបនឹងលេខឡើង មកដល់ថែមទៀត ក៏ប្រាប់ពូញ៉ិបថា "ពូឯងកុំអាលទៅណា ចាំជូនខ្ញុំទៅរកលោក ស៊ី ឈឿនសិន" ។

នាងប្រឹងអង្វរចិត្តមិត្រនារី

- អូនឯងកុំអាលអស់សង្ឃឹមអ្វី ពិតមែនតែបានដំណឹងយ៉ាងនេះក៏ដោយ ក៏បងនៅតែធានានឹងទៅរកលោក ស៊ី ឈឿនឲ្យអូនឯងក្នុងគ្រានេះជាមិនខាន ពីព្រោះរឿងនេះវាមិនសមនឹងទៅជាយ៉ាងដូច្នេះសោះ !

យ៉ាហានឃាត់ទៅសម្លាញ់វិញ

- កុំទៅរកគេធ្វើអ្វីបងនី ទុកឲ្យគេសប្បាយចុះ ។

- អូនឯងកុំអាលព្រួយខ្លាំងពេក វាមិនទាន់ជាហួសអ្វីនៅឡើយទេ ។ ម្យ៉ាងទៀតអូនឯងបានប្រឡងជាប់ ហើយបានកន្លែងធ្វើការត្រឹមត្រូវទៅហើយ អូនឯងអាសង្ឃឹមលើខ្លួនឯងបានទាំងអស់អំពីថ្ងៃនេះតទៅមុខ...

យ៉ាហានស្តាប់មិនបានទៀតទេ ។ ចំពោះរូបនាងអស់មានរឿងប្រឡង អស់មានរឿងធ្វើការអ្វីទៀតហើយ ។

នាងនីមិនហ៊ានទៅចោលយ៉ាហានក៏ខ្សឹបៗ ប្រើពូញ៉ឹបឲ្យទៅស៊ើបសួររកលោក ស៊ី ឈឿន ឲ្យដឹងថាលោកនៅផ្ទះ ឬទេ រួចសឹមត្រឡប់មកប្រាប់នាងវិញឲ្យយ៉ាងឆាប់ ។ មុននឹងពូញ៉ឹបចេញទៅនាងនីបានផ្តាំហើយផ្តាំទៀតថាឲ្យរកលោក ស៊ី ឈឿនឲ្យសព្វកន្លែងឯផ្ទះ ឯ"ប៊ុយរ៉ូ" ឯកន្លែងឯទៀតដែលលោកធ្លាប់អញ្ជើញទៅ ។

យ៉ាហានចាប់មានអាការៈប្លែកអំពីសព្វដងជាច្រើន ។ នាងបើកទូរើសំពត់អាវយកមកមើល មករៀបចំ ។ សំពត់ហូលយ៉ាងល្អនេះលោកបានទិញឲ្យនាង នាងស្រឡាញ់ណាស់ មិនសូវទាំងដែលហ៊ានស្លៀកប៉ុន្មានផង ។ នាងលើកសំពត់ឡើងមើល ទឹកភ្នែករលីងរលោង ។ អាវហូលនេះលោកចូលចិត្តឲ្យនាងពាក់ជាមួយនិងសំពត់ហូល នៅពេលដែលចេញដើរលេងជាមួយគ្នា ។ ប្រអប់ម្សៅនិងទឹកអប់នេះ លោកបានទិញឲ្យនាងដែរ នាងទើបនឹងបើកប្រើពីរបីដង... ។

ល្ងាចបន្តិច ឃើញពូញ៉ឹបត្រឡប់មកវិញ មកខ្សឹបគ្នាធ្វើភ្នែកឡិងឡង់ជាមួយនឹងនាងនី "អស់មធ្យោបាយនឹងរកលោក ស៊ី ឈឿនទៀតហើយ" ។ បុគ្គលិកនៅឯការិយាល័យរបស់លោកក៏មិនបានដំណឹងអ្វីច្បាស់ដែរ គ្រាន់តែបានដឹងថា លោកបានសុំច្បាប់ឈប់ចំនួនមួយខែតែប៉ុណ្ណោះ ។ តាមពិតចន្នីបានចាត់គ្នា និងចាត់ការយ៉ាងតឹងរ៉ឹង ដើម្បីពង្វាងស៊ី ឈឿន មិនឲ្យជួបនឹងយ៉ាហាន មិនឲ្យអ្នកបានដំណឹងអ្វីពិតអំពីនាង ឲ្យចេះតែជឿជានិច្ចថា យ៉ាហានពិតជាក្បត់ និងភ្លេចអ្នកហើយ ។ ទទួល ស៊ី ឈឿន មានជំនឿហ្នឹងស្រាប់មកហើយផង មធ្យោបាយបំបែកបំបាក់របស់ចន្នីរឹងរឹតតែមានប្រសិទ្ធិភាព ។

## ចំពូក ៧
## ភ្លេងបើកវាំងនន

*ថ្ងៃនេះជាថ្ងៃរៀបអាពាហ៍ពិពាហ៍ ស៊ី ឈឿន និងនាង ចន្ទី ។ ល្ងាចនេះពិធីជប់លៀងយ៉ាងធំ នឹងត្រូវធ្វើឡើងនៅភោជនីយដ្ឋាន "រំចង់ទិព្វ" ។ នាងនីនិងពូញ៉ឹបរត់រក ស៊ី ឈឿន តាំងពីព្រលឹមឥតបានសំរេចអ្វីសោះ ។ គេរៀបការនេះសែនចំឡែក ដោយចូលរោងគ្មានកូនកំលោះដោយសូត្រមន្តថ្ងៃរសៀលមានតែកូនក្រមុំ និងសំលៀកបំពាក់របស់លោកប្រុស ។ គេលាក់កូនកំលោះទុក ចាំបញ្ចេញដល់ពេលជប់លៀងភ្ញៀវតែម្តង ។ ចន្ទីបានតាំងចិត្តនឹងបំផ្លាញយ៉ាហានឲ្យចប់ចុងចប់ដើម ។ សេចក្តីឈឺចិត្តនិងគំនុំទាំងប៉ុន្មាន បានយកមកប្រើសងសឹកក្នុងពេលហ្នឹងទាំងអស់ ។*

*ម៉ោងប្រាំពីរយប់ នៅមុខ "រំចង់ទិព្វ" រថយន្តចតត្រៀបត្រាជាជួរវែងតាមបណ្តោយចិញ្ចើមថ្នល់ទាំងសងខាង ។ នៅឯក្រោមឃើញភ្ញៀវមីរដេរដាស ។ ភ្លើងពណ៌ភ្លឺជាខ្សែច្រវាត់ច្រវែងជាមួយនឹងប៉េងប៉ោងដែលអណ្តែតរវើករវាម ។*

*កូនក្រមុំមុខរីកចិញ្ចាច ឈរជិតកូនកំលោះ ដែលស្រពាប់ស្រពោន ។*

*ល្ងាចនេះ យ៉ាហាននៅឯផ្ទះប្រឹងសង្រួមចិត្ត ឲ្យនឹងដូចជាមនុស្សដែលគេត្រូវយកទៅប្រហារជីវិតក្នុងពេលខាងមុខដ៏ខ្លី ។ នាងសង្ឃឹមថាជាសេចក្តីវេងកម្មរបស់នាង នឹងបានចប់នៅពេលល្ងាចនេះ ។ កូននៅក្នុងពោះបំរះកាន់តែញឹកញាប់ ។ នាងនឹកអាណិតដល់បុត្រជាខ្លាំង "បើកូនកើតមកក៏គង់តែព្រាត់ឪពុក បើម្តាយនៅរស់ក៏គង់តែព្រាត់ប្តី !" ទឹកភ្នែកនាងស្រក់ផាត់លាក់ដោយស្ងៀមស្ងាត់ នាងយកដៃសង្កត់ចុងដង្ហើមដែលកាន់តែណែនខ្លាំង ។*

ដល់ម៉ោងប្រាំពីរយប់ យ៉ាហានតឿននាងនីឲ្យជូនទៅច្រៀងនៅ "រំចង់ទិព្វ" ដូចរៀងរាល់ថ្ងៃ ។ ល្ងាចនេះនាងនីដូចជាមិនចង់អើពើនឹងការកិច្ចនេះសោះ ។

- យ៉ាហានឯងចាំបាច់ទៅច្រៀងធ្វើអ្វីទៀត ពីព្រោះត្រូវចប់កិច្ចសន្យាល្ងាចនេះហើយ ។

យ៉ាហានបញ្ជាក់ទៅសំឡាញ់វិញ

- ពីព្រោះតែត្រូវចប់ល្ងាចហ្នឹងហើយ បានជាខ្ញុំត្រូវតែទៅច្រៀងបញ្ចប់តែម្តង ដើម្បីឲ្យបានចប់ចុងចប់ដើម ។ បំណាច់នឹងធ្លាប់ទៀតទាត់តាំងពីដើមមកហើយ ខ្ញុំមិនគួររុញរានឹងបញ្ចប់មួយល្ងាចនេះទៀតទេ ។

- យ៉ាហានឯងមិនខ្មាសគេទេឬអ្វី ? គេទៅរៀបការជាមួយនឹងប្រុសរបស់ឯង រួចឯងទៅច្រៀងឲ្យគេស្តាប់ថែមទៀត !

យ៉ាហានមិនមែនស្ពឹកដល់ថ្នាក់នោះឡើយ ប៉ុន្តែនាងមានយោបល់ផ្សេងអំពីនាងនី

- ខ្ញុំមិនមែនទៅច្រៀងឲ្យលោកណា នាងណាស្តាប់ទេ ខ្ញុំទៅច្រៀងបញ្ចប់តែ "កុងត្រា" របស់ខ្ញុំតែប៉ុណ្ណោះ ។ បើសាមីខ្លួនគេដាច់ចិត្តនាំគ្នាទៅរៀបការនៅ "រំចង់ទិព្វ" ខ្ញុំក៏ត្រូវតែដាច់ចិត្តនឹងទៅច្រៀងនៅ "រំចង់ទិព្វ" ដែរ ។

នាងនីប្រឹងរកមធ្យោបាយនឹងឃាត់មិត្រនារីរបស់ខ្លួន

- ឲ្យបងសុំចិត្តអូនឯងម្តងទៅចុះ អូនឯងធ្វើអ្វីក៏បងមិនសូវដែលហ៊ានឃាត់ដែរ ប៉ុន្តែចំពោះរឿងនេះ ឲ្យបងសុំឃាត់ម្តងទៅចុះ!

យ៉ាហានអង្គុយសញ្ជប់សញ្ជឹងមួយស្របក់មិនចេញស្តី រួចក្រោកទៅមុជទឹកតាក់តែងខ្លួន ។ សម្លាញ់របស់នាងក្រោកទៅតាម

- អូនឯងគិតយ៉ាងម៉េចហ្នឹង ?

- អូនត្រូវតែទៅច្រៀង បើបងនីឯងមិនជូនអូនទៅ អូនទៅតែម្នាក់ឯងក៏បានដែរ ។

នាងនីរវៀបណ្តើរ រត់ទៅស្លៀកពាក់ខ្លួនឯងបណ្តើរ

- យី ! អញមិនដែលឃើញអ្នកណាមុខរឹងយ៉ាងហ្នឹងទេ ណើយ !

យ៉ាហានងាកទៅលបមើលមុខនាងនីដោយទន់ចិត្ត ។ នាងនីស្លៀកខោរៀបចំខ្លួនជារបៀបប្រុស ពីព្រោះនាងនឹកថាទៅនេះមិនដឹងជាមានការយ៉ាងណាខ្លះទេ គោងតែប្រុងស្មៀងឲ្យហើយ ។

ដោយនាងនីធ្វើឲ្យយឺយ៉ាវបន្តិច ទាល់តែដល់ម៉ោងប្រាំបី និងដប់ប្រាំនាទីយប់ ទើបបាននាំគ្នាចេញផុតពីផ្ទះទៅ ។ ពូញ៉ឹបបើកឡាន នាងនីនៅអង្គុយជាមួយនឹងយ៉ាហាន ។

"រាំចង់ទិព្វ" កំពុងតែអ៊ូអរ ភ្ញៀវអញ្ជើញចូលអស់ មុខសម្លចេញបានជិតពាក់កណ្ដាល ឯកូនក្រមុំនិងកូនកំលោះក៏បានដកខ្លួនថយអំពីមាត់ទ្វារ ។ ចន្ទីដើរទៅសើចកាច់កកាច់ស្រស់ជាមួយនឹងពួកម៉ាកនៅតុនានា សប្បាយណាស់បានគេសរសើរនិងចំអន់ជាមួយនឹងលោក ស៊ី ឈឿន ។ កូនកំលោះចេះតែភាំងៗ ទាល់តែចំអន់ខ្លាំង ទើបឃើញសើចម្ដង សើចស្ទើរតែមិនទាន់ផុតផង ក៏ប្រែជាស្រពាប់ស្រពោនទៅវិញ ។ ពួកម៉ាកនិងបុគ្គលិករបស់ស៊ី ឈឿនខ្សឹមខ្សៀវគ្នាជាអាពាហ៍ពិពាហ៍ហ្នឹងដូចជាពិបាកភ្នែកណាស់ ! ។

គេចម្លែកនឹងបាត់មិនឃើញលោកសុត និងលោកថៃក្នុងចំណោមភ្ញៀវទាំងឡាយ ។ ស៊ី ឈឿន នឹងអាណោចអាធម្មខ្លួននឹងបាត់អស់មនុស្សដែលអ្នកស្រឡាញ់ទាំងប៉ុន្មាន ។ អ្នកនឹកទៅដល់យ៉ាហាន រឿងអ្នកជាមួយនឹងនាងដូចជាមិនដែលបានច្បាស់លាស់អ្វីសោះ ! ។

តាំងពីព្រលប់ ភ្លេងនិងចម្រៀងនៅ "រាំចង់ទិព្វ" ចេះតែរងំរហូតប្រឹងតាំទ្រូបរិយាកាស ប៉ុន្តែបើទោះជាចន្ទីប្រឹងសើចបន្ថែមយ៉ាងណា ក៏ដូចជារិតតែពិបាកនឹងមើល ពិបាកនឹងស្ដាប់ទៅទៀត ។

បន្តិចក្រោយមក ស្រាប់តែភ្លេងឈប់ឈឹង ភ្ញៀវទាំងឡាយងាកទៅរកឆាកគ្រប់គ្នា ។ ឃើញប្រុសម្នាក់រាងដូចស្រីឡើងទៅកាន់ "មីក្រូ" ហើយជំរាបភ្ញៀវថា ៖

"ដើម្បីជាកិត្តិយសដល់អស់លោក លោកស្រីនិងអ្នកនាងដែលបានអញ្ជើញមកក្នុងរាត្រីនេះ តួឯកចម្រៀងនៅ "រំចង់ទិព្វ" ដែលទើបនឹងបានមកដល់ សូមជូនសម្លេងចុងក្រោយបំផុតរបស់នាង ពីព្រោះចាប់អំពីថ្ងៃស្អែកនេះទៅ នាងត្រូវលាលែងអំពីឋានៈជាអ្នកចម្រៀងហើយ"

ស៊ី ឈឿន ភ្ញាក់ខ្លួន គឺនាងប្រុសនេះហើយដែលអ្នកបានឃើញឡើងទៅលើផ្ទះយ៉ាហានចំនួនពីររាត្រីជាប់ៗគ្នា ។ មុខមាត់ប្រហាក់ប្រហែលនឹងនាងនី... នាងនីទេដឹង ! ។

តួឯកចម្រៀងរូបឆើតឆាយ ដើរចេញមកក្រោម ស្គរទះដៃនិងសម្លេងត្រេកអរយ៉ាងកងរំពង ។ ស៊ី ឈឿន ដែលកំពុងតែគួរសមជាមួយនឹងភ្ញៀវនៅចម្ងាយបីបួនតុអំពីឆាក តើបនឹងបានឃើញសាជាថ្មីនូវមុខសង្សារ ដែលវង្វេងគ្នាជិតមួយខែមកហើយ ។ តួទាំងពីរក្រឡេករកគ្នា សម្លឹងស្លុតទៅវិញទៅមក ដូចជាឥតនឹងឃើញថាមានមនុស្សម្នាឯទៀតនៅជិតជុំវិញខ្លួនឡើយ ។ ល្ងាចនេះយ៉ាហានល្អចម្លែកណាស់ នាងតាក់តែងខ្លួនដោយអំពត់និងអាវហូលដែលអ្នកប្រុសធ្លាប់ស្រឡាញ់ជាងគេ ។ ទឹកមុខលន្លង់លន្លោចស្រពាប់ស្រពោនរបស់នាងធ្វើឲ្យរឹតតែមានសម្ផស្ស ឲ្យសម្រស់របស់នាងរឹងរឹតតែមានតម្លៃដូចជារបស់ដែលបម្រុងនឹងឃ្លាតបាត់ទៅ ។

យ៉ាហានចាប់ហូតមីក្រូមកកាន់នៅដៃ គយគន់មើលភ្ញៀវហើយងាកឆ្ពោះទៅរកសង្សាររបស់នាង ។ គ្រប់គ្នាស្ងាត់មាត់ជ្រៀបហាក់ដូចជាគោរពចំពោះឥទ្ធិពលមនោសញ្ចេតនានៃសេចក្តីស្នេហា ។ តន្ត្រីចាប់ប្រគំ សម្លេងពីរោះខ្ពស់គ្រលួចរបស់យ៉ាហានចាប់ច្រៀងបទ "ភ្លេងបើករាំងនន" ដែលអណ្តែតឡើងជាទំនួញសែនខ្សឹកខ្សួល

"ភ្លេងលេងបើរាំងនន ព្រលឹងបងអើយ គេរៀបការប្រុសថ្ងៃ
ភ្ញៀវទាំងប្រុសទាំងស្រី ព្រលឹងបងអើយ គេទះដៃហោ ។
ដៃបងលើកប្រណម្យ ព្រលឹងបងអើយ បង្គំផ្កាស្លា ។
ថ្វាយបង្គំលោកមេបា ព្រលឹងបងអើយ ជូនតាលោកឲ្យពរ ។

.......................................................

ភៀវគ្មានកំរើក ពីព្រោះសម្លេងដែលច្រៀងហូរដង្ហក់ដូចជាយំ ធ្វើឲ្យទ្រូងគ្រប់គ្នាតឹងទៅជាមួយនិងបទដែលបន្តទៅទៀត

"ស្វរតងឃ្មោះផ្ញើយគ្នា ព្រលឹងបងអើយ គេរៀបចងដៃ"

..........................................

ទឹកភ្នែកទាំងដំណក់ហូររហាមមកលើថ្ពាល់យ៉ាហាន សម្លេងនាងកាន់តែញ័រ...

"ចិត្តបងសប្បាយរីករាយ ព្រលឹងបងអើយ បានថ្មីចោលចាស់" គេស្មានថាបទនាងចប់តែប៉ុណ្ណោះ ។ ប៉ុន្តែភ្លេងនៅតែលេង ហើយនាងក៏នៅតែច្រៀង

"ភ្លេងបាយខុនចងដៃ ព្រលឹងបងអើយ ប្រល័យជីវា
ឲ្យអូនផាច់សង្ខារ ព្រលឹងបងអើយ ដោយស្នាដៃបង" ។

ឃ្លាចុងក្រោយបំផុតរន្ធត់ខ្លាំងណាស់ ពីព្រោះយ៉ាហានបង្ខំច្រៀងទាំងណែនទ្រូង ស្ទើរតែមិនចប់ រួចដាក់ "មីក្រូ" ទៅវិញទាំងញ័រចំប្រប់ ដៃម្ខាងហូតយកកន្សែងមកខ្ទប់មុខយំ ។ ភៀវចាប់ជ្រួលច្របល់ នាងនីស្ទុះទៅទ្រទប់យ៉ាហាន ស៊ី ឈឿនស្ទុះទៅតាម ប៉ុន្តែចន្ទីចាប់កន្ត្រាក់ដៃអ្នកទាញមកក្រោយវិញ ឯពួកប្រុសៗ ក្រុមចន្ទីពីរបីនាក់ទៀតក៏មកជួយឃាត់លោកប្រុសដែរ ។

នាងនីគ្រាហ៍យ៉ាហានឡើងទៅលើ ទៅដល់រថយន្តដែលពូញ៉ិបនៅកាន់ចង្កូតរង់ចាំ

– ពូញ៉ិបឯងនាំ យ៉ាហាន ទៅផ្ទះមុខចុះ ខ្ញុំនឹងទៅតាមក្រោយឥឡូវនេះហើយ ខ្ញុំទៅជួបនឹងលោក ស៊ី ឈឿន មួយភ្លែត ។

ពូញ៉ិបចេញឡានមិនបង្អង់យូរ នាងនីស្ទុះរត់ចុះមកក្រោមវិញដោយឥតញញើត ។ ស៊ី ឈឿន ប្រឹងបម្រះកន្ត្រាក់ដៃរបស់ខ្លួនរបូតចេញអំពីអ្នកចាប់ទាំងប៉ុន្មាន ហើយឈមមុខបែរមកហាមប្រាមថា ៖

– អ្នកទាំងអស់គ្នាកុំចាប់ខ្ញុំទៀត តិចខ្ញុំមិនបានប្រាប់ ! នេះជារឿងផ្ទាល់ខ្លួនខ្ញុំទេ !

រួចអ្នកបែរទៅស្តីឲ្យចន្ទីទៀត

ចន្ទីឯងមានចិត្តដូចយក្ខ បើទោះជាសត្វតិរច្ឆានក៏វាចេះអាណិតដល់ស្ត្រីចម្រៀងមិញហ្នឹងដែរ !"

ស៊ី ឈឿន រត់ឡើងទៅលើ នាងនីរត់ចុះមកក្រោម មកជួបគ្នានៅនឹងពាក់កណ្តាលជណ្តើរច្រាំងទន្លេ ។ អ្នកប្រុសស្ទុះទៅចាប់ដៃនាងនីសួរមិនបង្អង់

- អូនឯងជានាងនីមែន ឬ ទេ ?

- ចាស ! តេជគុណ, តេជគុណមិនគួរជាមិនស្គាល់ខ្ញុំសោះ !

ស៊ី ឈឿនរិលសតិមួយរំពេច "យ៉ាហាន គ្មានកំហុសអ្វីសោះចំពោះអ្នក" ។ អ្នកចាប់ទាញដៃនាងនីឲ្យរត់ឡើងទៅលើទៀត

- ឥឡូវ យ៉ាហាន ទៅឯណាហើយ ?

- ចាស ! ខ្ញុំឲ្យពូញ៉ិបគាត់ជូនទៅផ្ទះមុនទៅហើយ

- អានីឯងទៅជាមួយនឹងខ្ញុំ...

គេនាំគ្នាផ្អើលឈូឆរពេញតែមុខ "រំចង់ទិព្វ" ។

ស៊ី ឈឿន រត់រកឡានរបស់ខ្លួន ។ បុគ្គលិកអធិការដ្ឋានម្នាក់រត់ទៅយករថយន្តផ្ទាល់ខ្លួន មកជូនចៅហ្វាយឲ្យបានរហ័ស ។ កំពុងតែជ្រួលច្រាល់ ស្រាប់តែលេចឃើញ ពូញ៉ិបបើកឡានទទេត្រឡប់មកវិញ ។ ស៊ី ឈឿន និងនាងនីស្ទុះទៅរកគាត់ហើយបើកទ្វារឡានចូលទៅជាមួយ ។ នាងនីឆ្លៀតសួរទៅគាត់ថា ៖

- ម៉េចក៏ពូញ៉ិបឯងត្រឡប់មកវិញ ?

- បាទ ! អ្នកហានចេះតែដេញខ្ញុំឲ្យមកទទួលអ្នកនីឯងវិញ ។

- បើអីចឹងពូញ៉ិបឯងទុកយ៉ាហានឲ្យនៅផ្ទះតែម្នាក់ឯង ?

- បាទ !

នាងនីក្តុកក្តួលក្នុងចិត្តហើយលាន់មាតថា ៖

- យីស ! ពូញ៉ិបឯងផ្តាស់តែម្តង ! ខ្ញុំគ្មានផ្តាំឲ្យមកទទួលខ្ញុំវិញសោះ ! ពូញ៉ិបឯងគ្មានយល់ការអ្វីសោះតែម្តង !

ពុដូច្នេះ ស៊ី ឈឿនបារម្ភខ្លាំងណាស់ ប៉ុន្តែមិនចេញស្តី ។ បុគ្គលិកអធិការដ្ឋានពីរបីនាក់នាំគ្នាបើកឡានទៅតាមក្រោយ ស៊ី ឈឿន ទៀត ។

ភ្ញៀវដែលមកស៊ីការ ចាប់នឹងរឿងច្បាស់លាស់ខ្លះហើយដោយអ្នកបំផី និងថៅកែ "រំចង់ទិព្វ" ទើបនឹងហ៊ានរៀបរាប់តាមការពិតថា នារីឯកខាងចម្រៀងនេះជាសង្សារកំសត់កម្ររបស់លោក ស៊ី ឈឿន ជាច្រើនឆ្នាំមកហើយ ។ នាងមិនមែនជាស្ត្រីចម្រៀងស្មោះទេ ពីព្រោះនាងជានិស្សិតពេញលក្ខណៈនៃសាលាជំនួញ នាងខំច្រៀងដើម្បីយកប្រាក់ទៅបន្តវិជ្ជា ហើយទើបនឹងបានប្រឡងចេញជាប់ក្នុងខែនេះ ។ នាងនៅជាប់ច្រៀងតែមួយល្ងាចនេះទៀតទេ ពីព្រោះនាងត្រូវចូលទៅធ្វើការនៅក្នុងក្រុមហ៊ុនអាកាសចរណ៍ ចាប់ពីអាទិត្យក្រោយនេះទៅ ។ ពួស្ងួរគេលាន់មាត់អាណោិត...... យ៉ាហានស្ទើរតែគ្រប់គ្នា អ្នកខ្លះមានទាំងលាន់មាត់ថែមទៀតផងថា ៖ "បើតាមបុកពានិងរូបសម្បត្តិ គឺគួរតែចន្ទីមកធ្វើជាស្រីអ្នកចម្រៀង ហើយនាងយ៉ាហានធ្វើជាលោកស្រីវិញ ទើបសមជាង" ។

លុះស៊ី ឈឿន នាងនី ពូញ៉ិប និងអស់លោកឯទៀតឡើងទៅដល់លើផ្ទះយ៉ាហាន ឃើញទ្វារគ្រាន់តែទាញផ្ទិប ខាងក្នុងស្ងាត់សូន្យ របស់ទាំងអស់នៅដដែល បាត់តែម្ចាស់ផ្ទះមិនដឹងជាទៅឯណា ។ ស៊ី ឈឿនរត់រកគ្រប់បន្ទប់ ផ្ទះបាយស្ងាត់ឈឹង រានហាលឥតមានមនុស្ស ដំណេកនៅចោលទទេ ។ ស៊ី ឈឿនកំពុងតែសញ្ជប់សញ្ជឹងនឹងកន្លែងដែលនាងធ្លាប់គេង ធ្លាប់សុខធ្លាប់សប្បាយស្រាប់តែចាប់ភ្នែកទៅលើស្រោមសំបុត្រមួយនៅលើគ្រែហើយលើកឡើងយកមកមើលជាមួយនឹងនាងនី ។ លើស្រោមមានការខ្ទង់ដែលអ្នកប្រុសស្គាល់ជាក់ថា ជាអក្សរសរសេរដៃយ៉ាហាន ៖

"បណ្ដាំចំពោះបងនី"

នៅខាងក្នុងមានរូបថត ស៊ី ឈឿន និងសំបុត្រតូចមួយមានសេចក្ដីថា ៖

បងនីជាទីស្រឡាញ់

ខ្ញុំសុំស្មារលាទោសនឹងបងនីឯង ដោយខ្ញុំបានធ្វើបាបបងនីឯងជាច្រើន ។ សូមឲ្យបងនីឯងនៅឲ្យបានសុខ ។ ខ្ញុំសុំលាបងនីឯងសិនហើយ ។ ខ្ញុំអាណិតបងនីឯងណាស់ ។ កុំចាំបាច់តាមរកខ្ញុំធ្វើអ្វីពីព្រោះខ្ញុំអស់វិលត្រឡប់មកវិញហើយ ។ សូមប្រគល់រូបថតនេះឲ្យម្ចាស់គេវិញផង ។

សម្លាញ់កំសត់កម្ររបស់បង

ខាន់ - យ៉ាហាន

*ស៊ី ឈឿនឈរធ្មឹងមើលសំបុត្រសង្សារដែលអ្នកទើបនឹងយល់ច្បាស់ថាជាបណ្ដូលចិត្តរបស់អ្នក ។ សំបុត្រនេះវែងណាស់ អ្នកមើលមិនចេះចប់ "កុំចាំបាច់តាមរកខ្ញុំធ្វើអ្វី ពីព្រោះខ្ញុំអស់វិលត្រឡប់មកវិញហើយ"... អស់វិលត្រឡប់វិញហើយ យ៉ាហានដែលអ្នកអាណិត... យ៉ាហានដែលអ្នកស្រឡាញ់... យ៉ាហានដែលអ្នកធ្វើបាប... "ឲ្យប្អូនដាច់សង្វារ...ដោយស្នាដៃបង"... រឿងចាស់ រឿងថ្មី សេចក្ដីក្នុងសបុត្រ និងសូរស័ព្ទចំរៀងអណ្ដែតវិលវល់នៅក្នុងវិញ្ញាណខ្វល់ខ្វាយរបស់ ស៊ី ឈឿន ។ អ្នកមិនដែលកំព្រាចិត្តដូចគ្រានេះឡើយ... កំព្រាឪពុក... កំព្រាម្ដាយ... កំព្រាគូកំសត់ដែលអ្នកស្រឡាញ់ និងរលឹកមិនដែលរសាយមួយវេលា ។ យ៉ាហាននៅឯណា !... ទៅឯណា ! "បងត្រូវតែដើររកអូនជានិច្ច... រហូតដល់ទាល់គ្នានឹងផុតជីវិត" ។ គេចាត់គ្នាឲ្យដើររកយ៉ាហាន ត្រូវប្រយ័ត្នចាត់ឲ្យច្រើនទៅខាងមាត់ទន្លេ សំខាន់ជាងគេគឺស្ពានព្រះមុនីវង្ស និងស្ពានសង្គមរាស្ត្រនិយមឆ្លងទៅជ្រុយចង្វា ពីព្រោះមនុស្សអស់សង្ឃឹមច្រើនតែមានទម្លាប់នឹងលោតទឹកអំពើលើស្ពាន ។ ក្រុមមួយទៀតឲ្យទៅមើលតាមផ្លូវរទេះភ្លើង ។ នាងនីនិយាយទូរស័ព្ទប្រាប់គ្រប់ឪសថស្ថាន បញ្ជាក់ថាបើឃើញស្រីម្នាក់ស្លៀកពាក់ហូលសក់វែងដល់ចង្កេះ អាយុប្រហែលម្ភៃឆ្នាំទៅរកទិញថ្នាំ សូមកុំលក់ឲ្យសោះជាពិសេសថ្នាំណាដែលមានជាតិពុលអាចឲ្យមានគ្រោះថ្នាក់ដល់ជីវិត។*

មួយយប់ទាល់ភ្លឺឥតបានការអ្វីសោះ ទៅឯណាក៏មិនឃើញ ទៅឯណាក៏មិនជួបប្រទះ សួរអ្នកឯណាក៏គេថាមិនបានឃើញស្ត្រីរូបនេះឡើយ ។

ដល់ភ្លឺស្រាងៗ ស៊ី ឈឿនត្រឡប់ចូលមកធ្មេចមួយស្របឡេត នៅនឹងបន្ទប់យ៉ាហាន គេងមិនលក់ រសាប់រសល់ខ្វល់ខ្វាយកាន់តែខ្លាំង ។ នាងនីនិងពូញ៉ិបចេះតែរលឹកទឹកចិត្តប្រឹងនិយាយរំលឹកអំពីសេចក្តីស្មោះត្រង់បរិសុទ្ធរបស់យ៉ាហាន ចំពោះអ្នកប្រុស ។ គេនាំគ្នារត់រកមួយថ្ងៃវាល់ល្ងាចទៀត នៅតែឥតបានការ ។

ដល់ម៉ោងបួនរសៀល លេខឃើញសំបុត្រមួយទៀតមកដល់អំពីប៉ុស្តិ៍ផ្ញើមកនាងនី កាខ្នងដោយអក្សរយ៉ាហានដដែល ។ លុះបើកឡើងឃើញស្រោមតូចមួយទៀតកាខ្នងថា ៖

"ជូនចំពោះបងស៊ី ឈឿន"

សំបុត្រនៅខាងក្នុងរាយសេចក្តីដ៏រន្ធត់ដូចតទៅ

ជីវិតតែមួយរបស់អូន
សំបុត្រនេះជាវិញ្ញាណចុងក្រោយបំផុតរបស់អូនមកដល់បង ។ បន្ទាប់មកសង្ខាររបស់អូននឹងរលត់ផុតលែងឲ្យបងមើលទាល់ចង្អៀតចង្អល់ដោយសារអូនទៀតហើយ ។ សេចក្តីកង្វល់តក់ក្រហល់របស់អូនក៏រលត់ ឯសេចក្តីមិនទុកចិត្តរបស់បងក៏បានរសាយត្រឹមណោះដែរ ។ អូនបានសញ្ជឹងគិតមួយរាត្រី ហាក់ដូចជាត្រូវរងកម្មមិនចេះចប់រាប់ច្រើនសតវត្ស អូនមិនអាចនឹងទ្រាំទ្រការព្រាត់ប្រាស់នេះបានឡើយ ។ អូនមិនអាចនឹងរស់នៅដោយគ្មានរូបបងមកនៅលួងលោមបបោស អង្អែលចិត្តរបស់អូនបានទេ ។ អារម្មណ៍របស់អូនមិនអាចនឹងទទួលយល់ព្រមកើតឲ្យស្រីម្នាក់ទៀតមានសំណាងជាងអូនជាមួយនឹងបងឡើយ

ពិតមែនតែការព្រាត់ប្រាសគ្នានេះនេះជាកំហុសរបស់អូនទាំងអស់ ពីព្រោះអូនយល់ច្បាស់ថា បងតែងតែសន្តោសអូនជានិច្ច ។

សូមធម្មជាតិ ព្រះអង្គធំ និងទឹកជ្រោះភ្នំគូលែនគត់នៅ ជាសាក្សីអចិន្ត្រៃនៃសេចក្ដីស្មោះត្រង់របស់ខ្ញុំ ចំពោះបុរសដែលបានសង្គ្រោះ ផ្ដល់សុភមង្គលដល់រូបខ្ញុំជាស្រីអនាថា ។

អូនរលឹកបងណាស់ អូនស្លាប់ដោយបិទភ្នែកមិនជិត ឡើយ ។ បើអាណិតអូន សូមបងកសាងទៅជួបនឹងអូនដែល នៅរង់ចាំបងជានិច្ច គ្រប់ជាតិ ។

ប្អូនស្រីកំសត់របស់បង
ខាន់ - យ៉ាហាន

*ស៊ី ឈឿនល្ហិតល្ហៃក្នុងខ្លួន សេចក្ដីសង្ឃឹមដែលនៅសេសសល់បន្តិចបន្តួចក៏រលត់អស់រលីង ។ សំដីយ៉ាហានគួរឲ្យស្រណោះណាស់ ! នៅតែទន់ នៅតែពិរោះ ដូចគ្រាដែលនៅកំសត់ និងសប្បាយជាមួយគ្នា ។ នាងនៅតែសន្តោសជានិច្ចចំពោះបុរសដែលនាងស្រឡាញ់ ។ សេចក្ដីស្ដាយល្វីងល្វើយរកទីបំផុតគ្មាននាំយកស្មារតីវង្វេងវង្វាន់របស់ ស៊ី ឈឿន បក់ផាត់រសាត់រសាយទៅឆ្ងាយដាច់សង្វែង ។ អំពីថ្ងៃនេះទៅ អ្នកនឹងនៅតែម្នាក់ឯង កណ្ដោចកណ្ដែងកណ្ដាលជីវិតឥតន័យ គ្មានអ្នកឯណាគេពិតជាសប្បាយជាមួយ គ្មានអ្នកឯណាគេពិតជាជួយរំលែកទុក្ខ ។ សន្ដានចិត្តដូចយ៉ាហាន មិនអាចនឹងរកបានទៀតទេ... ជាតិនេះហួសហើយ... ! ។*

*ពូញ៉ិបយំឃ្លូរៗ ដូចកូនក្មេង គាត់នឹកអាណិតចិត្តនារីដែលគាត់បានឃើញជាក់ច្បាស់ នូវការតស៊ូតាំងអំពីរាត្រីដំបូងដែលគាត់បានជូនរ៉ឺម៉កម៉ូតូរអំពីសៀមរាបទៅបារាយណ៍ទឹកថ្លា ។ ប្រឹងម៉្លឹងហើយនៅតែព្រាត់ប្រាស់បាន !*

*នាងនីលែងនិយាយអ្វីកើត គ្រប់គ្នារកកលចង់ឡប់អស់រលីងទៅហើយ ។*

សេចក្ដីក្នុងសំបុត្រធ្វើឲ្យ ស៊ី ឈឿន សង្ស័យទៅដល់ភ្នំគូលែន... ភ្នំគូលែនដែលយ៉ាហានស្រឡាញ់ ភ្នំគូលែនដែលយ៉ាហានស្រណោះ... និងអម្បោះសរសៃឈើដែលបានចងដៃនាងផ្សំផ្គុំជាមួយនឹងអ្នក ។

រថយន្តតូចពីរបើកចេញបន្តគ្នាទៅកាន់ "ប៉ុយប៉ែ" ស៊ី ឈឿន ដើម្បីនិយាយទូរស័ព្ទទៅសៀមរាប ។ លោកសុត និងលោកថៃ ឆ្លើយភ្ញាក់សម្លេងអំពីចម្ងាយ ហើយសួរបញ្ជាក់អំពីសំលៀកបំពាក់និងដំណើរទំនងរបស់យ៉ាហាន ។ លោកទាំងពីរសន្យាថានឹងស៊ើបសួរពួកឡានឈ្នួលភ្លាម ហើយនឹងជូនដំណឹងមកវិញក្នុងពេលបន្តិចទៀត ។ ក្រោយនោះប្រហែលជិតមួយម៉ោង ទូរស័ព្ទអំពីសៀមរាបបញ្ជូនសម្លេងហត់គឃូសរបស់លោកសុតមកដល់ ស៊ី ឈឿន វិញ

- អាឡូ !... តេជគុណអធិការ !

- យ៉ាងម៉េចទៅសុត ? បានដឹងអ្វីខ្លះទេ ?

- បាទ ! តេជគុណ... ពួកឡានដែលបានមកដល់អំពីភ្នំពេញព្រឹកមិញនិយាយថា បានសង្កេតឃើញស្រីម្នាក់ដែលរូបរាង និងសំលៀកបំពាក់របៀបដូចអ្នកនាងយ៉ាហាន ហើយដូចជាកាន់តែច្បាស់ត្រង់ថា នាងមានទឹកមុខក្រៀមក្រំជាខ្លាំង ។

- រួចសុតឯងមានឮគេថាឃើញចុះទៅត្រង់ណាទេ ?

- បាទ គេថាឃើញចុះនៅសៀមរាប ។ ដល់ខ្ញុំបាទទៅសួរពួកឡានភ្នំគូលែនគេថា កាលពីព្រឹកមិញពេលថ្ងៃខ្ពស់បន្តិចទៅហើយ ឃើញស្ត្រីម្នាក់របៀបដូចអ្នកនាងយ៉ាហានដែរ បានឡើងរថយន្តទៅភ្នំគូលែន ហើយនិយាយប្រាប់គេថាទៅរកជីដូនដែលនៅធ្វើកម្មដ្ឋាននៅលើភ្នំនោះ !

- សុតឯងរកឡាន "ឡង់រ៉ូវែរ" មួយទុកចាំខ្ញុំឲ្យស្រេចទៅ ដើម្បីនឹងឡើងភ្នំគូលែន ។ ខ្ញុំរៀបចំចេញដំណើរមកសៀមរាបទាំងអស់គ្នាឥឡូវនេះហើយ ។

លោកសុតទទួលរ៉ាប់រងគ្រប់បែបទាំងអស់ ។

ស៊ី ឈឿនមានកម្លាំងព្រឺសឡើងវិញ ពូញ៉ឹបបាត់យំ នាងនីរៀបចំឥវ៉ាន់ប្រញាប់ប្រញាល់ ។ ក្រោយនោះប្រហែលជាម៉ោងនាទី រថយន្តស៊ី ឈឿន បើកបោះពួយដូចព្រួញទៅកាន់រាជធានីនាបុរាណកាល និកសង្ឃឹមញញឹមទុកគ្រប់គ្នាថាយប់នេះ ឬព្រឹកស្អែក យ៉ាហាននឹងបានសប្បាយរីករាយ រួចអំពីទុក្ខសោកដែលគ្រាន់តែជាសុបិនអាក្រក់មួយពេលខ្លីតែប៉ុណ្ណោះ ។

ផ្លូវសែនឆ្ងាយ ឡានបើកលឿនណាស់ដែរ ប៉ុន្តែនៅតែយឺត ។ ចិត្តស៊ី ឈឿនលឿនទៅដល់មុន ទៅដល់ភ្នំគូលែន ទៅដល់លោកយាយរូតឥស៊ី ទៅជួបនឹងនាងយ៉ាហានដែលព្រលឹងអ្នក ស្ទុះទៅឱបបបោសអង្អែលលួងលោមអង្វរទទួលកំហុសទាំងអស់... ស្រមៃឃើញនាងទ្រោបយំមកលើទ្រូងអ្នក សុខចិត្តអត់ទោសឲ្យសង្សារគ្រប់កន្លែង... ឮសំលេងរបស់នាងខ្សឹកខ្សួលថា ៖ "អូនរលឹកបងណាស់ អូនស្មានថាមិនបានជួបមុខបងទៀតទេ" ។

បារាយណ៍... កំពង់ធំ... យប់កាន់តែងងឹត ព្រះចន្ទរឹតតែភ្លឺព្រះចន្ទដប់បួនកើត... ឆ្នាំមុខនេះ នៅពេលខែភ្លឺយ៉ាងដូច្នោះដែរ លោកបានជួបបានស្គាល់យ៉ាហានជាដំបូងនៅចំការដូងរបស់លោកសុត ។ ស្អែកជាថ្ងៃពេញបូណ៌មី លោកនឹងនាំនាងទៅលេងនៅចំការដូងម្តងទៀតដើម្បីរំលឹកអនុស្សាវរីយ៍...

ភ្លើង "ហ្វា" ចាំងរន្ទាល រថយន្តបោះពួយរហូតតាមផ្លូវស្រឡះធេង ប្រកបដោយដើមឈើដុះស្រោងអមសងខាង ។ សត្វមមាចហើរមីរព្រោងព្រាតនៅមុខភ្លើងឡាន រសាត់លឿនមកប៉ះនឹងកញ្ចក់មុខសូរស្រឹបៗ ។ ឮតែសំព្ទខ្យល់និងសន្ទឹកម៉ាស៊ីនដែលយ៉ុងគ្មានសម្រាក ។ ឡានទើបនឹងបរផ្លងផុតស្ពានថ្មបុរាណ "កំពុងក្តី" នៅតែហុកសិបគីឡូម៉ែត្រទៀតនឹងដល់សៀមរាបហើយ ។ ហុកសិបគីឡូម៉ែត្រខាងក្រោយនេះដូចជារឹតតែឆ្ងាយ ។

ម៉ោងជិតដប់មួយយប់ ទើបចូលទៅដល់សៀមរាប ។ លោកសុត លោកថៃ អ្នកបើកបរ និង កម្មករជំនួយម្នាក់បានរៀបចំត្រៀមខ្លួននៅចាំជាស្រេច បម្រុងនឹងឡើងភ្នំគូលែន ។

# ចំពូក ៨
# ជ្រោះភ្នំគូលែន

ដំណើរឡើងភ្នំគូលែននៅពេលយប់មិនមែនស្រួលសោះឡើយ ។ ពីសៀមរាបទៅជើងភ្នំគូលែន ផ្លូវមិនពិបាកដូចកាលឆ្នាំ ១៩៦២ ឡើយ ប៉ុន្តែចាប់អំពីជើងភ្នំនេះទៅ ផ្លូវដែលយ៉ាប់ស្រាប់ទៅហើយនៅពេលថ្ងៃ រឹងរឹតតែតឹងណាស់ទៅទៀតក្នុងពេលរាត្រី ។ ខែភ្លឺជាលំអមួយមែនពិត ប៉ុន្តែមិនមែនធ្វើឲ្យស្រួលដំណើរឡើងតាមផ្លូវរបៀបនេះទេ ពីព្រោះនាំឲ្យភ្លើង "ហ្វា" ទៅជាព្រាល មើលផ្លូវមិនសូវឃើញច្បាស់ស្រឡះឡើយ ។

រថយន្តចាប់ផ្តើមឡើងភ្នំនៅពេលរំលងអាធ្រាត្រ ។

× × × × × × × × × × × × × ×

អាសូរយ៉ាហានស្រីកំសត់ នាងហាត់នឹងធ្វើដំណើរអំពីភ្នំពេញមកសៀមរាប អំពីសៀមរាបមកដល់ភ្នំគូលែន ឥតមានបាយមួយគ្រាប់នៅក្នុងពោះ ញាំតែទឹកបន្តិចបន្តួចមកតាមផ្លូវ ។ នៅពេលដែលសង្សារបោះបង់នាងចោល នាងរលឹកនឹកឃើញភ្នំគូលែន រលឹកនឹកដល់បណ្តាំលោកយាយរូតឥសី "បើថ្ងៃណាចៅអស់សង្ឃឹមនឹងមនុស្សលោក សូមចៅកុំភ្លេចថា ព្រះធម៌របស់ព្រះសម្មាសម្ពុទ្ធជាផ្លូវដ៏ត្រជាក់សម្រាប់ជួយរំលត់ទុក្ខទាំងពួង..." ។ ពេលនេះនាងអស់សង្ឃឹមនឹងមនុស្សលោកហើយ នាងខំប្រឹងរត់មករកព្រះធម៌ ។ នាងបានមកដល់ភ្នំគូលែនដូចសេចក្តីប្រាថ្នា នាងមកដល់តែម្នាក់ឯង នាំចិត្តឥតសង្ឃឹមរបស់នាងមកជ្រកកោននឹងព្រះធម៌ព្រះសម្មាសម្ពុទ្ធ។ គួរឲ្យអាណោចអាធម្មដល់នាងដែលដើរត្រមោចត្រមង់នៅតាមផ្លូវដដែល ផ្លូវដែលមុខនេះប្រាំឆ្នាំ បុរសដែលនាងស្រឡាញ់ និងមិត្រជាច្រើនបាននាំនាងទៅកាន់សេចក្តីសង្ឃឹម ។ ឥឡូវនាងត្រឡប់មក

វិញហើយ មកសម្លាប់ចិត្តដើម្បីបំភ្លេចសេចក្តីសង្ឃឹមដែលនាងបាន នាំយកអំពីទីនេះទៅ ។

សេចក្តីសុខ សេចក្តីសប្បាយរីករាយរបស់សត្វលោកមិន ឋិតថេរឡើយ បីដូចជាពពុះទឹកដែលផ្ទុំហើយបែករលាយទៅវិញ ។ សូម្បីតែពាក្យសច្ចាក៏សែនរន្ធត់របស់សង្សារក៏អាចនឹងរលត់ទៅវិញ បានដែរ ។

ម៉ោងប្រាំមួយព្រលប់ យ៉ាហានទៅដល់អាស្រមរួតបុស្សី ។ នាងឈរទ្រឹងសម្លឹងមើលកន្លែងដែលនាងធ្លាប់ស្គាល់ នឹកដល់ អនុស្សាវរីយ៍ប្រាំឆ្នាំមុន ដែលនាងនិងលោកប្រុសត្រូវផ្សំផ្គុំនឹងគ្នានៅ កន្លែងនេះ ។ រឿងចាស់ដូចជានៅថ្មីៗនឹងភ្នែកនៅឡើយ... ។ សុភមង្គលរបស់នាងមានជីវិតខ្លីពេកណាស់ ! ទើបនឹងបានជួបសោះ ឥឡូវត្រូវបាត់បង់ទៅវិញទៅហើយ ! ។

លុះនាងចូលទៅក្នុងអាស្រម ឃើញលោកតាចាស់ម្នាក់ស្លៀក សពាក់សចេញមកទទួលសួរនាង

- ចៅអញ្ជើញមករកអ្វីថ្មើរណោះ ?

នាងលុតជង្គង់ឆ្លើយដោយគោរព

- ចាំស ! លោកតា ចៅមករកលោកយាយរួតឥសី ដែលចៅ ធ្លាប់បានស្គាល់មុននេះប្រាំឆ្នាំ ។

លោកតាដកដង្ហើមធំហើយតមមកវិញ

- លោកយាយគាត់អានិច្ចកម្មមួយឆ្នាំទៅហើយណាំចៅស្រី

យ៉ាហានស្លុតចិត្ត កាន់តែវិលវល់សតិ ។ នាងគ្មានពាក្យអ្វីនឹង ឆ្លើយទេ ហើយសំពះលាលោកតាថយមកក្រោយវិញ ។ អស់រលីង ហើយចំពោះនាង ! នៅសល់តែរូបនិងចិត្តដែលអស់ទីជំរក ។ នាង ត្រឡប់មកសុំសំណាក់នឹងអាស្រមយាយជីដែលនៅជិតវត្ត ។ ពួក លោកយាយនឹកឆ្ងល់ច្រើនដែរនឹងឃើញស្ត្រីក្មេងរូបស្អាតយ៉ាងនេះ ចូលមកដល់តីអារាម ។ គាត់នាំគ្នាសាកសួរដោយអាណិត ប៉ុន្តែ យ៉ាហានឥតមានថ្លែងទុក្ខថ្លែងទោសអ្វីជំរាបគាត់សោះឡើយ គ្រាន់ តែដោះស្រាយថានាងមកលាបំណន់នឹងព្រះអង្គធំតែប៉ុណ្ណោះ ។ នាង

សុំយាយជីសំណាក់ទំរាំតែមកដល់ភ្លឺនឹងវិលត្រឡប់ទៅវិញ ។ លោកយាយទទួលឲ្យនាងដំណាក់ដោយរីករាយ ។

យ៉ាហានសម្ងំគ្មានលក់មួយស្រទ្បេតឡើយ នឹកគិតថាល្ងាចនេះលោកស៊ី ឈឿនគេផ្សំដំណេកសប្បាយនឹងនាងចន្ទីហើយ... អាសូរខ្លួនដែលឃ្លាតមកគេងតែម្នាក់ឯងលើកំពូលភ្នំដាច់ស្រយាល... ប្រហែលជាគេមិនបាននឹកអាណិតមកដល់ទ្រូងនាងបន្តិចសោះឡើយ ។

ម៉ោងបីភ្លឺ យ៉ាហានក្រោកដើរថ្នមៗ ទៅយកធូបមួយខ្សុក និងឈើគូសមួយប្រអប់មកកាន់ជាប់នៅដៃ រួចងាកបែរទៅសម្លឹងមើលលោកយាយដែលកំពុងតែសម្រាន្តលក់ ។

នាងសូមអរគុណានឹងលោកយាយទាំងអស់គ្នា សូមឲ្យលោកយាយនៅឲ្យបានសេចក្ដីសុខ ។

នាងចុះដើរទៅតែម្នាក់ឯងកណ្ដាលយប់សែនស្ងាត់ ។ អាកាសត្រជាក់ណាស់ នាងរងាចំប្រប់ ។ មេឃស្រឡះខែជ្រេទាបបន្តិចទៅហើយ ។ ខ្យល់បក់មកហ៊ូៗ មកត្រជាក់ដូចទឹកកក ។ នាងអស់គ្នីអស់គ្នាហើយ នៅសល់តែស្រមោលរបស់នាងមួយទេដែលនៅតែសុខចិត្តទៅតាមនាងជាប់រហូត ។ ផ្លូវបត់ចូលទៅក្នុងព្រៃគួរឲ្យស្ញើបប្រកបទៅដោយព្រឹក្សាធំៗគ្របជុំជិតពីលើ ។ មនុស្សធម្មតាបើទោះជាក្លាហានយ៉ាងណាក៏មិនប្រថុយនឹងធ្វើដំណើរទៅតាមនេះតែម្នាក់ឯងនៅពេលថ្មើរនេះឡើយ ។ ប៉ុន្តែទ្រូងដែលកណ្ដោចកណ្ដែងលែងញញើតគ្រោះថ្នាក់អ្វីទៀតហើយ ។ អំពិលអំពែកបញ្ចេញភ្លើងភ្លឺភ្លែតៗ ធំៗ ខ្លះហើរទាំងគូ... យ៉ាហានអស់មានគូទៀតហើយ ។

ទឹកជ្រោះចាប់ឲ្យស្នូរកាន់តែខ្លាំង ។ កណ្ដាលយប់ស្ងាត់សូន្យសូរស័ព្ទនេះរំងំរឹតតែឮសម្បើមខ្ទរពេញព្រៃ ។ យ៉ាហានដើរដូចឥតវិញ្ញាណ ជូនជើងនាងជំពប់នឹងថ្មដួលជ្រហិតជ្រហម ។ នាងប្រឹងច្រត់ដៃក្រោកឡើងវិញហើយដើរតទៅទៀតតម្រង់ទៅតាមសូរទឹកធ្លាក់ដែលកាន់តែឮខ្លាំងឡើងៗ ។

*ឥតអ្នកឯណាអាចស្មានបានថាតួឯកចម្រៀងនៅ "រំចង់ទិព្វ" ដែលប្រុសៗ ទោរចិត្តទៅរកសឹងតែគ្រប់គ្នា កំពុងតែសោយសោក តែម្នាក់ឯងកណ្ដាលព្រៃយ៉ាងអាណោចអាធម្ម ។*

*មាត់ជ្រោះធំ ភ្នំគូលែនលេចឡើងល្អល្អេវក្រោមរស្មីព្រះច័ន្ទ ។ យ៉ាហានឈរសម្លឹងអន្លង់គ្រោះថ្នាក់ដែលនាងបានជ្រើសរើសសម្រាប់ឲ្យផ្ដាច់សេចក្ដីទុក្ខរបស់នាង ។ នាងអង្គុយអាណិតរូបខ្លួនឯងដែលបន្តិចទៀតនឹងក្លាយទៅជាវត្ថុសោះសូន្យ ។ ដំណក់ទឹកភ្នែកហូរមកលើភក្ត្រដែលក្រៀមក្រំមួយខ្សែរចមកហើយ ។*

*ខែកាន់តែជ្រេ សន្សើមកាន់តែធ្លាក់ជោគជាំ ខ្យល់ត្រជាក់បក់ផាត់លើខ្នងភ្នំ ។ យ៉ាហានអុជធូបប្រាំពីរសរសៃដោតនៅនឹងមាត់ជ្រោះ ហើយលុតជង្គង់យំបួងសួងដោយខ្លោចផ្សា*

"ខ្ញុំម្ចាស់ស្រឡាញ់គេស្មើជីវិត ស្មោះត្រង់នឹងគេគ្រប់វេលារលឹកនឹកឃើញគេគ្រប់ដង្ហើម... សេចក្ដីស្មោះត្រង់របស់ខ្ញុំម្ចាស់ត្រូវគេគ្រវាត់ចោលដូចជាសំរាម ។ សូមព្រះអង្គធំ និងវត្ថុសាកសិទ្ធិនៅភ្នំគូលែន មេត្តារកយុត្តិធម៌ប្រទានខ្ញុំម្ចាស់ផង ។ ខ្ញុំម្ចាស់មិនសុខចិត្តរបស់នៅជាមួយនឹងអយុត្តិធម៌របៀបនេះទេ ខ្ញុំម្ចាស់ស្លាប់ទៅដោយមិនសុខចិត្ត ។ ព្រលឹងរបស់ខ្ញុំម្ចាស់ សូមទូលប្ដឹងនឹងព្រះអង្គជានិច្ចចំពោះលទ្ធផលមិនត្រឹមត្រូវនៃសេចក្ដីបរិសុទ្ធរបស់ខ្ញុំម្ចាស់" ។

*នាងអុជធូបប្រាំពីរសរសៃទៀត មកកាន់ក្ដាប់ប្រណម្យនៅជាប់នឹងដៃ រួចនាងស្រី ខាន់-យ៉ាហាន រូបល្អឆើតឆាយក្រោកឈរសម្លឹងមើលយូរឆ្ពោះទៅរណ្ដៅល្វឹងល្វើយ ហើយធ្មេចភ្នែកប្រមូលអារម្មណ៍ឲ្យមូលស្អាតជាចុងក្រោយបំផុតថ្វាយចំពោះព្រះពុទ្ធ ព្រះធម៌បរិសុទ្ធរួចបោះជំហានដោយដាច់អាល័យទៅកាន់អន្លង់ជ្រោះធំ... ។*

*មេឃក្រហមឯកើត... ភ្លឺស្រាងៗហើយ... ។*

រថយន្ត ស៊ី ឈឿន ឡើងមកដល់កំពូលភ្នំគូលែនភ្លាមក៏ចាត់គ្នារត់រកយ៉ាហានច្រវាត់ច្រវែង ខ្លះទៅរូតឥសី ខ្លះទៅព្រះអង្គធំ ។ ពួកយាយផ្អើលឆោឡោ ទើបនឹងដឹងច្បាស់ថាគេនាំគ្នាមកតាមរកនាងស្រីមុខស្រពាប់ស្រពោន ដែលមកសុំសំណាក់ជាមួយនឹងគាត់កាលពីល្ងាចមិញ ។ ឥឡូវនាងមិនដឹងជាទៅឯណាបាត់ទៀតទៅហើយ... ។

គ្រាន់តែបានដំណឹងនេះភ្លាម ស៊ី ឈឿន នាំគ្នាទៅកាន់កន្លែងទឹកធ្លាក់មួយរំពេច រួចរត់ទៅរកមាត់ជ្រោះ ហើយប្រឹងស្រែកហៅឈ្មោះ យ៉ាហាន ដើម្បីឲ្យនាងដឹងថាអ្នកមកតាម ។ នាងនីដែលលុកព្រៃល្បះ ស្រទៀតអំបុិតទៅដល់កន្លែងមួយស្រឡះ ស្រែកប្រាប់ឆោឡោពីខាងណោះមកវិញថា ៖ "នៅខាងណោះដូចជាធុំក្លិនផ្សែងធូបថ្មីៗណាស់ !" ។ ស៊ី ឈឿនស្ទុះទៅតាម ឃើញធូបប្រាំពីរសរសៃកំពុងតែឆេះមិនទាន់ទាំងបានពាក់កណ្ដាលដើមផង ។ លុះអ្នកងាកទៅខាងក្នុងមាត់ជ្រោះ ក៏ឃើញធូបខ្លះទៀតនៅឆេះប្លុងៗទើរនឹងមែករុក្ខជាតិនៅជ្រោងក្រោម ។ ពិតមែនតែសញ្ញានេះ ប្រែថាហួសហើយ ប៉ុន្តែចិត្តសង្ឃារនៅតែសង្ឃឹមជានិច្ច ។ ពួកអ្នកស្រុកចាប់ផ្អើលមកដល់ជាច្រើន ។

ស៊ី ឈឿន ពោបខ្លួនផ្កាប់មុខទៅនឹងមាត់ជ្រោះ ប្រឹងអើតសម្លឹងទៅខាងក្រោមដែលនៅងងឹតស្លុងៗ នៅឡើយ..... អ្នកឃើញអ្វី ? ..... ! ... ឱអនិច្ចា ! ... សង្សាររបស់អ្នកនៅគេងស្ដូកស្ដឹងផ្ទឹងផ្ទៃ លើផ្ទៃថ្មមួយថ្នាក់ជ្រៅពីមាត់ជ្រោះ ក្បាលនាងបត់ផ្អៀងទៅគងលើវល្លិមួយកញ្ចុំ ឈាមក្រហមឆ្អិនហូរចេញបន្ដិចៗអំពីចំហៀងមាត់ខាងស្ដាំ... ។

យ៉ាហានស្លាប់ហើយឬនៅ ? !... យ៉ាហានស្លាប់ហើយឬនៅ? ! ... ស៊ី ឈឿន មិនសុខចិត្តឲ្យនាងនៅយ៉ាងនេះទេ... អ្នកមិនអស់ចិត្តទេ អ្នកត្រូវចុះទៅតាមភ្លាម... ឲ្យយ៉ាងប្រញាប់... ឲ្យឆាប់ទៅដល់... ឲ្យទាន់ពេល... ប៉ុន្តែចុះតាមណា ? ត្រង់ណា ? ចុះយ៉ាងដូចម្ដេចកើត ?... គេថាមានផ្លូវនៅខាងក្រោម... ប៉ុន្តែផ្លូវនោះកុង

ឆ្ងាយណាស់ ចុះរហូតទៅដល់ដងព្រៃឯនាយ... ។ ទេ ! ទៅមិនទាន់ទេ... ស៊ី ឈឿនសម្រេចចិត្តថាចុះត្រង់ហ្នឹងតែម្តង ឲ្យឆាប់បានទៅដល់រូបដែលអ្នកស្រឡាញ់ ដែលអ្នកអាណិត ដែលជាជីវិតរបស់អ្នក "បើខ្លួនត្រូវធ្លាក់ស្លាប់ជាមួយគ្នាក្នុងគ្រានេះ ក៏រឹងរឹតតែប្រសើរដែរ" ។

លោក សុត រត់ទៅយកខ្សែពួរឆ្នៃមួយចង្វាយវែងចេញពីឡាន "ឡង់រ៉ូវែរ" ។ ស៊ី ឈឿន ចងសម្រូតខ្លួនចុះទៅក្នុងរណ្តៅជ្រោះលុះត្រាតែដល់ថ្នាក់ថ្មដែលប្រាណ យ៉ាហាន បានធ្លាក់ទៅទើរពីលើ ។ អ្នកប្រុសស្ទុះទៅលុងជង្គង់ចាប់ផរាបចាប់រឹត ចាប់ថើបរូបឥតព្រលឹងដែលនៅក្តៅគគុកនៅឡើយ ។

គួរអស្ចារ្យនឹងឥទ្ធិពលស្នេហា ! យ៉ាហានដែលដូចជារលត់ផុតជីវិតទៅហើយ ហាក់ឮសម្លេងយំស្រែកហៅរបស់សង្សារដែលប្រឹងចាប់អង្រួនប្រឹងអោបប្រឹងរឹត ប្រឹងថើបជញ្ចក់ឈាមរបស់នាងដែលហូរមកតាមមាត់បន្តិចៗ ។ វិញ្ញាណរបស់នាងដែលដើរចេញផុតទៅហើយ ហាក់ដូចជាអាឡោះអាល័យរូបចាស់ ហើយបានទទួលសញ្ញាឲ្យត្រូវវិលត្រឡប់មកវិញមួយភ្លែត មកចូលក្នុងរូបកាយដែលនៅក្តៅនៅឡើយ ។ នាងបើកភ្នែកឡើងបង្ហូរទឹកនេត្រាចុងក្រោយបំផុតសម្លឹងមើលសង្សារដែលកំពុងយំអណ្តឹតអណ្តកស្រែកឃាត់ដំណើរនាង

- យ៉ាហាន ! យ៉ាហានជីវិតរបស់បង ! បងមកដល់ហើយអូនកុំទៅណាចោលបងណាំអូនណាំ... ។

សម្លេងខ្សាវរបស់យ៉ាហានផុតចេញមកដោយលំបាក

- បងមករកអូនធ្វើអ្វី បងមានប្រពន្ធហើយ...

ស៊ី ឈឿន ប្រឹងស្រែកប្រកែកបញ្ជាក់ប្រាប់នាង

- មិនមែនទេអូន ព្រះអង្គធំជាសាក្សី បងឥតមានប្រពន្ធសោះឡើយ មានតែអូនមួយទេដែលជាប្រពន្ធរបស់បង បងបានផ្តាច់ចំណងអាពាហ៍ពិពាហ៍ ដែលគេបង្ខិតបង្ខំនោះចោលអស់ទៅហើយ... ។ អូនច្រៀងរួចអូនរត់ចោលបងមក បងចេះតែប្រឹងរត់

តាមរកអូនរហូត... អត់បាយអត់ទឹកមកទល់នឹងពេលនេះ... ឲ្យបង
សុំទោសទាំងអស់ណា៎ អូនណា៎ បងបានធ្វើបាបអូនច្រើនណាស់ ។

បបូរមាត់ យ៉ាហាន ប្រែជាញញឹមព្រាល បង្ហាញសម្រស់ឥត
គណនារបស់នាងដែល ស៊ី ឈឿនកំពុងតែងល្អើមជាមួយនឹង
មច្ចុរាជ ។ នាងប្រឹងលើដៃទាញមុខសង្សារទៅជិត ទៅថើបលា
"បងអត់ទោសឲ្យបងទាំងអស់ ពីព្រោះបងស្មោះនឹងអូនពិត...
ប៉ុន្តែធ្វើម្តេចយើងនឹងបានជួបគ្នាទៀតកើត ? !..."

ស៊ី ឈឿន អោបថើបសង្សារ ហើយយំសច្ចានៅនឹងត្រចៀក
នាង

"បងសូមប្រាថ្នាឲ្យជួបនឹងអូនគ្រប់ជាតិ ជាតិនេះក៏បងសូមបូជា
រូបកាយចំពោះអូនដែរ ។ បងសូមកសាងឲ្យបានត្រាស់ជាព្រះពុទ្ធ
មួយព្រះអង្គ ដើម្បីស្រោចស្រង់សត្វលោកឲ្យផុតពីសេចក្តីព្រាត់ប្រាស់
យ៉ាងដូចយ៉ាងដូច្នេះ ។ បងសូមឲ្យអូនបានទៅជាជំនិតស្តាំរបស់
បងគ្រប់ៗជាតិ សម្រាប់ជួយគាំទ្រកម្លាំងចិត្តរបស់បងកុំឲ្យអស់សង្ឃឹម
នៅក្នុងសេចក្តីប្រាថ្នា និងការកសាងយ៉ាងវែងឆ្ងាយនេះ ។

សម្លេងកាន់តែខ្សោយរបស់យ៉ាហានខ្សឹបស្រាលនៅជាប់នឹង
ត្រចៀករបស់ស៊ី ឈឿន

"ចា៎ស... អូនពេញចិត្តណាស់... សូមបងបានសម្រេច... អូន
សូមទៅចាំបងមុន ចាំជាប្រពន្ធរបស់បង ចាំជាអ្នកបម្រើបង... សូម
បងកុំឲ្យអូននៅរង់ចាំបងយូរពេក អូនរលឹកបងណាស់... អូន
អាណិតបងណាស់... " ។

សម្លេងនាងបាត់តែត្រឹមនេះ ក្បាលនាងធ្លាក់ផ្ងាកទៅក្រោយ
រំសាយសក់ដាបទៅដល់ផ្ទៃថ្ម ។ សង្សាររបស់លោកស៊ី ឈឿន
រលត់ផុតជីវិតទៅហើយ ផុតនៅក្នុងដៃលោកស៊ី ឈឿន ផុតដោយ
ចិត្តរបស់នាងនៅតែអាណិតមកដល់រូបលោកជានិច្ច ។

ស៊ី ឈឿន យំអោបខ្មោចប្អូនស្រី ជីវិតស្នេហារបស់អ្នកបាន
ផ្ញើទៅជាមួយនឹងព្រលឹងរបស់នាងអស់ទៅហើយ... ទុកនៅតែរូប

និងសតិបញ្ញាដែលអ្នកត្រូវថែរក្សា ដើម្បីបំពេញការកសាងតាមផ្លូវព្រះពុទ្ធសាសនា នៅកាន់ឋានរំលត់ទុក្ខ ។

មនុស្សកាន់តែផ្អើលមកច្រើនអ៊ូអរ នាំគ្នាអើតកមើលទៅក្នុងជ្រោះ រន្ធត់នឹងពលិកម្មយ៉ាងស្ដែងរបស់នារីរូបស្រស់ ស្លុតចិត្តនឹងឃើញរូបកាយសង្ខារទាំងពីរនៅអោបផ្ដេកផ្ដួលជាមួយគ្នាឥតកំរើក។ មនុស្សដែលមានទាំងប៉ុន្មាននៅលើខ្នងភ្នំគូលែនបានស្រែកប្រាប់បន្តគ្នាឲ្យមកមើលភ័ស្តុតាងនៃសេចក្ដីស្នេហាដ៏ខ្លោចផ្សានេះ ។

គ្មានអ្នកណាហ៊ានចុះទៅតាម ស៊ី ឈឿន ឡើយ គេនាំគ្នារត់ឆ្លងដងព្រៃទៅរកផ្លូវវាង ។ លោក សុត លោកថៃ នាងនី និងពូញ៉ិបប្រឹងស្រូតស្រូតជ្រហឹមជ្រហមចុះឡើងតាមផ្ទាំងថ្មរហូតទៅដល់ផែនសិលាដែលបានផ្ដាច់សង្ខារ យ៉ាហាន ។

លោក សុត ស្ទុះទៅចាប់រឹតចៅហ្វាយប្រុសឲ្យដឹងខ្លួនឡើងវិញ នាងនីយំបោកខ្លួននឹងប្អូនស្រី សោកស្ដាយមកមិនទាន់ពេល "ប្រសិនជាបងបាមកដល់មុននេះតែកន្លះម៉ោង ប្រាកដអូនមិនស្លាប់ចោលបងឡើយ ពីព្រោះធូបដែលអូនបានអុជ ឆេះមិនទាន់ទាំងអស់ពាក់កណ្ដាលផង... មិនគួរអូនដាច់ចិត្តដល់ម្លឹងសោះ !..." ។

ពូញ៉ិបគ្រវីក្បាល "វាត្រូវនឹងព្រាត់គឺព្រាត់ឲ្យទាល់តែបាន !..."។ អ្នកដែលបានដឹងទាំងប៉ុន្មានមកជួយជ្រោមជ្រែងគ្រប់គ្នា ។ មិត្តសម្លាញ់របស់ ស៊ី ឈឿន ទើបនឹងមកដល់តាមក្រោយបីឡានទៀតមានប្រុសមានស្រី នាំគ្នាដើរវាងចុះទៅដល់សព ។ អ្នកណាក៏ស្រក់ទឹកភ្នែករឹតទ្រូងអាណិត មកស្ទាបមកអង្អែលរូបរាងកាយយ៉ាហាន ដែលស៊ី ឈឿន នៅតែបីជាប់នឹងដៃ ។

ម៉ោងប្រាំពីរព្រឹក ថ្ងៃរះច្បាស់ អាកាសនៅត្រជាក់ណាស់នៅឡើយ ស៊ី ឈឿន លើកសពសង្ខារបីដើរយកទៅព្រះអង្គធំ... អ្នកឯទៀតដើរដង្ហែតាមក្រោយ ។ នាងនីបានដកយកជើងធូបទាំងប្រាំពីរសរសៃដែលមុននេះ ចំនួនជាពីរម៉ោង យ៉ាហានបានដោតយំសំបូងសង្រួងផ្ទាល់ដៃនៅនឹងមាត់ជ្រោះភ្នំ ។

*គេយកសពនាងស្រីទៅតម្កល់នៅលើបុស្បុក មួយដែលគេបានរៀបចំភ្លាមៗ នៅចំពីមុខមហាសិលាព្រះអង្គធំ ។ យ៉ាហាន ភ័ក្ត្រស្រស់ញញឹម គេងបិទភ្នែកឈឹង ឈប់ទុក្ខឈប់សោក ឈប់តឹងទ្រូងទៀតហើយ ។ សំពត់និងអាវហូលនៅតាក់តែងរូបកាយនាងឲ្យស្រុបនឹងចិត្តរបស់សង្សារដែលនាងប្រាថ្នានឹងធ្វើមិនឲ្យមាឃ្លើសទល់គ្នានឹងផុតរូបផុតសង្ខារ ។*

*ភ្នំគូលែននាំគ្នារៀបចំធ្វើបុណ្យបុត្រីកំសត់នៃព្រះអង្គធំ ខ្សឹកខ្សួលក្រៀមក្រំគ្រប់រូបកាយ ។ បុប្ផ ផ្កាចន្ទន៍ទាំងឡាយ ត្រូវគេនាំយកមកបាចរោយរាយដោយអាណិតលើសសពនារី ។ ភ្លើងទៀនផ្សែងធូបឆេះហុយផ្សព្វផ្សាយអាកាស យាយជីអង្គុយបទជើង សដេរដាស ពិចារណារូបអនិច្ចារបស់ ខាន់ យ៉ាហាន ។ ព្រះសង្ឃសូត្រធម៌បញ្ជូនកុសលទៅដល់វិញ្ញាណល្អបរិសុទ្ធរបស់នារីដែលបានដឹកលំអារម្មណ៍ចំពោះព្រះពុទ្ធ ។*

*យប់នេះ ជាថ្ងៃពេញបូរមី ព្រះច័ន្ទភ្លឺថ្លាអណ្តែតខ្ពស់នៅលើកំពូលភ្នំគូលែន ប្រទានរស្មីបំភ្លឺផ្លូវដល់ព្រលឹងរបស់ ខាន់ យ៉ាហាន ទៅកាន់សុគតិភព ។ លាហើយចំការដូងសៀមរាប និងភ្នំពេញ លាចម្រៀង លាទឹកភ្នែក ។ ស៊ី ឈឿន អោបថើបរូបកាយសង្សារជាបង្ហើយបំផុត មុននឹងព្រះអគ្គីត្រូវឆាបឆេះរំលាយរូបធម្មជាតិឲ្យត្រឡប់ទៅជា ធាតុទឹក ធាតុដី ធាតុភ្លើង ធាតុខ្យល់វិញ ។*

*លោក ស៊ី ឈឿន បានបួសមុខភ្លើងឲ្យប្អូនស្រីសម្លាញ់ស្មើជីវិត ។ នៅពេលកំពុតរំលាងសព្វ លោកបានអញ្ជើញញាតិមិត្រទាំងអស់មកផ្តាំថា ៖*

“ សុំឲ្យលោក សុត មេត្តាយកសំបុត្រនេះទៅសុំសេចក្តីអនុញ្ញាតអំពីរាជការខាងលើជាផ្លូវការ ឲ្យខ្ញុំផង ពីព្រោះខ្ញុំមិនវិលត្រឡប់ទៅកាន់លំនៅស្ថានវិញទេ ខ្ញុំបានសម្រេចចិត្តនឹងសាងផ្នូសរហូតរៀងទៅ ដើម្បីនឹងសម្រេចសេចក្តីប្រាថ្នាដែលខ្ញុំបានសច្ចាជាមួយនឹង ខាន់-យ៉ាហាន នៅពេលចុងក្រោយបំផុតនៃជីវិតរបស់នាង ។ ខ្ញុំសូមអរគុណចំពោះញាតិមិត្រទាំងអស់ដែលបានមកជួយអាណិត មេត្តាដល់

សពនីកំសត់នេះ សូមឲ្យលោកអ្នកបានសម្រេចតាមគន្លង ព្រះពុទ្ធសាសនា ឲ្យបានឆ្លងផុតនូវសេចក្ដីទុក្ខនិងការព្រាត់ប្រាសទាំងពួង ។ ចំណែកឯទ្រព្យសម្បត្តិប្រាក់កាសរបស់ខ្ញុំ ដែលមាននឹងនៅសល់ទាំងប៉ុន្មាន ខ្ញុំសូមបែងចែកដូចតទៅ ៖

មួយចំណែកជូនទៅក្រុមកាកបាទក្រហម ក្នុងនាមនាង ខាន់ យ៉ាហាន ។

មួយចំណែកទៀតជូនទៅម្ដាយរបស់នាង សម្រាប់តបគុណគាត់ជំនួសនាង

ចំណែកទីបី សូមបូជាចំពោះព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ សម្រាប់រៀបចំតំបន់អាស្រមកម្មដ្ឋាន លើភ្នំគូលែនតទៅទៀត ដើម្បីឲ្យបានមគ្គផលទៅដល់នាង ខាន់ យ៉ាហាន ។

× ×

×

*អំណើះតមកលោកធុតង្គ[1] ស៊ី ឈឿន តែងប្រព្រឹត្តិធម៌តឹងរ៉ឹងជាប់ជានិច្ច ។ លោករមែងតែនិមន្តទៅចង្រ្កមភាវនានៅតាមមាត់ជ្រោះភ្នំគូលែន ដើម្បីជួយរំលឹកស្រោចស្រង់វិញ្ញាណរបស់នារីកំសត់កុំឲ្យវង្វេងនៅក្នុងវាលវដ្តសង្សារ ។ ជួនកាលនៅពេលរាត្រីស្ងាត់ថ្ងៃពេញបូណ៌មី គេរមែងឮល្វើយៗនូវចម្រៀងកីសែនស្រណោះដែលហាក់ដូចជារណ្ដែតឡើងមកអំពីក្នុងជ្រោះភ្នំគូលែន ។*

*មានពាក្យចចាមអារ៉ាមនិយាយថា ព្រលឹងរបស់យ៉ាហានបាននៅរង់ចាំលោក ស៊ី ឈឿន នៅតាមថែរក្សាការពារបម្រើលោកដែលកំពុងខំកសាងបារមី ដើម្បីឲ្យឆាប់បានទៅចាប់ជាតិជួបគ្នាសាជាថ្មី ។ គ្មានអ្វីអាចបំបែកបំបាក់សង្សារទាំងពីរបានឡើយ សូម្បីតែសេចក្ដីស្លាប់ក៏មិនអាចនឹងមកផ្ដាច់ចិត្តតស៊ូនៃគូទាំងពីរបានដែរ ។*

[1] (ធុតុង)